# ព្រះរាជាណាចក្រកម្ពុជា

## គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ៣
## (LASED III)

## ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម
## (ESMF)


រៀបចំឡើងដោយ ៖

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)



**ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា**

ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០២០


DRAFT

# មាតិកា

**ពាក្យកាត់**.....vii

**សេចក្តីសង្ខេប**.....x

**១សេចក្តីផ្តើម**.....1

១.១ ដំណើរការផ្តល់សម្បទានដីសង្គមកិច្ច និងប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច.....1

១.២ ទីតាំងសម្បទានដីសង្គមកិច្ចដែលមានស្រាប់នៅថ្នាក់ឃុំ និងការផ្តល់ប័ណ្ណកម្មសិទ្ធិដី សមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច.....5

១.៣ គោលបំណងនៃគម្រោង.....7

១.៤ សមាសភាគគម្រោង.....8

១.៥ ការកំណត់គោលដៅ រួមទាំងការជ្រើសរើសទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច.....13

១.៧ វិធីសាស្ត្រ និងគោលបំណងនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម.....18

១.៨ ក្របខណ្ឌគតិយុត្តិ និងក្របខណ្ឌស្ថាប័ន.....20

១.៨.១ លក្ខខណ្ឌតម្រូវក្នុងក្របខណ្ឌគតិយុត្តិ និងច្បាប់ជាតិ.....20

១.៨.២ គោលនយោបាយរបស់ធនាគារពិភពលោក ៖ បទដ្ឋានបរិស្ថាន និងសង្គមជាធរមាន.....25

១.៨.៣ ការរៀបចំ និងសមត្ថភាពផ្នែកស្ថាប័ន.....26

**២.មេរៀនពីការអនុវត្តបទដ្ឋានបរិស្ថាន និងសង្គមក្នុងគម្រោងជំហានដំបូង និងគម្រោងជំហានទី ២**.....29

២.១ ក្របខណ្ឌការពារសុវត្ថិភាពបរិស្ថាន និងសង្គម.....29

២.២ ភស្តុតាងនៃផលប៉ះពាល់របស់គម្រោងលើបរិស្ថាន.....29

២.៣ ភស្តុតាងនៃផលប៉ះពាល់របស់គម្រោងលើសង្គម.....30

២.៤ ការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងជំហានទី ២.....31

២.៥ ការវិភាគចំណុចខ្វះខាត.....31

**៣.សាវតារបរិស្ថាន និងសង្គមរបស់ខេត្តគោលដៅសំខាន់ៗ**.....43

**៤.ហានិភ័យ និងផលប៉ះពាល់របស់គម្រោងលើបរិស្ថាន និងសង្គម**.....50

៤.១ វិធីសាស្ត្រ.....50

៤.២ ហានិភ័យបរិស្ថាន និងសង្គមដែលអាចកើតឡើង.....51

៤.៣ ហានិភ័យបរិស្ថាន និងសង្គមដែលរកឃើញ.....53

៤.៣.១ បទដ្ឋានបរិស្ថាន និងសង្គមទី ១ ៖ ការវាយតម្លៃ និងគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម.....53

៤.៣.២ បទដ្ឋានបរិស្ថាន និងសង្គមទី ២ ៖ លក្ខខណ្ឌពលកម្ម និងការងារ.....55

DRAFT

៤.៣.៣ បទដ្ឋានបរិស្ថាន និងសង្គមទី ៣ ៖ ប្រសិទ្ធភាពធនធាន និងការទប់ស្កាត់ និងការគ្រប់គ្រងការបំពុល ....58
៤.៣.៤ បទដ្ឋានបរិស្ថាន និងសង្គមទី៤ – សុខភាព និងសុវត្ថិភាពសហគមន៍....60
៤.៣.៥ បទដ្ឋានបរិស្ថាន និងសង្គមទី ៥ - លទ្ធកម្មដីធ្លី ការរឹតត្បិតលើការប្រើប្រាស់ដីធ្លី និងការតាំងទីលំនៅថ្មីដោយបង្ខំ....66
៤.៣.៦ បទដ្ឋានបរិស្ថាន និងសង្គមទី ៦ - ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតដោយនិរន្តរភាព..69
៤.៣.៧ បទដ្ឋានបរិស្ថាន និងសង្គមទី ៧ - ជនជាតិដើមភាគតិច....71
៤.៣.៨ បទដ្ឋានបរិស្ថាន និងសង្គមទី ៨ - បេតិកភណ្ឌវប្បធម៌....76
**៥. ក្របខណ្ឌគ្រប់គ្រងហានិភ័យ** ....86
៥.១ ទិដ្ឋភាពជាទូទៅនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣....86
៥.២ ដំណើរការគ្រប់គ្រងហានិភ័យនៅកម្រិតគម្រោង....87
៥.៣ ដំណើរការគ្រប់គ្រងហានិភ័យកម្រិតទីតាំង....88
៥.៣.១ ទីតាំងនៃការផ្តល់សម្បទានដីសង្គមកិច្ច (SLC)....89
៥.៣.២ ការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច (ICLT)....95
៥.៣.៣ ការពិនិត្យបឋមហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម....98
៥.៤ ការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំង ៖ ការគូសផែនទីថ្នាក់ខេត្ត....99
៥.៥ នីតិវិធីវាយតម្លៃហានិភ័យ....102
៥.៦ ការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំង ៖ ឧបករណ៍ពាក់ព័ន្ធនឹងបរិស្ថាន និងសង្គម....102
៥.៦.១ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង....103
៥.៦.២ ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP)....105
៥.៦.៣ ផែនការដោះស្រាយផលប៉ះពាល់លើការផ្លាស់ទីលំនៅដោយសារគម្រោង (RP)....106
៥.៦.៤ ផែនការសម្រាប់ជនជាតិដើមភាគតិច(IPP)....106
៥.៦.៥ ការរៀបចំផែនការដែលជំរុញការចូលរួម....107
៥.៧ ការគ្រប់គ្រងហានិភ័យនៅកម្រិតអនុគម្រោង....107
៥.៧.១ ប្រភេទអនុគម្រោង ការពិនិត្យបឋម និងតារាងបង្ហាញផលប៉ះពាល់អវិជ្ជមាន....107
៥.៧.២ ឧបករណ៍គ្រប់គ្រងហានិភ័យសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ....110
៥.៧.៣ ការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព....110
៥.៧.៤ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ....111
៥.៧.៥ បញ្ញត្តិគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមបន្ថែមតាមប្រភេទអនុគម្រោង....112
៥.៧.៦ លទ្ធកម្មដីសម្រាប់អនុគម្រោង....112

DRAFT

៥.៧.៧ ឧបករណ៍គ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមសម្រាប់អនុគម្រោងកសិកម្ម 113
៥.៧.៨ ឧបករណ៍គ្រប់គ្រងហានិភ័យសម្រាប់អនុគម្រោងដទៃទៀត 114
៥.៧.៩ ខ្លឹមសារសង្ខេបឧបករណ៍គ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នៃអនុគម្រោង តាមប្រភេទគម្រោង 114
៥.៨ ការតាមដានការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម 117
**៦. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន** 119
**៧. ការរៀបចំការអនុវត្ត** 120
៧.១ តួនាទី និងការទទួលខុសត្រូវ 120
៧.២ ផែនការកសាងសមត្ថភាព 122
៧.២.១ ការវាយតម្លៃសមត្ថភាពសង្ខេប 122
៧.២.២ យុទ្ធសាស្ត្របណ្តុះបណ្តាល និងវគ្គបណ្តុះបណ្តាលសំខាន់ៗ 123
៧.៣ ថវិកាសម្រាប់ការអនុវត្តក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម 126
**៨. យន្តការដោះស្រាយបណ្តឹងតវ៉ា** 127
៨.១ យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) 127
៨.២ សេវាកម្មដោះស្រាយបណ្តឹងតវ៉ារបស់ធនាគារពិភពលោក 131
**៩. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន ក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម** 132
៩.១ ការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធលើក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម និងឧបករណ៍ដែលពាក់ព័ន្ធ 132
**ឧបសម្ព័ន្ធ** 134
**ឧបសម្ព័ន្ធ ១៖ សេចក្តីសង្ខេបនៃប្រភេទអនុគម្រោង ដែលមានសិទ្ធិទទួល បាន និងមិនមានសិទ្ធិទទួលបាននៃ គម្រោង** LASED III 135
**ឧបសម្ព័ន្ធ ២៖ បទពិសោធន៍ការគ្រប់គ្រងហានិភ័យទាក់ទងបរិស្ថាន និងសង្គម នៅក្នុងគម្រោង** LASED II 137
*1.* ក្របខណ្ឌសម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងបរិស្ថាន និងសង្គម 137
*2.* ភស្តុតាងនៃផលប៉ះពាល់ផ្នែកបរិស្ថាននៃគម្រោង 141
*3.* ភស្តុតាងនៃផលប៉ះពាល់ផ្នែកសង្គមនៃគម្រោង 143
*4.* បទពិសោធន៍ជាមួយយន្តការដោះស្រាយបណ្តឹងតវ៉ា 145
*5.* ការវិភាគផ្នែកខ្វះខាត 146
បទដ្ឋានបរិស្ថាន និងសង្គមទី ១ –ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ទាក់ទងនឹងបរិស្ថាន និងសង្គ146

DRAFT

បទដ្ឋានបរិស្ថាន និងសង្គមទី ២ ៖ លក្ខខណ្ឌការងារ និងពលកម្ម.....147
បទដ្ឋានបរិស្ថាន និងសង្គមទី ៣- ប្រសិទ្ធភាពធនធាន និងការទប់ស្កាត់ និងគ្រប់គ្រងការបំពុល.....148
បទដ្ឋានបរិស្ថាន និងសង្គមទី ៤ – សុខភាព និងសុវត្ថិភាពសហគមន៍.....149
បទដ្ឋានបរិស្ថាន និងសង្គមទី ៥ - លទ្ធកម្មដីធ្លី ការរឹតត្បិតលើការប្រើប្រាស់ដីធ្លី និងការតាំងទីលំនៅថ្មីដោយបង្ខំ.....149
បទដ្ឋានបរិស្ថាន និងសង្គមទី ៦ - ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតដោយនិរន្តរភាព.....150
បទដ្ឋានបរិស្ថាន និងសង្គមទី ៧ - ជនជាតិដើមភាគតិច/សហគមន៍បុរាណក្នុងអនុតំបន់សាហារ៉ាទ្វីបអាហ្វ្រិកដែលមិនមានការទទួលស្គាល់ជាប្រវត្តិសាស្ត្រ.....150
បទដ្ឋានបរិស្ថាន និងសង្គមទី ៨- បេតិកភណ្ឌវប្បធម៌.....151
បទដ្ឋានបរិស្ថាន និងសង្គម – ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌មាន.....151
**ឧបសម្ព័ន្ធទី ៣៖ ទម្រង់ការពិនិត្យបឋមនៃទីតាំង**.....- 153 -
**ឧបសម្ព័ន្ធទី ៤៖ គម្រោងតាមទីតាំងនៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម**.....160
**ឧបសម្ព័ន្ធ ៥ ៖ ទម្រង់ពិនិត្យបឋមលើអនុគម្រោង**.....163
**ឧបសម្ព័ន្ធ ៦ ៖ ទម្រង់ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ក្នុងអនុគម្រោង**.....167
**ឧបសម្ព័ន្ធ ៧ ៖ ក្រមប្រតិបត្តិផ្នែកបរិស្ថាន** (*ECOP*) **សម្រាប់អនុគម្រោង**.....168
**ឧបសម្ព័ន្ធ ៨ ៖ ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងលើបរិស្ថាន និងវិធានការកាត់បន្ថយផលប៉ះពាល់**.....177

## តារាង

តារាង ១ក ៖ ខ្លឹមសារសង្ខេបជំហានទាំង ១០ ក្នុងដំណើរការផ្តល់សម្បទានដីសង្គមកិច្ចនៅថ្នាក់ឃុំ.....1
តារាង ១ខ ៖ ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច.....2
តារាង ២ក ៖ សម្បទានដីសង្គមកិច្ចដែលមានស្រាប់នៅថ្នាក់ឃុំ.....4
តារាង ២ខ ៖ ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលទទួលបាន.....4
តារាង ៣ ៖ ការវិភាគចំណុចខ្វះខាតក្នុងក្របខណ្ឌគតិយុត្តិ និងច្បាប់ ធៀបនឹងលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គម.....24
តារាង ៤ ៖ ខ្លឹមសារសង្ខេបហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ២.....41
តារាង ៥ ៖ ខ្លឹមសារសង្ខេបហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៣.....43
តារាង ៦ ៖ ខ្លឹមសារសង្ខេបហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៤.....46
តារាង ៧ ៖ ខ្លឹមសារសង្ខេបហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៥.....49
តារាង ៨ ៖ ខ្លឹមសារសង្ខេបហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៦.....51
តារាង ៩ ៖ ខ្លឹមសារសង្ខេបហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៧.....53

DRAFT

តារាង ១០ ៖ ខ្លឹមសារសង្ខេបហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៨........................56
តារាង ១១ ៖ ហានិភ័យ និងវិធានការកាត់បន្ថយផលប៉ះពាល់ ........................57
តារាង ១២ ៖ ចំនួនទីតាំងសម្បទានដីសង្គមកិច្ច និងទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ដែលត្រូវទទួលបានការគាំទ្រ ........................62
តារាង ១៣.ក ៖ ការគ្រប់គ្រងហានិភ័យកម្រិតទីតាំងសម្រាប់សម្បទានដីសង្គមកិច្ចថ្មី ៖ ដំណើរការផ្តល់សម្បទានដីសង្គមកិច្ច និងការវិនិយោគ ........................64
តារាង ១៣.ខ ៖ ការគ្រប់គ្រងហានិភ័យកម្រិតទីតាំងសម្រាប់សម្បទានដីសង្គមកិច្ចមានស្រាប់ ៖ ការគាំទ្រដល់ការអភិវឌ្ឍ/ការវិនិយោគ ...66
តារាង ១៤ ៖ វិធានការគ្រប់គ្រងហានិភ័យកម្រិតទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពថ្មីដល់សហគមន៍ជនជាតិដើមភាគតិច69
តារាង ១៥ ៖ តារាងបង្ហាញផលប៉ះពាល់អវិជ្ជមាន........................77
តារាង ១៦ ៖ ឧបករណ៍សម្រាប់កាត់បន្ថយផលប៉ះពាល់ដែលអាចកើតឡើងនៅកម្រិតអនុគម្រោង ........................82
តារាង១៧ ៖ ប្លង់ផែនការបណ្តុះបណ្តាល ........................89
តារាង ១៨ ៖ ចំណាយប៉ាន់ស្មានលើការអនុវត្តក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ........................90
តារាង ១៩ ៖ គោលនយោបាយការពារសុវត្ថិភាពដែលបំផុសដោយគម្រោងជំហានទី ២ ........................100
តារាង ២០ ៖ ឧបករណ៍ការពារសុវត្ថិភាពក្នុងក្របខណ្ឌបរិស្ថាន និងសង្គម ធៀបនឹងក្របខណ្ឌការពារសុវត្ថិភាពរបស់គម្រោងជំហានទី២105
តារាង ២១ ៖ ការប្រៀបធៀបលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ១០ និង ក្របខណ្ឌជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងគម្រោងជំហានដំបូង........................108


## ឧបសម្ព័ន្ធ

1. ក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី
2. ក្របខណ្ឌរៀបចំផែនការសម្រាប់ជនជាតិដើមភាគតិច
3. ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌
4. នីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ

DRAFT

| ពាក្យកាត់ | |
|---|---|
| AEA | ការវិភាគកសិ-ប្រព័ន្ធអេកូឡូស៊ី |
| CDB | មូលដ្ឋានទិន្នន័យឃុំ (ក្រសួងផែនការ) |
| CEF | ក្របខណ្ឌជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ |
| CHC | គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា |
| CHPF | ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ |
| CHM | ការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ |
| CHMP | ផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ |
| CLMP | នីតិវិធីគ្រប់គ្រងការងារក្នុងសហគមន៍ |
| CLUP | ការរៀបចំផែនការប្រើប្រាស់ដីសហគមន៍ |
| CPR | ធនធានទ្រព្យសម្បត្តិរួម |
| CWCC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ |
| DWG | ក្រុមការងារថ្នាក់ស្រុក |
| EA | ស្ថាប័នដឹកនាំការអនុវត្ត |
| E&S | បរិស្ថាន និងសង្គម |
| ELC | សម្បទានដីសេដ្ឋកិច្ច |
| ESA | ការវាយតម្លៃបរិស្ថាន និងសង្គម |
| ESCP | ផែនការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម |
| ESF | ក្របខណ្ឌបរិស្ថាន និងសង្គម |
| ESMF | ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESMP | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESP | សាវតារបរិស្ថាន និងសង្គម |
| ESRS | ខ្លឹមសារសង្ខេបស្តីពីការពិនិត្យឡើងវិញផ្នែកបរិស្ថាន និងសង្គម |
| ESS | បទដ្ឋានបរិស្ថាន និងសង្គម |
| ESHSS | ការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព |
| GCF | មូលនិធិអាកាសធាតុបៃតង |
| GDCG | អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) |
| GDH | អគ្គនាយកដ្ឋានលំនៅដ្ឋាន (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) |
| GDR | អគ្គនាយកដ្ឋានកិច្ចការតាំងទីលំនៅឡើងវិញ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) |
| GIS | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| GRM | យន្តការដោះស្រាយបណ្តឹងតវ៉ា |
| GIZ | កិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (អង្គការមិនមែនរដ្ឋាភិបាលរបស់អាល្លឺម៉ង់) |
| GSSLC | អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច |

DRAFT

| | |
|---|---|
| IA | ស្ថាប័នអនុវត្តន៍ |
| IC | សហគមន៍ជនជាតិដើមភាគតិច |
| ICLT | ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច |
| IDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ |
| IP | ជនជាតិដើមភាគតិច |
| IPP | ផែនការសម្រាប់ជនជាតិដើមភាគតិច |
| IPCC | គណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច |
| IPPF | ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច |
| JSDF | មូលនិធិអភិវឌ្ឍន៍សង្គមរបស់ជប៉ុន |
| KfW-IPLR | កម្មវិធីហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចដើម្បីជានានិរន្តរភាពនៃការអនុវត្តកំណែទម្រង់ដីធ្លី |
| LASED | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| LWCP | នីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ |
| M&E | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoE | ក្រសួងបរិស្ថាន |
| MoI | ក្រសួងមហាផ្ទៃ |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NCSLC | គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| OHSP | ផែនការសុខភាព និងសុវត្ថិភាពក្នុងការងារ |
| OP | គោលនយោបាយប្រតិបត្តិ ( ធនាគារពិភពលោក ) |
| PAWG | ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត |
| PGRM | យន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោង |
| PIM | សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង |
| PLUAC | គណៈកម្មាធិការប្រើប្រាស់ និងបែងចែកការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត |
| PPCLFL | នីតិវិធីទប់ស្កាត់ពលកម្មកុមារ និងការងារដោយបង្ខំ |
| PT | ក្រុមគម្រោង |
| PPT | ក្រុមគម្រោងថ្នាក់ខេត្ត |
| PWGRM | យន្តការដោះស្រាយបណ្តឹងតវ៉ារបស់កម្មករដែលធ្វើការក្នុងគម្រោង |
| RF | មូលនិធិវិលជុំ |

DRAFT

| | |
|---|---|
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RP | ផែនការដោះស្រាយផលប៉ះពាល់ |
| RPF | ក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី |
| SEP | ផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ |
| SLC | សម្បទានដីសង្គមកិច្ច |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SOP | នីតិវិធីប្រតិបត្តិស្តង់ដារ ( សម្រាប់គម្រោងទទួលបានហិរញ្ញប្បទានពីខាងក្រៅ ) |
| TLRs | អ្នកដែលជាមុខសញ្ញាទទួលបានដីធ្លី |

DRAFT

# សេចក្តីសង្ខេប

1. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ៣ (LASED-III) នឹងបន្តគាំទ្រដល់សម្បទានដីសង្គមកិច្ចនៅថ្នាក់ឃុំរបស់រាជរដ្ឋាភិបាលកម្ពុជា ពីគម្រោងជំហានដំបូង និងជំហានទី ២ ហើយនឹងជួយគាំទ្រដល់កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច (ICLT) របស់រាជរដ្ឋាភិបាលកម្ពុជា ដែលសុទ្ធតែពាក់ព័ន្ធនឹងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការពង្រីកមុខរបរចិញ្ចឹមជីវិត។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) គឺជាស្ថាប័នដឹកនាំការអនុវត្តគម្រោងមួយនេះ ចំណែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមគម្រោងនៅថ្នាក់ខេត្តគឺជាស្ថាប័នអនុវត្តន៍។

2. ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ត្រូវបានតាក់តែងឡើងដោយពណ៌នាយ៉ាងល្អិតល្អន់ អំពីនីតិវិធី និងលក្ខខណ្ឌតម្រូវផ្នែកស្ថាប័នសម្រាប់តម្រង់ទិសការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ៣ (LASED III) ដើម្បីធានាឱ្យបាននូវភាពស្របគ្នាជាមួយនឹងបទដ្ឋានបរិស្ថាន និងសង្គម (ESS) របស់ធនាគារពិភពលោក ព្រមទាំងលក្ខខណ្ឌតម្រូវផ្នែកច្បាប់របស់កម្ពុជាសម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាអាទិ៍ ច្បាប់ភូមិបាល (ឆ្នាំ ២០០១) និងអនុនីតិកម្មនានា រួមទាំងក្របខណ្ឌសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច (ICLT) និងសម្បទានដីសង្គមកិច្ច (SLC) ច្បាប់ស្តីពីការងារ (ឆ្នាំ ១៩៩៧) ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (ឆ្នាំ ១៩៩៦) ច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ ២០០២) និងច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ (ឆ្នាំ ១៩៩៦)។ គេបានកំណត់ថា បទដ្ឋានបរិស្ថាន និងសង្គមទាំង ១០ របស់ធនាគារពិភពលោក (លើកលែងតែបទដ្ឋានបរិស្ថាន និងសង្គមទី ៩ ៖ អន្តរការីហិរញ្ញវត្ថុ) សុទ្ធតែអាចអនុវត្តបានក្នុងគម្រោងជំហានទី ៣ នេះ។ ការវិភាគ គម្លាតក្នុងក្របខណ្ឌគតិយុត្តិនៅកម្ពុជា ធៀបនឹងបទដ្ឋានបរិស្ថាន និងសង្គម មានបង្ហាញក្នុងឯកសារក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) បូករួមនឹងវិធានការលុបបំបាត់ចំណុចខ្វះខាតទាំងនោះ។

3. ស្ថាប័នអនុវត្តន៍គម្រោងជំហានទី ៣ នេះ មានបទពិសោធន៍ប្រើប្រាស់ក្របខណ្ឌការពារសុវត្ថិភាពបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក ក្នុងពេលអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានដំបូង និងជំហានទី ២។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលិក និងមន្ត្រីអនុវត្តន៍គម្រោងនៅតែមិនទាន់យល់ដឹងច្បាស់ពីវិសាលភាពដែលគេបានកំណត់បន្ថែមទៀតនៅក្នុងបទដ្ឋានបរិស្ថាន និងសង្គម និងនីតិវិធីគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមថ្មីដែលត្រូវការជាចាំបាច់។ ជាមួយគ្នានេះដែរ គេសង្កេតឃើញមានការផ្លាស់ប្តូរក្របខណ្ឌច្បាប់កម្ពុជា ជាពិសេសពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅថ្មី។ បុគ្គលិក និងមន្ត្រីអនុវត្តន៍គម្រោង មិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ក្នុងការគ្រប់គ្រងហានិភ័យដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិចនៅឡើយទេ។ លក្ខខណ្ឌតម្រូវលើការអនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមទី ២ (ESS2) ដែលផ្តោតលើលក្ខខណ្ឌពលកម្មនិងការងារ បន្សុីគ្នាបំផុតទៅនឹងច្បាប់ស្តីពីការងាររបស់កម្ពុជាដែលមានការអនុវត្តភាគច្រើនក្នុងវិស័យឧស្សាហកម្មសំណង់។ ហេតុនេះហើយទើបទាមទារឱ្យមានការកសាងសមត្ថភាព ដើម្បីធានាការអនុវត្តគម្រោង គ្រប់ជ្រុងជ្រោយ។

4. ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ត្រូវបានតាក់តែងឡើងដោយផ្អែកលើមេរៀនដែលទទួលបានពីការអនុវត្តគម្រោងមុនៗ (LASED និង LASED-II)។ គួរកត់សម្គាល់ថា ដំណើរការកំណត់អត្តសញ្ញាណដីធ្លី ការគូសផែនទី ការផ្តល់ប័ណ្ណកម្មសិទ្ធិ និងការបែងចែកដីសម្រាប់សម្បទានដីសង្គមកិច្ច ទទួលបានជោគជ័យគួរជាទី

DRAFT

មោទនៈក្នុងការបញ្ចៀសផលប៉ះពាល់អវិជ្ជមានដល់អ្នកប្រើប្រាស់ដីធ្លី ដែលមានស្រាប់។ ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍បង្ហាញថា ការទាមទារ និងការតវ៉ាអាចនឹងកើតឡើងដោយជៀសមិនផុតក្នុងគម្រោងខាងមុខ។ ហេតុនេះហើយត្រូវមានការគ្រប់គ្រងបញ្ហាទាំងអស់នេះប្រកបដោយតម្លាភាព។ យន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងជំហានទី ២ (LASED-II) ត្រូវបានកត់សម្គាល់ឃើញថាមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ។ ទោះបីជាអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធបានបញ្ចៀសលទ្ធកម្មដីធ្លី ប៉ុន្តែក៏ត្រូវត្រៀមលក្ខណៈសម្រាប់កន្លែងផ្សេងទៀតបើមានការប៉ះពាល់។ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លីក្នុងទីតាំងគម្រោងសម្បទានដីសង្គមកិច្ច និងការកំណត់ព្រំប្រទល់នៃតំបន់ទាំងនោះ ក៏ត្រូវបានកត់សម្គាល់ថាមិនទាន់ទទួលបានជោគជ័យពេញលេញក្នុងធានាសន្តិសុខសិទ្ធិកាន់កាប់ដីធ្លីរបស់អ្នកទទួលបានដីធ្លីនោះទេ។ ការអនុវត្តអនាម័យ និងការគ្រប់គ្រងសំណល់រឹងឱ្យបានសមស្របនៅទីតាំងគម្រោងសម្បទានដីសង្គមកិច្ចនៅតែមានបញ្ហាប្រឈមមួយចំនួន ដែលអាចធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន និងសុខភាពសហគមន៍យ៉ាងខ្លាំង និងយូរអង្វែង។ គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ២ (LASED-II) បានប្រើប្រាស់វិធីសាស្រ្តការពារសុវត្ថិភាពដោយផ្អែកលើផែនទីភូមិសាស្រ្តជាក់លាក់ ដោយមិនបានគិតគូរពីហានិភ័យដែលអាចកើតឡើង ឬបណ្តាលមកពីកត្តាផ្សេងៗដែលកើតមាននៅខាងក្រៅខណ្ឌសីមាទីតាំងគម្រោងសម្បទានដីសង្គមកិច្ច ឬហានិភ័យដែលមិនត្រូវបានកំណត់ឡើងពាក់ព័ន្ធនឹងភូមិសាស្រ្ត។ បញ្ហាដែលមិនទាន់ត្រូវបានដោះស្រាយជាប្រព័ន្ធក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ២ (LASED-II) ប៉ុន្តែត្រូវតែដោះស្រាយតាមរយៈការអនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក រួមមានលក្ខខណ្ឌពលកម្ម និងការងាររបស់កម្មករដែលធ្វើការក្នុងគម្រោង បញ្ហាសុវត្ថិភាព ដូចជា សុវត្ថិភាពតាមផ្លូវក្នុងតំបន់គម្រោង និងការការពារសិទ្ធិរបស់ជនជាតិដើមភាគតិច។

5. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ៣ នឹងគាំទ្រសកម្មភាពសម្រាប់សម្បទានដីសង្គមកិច្ច (SLC) នៅក្នុងតំបន់ ១៤ ដែលមានស្រាប់ និងតំបន់ប្រហែល ១៥ ថ្មីទៀតដែលត្រូវកំណត់អត្តសញ្ញាណ ព្រមទាំងសហគមន៍ជនជាតិដើមភាគតិចប្រហែល ៣០ ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពរួចហើយ និងសហគមន៍ជនជាតិដើមភាគតិច ១៥ ទៀតដែលបានដាក់ពាក្យសុំ ប៉ុន្តែមិនទាន់បានទទួលបណ្ណ័កម្មសិទ្ធិដីសមូហភាពនៅឡើយ។ LASED-III ជាគម្រោងថ្នាក់ជាតិ។ តាមគោលការណ៍ ការផ្តល់សម្បទានដីសង្គមកិច្ចថ្មី (SLC) និងប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច (ICLT) អាចអនុវត្តនៅក្នុងបណ្តាខេត្តជាច្រើនក្នុងប្រទេសកម្ពុជា ប៉ុន្តែគេរំពឹងថា ខេត្តទាំងឡាយដែលត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច (ICLT) ទាំងអស់ និងសម្បទានដីសង្គមកិច្ចថ្មីភាគច្រើន ឬទាំងអស់ នឹងត្រូវអនុវត្តនៅបណ្តាខេត្តភូមិភាគឦសានចំនួន ៦។ ខេត្តទាំងនេះមានដង់ស៊ីតេប្រជាជនទាប។ សរុបរួម ជនជាតិដើមភាគតិចមានប្រហែល ១៤%ប៉ុន្តែមាន ៦០%នៅខេត្តរតនគិរី និង ៤៦%នៅខេត្តមណ្ឌលគិរីដែលស្ថិតក្នុងតំបន់ខ្ពង់រាបភាគខាងកើត។ ក្នុងបណ្តាខេត្តទាំងនេះ ប្រជាជនមានអាយុជាមធ្យម ២២ ឆ្នាំ និងមានកំណើនលឿនជាងមធ្យមភាគទូទាំងប្រទេស មួយផ្នែកដោយសារការធ្វើចំណាកស្រុកពីបណ្តាខេត្តផ្សេងៗ។ អត្រាភាពក្រីក្រគឺខ្ពស់ជាងមធ្យមភាគទូទាំងប្រទេស ខណៈដែលការទទួលបានសេវាសាធារណៈ និងសូចនាករសេដ្ឋកិច្ចសង្គមភាគច្រើននៅមានកម្រិតទាបជាងមធ្យមភាគថ្នាក់ជាតិ។ កសិកម្មជាសកម្មភាពចម្បងសម្រាប់ទ្រទ្រង់សេដ្ឋកិច្ច និងជីវភាពប្រចាំថ្ងៃ ប៉ុន្តែមានមនុស្សពេញវ័យត្រឹមតែ ៧% ប៉ុណ្ណោះដែលមានការងារផ្លូវការ។ ការធ្វើចំណាកស្រុករកការងារមានសារៈសំខាន់ណាស់ (ប្រហែល ១១% នៃចំនួនមនុស្សពេញវ័យ) ប៉ុន្តែមានតិចតួចប៉ុណ្ណោះសម្រាប់សហគមន៍ជនជាតិដើមភាគតិច។

DRAFT

6. បញ្ហាកុមារកង្វះអាហារូបត្ថម្ភរបស់កុមារ នៅតែជាកង្វល់ចំបងចំពោះសុខភាពកុមារ។ ក្នុងចំណោមជំងឺឆ្លងនានា ជំងឺរបេងមានអត្រាស្លាប់ខ្ពស់បំផុត ប៉ុន្តែអត្រាស្លាប់ដោយសារជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាមក៏ស្ថិតក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ផងដែរ។ ការស្លាប់ និងរបួសដោយសារសំណល់អាវុធជាតិផ្ទុះបន្សល់ពីសង្គ្រាម បានថយចុះយ៉ាងឆាប់រហ័ស ប៉ុន្តែគ្រោះថ្នាក់ចរាចរណ៍កំពុងកើនឡើង និងក្លាយជាការព្រួយបារម្ភដ៏ធំមួយរបស់ប្រជាពលរដ្ឋ។ អាជ្ញាធរមូលដ្ឋានកំពុងខិតខំប្រឹងប្រែងកាត់បន្ថយអំពើហិង្សាផ្អែកលើយេនឌ័រ តែនៅមានកម្រិតដោយសារតែកង្វះសមត្ថភាព និងបទដ្ឋានសង្គម។

7. សិទ្ធិកាន់កាប់ដីធ្លីត្រូវបានកំណត់នៅក្នុងច្បាប់ ប៉ុន្តែការអនុវត្តជាក់ស្តែងច្រើនតែមិនដូចក្នុងច្បាប់នោះទេ ដោយសារតែកង្វះការវាស់វែងដីធ្លីជាប្រព័ន្ធ និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។ ដីធ្លីភាគច្រើននៅតាមខេត្តគោលដៅមានត្រឹមតែ "ប្លង់ទន់" ឬទទួលបានពីការទន្ទ្រានកាន់កាប់ដីរដ្ឋ រួមទាំងតំបន់ការពារធម្មជាតិ និងដីដែលសហគមន៍ជនជាតិដើមភាគតិចចាត់ទុកជាដីសម្រាប់ការប្រើប្រាស់ជាប្រពៃណីរបស់ពួកគេ (ហើយដីទាំងនេះមានលក្ខណៈសម្បត្តិ សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច)។ បញ្ហាវិវាទដីធ្លី បានក្លាយជារឿងធម្មតាទៅហើយ ដែលក្នុងនោះមានអ្នកពាក់ព័ន្ធជាច្រើន ដូចជា សហគមន៍មូលដ្ឋាន និងអ្នកទន្ទ្រានមកពីខាងក្រៅសហគមន៍ និងក្រុមហ៊ុនកាន់កាប់សម្បទានដីសេដ្ឋកិច្ចផងដែរ ។ ដីទាំងនេះ ភាគច្រើនត្រូវបានកាន់កាប់ដោយពុំបានវាស់វែង ឬកំណត់ព្រំប្រទល់ច្បាស់លាស់ ឬគ្មានការដោះស្រាយជាប្រព័ន្ធលើការទាមទារដីត្រួតគ្នា។ ការមិនកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបានច្បាស់លាស់ក៏ជាបញ្ហាមួយដែរ ពិសេសនៅតំបន់ដែលត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច។ ដំណើរការផ្តល់សម្បទានដីសង្គមកិច្ច និងប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងគម្រោងនេះ នឹងត្រូវធ្វើឡើងដោយមានការកំណត់អត្តសញ្ញាណ និងវាយតម្លៃលើការទាមទារដីធ្លីនៅក្នុងតំបន់ការពារធម្មជាតិ រាប់បញ្ចូលទាំងតំបន់សំបូរដោយជីវចម្រុះ សម្បទានដីសេដ្ឋកិច្ច ប៉ុន្តែដីឯកជនដែលមានកម្មសិទ្ធិស្របច្បាប់ត្រូវផាត់ចេញ ហើយដីដែលស្ថិតក្រោមការកាន់កាប់របស់ឯកជន ប៉ុន្តែមិនមានកម្មសិទ្ធិផ្លូវការ ក៏ត្រូវផាត់ចេញផងដែរ។

8. តំបន់ភូមិភាគឦសាននៃប្រទេសកម្ពុជា ជាតំបន់ព្រៃឈើដែលសំបូរដោយជីវចម្រុះ ហើយផ្ទៃដីប្រហែល ៥០% គឺជាតំបន់ការពារធម្មជាតិ (ព្រៃឈើ និងដែនជម្រកសត្វព្រៃ។ល។)។ ជីវចម្រុះទាំងនេះកំពុងទទួលរងការគំរាមកំហែងពីការកាប់បំផ្លាញព្រៃឈើ និងការបម្លែងដីសម្រាប់កសិកម្ម និងសកម្មភាពខុសច្បាប់ ដូចជា ការកាប់យកឈើមានតម្លៃខ្ពស់ ការបរបាញ់សត្វ រួមទាំងការបរបាញ់ប្រភេទសត្វដែលជិតផុតពូជ (ឧ. ពង្រូល) និងការជីកយកត្បូងជាដើម។ សហគមន៍ក្នុងតំបន់ព្រៃឈើអាស្រ័យផលពីផលិតផលព្រៃឈើដើម្បីចិញ្ចឹមជីវិត ប៉ុន្តែដោយសារការខ្វះខាត ពួកគេអាចចូលរួមក្នុងសកម្មភាពខុសច្បាប់ និងសកម្មភាពបំផ្លិចបំផ្លាញ។ តំបន់សម្បទានដីសង្គមកិច្ចចាស់មួយចំនួន និងតំបន់ដែលនឹងក្លាយជាទីតាំងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច (ICLT) ក៏ស្ថិតនៅជិតតំបន់សំបូរជីវចម្រុះផងដែរ។

9. ការប្រែប្រួលអាកាសធាតុត្រូវបានព្យាករណ៍ថា នឹងបណ្តាលឱ្យមានរដូវប្រាំងដែលកាន់តែហួតហែង និងអូសបន្លាយ ហើយរដូវវស្សាក៏មានស្ថានភាពគំហុកខ្លាំងផងដែរ។ សីតុណ្ហភាពនឹងកើនឡើង ចំណែកគ្រោះធម្មជាតិនឹងកើតឡើងញឹកញាប់ជាងមុន និងកាន់តែធ្ងន់ធ្ងរ។ ធនធានទឹកគឺអាស្រ័យទៅលើទឹកភ្លៀង និងលំហូរចូលឆ្លងដែននៃទឹកទន្លេមេគង្គ និងដៃទន្លេនានា ប៉ុន្តែប្រភពទាំងនេះរងសម្ពាធពីការប្រែប្រួលអាកាសធាតុ និងការសាងសង់ទំនប់វារីអគ្គិសនី។ ពេលខ្លះ ទំនប់ទាំងនេះបង្កផលប៉ះពាល់អវិជ្ជមានលើសហគមន៍នៅខ្សែទឹកខាងក្រោម ដែលក្នុងនោះក៏អាច

DRAFT

មានផលប៉ះពាល់មកលើតំបន់សម្រាប់សម្បទានដីសង្គមកិច្ច និងតំបន់ដែលត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច (ICLT) ផងដែរ។ សហគមន៍មូលដ្ឋានពឹងផ្អែកលើខ្សែទឹកខាងលើ និងទឹកក្រោមដី ប៉ុន្តែនៅក្នុងតំបន់មួយចំនួន ទឹកក្រោមដីមានកម្រិតសារធាតុអាសេនិកដែលអាចបង្កគ្រោះថ្នាក់។ ប្រភពនៃការបំពុលបរិស្ថាននៅក្នុងខេត្តគោលដៅរួមមានការហូរច្រោះសារធាតុគីមីពីកសិដ្ឋានធំៗ និងសារធាតុគីមីពុលពីសកម្មភាពរុករករ៉ែ។ ប្រភពទាំងនេះអាចស្ថិតនៅខ្សែទឹកខាងលើនៃតំបន់សម្បទានដីសង្គមកិច្ច និងតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច។ ដោយសារគម្រោងនេះពាក់ព័ន្ធនឹងការជម្លៀសសហគមន៍ទៅតំបន់សម្បទានសង្គមកិច្ច មុខសញ្ញាគ្រោះថ្នាក់ខាងលើអាចបង្កហានិភ័យដល់សុខភាព និងសុវត្ថិភាពរបស់សហគមន៍នៅក្នុងគម្រោង។

10. ហានិភ័យបរិស្ថាន និងសង្គម ដែលត្រូវបានគេរកឃើញ និងវិធានការគ្រប់គ្រងហានិភ័យទាំងនេះដែលត្រូវបានលើកឡើងក្នុងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមរួមមាន ១) ហានិភ័យចំពោះកម្មករដែលធ្វើការក្នុងគម្រោងផ្ទាល់ ជាពិសេសការធ្វើដំណើរ និងការបំពេញការងារនៅតាមទីតាំងដាច់ស្រយាល ២) លក្ខខណ្ឌការងារ និងហានិភ័យសុខភាព និងសុវត្ថិភាពក្នុងការងារចំពោះកម្មករជាប់កិច្ចសន្យា ជាពិសេសកម្មករសំណង់ ៣) ការប្រើប្រាស់ធនធានទឹកដោយគ្មាននិរន្តរភាព ជាពិសេស សម្រាប់ប្រព័ន្ធធារាសាស្ត្រ ៤) ការបំពុលបរិស្ថានដោយសារការប្រើប្រាស់សារធាតុគីមីកសិកម្មមិនត្រឹមត្រូវ កាកសំណល់ដែលបង្កគ្រោះថ្នាក់ និងមិនបង្កគ្រោះថ្នាក់ និងការងារសាងសង់ ៥) ហានិភ័យសុវត្ថិភាពរបស់ទំនប់ទឹក រួមទាំងទំនប់ទឹកក្នុងគម្រោង និងទំនប់ទឹកនៅខ្សែទឹកខាងលើ ៦) សំណល់អាវុធជាតិផ្ទុះដែលបន្សល់ពីសង្គ្រាម ៧) ជំងឺឆ្លង និងជំងឺឆ្លងតាមទឹក ៨) ផលប៉ះពាល់សុខភាពដោយសារការផ្គត់ផ្គង់ទឹកមិនស្អាត ឬមានជាតិពុល ៩) គ្រោះថ្នាក់ចរាចរណ៍ ១០) ផលប៉ះពាល់អវិជ្ជមានដែលអាចបណ្តាលឲ្យមានបញ្ហាកង្វះអាហារូបត្ថម្ភលើកុមារ លទ្ធភាពតិចតួចក្នុងការទទួលបានសេវាសុខភាព ការផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយេនឌ័រ ដែលពាក់ព័ន្ធនឹងការតាំងទីលំនៅនៅតំបន់សម្បទានដីសង្គមកិច្ច ១១) មុខសញ្ញាគ្រោះថ្នាក់នៅទីសាធារណៈដោយសារការងារសាងសង់ ១២) ផលប៉ះពាល់អវិជ្ជមានលើអ្នកប្រើប្រាស់ដីធ្លី រួមទាំងម្ចាស់ដីស្របច្បាប់ និងអ្នកកាន់កាប់ដីក្រៅផ្លូវការដែលមិនត្រូវបានការពារដោយច្បាប់កម្ពុជា និងអ្នកប្រើប្រាស់ដីសម្រាប់គោលបំណងធនធានទ្រព្យសម្បត្តិរួម ១៣) ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានលើតំបន់សំបូរជីវចម្រុះ ដែលស្ថិតនៅជិតទីតាំងសម្បទានដីសង្គមកិច្ច ១៤) ផលប៉ះពាល់អវិជ្ជមានលើសិទ្ធិដីធ្លី របរចិញ្ចឹមជីវិត ឬបេតិកភណ្ឌវប្បធម៌របស់ជនជាតិដើមភាគតិច ១៥) សក្តានុពលនៃការបង្កការខូចខាតដល់បេតិកភណ្ឌវប្បធម៌រូបី ឬអរូបី។

11. ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម នៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ នឹងបែងចែកជា ៣ កម្រិត ៖ កម្រិតគម្រោង កម្រិតទីតាំង (SLC ឬ ICLT) និងកម្រិតអនុគម្រោង តែមានការផ្តោតជាពិសេសទៅលើកម្រិតពីរចុងក្រោយដោយសារកម្រិតទាំងនេះមានការអនុវត្តសកម្មភាពគម្រោងច្រើនជាងគេ។ ក្នុងករណីខ្លះ (ឧ. តំបន់សម្បទាដី សង្គកិច្ចជាច្រើនដែលនៅជាប់គ្នា) ប្រហែលជាត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជារួមតែម្តង។ ឧបករណ៍គ្រប់គ្រងហានិភ័យនៅកម្រិតគម្រោងរួមមាន ១) ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) នីតិវិធីគ្រប់គ្រងការងារ (LMP) ក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី (RPF) ក្របខណ្ឌរៀបចំផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF) ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF) និងផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP) ដែលមានរួមបញ្ចូលយន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)។ គម្រោងនឹងរៀបចំ និងអនុវត្តផែនការប្រតិបត្តិសុខភាព និងសុវត្ថិភាពសម្រាប់កម្មករដែលធ្វើការ

ក្នុងគម្រោងផ្ទាល់ និងបទដ្ឋានបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព សម្រាប់ដាក់បញ្ចូលក្នុងឯកសារកិច្ចសន្យារបស់កម្មករ។ បទដ្ឋានបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព នឹងរួមបញ្ចូលការការពារលក្ខខណ្ឌការងារសម្រាប់កម្មករជាប់កិច្ចសន្យា និង វិធានការ បរិស្ថាន និងសង្គមផ្សេងៗទៀត។

12. ការវាយតម្លៃហានិភ័យ និងការពិនិត្យបឋមលើបរិស្ថាន និងសង្គម នឹងធ្វើឡើងនៅតាមទីតាំងនីមួយៗ និងកំណត់រកលក្ខណៈសំខាន់ៗមួយចំនួននៅក្នុង ឬនៅជិតទីតាំងគម្រោង ដោយកំណត់ហានិភ័យទាំងឡាយណាដែលបានកត់សម្គាល់ក្នុងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) (ព្រមទាំងកត្តាហានិភ័យតាមទីតាំងផ្សេងទៀត)។ ផ្អែកលើការពិនិត្យបឋម និងងមានការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំងរួមជាមួយនឹងផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP) (សម្រាប់ទីតាំង SLC ថ្មី និងទីតាំង ICLT ទាំងអស់) ផែនការដោះស្រាយផលប៉ះពាល់ (RP) ផែនការសម្រាប់ជនជាតិដើមភាគតិច (IPP) និងផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ (CHMP)។ គោលការណ៍នៃការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ (FPIC) នឹងត្រូវយកមកអនុវត្តចំពោះសកម្មភាពទាំងឡាយណា ដែលអាចបង្កប៉ះពាល់ជាអវិជ្ជមានលើជនជាតិដើមភាគតិច។

13. រាល់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងរបរចិញ្ចឹមជីវិតដែលលើកឡើង នឹងត្រូវឆ្លងកាត់ការពិនិត្យបឋមដើម្បីកំណត់រកហានិភ័យបរិស្ថាន និងសង្គម។ រាល់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងអនុគម្រោងរបរចិញ្ចឹមជីវិត នឹងប្រើប្រាស់ទម្រង់តារាងធម្មតានៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP)។ ESMP នឹងមានបទប្បញ្ញត្តិស្តង់ដារទៅតាមប្រភេទអនុគម្រោងនីមួយៗ និង បទប្បញ្ញត្តិជាក់លាក់ដែលត្រូវបានរកឃើញពីការពិនិត្យបឋម។ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមក្នុងអនុគម្រោង និងបទដ្ឋានបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព(ដែលគ្រប់ដណ្តប់លើការគ្រប់គ្រងកម្មករជាប់កិច្ចសន្យា សុវត្ថិភាព និងសុខភាពនៅការដ្ឋាន ការត្រួតពិនិត្យការបំពុលបរិស្ថាន សុវត្ថិភាព សហគមន៍ក្នុងអំឡុងពេលសាងសង់ ឧប្បត្តិហេតុនៃសំណល់អាវុធជាតិផ្ទុះដែលបន្សល់ពីសង្គ្រាម និងការរកឃើញវត្ថុបុរាណ) នឹងត្រូវដាក់បញ្ចូលក្នុងឯកសារកិច្ចសន្យាការងារទាំងអស់។ ការស្ថាបនាទំនប់ទាំងអស់នឹងឆ្លងកាត់ការត្រួតពិនិត្យសុវត្ថិភាពជាចម្បង ចំណែកការកសាងផ្លូវនៅកាន់ការដ្ឋាន មានផែនការ និងការត្រួតពិនិត្យសុវត្ថិភាព។

14. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំហានទី ៣ នឹងបង្ហាញព័ត៌មានសំខាន់ៗ ឱ្យបានទាន់ពេលវេលា និងផ្តល់ភាពងាយស្រួលដល់អ្នកពាក់ព័ន្ធ និងអ្នកដែលរងផលប៉ះពាល់ និងជំរុញឱ្យអ្នកពាក់ព័ន្ធចូលរួមក្នុងការពិគ្រោះយោបល់ក្នុងគម្រោង ស្របតាមផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធនៅកម្រិតគម្រោង ផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធនៅកម្រិតទីតាំង និងលក្ខខណ្ឌស្តង់ដារដែលបានតាក់តែងឡើងសម្រាប់ដំណើរការផ្តល់សម្បទាដីសង្គមកិច្ច និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច។ ការជំរុញឲ្យមានការចូលរួមរបស់ជនជាតិដើមភាគតិច សមស្របតាមវប្បធម៌របស់គេ និងប្រើប្រាស់ភាសា មូលដ្ឋានរបស់ជនជាតិដើមភាគតិច ទៅតាមលទ្ធភាពដែលអាចធ្វើបាន។ គម្រោងនឹងជ្រើសរើសអ្នកសម្របសម្រួលសហគមន៍ចេញពីសហគមន៍ជនជាតិដើមភាគតិចដើម្បីជួយដល់ដំណើរការពិគ្រោះយោបល់នេះ។គម្រោង នេះនឹងបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា ដូចមានរៀបរាប់ក្នុងឯកសារផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP)។ បណ្តឹងតវ៉ាទាំងឡាយណាដែលកើតឡើងចេញពីសកម្មភាពគម្រោង និងពាក់ព័ន្ធនឹងជនជាតិដើមភាគតិច នឹងត្រូវដោះស្រាយដំបូងតាមរយៈដំណើរការដោះស្រាយបែបប្រពៃណីរបស់ជនជាតិដើមភាគតិច (IP) ហើយគម្រោងនឹងជួយគាំទ្រដល់ជនជាតិដើមភាគតិចក្នុងដំណើរការដោះស្រាយបណ្តឹងតវ៉ា ដោយចេញសាហ៊ុយចំណាយសម្រាប់សមាជិក

DRAFT

សហគមន៍ណាម្នាក់ដែលឈរជាតំណាងក្នុងដំណើរការបណ្ដឹង។ ការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងអំឡុងពេលរៀបចំគម្រោង ត្រូវបានពិពណ៌នាលម្អិតក្នុងផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP)។

15. ការអនុវត្តសកម្មភាពគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ជាការទទួលខុសត្រូវរបស់ ស្ថាប័នអនុវត្តន៍គម្រោង និងដៃគូគម្រោងទាំងអស់ ក្រោមការសម្របសម្រួលរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រសួងនឹងជ្រើសរើសអ្នកឯកទេសផ្នែកបរិស្ថាន ១ នាក់, អ្នកឯកទេសផ្នែកសង្គម ១ នាក់, ទីប្រឹក្សាអ្នកឯកទេសផ្នែកជនជាតិដើមភាគតិច ១ នាក់ និងទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមមួយចំនួនទៀតនៅថ្នាក់ខេត្ត។ ស្ថាប័នអនុវត្តន៍ទាំងអស់ នឹងចាត់តាំងមន្ត្រីបង្គោលផ្នែកបរិស្ថាន ១ នាក់ និងមន្ត្រីបង្គោលផ្នែកសង្គម ១ នាក់។ ក្នុងករណីដែលគម្រោងពាក់ព័ន្ធជាចាំបាច់នឹងលទ្ធកម្មដីធ្លីដោយស្ម័គ្រចិត្ត ផែនការដោះស្រាយផលប៉ះពាល់ (RP) នឹងត្រូវបានរៀបចំឡើង និងអនុវត្តដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គម្រោងនឹងពិនិត្យតាមដាន និងរាយការណ៍ពីការអនុវត្តការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម និងឧប្បត្តិហេតុសំខាន់ៗដែលពាក់ព័ន្ធនឹងបរិស្ថាន និង សង្គម។ ការត្រួតពិនិត្យការអនុវត្តន៍តាមបទដ្ឋានបរិស្ថាន និងសង្គម នឹងធ្វើឡើងមុនការវាយតម្លៃគម្រោងនៅពាក់កណ្ដាលអាណត្តិ។

16. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ៣ នឹងអនុវត្តផែនការកសាងសមត្ថភាពគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ដែលបង្ហាញក្នុងឯកសារក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមនេះ។ អ្នកដែលត្រូវចូលរៀនវគ្គបណ្ដុះបណ្ដាល រួមមាន ១) មន្ត្រីគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ២) កម្មករដែលធ្វើការផ្ទាល់ជាមួយគម្រោង ដោយបណ្ដុះបណ្ដាលពួកគេនូវចំណេះដឹងមូលដ្ឋានទាក់ទងនឹងការទទួលខុសត្រូវក្នុងពេលបំពេញការងារ ៣) បុគ្គលិករបស់ អង្គការដៃគូ និង ៤) បុគ្គលិកត្រួតពិនិត្យរបស់ក្រុមហ៊ុនម៉ៅការគម្រោង។

17. ការចំណាយលើការអនុវត្តវិធានគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម (ESMF) រួមមានចំណាយជាក់លាក់ និងចំណាយថវិកាគម្រោងទូទៅ។ តម្រូវការថវិកាសម្រាប់ការអនុវត្តសកម្មភាព (ESMF) នេះគឺប្រមាណ ១,០៧៨,000 ដុល្លារសហរដ្ឋអាមេរិក ក្នុងនោះថវិកាប្រមាណ ៥00,000 ដុល្លារសហរដ្ឋអាមេរិក គឺជាប្រាក់ខែសម្រាប់ទីប្រឹក្សាគម្រោង។

18. ឯកសារក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ដែលរាប់បញ្ចូលទាំងឯកសារសាវតារ បរិស្ថាន និងសង្គម (ESP) នីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ (LWCP) ក្របខណ្ឌគោលនយោបាយស្ដីពីការតាំងទីលំនៅថ្មី (RPF) ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច (IPPF) និងក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF) ត្រូវយកទៅផ្សព្វផ្សាយរួមជាមួយនឹងផែនការប្ដេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP) និងផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ(SEP) នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០។ ការផ្សព្វផ្សាយត្រូវធ្វើឡើងតាមវិធីជាច្រើន។

19. ដោយមើលឃើញពីវិធានការរបស់រដ្ឋាភិបាលដើម្បីបញ្ចៀសការរីករាលដាលនៃជំងឺ COVID-19 ការពិគ្រោះយោបល់ដោយផ្ទាល់មិនអាចធ្វើទៅបានទេ។ ដូច្នេះ ការពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញនឹងត្រូវបានប្រើប្រាស់ទៅតាមកាលៈទេសៈសមស្រប។ ដូចដែលបានព្រមព្រៀងជាមួយធនាគារពិភពលោករួចមកហើយ ដំណើរការពិគ្រោះយោបល់នឹងអនុវត្តតាមវិធីសាស្ត្រ ៣ ដូចជា អ៊ិនធឺណែត ការហៅទូរស័ព្ទ/អ៊ីមែល និងសាលាឃុំ។ អ្នកពាក់ព័ន្ធដែលត្រូវពិគ្រោះយោបល់ក្នុងដំណើរការនេះរួមមានអ្នកពាក់ព័ន្ធនៅខេត្ត (ក្រចេះ មណ្ឌលគិរី និងរតនគិរី) នៅថ្នាក់ឃុំ និងថ្នាក់សហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាអ្នកពាក់ព័ន្ធនៅទីក្រុងភ្នំពេញ។

DRAFT

20. មតិយោបល់របស់អ្នកពាក់ព័ន្ធ នឹងត្រូវយកមកពិចារណាសម្រាប់កែលម្អបញ្ចប់ឯកសារក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម និងឧបករណ៍សម្រាប់ការគ្រប់គ្រងបរិស្ថាន និងសង្គមផ្សេងទៀត។

DRAFT

# ១ សេចក្តីផ្តើម

## ១.១ ដំណើរការផ្តល់សម្បទានដីសង្គមកិច្ច និងប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច

21. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ៣ ( LASED-III ) នឹងបន្តគាំទ្រដល់សម្បទានដីសង្គមកិច្ចនៅថ្នាក់ឃុំរបស់រាជរដ្ឋាភិបាលកម្ពុជា ពីគម្រោងជំហានដំបូង និងជំហានទី ២ ហើយនឹងជួយគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិចដែលបានដាក់ពាក្យសុំ ឬទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។

22. សម្បទានដីសង្គមកិច្ចត្រូវបានកំណត់រក និងអនុវត្តតាមរយៈដំណើរការ ១០ ជំហាន ដែលគាំទ្រដោយគម្រោងពីដំបូង និងគម្រោងជំហានទី ២។ ដំណើរការនេះមានពណ៌នាក្នុងតារាង ១ក ខាងក្រោម។

**តារាង ១ក ៖ ខ្លឹមសារសង្ខេបស្តីពីជំហានទាំង ១០ ក្នុងដំណើរការផ្តល់សម្បទានដីសង្គមកិច្ចនៅថ្នាក់ឃុំ**

| ជំហាន | ការពិពណ៌នា | លទ្ធផល |
|---|---|---|
| ១ | ផ្តួចផ្តើម និងពិនិត្យបឋមលើសម្បទានដីសង្គមកិច្ច | ក្រុមប្រឹក្សាឃុំដាក់ស្នើសម្បទានដីសង្គមកិច្ច (ការរៀបចំផែនទីព្រាង និងប្រវត្តិនៃការប្រើប្រាស់ដីធ្លី) |
| | | ការពិនិត្យបឋមលើហានិភ័យបរិស្ថាន និងសង្គម |
| | | ការអនុញ្ញាតឱ្យអនុវត្ត |
| ២ | គ្រោងការសិក្សាផ្នែកបច្ចេកទេស | ផែនការការងារសម្រាប់ដំណើរការផ្តល់សម្បទានដីសង្គមកិច្ច |
| ៣ | ការកសាងការយល់ដឹងដោយក្រុមប្រឹក្សាឃុំ | ប្រជាពលរដ្ឋមូលដ្ឋានយល់ពីសម្បទានដីសង្គមកិច្ច |
| | | មធ្យោបាយជ្រើសរើសអ្នកដែលត្រូវទទួលបានដីធ្លី ត្រូវបានសម្រេចយក |
| | | ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងអ្នកកាន់កាប់ដីធ្លីដោយខុសច្បាប់ |
| ៤ | កិច្ចប្រជុំស្តីពីដីរដ្ឋ | ធ្វើបច្ចុប្បន្នភាពផែនទីព្រាង ធៀបនឹងដីកម្មសិទ្ធិបុគ្គល និងដីសមូហភាព |
| | | ការគូសផែនទីសម្បទានដីសង្គមកិច្ចចុងក្រោយ ដោយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ៖ នេះជាមូលដ្ឋានសម្រាប់កាលបរិច្ឆេទ ឱសានវាទ។ |
| | | កំណត់រកច្រកចេញចូល និងកំណត់ថាតើចាំបាច់ត្រូវមានលទ្ធកម្មដីធ្លីសម្រាប់ការសាងសង់/ការកែលម្អផ្លូវចេញចូល ឬទេ។ |
| | | ប៉ាន់ប្រមាណផលប៉ះពាល់លើអ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម ដូចជា វាលស្មៅចិញ្ចឹមសត្វ អុស អនុផលព្រៃឈើនៅលើទីតាំងដីសម្បទានដីសង្គមកិច្ច។ ជានានូវ ១) លទ្ធភាពទទួលបានជម្រើសសមមូល ២) ការរួមបញ្ចូល |

ជំហានទី ៣, ៤ និង ៥ អនុវត្តក្នុងពេលតែមួយ។

| | | |
|---|---|---|
| | | អ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួមជាអ្នកទទួលផលពីសម្បទានដីសង្គមកិច្ច ឬ ៣) ការរៀបចំការផ្តល់សំណងសមស្រប។ |
| | | ការពិនិត្យឡើងវិញលើលទ្ធកម្មដីធ្លី និងផលប៉ះពាល់នៃការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត |
| | | ក្នុងករណីមានការកំណត់ថាត្រូវមានលទ្ធកម្មដីធ្លី អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់។ |
| | | ដីសម្រាប់សម្បទានដីសង្គមកិច្ចត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ។ |
| ៥ | ការរៀបចំផែនការ និងការគូសផែនទីស្តីពីការប្រើប្រាស់ដីធ្លីតាមបែបជំរុញការចូលរួម | ការវិភាគកសិ-ប្រព័ន្ធអេកូឡូស៊ី |
| | | ការវាយតម្លៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធ |
| | | ពិគ្រោះយោបល់ រៀបចំ ផ្សព្វផ្សាយពីផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង ផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ និងឧបករណ៍គ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមផ្សេងទៀត ទៅតាមភាពចាំបាច់។ ប្រសិនបើសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ សូមផ្ទៀងផ្ទាត់ការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ។ |
| | | របាយការណ៍សម្បទានដីសង្គមកិច្ច |
| ៦ | ការពិនិត្យឡើងវិញលើរបាយការណ៍សម្បទានដីសង្គមកិច្ច | ការបែងចែកហេដ្ឋារចនាសម្ព័ន្ធ និងសេវានៅជនបទ |
| ៧ | ការជ្រើសរើសអ្នកដែលត្រូវទទួលបានដីធ្លី | តារាងពាក្យស្នើសុំអាទិភាព |
| | | តារាងពាក្យស្នើសុំបម្រុង |
| ៨ | ផែនការពេញលេញសម្រាប់សម្បទានដីសង្គមកិច្ច | ការចែកក្បាលដី |
| | | ផែនការពេញលេញសម្រាប់សម្បទានដីសង្គមកិច្ច ត្រូវបានអនុម័ត |
| ៩ | ការរៀបចំទីតាំង | ការកំណត់ព្រំប្រទល់ក្បាលដីក្នុងទីតាំងសម្បទានដីសង្គមកិច្ច |
| | | ការផ្គត់ផ្គង់ទឹកស្អាតនៅជនបទ |
| | | ការសម្អាតទីតាំង |
| | | ច្រកចេញចូល |

| | | |
|---|---|---|
| | | ការផ្ទេរកម្មសិទ្ធិដីធ្លីជាផ្លូវការ |
| ១០ | ការតាំងទីលំនៅ និងការអភិវឌ្ឍជនបទ | ការតាំងទីលំនៅដោយទទួលបានជំនួយ |
| | | ហេដ្ឋារចនាសម្ព័ន្ធ និងសេវានៅជនបទ |
| | | សហគមន៍ដែលមាននិរន្តរភាព |

23. ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានអនុវត្តជា ៣ ដំណាក់កាលដូចតទៅ។ ដំណាក់កាលទី ១ ការទទួលស្គាល់សហគមន៍គោលដៅជាសហគមន៍ជនជាតិដើមភាគតិចដែលមានលក្ខណៈសម្បត្តិ ដោយក្រសួងអភិវឌ្ឍន៍ជនបទ។ ដំណាក់កាលទី ២ ការចុះបញ្ជីសហគមន៍ជាផ្លូវការជានីតិបុគ្គល ដោយក្រសួងមហាផ្ទៃ។ ដំណាក់កាលទី ៣ ការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ដំណើរការនេះត្រូវបានបង្កើតឡើងក្នុងការអនុវត្តជាក់ស្តែង។ ដូច្នេះហើយទើបមាន "ដំណាក់កាល ២.៥"។ ក្នុងដំណាក់កាលនេះ សហគមន៍ជនជាតិដើមភាគតិចត្រូវរៀបចំ និងដាក់ពាក្យសុំរបស់ខ្លួនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គម្រោងជំហានទី ៣ នឹងគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិចដែលបានដាក់ពាក្យសុំទៅក្រសួងពោលគឺនៅពេលពួកគេបានឈានដល់ពេលចាប់ផ្តើមដំណាក់កាលទី ៣ ឬដំណាក់កាលក្រោយទៀត។ គម្រោងនឹងគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ក្នុងការបញ្ចប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច និងផ្តល់ជំនួយផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងរបរចិញ្ចឹមជីវិតក្នុងកសិកម្ម។ សហគមន៍ជនជាតិដើមភាគតិចដែលទទួលបានប័ណ្ណកម្មសិទ្ធិរួចរាល់ (បញ្ចប់ដំណាក់កាលទី ៣) នឹងមានលក្ខណៈសម្បត្តិក្នុងការទទួលបានជំនួយផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងរបរចិញ្ចឹមជីវិត។ ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចមានបង្ហាញក្នុងតារាង ១ខ។

| តារាង ១ខ ៖ ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច | | | |
|---|---|---|---|
| ដំណាក់កាលទី ១ | ដំណាក់កាលទី ២ | ដំណាក់កាល ២.៥ | ដំណាក់កាលទី ៣ |
| ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច | ក្រសួងមហាផ្ទៃ ៖ ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការជា "នីតិបុគ្គល" | សហគមន៍ជនជាតិដើមភាគតិច ៖ ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ វាស់វែង ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ បែងចែកប្រភេទដីឡើងវិញ និងចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច |
| ជំហានទី ១ ៖ ការកសាងការយល់ដឹងជាសាធារណៈក្នុងចំណោមអាជ្ញាធរខេត្ត | ជំហានទី ១ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវព្រាងលក្ខន្តិកៈក្នុង | ជំហានទី ១ ៖ ប្រមូលទិន្នន័យ និងផលិតផែនទី | ជំហានទី ១ ៖ ការវាស់វែង និងការប្រមូលទិន្នន័យស្តីពីព្រំប្រទល់ដី ទៅតាមប្រភេទនៃការប្រើប្រាស់ ការកំណត់ |

| តារាង ១៨ ៖ ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច | | | |
|---|---|---|---|
| ដំណាក់កាលទី ១ | ដំណាក់កាលទី ២ | ដំណាក់កាល ២.៥ | ដំណាក់កាលទី ៣ |
| ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច | ក្រសួងមហាផ្ទៃ ៖ ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការជា "នីតិបុគ្គល" | សហគមន៍ជនជាតិដើមភាគតិច ៖ ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ វាស់វែង ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ បែងចែកប្រភេទដីឡើងវិញ និងចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច |
| (មន្ទីរពាក់ព័ន្ធ) និងអាជ្ញាធរនៅថ្នាក់ស្រុក ឃុំ និងភូមិ និងសហគមន៍ជនជាតិដើមភាគតិច។ | សហគមន៍ និងរៀបចំគណៈកម្មាធិការតំណាងសហគមន៍ | បឋមដោយកំណត់ព្រំប្រទល់នៃប្រភេទដីសហគមន៍ ដែលចូលរួមដោយម្ចាស់ដីទាំងអស់ (នៅចំណុចនេះ ត្រូវផ្តោតសំខាន់លើការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ) | ព្រំប្រទល់ និងការកំណត់អត្តសញ្ញាណដីរដ្ឋ (នៅចំណុចនេះ ត្រូវផ្តោតសំខាន់លើការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ)។ |
| ជំហានទី ២ ៖ សហគមន៍ជនជាតិដើមភាគតិចបង្ហាញឆន្ទៈក្នុងការផ្តួចផ្តើមដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច | ជំហានទី ២ ៖ ការពិនិត្យឡើងវិញលើការប្តេជ្ញាចិត្ត និងគោលបំណងរបស់សមាជិកសហគមន៍ | ជំហានទី ២ ៖ សហគមន៍ជនជាតិដើមភាគតិចបង្កើតវិធានផ្ទៃក្នុង ក្រោមការសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាល (ព្រាងដោយក្រសួងមហាផ្ទៃ) | ជំហានទី ២ ៖ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈនូវឯកសារវាយតម្លៃដីធ្លី និងបណ្តឹងតវ៉ា |
| ជំហានទី ៣ ៖ ការកសាងការយល់ដឹងពីដំណើរការនេះដល់សហគមន៍គោលដៅ | ជំហានទី ៣ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវរៀបចំសមាជ សហគមន៍ ដើម្បីធ្វើការ អនុម័តជាផ្លូវការលើ "លក្ខន្តិកៈសហគមន៍" និងគណៈកម្មាធិការរបស់សហគមន៍" | ជំហានទី ៣ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវដាក់ពាក្យសុំ ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជំហានទី ៣ ៖ ការរាយការណ៍ពីលទ្ធផលចេញពីការផ្សព្វផ្សាយឯកសារវាយតម្លៃដីធ្លី |
| ជំហានទី ៤ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវជ្រើសរើសតំណាង គណៈកម្មការសហគមន៍ និងធ្វើការកំណត់អត្តសញ្ញាណដោយខ្លួនឯងជា "ជនជាតិដើមភាគតិច" | ជំហានទី ៤ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវដាក់ពាក្យសុំចុះបញ្ជីជានីតិបុគ្គលទៅក្រសួងមហាផ្ទៃ | | ជំហានទី ៤ ៖ កិច្ចប្រជុំជាមួយ PSLC ដើម្បីសម្រេចយករបាយការណ៍ចេញពីលទ្ធផលនៃការផ្សព្វផ្សាយជាសាធារណៈស្តីពីការវាយតម្លៃដីធ្លី និងការស្នើឱ្យក្រសួងរៀបចំដែនដី ចេញប័ណ្ណកម្មសិទ្ធិដីដល់សហគមន៍ជនជាតិដើមភាគតិច |

| តារាង ១ខ ៖ ដំណើរការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច | | | |
|---|---|---|---|
| ដំណាក់កាលទី ១ | ដំណាក់កាលទី ២ | ដំណាក់កាល ២.៥ | ដំណាក់កាលទី ៣ |
| ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច | ក្រសួងមហាផ្ទៃ ៖ ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការជា "នីតិបុគ្គល" | សហគមន៍ជនជាតិដើមភាគតិច ៖ ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ វាស់វែង ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ បែងចែកប្រភេទដីឡើងវិញ និងចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច |
| ជំហានទី ៥ ៖ ក្រសួងអភិវឌ្ឍន៍ជនបទចេញវិញ្ញាបនបត្រអត្តសញ្ញាណដល់សហគមន៍ជនជាតិដើមភាគតិច | ជំហានទី ៥ ៖ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជា "នីតិបុគ្គល" | | ជំហានទី៥ ៖ ក្រសួងរៀបចំដែនដីផ្ញើលិខិតទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសុំឱ្យមានការពិនិត្យ និងអនុម័តដីធ្លីពាក់ព័ន្ធ។ |
| | | | ជំហានទី ៦ ៖ ក្រសួងរៀបចំដែនដីផ្ញើលិខិតទៅ CoM ដើម្បីស្នើឱ្យមានការបែងចែកប្រភេទដីធ្លីដែលត្រូវចុះបញ្ជីជាដីសមូហភាពឡើងវិញ ដោយផ្អែកតាមសេចក្ដីសម្រេចរបស់ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ |
| | | | ជំហានទី ៧ ៖ ចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច |

## ១.២ ទីតាំងសម្បទានដីសង្គមកិច្ចដែលមានស្រាប់នៅថ្នាក់ឃុំ និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដី សមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច

24. ទីតាំងសម្បទានដីសង្គមកិច្ចចាស់នៅថ្នាក់ឃុំ (ឧ. ទីតាំងដែលទទួលបានជំនួយពីគម្រោងជំហានដំបូង និងជំហានទី ២ នឹងមានលក្ខណៈសម្បត្តិក្នុងការទទួលបានជំនួយបន្ថែមលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងបរេចិញ្ចឹមជីវិតពីគម្រោងជំហានទី ៣)។ មានសម្បទានដីសង្គមកិច្ច ១៤ ទីតាំងក្នុងប្រភេទនេះ (តារាង ២ក)។

| តារាង ២ក ៖ សម្បទានដីសង្គមកិច្ចដែលមានស្រាប់នៅថ្នាក់ឃុំ | | | | | |
|---|---|---|---|---|---|
| ខេត្ត | ស្រុក | ឃុំ | ឈ្មោះសម្បទានដីសង្គមកិច្ច | ចំនួនគ្រួសារ | ទំហំសរុប (ហិចតា) |
| ក្រចេះ | ចិត្របុរី | សំបុក | សម្បទានដីសង្គមកិច្ចសំបុក | 554 | 3,294.36 |
| | | ចង្ក្រង | សម្បទានដីសង្គមកិច្ចចង្ក្រង | 331 | 612.21 |

| | | | | | |
|---|---|---|---|---|---|
| | | ដារ | សម្បទានដីសង្គមកិច្ចដារ | 402 | 572.37 |
| | | ថ្មី | សម្បទានដីសង្គមកិច្ចថ្មី | 432 | 923.9 |
| | ព្រែកប្រសព្វ | ចំបក់ | សម្បទានដីសង្គមកិច្ចចំបក់ | 400 | 1,163.20 |
| ត្បូងឃ្មុំ | មេមត់ | ចោមក្រវៀន | សម្បទានដីសង្គមកិច្ចចោមក្រវៀន | 250 | 863.65 |
| កំពង់ធំ | សន្ទុក | ទីពោធិ៍ ១ | សម្បទានដីសង្គមកិច្ចទីពោធិ៍ ១ | 479 | 1,508.00 |
| | | ទីពោធិ៍ ២ | សម្បទានដីសង្គមកិច្ចទីពោធិ៍ ២ | 300 | 1,335.44 |
| កំពង់ឆ្នាំង | សាមគ្គីមានជ័យ | ក្រាំងល្វា | សម្បទានដីសង្គមកិច្ចសំបុកក្រៀល | 196 | 854.3 |
| | | | សម្បទានដីសង្គមកិច្ចខ្សាច់ស | 258 | 975.6 |
| | | ពាម | សម្បទានដីសង្គមកិច្ចពាម | 233 | 468.78 |
| | | ឈានឡើង | សម្បទានដីសង្គមកិច្ចឈានឡើង | 206 | 428.99 |
| កំពង់ស្ពឺ | ឱរ៉ាល់ | ស្មើសាមគ្គី | សម្បទានដីសង្គមកិច្ចព្រៃធំ | 400 | 1,120.00 |
| កំពង់ធំ | ប្រាសាទ បល្ល័ង្ក | ដុង | សម្បទានដីសង្គមកិច្ចដុង (ទីតាំងថ្មី) | 572 | 1,992.79 |

25. បច្ចុប្បន្ន មានសហគមន៍ជនជាតិដើមភាគតិច ១៥០ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ (ដំណាក់កាលទី ១)។ ក្នុងនោះ សហគមន៍ជនជាតិដើមភាគតិច ១៤១ ត្រូវបានចុះបញ្ជីជានីតិបុគ្គលដោយក្រសួងមហាផ្ទៃ (ដំណាក់កាលទី ២)។ សហគមន៍ជនជាតិដើមភាគតិច ៣០ បានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដំណាក់កាលទី ៣)។ ទីតាំងដាក់ស្លែង និងទីតាំងដែលបានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចស្ទើរតែទាំងអស់ស្ថិតក្នុងខេត្តភាគឦសាន (រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ)។ ការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ សហគមន៍ជនជាតិដើមភាគតិចទាំង ៣០ មានបង្ហាញក្នុងតារាង ២ខ។

| តារាង ២ខ ៖ ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលទទួលបាន | | | | |
|---|---|---|---|---|
| ខេត្ត | ភូមិ | ចំនួនប័ណ្ណកម្មសិទ្ធិ | ទំហំសរុប (ហិចតា) | ចំនួនគ្រួសារ |
| រតនគិរី | ឡឺនក្រឹន (Laern Kraen) | 17 | 723.50 | 84 |
| | ឡាអិន (La-Inn) | 64 | 1501.89 | 242 |
| | ឡឺនចុង (Laern Chong) | 16 | 675.90 | 96 |
| | ក្រឡា (Krala) | 21 | 1765.98 | 205 |
| | ភូមិពិ (Phum Pir) | 23 | 854.86 | 165 |
| | តាង៉ាច (Ta Ngach) | 9 | 624.16 | 70 |

| | | | | |
|---|---|---|---|---|
| | កុងកុយ (Kong Koy) | 6 | 463.52 | 43 |
| | កញ្ចឹង (Kancherng) | 9 | 1512.10 | 106 |
| | ក្រេស (Kres) | 15 | 748.29 | 73 |
| | លើ (Laer) | 24 | 768.7 | 108 |
| | កាចាញ (Kachanh) | 27 | 789.31 | 151 |
| | កាឡុង (Kalong) | 20 | 628.10 | 65 |
| | កាទៀង (Katieng) | 30 | 656.25 | 115 |
| | ទុន (Tun) | 23 | 2421.11 | 102 |
| | ទំពួនរ៉ុងតូច (Tumpuon Roeung Toch) | 15 | 2119.35 | 60 |
| | ព្យ៉ាង (Pyang) | 17 | 1593.03 | 64 |
| | សៀងសាយ (Sieng Say) | 24 | 827.29 | 57 |
| មណ្ឌលគិរី | អូរណា (Orana) | 59 | 648.05 | 80 |
| | អូរច្រា (Ochra) | 27 | 526.12 | 27 |
| | កាទី (Gati) | 22 | 482.69 | 45 |
| | ស្រែខ្ទុម (Srae Ktum) | 61 | 1084.52 | 93 |
| | ស្រែឡាវី (Srae Lavy) | 12 | 383.84 | 31 |
| | អណ្ដូងក្រឡឹង (Andong Kraleung) | 37 | 1424.26 | 81 |
| | ពូត្រុម (Putrom) | 60 | 1606.18 | 116 |
| ក្រចេះ | ពុនជា (Ponchea) | 35 | 597.31 | 132 |
| | អូរកុក (Okok) | 21 | 402.03 | 37 |
| | ប៉ាខ្លែ (Pa Khlae) | 35 | 1577.81 | 237 |
| | រវៀង (Rovieng) | 43 | 2207.84 | 223 |
| ស្ទឹងត្រែង | កាតូត (Katot) | 21 | 685.04 | 58 |
| | រំពាត់ (Rompoat) | 26 | 1306.47 | 67 |
| **សរុប** | | **819** | **31605.53** | **3033** |

## ១.៣ គោលបំណងនៃគម្រោង

26. គោលបំណងនៃការរៀបចំគម្រោង (PDO) គឺដើម្បីផ្ដល់លទ្ធភាពទទួលបានសន្តិសុខសិទ្ធិកាន់កាប់ដីធ្លី សេវាកសិកម្ម និងសង្គម និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនដល់កសិករមានដីធ្លីតិចតួច និងសហគមន៍ក្នុងតំបន់គម្រោង។ មានសូចនាករ ៣ នៅកម្រិតគោលបំណងនៃការរៀបចំគម្រោង ដែលនឹងត្រូវវាស់វែងដោយសូចនាករដូចតទៅ។ ទី ១ គឺសន្តិសុខសិទ្ធិកាន់កាប់ដែលផ្ដល់ដល់កសិករ និងក្រុមសហគមន៍ដែលជាអ្នកទទួលផល។ សមិទ្ធិផលត្រូវបានកំណត់ដោយចំនួនប័ណ្ណកម្មសិទ្ធិដីធ្លីដែលបានចុះបញ្ជី និងទំហំផ្ទៃដីពាក់ព័ន្ធ (ហិចតា) និងការវាស់វែងការយល់ដឹងពីសន្តិសុខសិទ្ធិកាន់កាប់។ ទិន្នន័យដែលប្រមូលបាន នឹងបែងចែកតាមភេទ បុគ្គលពាក់ព័ន្ធ និងសិទ្ធិទទួលបានដីសមូហភាព។ ទី ២ ការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាក្នុងតំបន់គម្រោង។ សមិទ្ធផលនេះកំណត់ដោយលទ្ធភាពទទួលបានសេវាកសិកម្ម ទឹកស្អាត ការតភ្ជាប់បណ្ដាញផ្លូវ សាលារៀន និងប៉ុស្តិ៍សុខភាព។ ទី ៣ គឺការអភិវឌ្ឍ របរចិញ្ចឹមជីវិតក្នុងការងារកសិកម្មប្រកបដោយនិរន្តរភាពសម្រាប់បុគ្គល និងក្រុមទាំងឡាយដែលពាក់ព័ន្ធនឹងសហគមន៍ក្នុងតំបន់គម្រោង។ សមិទ្ធផលនេះកំណត់ដោយភាពប្រសើរឡើងនៃ

ស្ថានភាពភាពក្រីក្ររបស់អ្នកទទួលផល។ ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានវាស់វែងដោយការពេញចិត្ត របស់អ្នកទទួលផលចំពោះដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងការផ្តល់សេវាកសិកម្ម។

## ១.៤ សមាសភាគគម្រោង

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ ( LASED III ) មានសមាសភាគ ៥ ៖ ១) ការជ្រើសរើស និងរៀបចំផែនការអភិវឌ្ឍន៍សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព របស់សហគមន៍ជនជាតិដើមភាគតិច ២) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ៣) ការអភិវឌ្ឍកសិកម្ម និង របរចិញ្ចឹមជីវិត ៤) ការគ្រប់គ្រង ការសម្របសម្រួល និងការពិនិត្យតាមដាន និងវាយតម្លៃគម្រោង និង ៥) ការ ឆ្លើយតបចំពោះគ្រោះអាសន្នជាយថាហេតុ។

27. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ អនុវត្តវិធីសាស្ត្រ ២ ៖ ១) ការបូកសរុបតាមរយៈសកម្មភាពបំពេញបន្ថែមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចបច្ចុប្បន្នក្នុងគម្រោងដំណាក់កាលទី ២ និងការពង្រីកសកម្មភាពនេះឱ្យគ្របដណ្តប់លើទីតាំងសម្បទានដីសង្គមកិច្ចថ្មីៗ និង ២) ការអនុវត្តវិធីសាស្ត្រ ដែលបានកែសម្រួលក្នុងសហគមន៍ជនជាតិដើមភាគតិចនៅតាមខេត្តថ្មីៗដែលអនុវត្តគម្រោង។ គម្រោងដំណាក់កាល ទី ៣ នេះនឹងផ្អែកលើនីតិវិធីដែលត្រូវបានបង្កើតឡើងយ៉ាងល្អ និងទទួលបានជោគជ័យក្នុងគម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី ២ សម្រាប់ការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ច ប៉ុន្តែគម្រោងនឹងកែ សម្រួលនីតិវិធីទាំងនោះសម្រាប់សហគមន៍ជនជាតិដើមភាគតិច។

28. ***សមាសភាគទី ១ ៖ ការជ្រើសរើស និងរៀបចំផែនការអភិវឌ្ឍន៍សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណ កម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច*** ៖ គម្រោងដំណាក់កាលទី ៣ នឹងគាំទ្រដល់ការដាក់ពាក្យ សុំសម្បទានដីសង្គមកិច្ច ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងជំនួយ អភិវឌ្ឍន៍ដល់សហគមន៍ជនជាតិដើមភាគតិច ក្រោមគោលការណ៍ "អ្នកមកមុន បានមុន"។ សម្រាប់សម្បទាន ដីសង្គមកិច្ចថ្មី ឃុំត្រូវដាក់សំណើ ហើយបន្ទាប់ពីគម្រោងបានកំណត់ពីទីតាំងដីទំនេរធៀបនឹងតម្រូវការរបស់សហ គមន៍ នឹងមានការរៀបចំផែនការស្តីពីការប្រើប្រាស់ដីធ្លី និងការវាយតម្លៃបរិស្ថាន និងសង្គមគ្រប់ជ្រុងជ្រោយ មុន នឹងអនុម័តទីតាំងនោះសម្រាប់ការអនុវត្តគម្រោង។ សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ ជនជាតិដើមភាគតិច និងជំនួយអភិវឌ្ឍន៍ដល់សហគមន៍ជនជាតិដើមភាគតិច ពួកគេត្រូវមកសុំជំនួយដោយខ្លួន ឯង។សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចគម្រោង នឹងផ្តល់ជំនួយ ដល់ដំណាក់កាលចាំបាច់ផ្សេងៗដើម្បីបញ្ចប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ[1]។ ចំណុចនេះរួមមានសហគមន៍ជនជាតិ ដើមភាគតិចដែលបានដាក់ពាក្យសុំចុះបញ្ជីដីធ្លី ហើយពាក្យសុំទាំងនោះត្រូវបានទទួលយកដោយមន្ទីរភូមិបាល ខេត្ត ប៉ុន្តែការចុះបញ្ជីដីធ្លីមិនទាន់បានចាប់ផ្តើម និងសហគមន៍ជនជាតិដើមភាគតិចដែលមានការទទួលស្គាល់ផ្លូវ ច្បាប់ពីក្រសួងមហាផ្ទៃ ប៉ុន្តែមិនទាន់បានបង្កើតនិងប្រមែប្រមូលឯកសារចាំបាច់ទាំងអស់សម្រាប់ដាក់ពាក្យសុំចុះ បញ្ជីដីធ្លី។ សម្រាប់សហគមន៍ជនជាតិដើមភាគតិច ដែលបានបញ្ចប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធដីសមូហភាព របស់សហគមន៍ជនជាតិដើមភាគតិចនៅពេលគម្រោងចាប់ផ្តើមដំបូង គម្រោងនឹងផ្តល់ជំនួយអភិវឌ្ឍន៍ក្នុងទម្រង់

[1] ឧបសម្ព័ន្ធ ២ រៀបរាប់ពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងការណែនាំស្តីពីជំនួយ អភិវឌ្ឍន៍សម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលទទួលបានប័ណ្ណកម្មសិទ្ធិរួចរាល់។

ជាជំនួយ ហេដ្ឋារចនាសម្ព័ន្ធ និងសេវា។ គម្រោងនឹងផ្ដល់ជំនួយការបច្ចេកទេសអន្តរជាតិ និងជំនួយការបច្ចេកទេសក្នុងស្រុកដែលមានបទពិសោធន៍ដើម្បីរៀបចំផែនការក្នុងសហគមន៍ជនជាតិដើមភាគតិច។

29. ផែនការប្រើប្រាស់ដីធ្លីជាឧបករណ៍ដ៏សំខាន់សម្រាប់ការកំណត់អត្តសញ្ញាណ និងការបង្កើត ផែនការអភិវឌ្ឍន៍សម្រាប់សម្បទានដីសង្គមកិច្ច និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ សហគមន៍ជនជាតិដើមភាគតិច ព្រោះឧបករណ៍នេះផ្ដល់មូលដ្ឋានព័ត៌មានដល់យុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាពនៅតាមមូលដ្ឋាន រួមទាំងការកំណត់រកការប្រើប្រាស់ធនធានដីធ្លីដែលមានភាពសមស្របបំផុត និងការស្ដារដីធ្លីដែលសឹករេចរឹល។ ចំណុចសំខាន់គឺ ផែនការប្រើប្រាស់ដីធ្លីនឹងផ្ដោតលើការរក្សាការពារធនធានទឹកធម្មជាតិ គម្របព្រៃឈើ យកចិត្តទុកដាក់លើបណ្ដាញប្រឡាយបង្ហូរទឹកធម្មជាតិ ឬអាងទឹក ដើម្បីធានាការប្រើប្រាស់ដីធ្លីដែលកាត់បន្ថយហានិភ័យ មុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ដូចជា គ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់។ ក្នុងការកំណត់អត្តសញ្ញាណ និងការបង្កើតផែនការអភិវឌ្ឍន៍សម្រាប់សម្បទានដីសង្គមកិច្ច និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច សកម្មភាពសំខាន់ៗ ៣ ក្នុងសមាសភាគនេះនឹងទទួលបានជំនួយហិរញ្ញវត្ថុ។ ទីមួយ គឺការរៀបចំផែនការដោយមានការចូលរួមសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចសម្រាប់ទីតាំងថ្មីៗ។ ទីពីរ គឺការកំណត់អត្តសញ្ញាណ ការកំណត់អាទិភាព និងការរៀបចំផែនការសម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទដែលធន់នឹងអាកាសធាតុ ដូចជា គម្រោងធារាសាស្ត្រ ផ្លូវថ្នល់ សាលារៀន ផ្ទះគ្រូ មជ្ឈមណ្ឌលសហគមន៍ មូលដ្ឋានថែទាំសុខភាព ការផ្គត់ផ្គង់ទឹកស្អាត។ ដំណើរការរៀបចំផែនការនឹងជួយប្រមូលទិន្នន័យដើមគ្រាពាក់ព័ន្ធសម្រាប់គម្រោង ដែលជួយដល់ការធ្វើសេចក្ដីសម្រេចលើការរៀបចំផែនការអភិវឌ្ឍន៍សហគមន៍ដែលធន់នឹងអាកាសធាតុ។ ទីបី គឺការដំណើរការផ្ដល់ប័ណ្ណកម្មសិទ្ធិដី ក្នុងទីតាំងសម្បទានដីសង្គមកិច្ចដល់អ្នកដែលមានលក្ខណៈសម្បត្តិទទួលបានដីធ្លី និងប័ណ្ណកម្មសិទ្ធិដីសមូហភាពក្នុងសហគមន៍ជនជាតិដើមភាគតិច។

30. គម្រោងនឹងផ្ដល់ជំនួយបច្ចេកទេស សម្រាប់ការរៀបចំផែនការសកម្មភាពគម្រោង នៅគ្រប់ទីតាំងគម្រោង ទាំងអស់ ដោយមិនគិតពីស្ថានភាពរបស់ទីតាំងទាំងនោះក្នុងដំណើរការផ្ដល់ប័ណ្ណកម្មសិទ្ធិ។ គម្រោងនឹងពិនិត្យឡើងវិញលើភាពសំបូរបែបផ្នែកជីវៈ-រូបវន្ត សង្គម-សេដ្ឋកិច្ច និងវប្បធម៌របស់សហគមន៍ទាំងនោះ និងបរិស្ថានជុំវិញ ព្រមទាំងវាយតម្លៃលើសមត្ថភាពអនុវត្តន៍នៅតាមទីតាំងទាំងនោះ និងផលវិបាកសម្រាប់ការប្រកបរបរកសិកម្មរបស់អ្នកទទួលបានដីធ្លី។ ក្រៅពីនេះ ការដាក់បញ្ចូលការរៀបចំផែនការទីតាំងក្នុងផែនការអភិវឌ្ឍន៍ឃុំ/ផែនការវិនិយោគឃុំ នឹងជួយពង្រឹងនិរន្តរភាពរយៈពេលវែង។ ដូច្នេះហើយទើបរដ្ឋាភិបាលស្នើឱ្យមានការរៀបចំផែនការអភិវឌ្ឍន៍ឃុំសម្រាប់ស្រុកទាំងអស់ដែលជាទីតាំងសម្បទានដីសង្គមកិច្ច ដែលនឹងត្រូវយកមកអនុវត្តក្នុងគម្រោងជំហានទី ៣ នេះ។ នឹងមានការរៀបចំផែនការប្រើប្រាស់ដីសហគមន៍ តាមរយៈការគូសផែនទី និងឧបករណ៍ GPS និងការចូលរួមយ៉ាងសកម្មរបស់សមាជិកសហគមន៍។ ប្លង់លម្អិតនៃសកម្មភាពរៀបចំផែនការ និងដំណើរការ និងឧបករណ៍គ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ដែលគួររៀបចំឡើងសម្រាប់ទីតាំងគម្រោងផ្សេងៗ នឹងត្រូវបានដាក់បញ្ចូលក្នុងសៀវភៅណែនាំស្ដីពីការអនុវត្តគម្រោង។ សៀវភៅណែនាំនេះនឹងបង្ហាញលម្អិតពីលក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំផែនការនេះ។

31. ***សមាសភាគទី ២ ៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍៖*** បន្ទាប់ពីការជ្រើសរើសការវិនិយោគហេដ្ឋារចនាសម្ព័ន្ធជាអាទិភាព និងអាចអនុវត្តទៅបាននៅទីតាំងគម្រោងថ្មីក្នុងសមាសភាគទី ១ សមាសភាគទី

២ នឹងផ្តោតលើការផ្តល់ហិរញ្ញប្បទានដល់ការអនុវត្តការវិនិយោគ ដូចជា ការផ្តល់ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសហគមន៍ដែលផ្តល់ផលិតភាព/ពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងសង្គមកិច្ច (ឧ. ផ្លូវជនបទ ប្រព័ន្ធបង្ហូរទឹកពីចំហៀង កងលូ ការផ្គត់ផ្គង់ទឹក និងមូលដ្ឋានអនាម័យ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច អគារសិក្សា ផ្ទះគ្រូ ប៉ុស្តិ៍សុខភាព និងមជ្ឈមណ្ឌលសហគមន៍។ល។)។ ផ្អែកតាមបទពិសោធន៍ក្នុងតំបន់សម្បទានដីសង្គមកិច្ចចាស់ និងការឆ្លើយតបនឹងការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធយ៉ាងច្រើននៅទីតាំងគម្រោងថ្មីដែលស្នើឡើងនៅជនបទ គម្រោងនឹងផ្តល់បណ្តាញ ត ភ្ជាប់ការដឹកជញ្ជូន ដូចជា ផ្លូវចេញចូលទីតាំង ផ្លូវចេញចូលតំបន់រស់នៅ និងតំបន់កសិកម្ម និងប្រកច្បើជើងទាំងក្នុង និងទូទាំងទីតាំងសម្បទានដីសង្គមកិច្ច។ គេរំពឹងថា គម្រោងនឹងវិនិយោគច្រើនបំផុតលើការតភ្ជាប់បណ្តាញដឹកជញ្ជូនដែលផ្តល់ប្រយោជន៍លើសពីអ្នកទទួលផលផ្ទាល់ពីគម្រោង (ឃុំទាំងមូល និងតំបន់ធំទូលាយ)។ ការវិនិយោគបន្ទាប់ផ្តោតលើការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតំបន់រស់នៅ និងគម្រោងធារាសាស្ត្រខ្នាតតូចដែលមាននិរន្តរភាព និងធន់នឹងការប្រែប្រួលអាកាសធាតុ។ បញ្ហានិរន្តរភាពត្រូវបានដោះស្រាយតាមរយៈការដាក់បញ្ចូលវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងការរចនា និងសាងសង់ និងវិសាលភាពរបស់ផ្លូវថ្នល់ និងហេដ្ឋារចនា សម្ព័ន្ធសហគមន៍ផ្សេងទៀត ដោយផ្អែកតាមទំហំមូលនិធិសម្រាប់ការជួសជុលថែទាំ ដែលគ្រោងឡើងដោយរដ្ឋាភិបាលមូលដ្ឋានពាក់ព័ន្ធ។ គម្រោងនឹងអនុវត្តតាមគោលនយោបាយ និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា/ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធជន បទ។

32. ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវកសាងឡើងក្រោមគម្រោងនេះផ្តោតសំខាន់លើភាពធន់ ពោលគឺធន់នឹងការប្រែប្រួលអាកាសធាតុ និងពង្រឹងភាពធន់របស់សហគមន៍។ ហេដ្ឋារចនាសម្ព័ន្ធធ្វើដំណើរនឹងត្រូវបានកសាងឡើងឱ្យធន់នឹងមុខសញ្ញាគ្រោះថ្នាក់ក្នុងអាកាសធាតុ ដូចជា ការឡើងកម្តៅខ្លាំង និងគ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់ និងគាំទ្រដល់ភាពធន់របស់សហគមន៍នៅតាមដងផ្លូវ តាមរយៈការរចនាបែបឆ្លាតវៃដែលបង្វែរលំហូទឹកភ្លៀងពីផ្លូវដែលទើបតែសង់ថ្មីសម្រាប់ការដាំដុះ ម៉ាស៊ីនបូមទឹក ពីកងលូទៅធារាសាស្ត្រផ្សេងទៀត។ ហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជា អគារសិក្សា មជ្ឈមណ្ឌលសហគមន៍ ប៉ុស្តិ៍សុខភាព នឹងត្រូវបានរចនាឡើងឱ្យធន់នឹងមុខសញ្ញាគ្រោះថ្នាក់ក្នុងអាកាសធាតុ មានប្រសិទ្ធភាពថាមពល និងដើរដោយថាមពលកកើតឡើងវិញ។ ដើម្បីឱ្យផ្លូវថ្នល់ធន់នឹងអាកាសធាតុ គេត្រូវពិចារណា និងប្រើប្រាស់វិធានការបច្ចេកវិទ្យាជាច្រើន។ វិធានការ បន្សាំនឹងការប្រែប្រួលអាកាសធាតុ ដូចជា ការលើកទំនប់ទប់ឱ្យបានកម្ពស់យ៉ាងតិច ០,៥ ម៉ែត្រផុតពីកម្រិតទឹកជំនន់អតិបរមា ការកែសម្រួលជម្រាលសងខាងឱ្យបាន ១:៣ ការកសាងប្រព័ន្ធបង្ហូរទឹកពីចំហៀង និងគម្រោងបង្ហូរទឹកខ្វែង និងការកែសម្រួលលក្ខណៈបច្ចេកទេសដើម្បីឱ្យហាប់ល្អ នឹងត្រូវបានលើកមកពិចារណាក្នុងការរចនាផ្នែកវិស្វកម្ម និងការសាងសង់។ ផ្អែកតាមការពិចារណាទាំងនេះ គម្រោងត្រូវការដីថ្លីកាន់តែច្រើនសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ជាងគម្រោងមុនៗ។ ឧ. យើងនឹងធ្វើផ្លូវដែលមានទទឹងរហូតដល់ ៣០ ម៉ែត្រដើម្បីចូលទៅការដ្ឋាន និងផ្លូវដែលមានទទឹង ២៤ ម៉ែត្រសម្រាប់ចូលទៅតំបន់រស់នៅ និងកសិកម្ម ប្រសិនបើសកម្មភាពនេះមិនធ្វើឱ្យមានការតាំងទីលំនៅថ្មី។ ការឈូសឆាយពង្រាបផ្លូវនឹងជួយឱ្យផ្លូវធន់នឹងអាកាសធាតុ ព្រោះផ្លូវដី និងផ្លូវក្រាលគ្រួសងាយខូចដោយសារការប្រែប្រួលអាកាសធាតុ។ ប៉ុន្តែគម្រោងនឹងឈូសឆាយផ្លូវមួយចំនួនតូចបំផុត ព្រោះថវិកាមិនគ្រប់គ្រាន់។ គម្រោងជំហានទី ៣ ក៏មិនខុសពីគម្រោងមុនៗដែរ ព្រោះវិស្វករគម្រោងនឹងរៀបចំប្លង់រចនាបច្ចេកទេសលម្អិត និងត្រួតពិនិត្យការសាងសង់ ក្រោមជំនួយរបស់បុគ្គលិកបច្ចេកទេសមកពីមន្ទីរពាក់ព័ន្ធ។ ដូច្នេះ វិស្វករគម្រោងនឹងផ្តល់ការបណ្តុះបណ្តាលក្នុងពេលបំពេញការងារដល់មន្ត្រីថ្នាក់ខេត្តស្តីពីការរចនា

និងការត្រួតពិនិត្យការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ សម្រាប់ផ្លូវជនបទ ក្រុមហ៊ុនម៉ៅការត្រូវប្រើប្រាស់កម្លាំងពលកម្ម និងសម្ភារៈក្នុងមូលដ្ឋានតាមដែលអាចធ្វើទៅបាន ដើម្បីជួយកសាងសមត្ថភាពជួសជុលថែទាំក្នុងមូលដ្ឋាន និងផ្ដល់ឱកាសការងារ។

33. ***សមាសភាគទី ៣ ៖ ការអភិវឌ្ឍកសិកម្ម និងរបរចិញ្ចឹមជីវិត ៖*** សមាសភាគនេះនឹងជួយដល់ដំណើរការតាំងទីលំនៅរបស់គ្រួសារអ្នកទទួលផលការកសាងធនធានសង្គម-សេដ្ឋកិច្ច (ក្រុមអ្នក ផលិត/សហករណ៍) និងការអភិវឌ្ឍប្រព័ន្ធផលិតកម្មកសិកម្មដោយផ្អែកតាមតម្រូវការទីផ្សារ និងធន់នឹងការប្រែប្រួលអាកាសធាតុ។ សកម្មភាពទាំងនេះរួមមានការផ្ដល់ជំនួយដល់ ១) ការតាំងទីលំនៅថ្មី[2] ដល់អ្នកដែលទើបទទួលបានដីធ្លី និងជំនួយលើការរៀបចំដីធ្លីសម្រាប់ការដាំដំណាំគម្របជាលើកដំបូង និង/ឬការដាំកូនឈើហូបផ្លែ ដូចជា ស្វាយចន្ទី ដើម្បីអាចឱ្យអ្នកទទួលបានដីធ្លីអាចចាប់ផ្ដើមការរស់នៅ និងប្រើប្រាស់ដីកសិកម្មថ្មីរបស់ខ្លួន ២) ការអនុវត្តយុទ្ធសាស្ត្រសេវាកសិកម្មគ្រប់ជ្រុងជ្រោយ (មើលកថាខណ្ឌបន្ទាប់) ដោយផ្ដោតសំខាន់លើបច្ចេកទេសធ្វើកសិកម្មដែលធន់នឹងអាកាសធាតុ និងកម្រិតចំណេះដឹង ជំនាញ និងចំណាប់អារម្មណ៍របស់អ្នកទទួលបានដីធ្លី។ អ្នកទទួលបានដីធ្លីមានចាប់ពីអ្នកដែលត្រូវមានជំនាញមូលដ្ឋានក្នុងការធ្វើកសិកម្ម រហូតដល់អ្នកដែលមានជំនាញច្រើន និងត្រៀមខ្លួនចូលរួមក្នុងទីផ្សារតូចៗដែលផ្ដល់ប្រាក់ចំណេញក្នុងប្រទេស ឬសម្រាប់ការនាំចេញ និងភាពចាំបាច់នៃវិធីសាស្ត្រផ្អែកតាមយេនឌ័រ។ ជារួមសកម្មភាពនេះរួមមានការផ្ដល់ការបណ្ដុះបណ្ដាលស្ដីពីបច្ចេកទេសសំខាន់ៗដែលធន់នឹងអាកាសធាតុ និងការផ្ដល់ និងការប្រើប្រាស់សេវាព័ត៌មានអាកាសធាតុដើម្បីផ្ដល់មូលដ្ឋានព័ត៌មានដល់ការធ្វើសេចក្ដីសម្រេចរបស់សហគមន៍ស្ដីពីហានិភ័យអាកាសធាតុ។ យុទ្ធសាស្ត្រនេះនឹងទាញប្រយោជន៍ពីកម្លាំងផ្គួបជាមួយគម្រោងអាហារូបត្ថម្ភបច្ចុប្បន្ន ដែលគាំទ្រដោយធនាគារពិភពលោក (កថាខណ្ឌ ២៥) ព្រមទាំងលើកកម្ពស់ផលិតកម្មកសិកម្មដែលយកចិត្តទុកដាក់លើអាហារូបត្ថម្ភ ៣) ការបង្កើត និង/ឬពង្រឹងអង្គការកសិករលើសកម្មភាពផលិតកម្ម និងការធ្វើទីផ្សារ និងក្រុមចំណាប់អារម្មណ៍ផ្សេងទៀតក្នុងសហគមន៍ ដើម្បីឱ្យមានការផ្លាស់ប្ដូរចំណេះដឹង និងការរៀនសូត្រពីគ្នាទៅវិញទៅមកស្ដីពីការធ្វើកសិកម្មដែលធន់នឹងអាកាសធាតុ (ឧ. ការប្រើប្រាស់ជីកាន់តែប្រសើរ ការគ្រប់គ្រងជីអាចម៍សត្វ និងការគ្រប់គ្រងធនធានទឹកចម្រុះ និងការទទួលបានព័ត៌មានបឋមស្ដីពីអាកាសធាតុ និង ៤) ការផ្ដល់មូលនិធិសម្រាប់ការអភិវឌ្ឍសហគមន៍ ដើម្បីពង្រីកគំនិតផ្ដួចផ្ដើមជោគជ័យក្នុងមូលដ្ឋាន។ មូលនិធិនេះនឹងមានទម្រង់ជាមូលនិធិវិលជុំ និងផ្ដោតអាទិភាពលើគំនិតផ្ដួចផ្ដើមនៅមូលដ្ឋានដែលបង្កើនអត្ថប្រយោជន៍ឈ្នះៗ ៣ ដង ដូចជា ការបង្កើនផលិតភាព និងប្រាក់ចំណូលសម្រាប់កសិករ និងការកាត់បន្ថយផលប៉ះពាល់ និងការបន្សាំ។ ការអនុវត្តសមាសភាគនេះនឹងទទួលបានជំនួយបច្ចេកទេសយ៉ាងច្រើនពីថ្នាក់ជាតិ និងអន្តរជាតិ ក្រោមកិច្ចសហការយ៉ាងស្អិតរមួតជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នអនុត្តន៍ផ្សេងទៀត និងមន្ទីរពាក់ព័ន្ធ។

34. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតយុទ្ធសាស្ត្រផ្ដល់សេវាកសិកម្មគ្រប់ជ្រុងជ្រោយសម្រាប់គម្រោងជំហានទី ៣ នេះ ដូចជា ការផ្សព្វផ្សាយ និងការគាំទ្រដល់សហករណ៍កសិកម្ម។ រហូតមកដល់ពេលនេះ ការផ្ដល់សេវាផ្សព្វផ្សាយក្រោមគម្រោងជំហានទី ២ ខិតខំប្រើប្រាស់វិធីសាស្ត្រ "Farmers' Field School-FFS" ប៉ុន្តែការអនុវត្តនៅមានកម្រិតបំផុត ដោយសារតែការមិនយល់ច្បាស់ពីលក្ខណៈសំខាន់ៗនៃវិធី

---

[2] សម្ភារចាំបាច់ក្នុងគ្រួសារ សម្ភារសាងសង់មួយចំនួន អាហារក្នុងពេលធ្វើការ និងសម្ភារ និងបរិក្ខារតូចៗសម្រាប់ការងារកសិកម្ម (មានបញ្ជាក់លម្អិតក្នុងសៀវភៅណែនាំស្ដីពីការអនុវត្តគម្រោង)។

សាស្ត្រនេះ កម្សោយសមត្ថភាពបច្ចេកទេស និងកង្វះមូលនិធិ។ បន្ទាប់ពីការវិភាគគ្រប់ជ្រុងជ្រោយរកបញ្ហាក្នុងសេវាផ្សព្វផ្សាយបច្ចុប្បន្ន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកែសម្រួលយុទ្ធសាស្ត្រផ្តល់សេវាឡើងវិញ។ យុទ្ធសាស្ត្រនេះរួមមានវិធីសាស្ត្រអ្នកផ្តល់សេវាចម្រុះដែលចូលរួមដោយបុគ្គលិកបច្ចេកទេសមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ភ្នាក់ងារក្នុងវិស័យឯកជន (កសិឧស្សាហកម្មខ្នាតមធ្យម-ធំ និងទីប្រឹក្សា) និងអង្គការមិនមែនរដ្ឋាភិបាល ២) ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ទំនើប ដើម្បីផ្សព្វផ្សាយពីបច្ចេកវិទ្យាថ្មីៗដែលធន់នឹងអាកាសធាតុ ឬការកែលម្អការធ្វើកសិកម្ម ៣) ការបញ្ជាក់ពីនីតិវិធីប្រតិបត្តិមូលដ្ឋាននៃវិធីសាស្ត្រ FFS ដូចជា ដំណើរការរៀបចំ និងអនុវត្តការបង្ហាញលើក្បាលដីក្រោមការគ្រប់គ្រងរបស់កសិករ អន្តរកម្មរវាងអ្នកផ្សព្វផ្សាយ និងកសិករ ទន្ទឹមនឹងការពិចារណាពីបរិយាកាសសង្គមវប្បធម៌ និងបរិយាកាសជីវៈរូបសាស្ត្រនៅទីតាំងគម្រោងថ្មីៗ ជាពិសេសនៅតំបន់សហគមន៍ជនជាតិដើមភាគតិច និង ៤) ការបង្កើតភាពជាដៃគូជាមួយស្ថាប័នស្រាវជ្រាវកសិកម្មដើម្បីសាកល្បងបច្ចេកវិទ្យាថ្មីៗដែលធន់នឹងអាកាសធាតុ (ឧ. ដំណាំ និងពូជដំណាំដែលធន់នឹងអាកាសធាតុ) សម្រាប់យកទៅអនុវត្តជាមួយកសិករ។ ផែនការសកម្មភាពលម្អិតត្រូវបានរៀបចំឡើង ដោយរៀបរាប់ពីសកម្មភាពសំខាន់ៗដែលត្រូវធ្វើឡើងនៅមុន ក្នុងអំឡុង និងក្រោយរដូវធ្វើកសិកម្ម។ សមាសភាគទីពីរនៃយុទ្ធសាស្ត្រនេះ (ការគាំទ្រដល់ការអភិវឌ្ឍសហករណ៍កសិកម្ម) ក៏ត្រូវបានលើកឡើងផងដែរ។ ប្រសិនបើអនុវត្តដោយប្រសិទ្ធភាព សមាសភាគនេះនឹងអាចទទួលបានជំនួយផ្នែកបច្ចេកទេស និងជំនួយផ្នែកការគ្រប់គ្រងសម្រាប់សហករណ៍កសិករ។ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង ពិព៌ណនាពីសមាសធាតុសំខាន់ៗនៃយុទ្ធសាស្ត្រសេវាកសិកម្មថ្មីនេះ។

35. <u>សមាសភាគនេះនឹងផ្តោតលើការដោះស្រាយភាពងាយរងគ្រោះ ដោយសារមុខសញ្ញាគ្រោះថ្នាក់ក្នុងអាកាសធាតុ និងការស្ថិតនៅជិតដែនជម្រកធម្មជាតិ។</u> ដោយសារតែទីតាំងគម្រោងថ្មីៗមួយចំនួន នឹងរួមបញ្ចូលតំបន់ក្នុងបណ្តាខេត្តដែលមានដែនជម្រកធម្មជាតិ គម្រោងនឹងដាក់បញ្ចូលសកម្មភាពការពារដីឯកជន ដីសមូហភាព និងដីសាធារណៈក្នុងផែនការអភិវឌ្ឍន៍កសិកម្ម និងរបរចិញ្ចឹមជីវិត។ សកម្មភាពព្រៃឈើរបស់សហគមន៍នឹងទទួលបានជំនួយទន្ទឹមគ្នានឹងសកម្មភាពកសិកម្មឯកជន ប្រសិនបើអាចអនុវត្តបាន។ គម្រោងនឹងផ្តល់ការឆ្លើយតបរយៈពេលខ្លី និងរយៈពេលវែងដល់បញ្ហាប្រឈមដោយសារការប្រែប្រួលអាកាសធាតុ ដើម្បីពង្រឹងភាពធន់របស់ប្រព័ន្ធផលិត កម្ម។ គម្រោងនឹងផ្តោតសំខាន់ និងបង្រៀនពីការធ្វើកសិកម្មដែលធន់នឹងអាកាសធាតុ ដូចជា ការដាំដំណាំដែលកាន់តែធន់ កសិរុក្ខកម្ម និងការគ្រប់គ្រងដីប្រកបដោយនិរន្តរភាព ក្នុងសេវាផ្សព្វផ្សាយកសិកម្ម។ ធារាសាស្ត្រខ្នាតតូចនឹងជួយបង្កើនទាំងផលិតកម្ម និងភាពធន់នឹងអាកាសធាតុរបស់អ្នកទទួលផល ព្រមទាំងសម្រួលដល់ការផ្លាស់ទៅរកដំណាំដែលផ្តល់តម្លៃកាន់តែខ្ពស់ និងពិធកម្មកាន់តែខ្លាំង ដើម្បីត្រួសត្រាយទីផ្សារថ្មី និងផ្តល់ឱកាសរកប្រាក់ចំណូលដល់អ្នកផលិត។

36. ការអនុវត្តក្របខណ្ឌដោះស្រាយផលប៉ះពាល់នឹងគាំទ្រដល់ការកំណត់រក និងអនុវត្តគំនិតផ្តួចផ្តើមសេដ្ឋកិច្ចនៅមូលដ្ឋាន ដែលនឹងផ្តល់ប្រយោជន៍ដល់ក្រុមនានា (ជាពិសេសសហករណ៍កសិកម្ម) និងកសិករម្នាក់ៗ។ ការអនុវត្តក្របខណ្ឌដោះស្រាយផលប៉ះពាល់ ដូចជា ការគ្រប់គ្រងគំនិតផ្តួចផ្តើមក្នុងសហគមន៍ និងគំនិតផ្តួចផ្តើមឯកជនដែលបានរកឃើញ នឹងត្រូវបានសម្របសម្រួលដោយក្រុមហ៊ុនឯកទេស និង/ឬអង្គការមិនមែនរដ្ឋាភិបាល។

37. ***សមាសភាគទី ៤ ៖ ការគ្រប់គ្រង ការសម្របសម្រួល និងការពិនិត្យតាមដាន និងវាយតម្លៃគម្រោង*** *(ប្រមាណ ១០ លានដុល្លា)*។ សមាសភាគនេះពាក់ព័ន្ធនឹងសមត្ថភាពក្នុងការពិនិត្យបឋមលើការការពារសុវត្ថិភាព ការរៀបចំផែនការគ្រប់គ្រងហានិភ័យ និងការពិនិត្យតាមដានការអនុវត្ត។

38. ***សមាសភាគទី ៥ ៖ ការឆ្លើយតបនឹងគ្រោះអាសន្នយថាហេតុ*** *(០ លានដុល្លា)*។សមាសភាគនេះផ្តោតលើការបែងចែកមូលនិធិគម្រោងឡើងវិញដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន (ឧ. គ្រោះទឹកជំនន់) ដែលអាចកើតឡើងក្នុងពេលអនុវត្តគម្រោង។

## ១.៥ ការកំណត់គោលដៅ រួមទាំងការជ្រើសរើសទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច

39. ***ទីតាំងភូមិសាស្ត្រគោលដៅ ៖*** តាមគោលការណ៍ គម្រោងអាចត្រូវបានអនុវត្តនៅទូទាំងប្រទេស លើកឡើងតែទីក្រុងភ្នំពេញ អាស្រ័យលើតម្រូវការ និងឱកាសអភិវឌ្ឍន៍ក្នុងទីតាំងសម្បទានដីសង្គមកិច្ច និងទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ទោះជាយ៉ាងណា កិច្ចព្រមព្រៀងបច្ចុប្បន្ន (និងទំនងជាកិច្ចព្រមព្រៀងចុងក្រោយ) ជាមួយ អាជ្ញាធរ បានរឹតត្បិតវិសាលភាពរបស់គម្រោងឱ្យគ្របដណ្តប់លើខេត្តត្រឹមតែ ១៤[3] ដែលមានទីតាំង និងសហគមន៍ជនជាតិដើមភាគតិចប្រហែល ៧១។

40. ***អ្នកទទួលផលគោលដៅ ៖*** វិធីសាស្ត្រអនុវត្តន៍គម្រោងជំហានទី ៣ ដែលពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចគឺ "ផ្អែកតាមតម្រូវការ"។ ពោលគឺការបែងចែកទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច គឺផ្អែកតាមឃុំ ឬសហគមន៍ជនជាតិដើមភាគតិច មិនមែនកំណត់ទុកជាមុនដោយគម្រោងនោះទេ។ ចំណុចនេះធានាបានថា គម្រោងឆ្លើយតបនឹងតម្រូវការរបស់អ្នកទទួលបានដីថ្មីនិងសមត្ថភាពរបស់ឃុំ/សហគមន៍ និងសហគមន៍ជនជាតិដើមភាគតិច និងអ្នកទទួលផល ដើម្បីឱ្យពួកគេមានភាពម្ចាស់ការកាន់តែខ្លាំងលើសកម្មភាពក្នុងគម្រោងនេះ។ ដូច្នេះ គម្រោងនឹងគាំទ្រដល់ ១) សហគមន៍ជនជាតិដើមភាគតិច ១៥ ក្នុងការអនុវត្តដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ២) សហគមន៍ជនជាតិដើមភាគតិចប្រហែល ៣០ ដែលបានបញ្ចប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ តាមរយៈសកម្មភាពអភិវឌ្ឍន៍ ៣) ទីតាំងសម្បទានដីសង្គមកិច្ចថ្មី ១២ ទាំងក្នុងខេត្តគោលដៅបច្ចុប្បន្ន និងខេត្តគោលដៅថ្មីសម្រាប់សកម្មភាពបែងចែកដី និងអភិវឌ្ឍន៍ និង ៤) ទីតាំងសម្បទានដីសង្គមកិច្ច ១៤ ក្រោមគម្រោងជំហានទី ២ ដែលមានសកម្មភាពតិចតួច ដាច់ដោយឡែក និងបំពេញបន្ថែម ដូចជា ធារាសាស្ត្រខ្នាតតូច និងច្រកចេញចូលទីតាំងកសិកម្មក្នុងតំបន់សម្បទានដីសង្គមកិច្ច។ ប៉ុន្តែគេមិនរំពឹងថាអាចកំណត់អត្តសញ្ញាណ និងពិពណ៌នាលម្អិតពីទីតាំងថ្មី និងសហគមន៍ទាំង ៥៧ បានឡើយ ហើយក៏មិនអាចបញ្ចប់ការបែងចែកប្រភេទឡើងវិញ និង/ឬការបែងចែកឡើងវិញដែលចាំបាច់ទាំងអស់ មុនពេលចាប់ផ្តើមគម្រោងបានដែរ។សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងនឹងរៀបរាប់ពីការណែនាំចាំបាច់ដើម្បីធានាថា ទីតាំង និងសហគមន៍ទាំងអស់ដែលមានការជ្រើសរើសអ្នកទទួលផលពីគម្រោង នឹងអនុលោមតាមច្បាប់ភូមិបាល និងលក្ខខណ្ឌតម្រូវក្នុងក្របខណ្ឌបរិស្ថាន និងសង្គម នៅពេល

---

[3] រចនាសម្ព័ន្ធរដ្ឋបាលនៅកម្ពុជាចែកចេញជា រាជធានីភ្នំពេញ និង ២៥ ខេត្ត ហើយខេត្តចែកចេញជាក្រុង និងស្រុក។ ស្រុកចែកចេញជាឃុំដែលគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោត និងជាកម្រិតទាបបំផុតនៃរដ្ឋបាលថ្នាក់ក្រោមជាតិផ្លូវការ។ មេភូមិ និងជំនួយការ រាយការណ៍ទៅក្រុមប្រឹក្សាឃុំ។

អនុវត្តគម្រោង។ ចំនួនអ្នកទទួលផលផ្ទាល់ពីគម្រោងជំហានទី ៣ គឺប្រជាជនជនបទប្រហែល ១៥.០០០ គ្រួសារ។ ភាពអាចរកបាន និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដែលបានកែលម្អ នឹងផ្តល់អត្ថប្រយោជន៍បន្ថែមទៀតដល់ប្រជាជនកាន់តែច្រើន ក្រៅពីគ្រួសារគោលដៅក្នុងតំបន់ អនុវត្តន៍គម្រោង។

41. អ្នកទទួលផលផ្ទាល់ពីគម្រោងរួមមាន ១) គ្រួសារគោលដៅក្នុងសហគមន៍តាមតំបន់សម្បទានដីសង្គមកិច្ចថ្មីដែលស្ថិតក្នុងខេត្តដែលកំពុងអនុវត្តគម្រោងជំហានទី ២ និងខេត្តថ្មី ២) សហគមន៍ និង/ឬគ្រួសារគោលដៅក្នុងខេត្តថ្មីៗដែលមានជនជាតិដើមភាគតិច និង ៣) គ្រួសារក្នុងសហគមន៍តាមតំបន់សម្បទានដីសង្គមកិច្ចចាស់នៃគម្រោងជំហានទី ២។ គេរំពឹងថា នឹងមានការដាក់បញ្ចូលទីតាំងសម្បទានដីសង្គមកិច្ចថ្មីដែលអាចអនុវត្តបានចំនួន ១២ ក្នុងគម្រោងជំហានទី ៣ នេះ ហើយនឹងមានអ្នកទទួលផលពីសម្បទានដីសង្គមកិច្ចចំនួន ៥.០០០ គ្រួសារបន្ថែមទៀត។ សហគមន៍ក្នុងតំបន់សម្បទានដីសង្គមកិច្ចដែលស្ថិតក្រោមគម្រោងជំហានទី ២ ដែលមានលក្ខណៈសម្បត្តិទទួលបានការគាំទ្រពីគម្រោងជំហានទី ៣ រួមមាន ទីតាំងដែលមានការព្យាករណ៍ពីហេដ្ឋារចនាសម្ព័ន្ធបំពេញបន្ថែម ដូចជា ធារាសាស្ត្រខ្នាតតូច និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងតំបន់សម្បទានដីសង្គមកិច្ច ប៉ុន្តែគ្មានការសាងសង់ជាក់ស្តែង និងការផ្តល់ជំនួយ និងសេវាដល់គ្រួសារនៅសេសសល់ ជាពិសេសនៅទីតាំងឃុំដុង ដែលមិនងាយនឹងបញ្ចប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ខ្លួន ក្រោយការបិទបញ្ចប់គម្រោងជំហានទី ២។

42. លក្ខណៈសម្បត្តិទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ៖ ផ្អែកលើលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលត្រូវកំណត់ឡើងនៅពេលវាយតម្លៃ បេក្ខជនដែលដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចគឺសហគមន៍ជនជាតិដើមភាគតិច ដែលកំពុងស្ថិតក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ចាប់ពីសហគមន៍ជនជាតិដើមភាគតិចដែលត្រឹមតែមានការទទួលស្គាល់ផ្លូវច្បាប់ពីក្រសួងមហាផ្ទៃ រហូតដល់សហគមន៍ជនជាតិដើមភាគតិចដែលបានបញ្ចប់ជំហានទាំងអស់ លើកឡើងតែការចុះបញ្ជីដីធ្លីជាក់ស្តែង។ គេរំពឹងថា សហគមន៍ជនជាតិដើមភាគតិច ឬសហគមន៍ដែលអាចចូលរួមក្នុងការ ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច រហូតដល់ ៤៥ នឹងមានលក្ខណៈសម្បត្តិទទួលបានជំនួយតាមកម្រិតផ្សេងៗពីគម្រោង។

## ១.៦ ការទទួលខុសត្រូវលើការអនុវត្តគម្រោង

43. **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ជាអ្នកដឹកនាំការរៀបចំផែនការអនុវត្តន៍ និងការសម្របសម្រួលជារួម ដោយសហការយ៉ាងជិតស្និទ្ធជាមួយ**ស្ថាប័នអនុវត្តន៍។** ក្រសួងមានភារកិច្ចគ្រប់គ្រងការអនុវត្ត ៖ ១) សកម្មភាពហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវជនបទ គម្រោងធារាសាស្ត្រខ្នាតតូច និងសាលារៀន និងមូលដ្ឋានសុខភាព២) សកម្មភាពពាក់ព័ន្ធនឹងការផ្តល់ប័ណ្ណកម្មសិទ្ធិដី សមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដែលក្នុងនោះក្រសួងនឹងកៀរគរសមត្ថភាព និងធនធានពាក់ព័ន្ធទៅតាមភាពចាំបាច់ពីក្រសួង/មន្ទីរនានាដើម្បីដោះស្រាយបញ្ហាផ្នែកបច្ចេកទេស និងច្បាប់ដែលពាក់ព័ន្ធនឹងអន្តរាគមន៍ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ៣) សកម្មភាពលទ្ធកម្មសម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលលើសពីផែនការនៅកម្រិតឃុំ និងសហគមន៍ (សម្រាប់ការទទួលខុសត្រូវលើការពិនិត្យតាមដានការអនុវត្តការងាររបស់ក្រុមហ៊ុនម៉ៅការ និងផ្តល់ការបញ្ជាក់ដល់សំណើសុំការទូទាត់ ក្រសួងនឹងផ្ទេរភារកិច្ចនេះទៅភ្នាក់ងារ

ដែលមានឯកទេសលើផ្នែកនេះ) និង ៤) ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលនៅកម្រិតគម្រោងទាំងអស់។

44. បុគ្គលិកជានាសុវត្ថិភាពដែលបានចាត់តាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអ្នកជំនាញផ្នែកទំនាក់ទំនង នឹងខិតខំធ្វើយ៉ាងណាឱ្យមានការយល់ច្បាស់ និងអនុវត្តតាមនីតិវិធីអនុ វត្តន៍គម្រោង។ ក្រុមធានាសុវត្ថិភាពនឹងធានាការអនុវត្ត និងចងក្រងឯកសារយ៉ាងសមស្របនូវដំណើរការដែលមានរៀបរាប់ក្នុងក្របខណ្ឌបរិស្ថាន និងសង្គម និងក្របខណ្ឌពាក់ព័ន្ធ ផែនការ និងនីតិវិធីនានា។ ក្រុមទំនាក់ទំនងរបស់គម្រោងនឹងធានាធ្វើយ៉ាងណាឱ្យការចែករំលែកព័ត៌មានផ្ទៃក្នុង និងខាងក្រៅ និងការកសាងការយល់ដឹង ផ្សព្វផ្សាយដល់អ្នកទទួលផល និងក្រុមគ្រួសាររបស់ពួកគេ តាមរយៈមធ្យោបាយផ្សព្វផ្សាយសមស្រប។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងស្វែងរកការកសាងសមត្ថភាព និងជំនួយពីអ្នកផ្តល់សេវាខាងក្រៅ (NGO, ទីប្រឹក្សា) ទៅតាមភាពចាំបាច់។

45. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នអនុវត្តន៍ដែលមានតួនាទីអនុវត្តសកម្មភាពបរចិញ្ចឹមជីវិតដែលពាក់ព័ន្ធនឹងកសិកម្ម។ ការទទួលខុសត្រូវរបស់ក្រសួងរួមមាន ១) សម្របសម្រួល និងធានាការអនុវត្តរាល់សកម្មភាពបរចិញ្ចឹមជីវិតដែលពាក់ព័ន្ធនឹងកសិកម្ម ២) រៀបចំផែនការ និងអនុវត្តក្របខណ្ឌដោះស្រាយផលប៉ះពាល់ និង ៣) ធ្វើលទ្ធកម្មទំនិញ និងសេវាចាំបាច់សម្រាប់ការអនុវត្តសកម្មភាពពាក់ព័ន្ធ។ ក្រៅពីនេះ ក្រសួងនឹងទទួលបានធនធានហិរញ្ញវត្ថុចាំបាច់ដើម្បីចុះកិច្ចសន្យាជាមួយទីប្រឹក្សាជាតិ និងអន្តរជាតិដែលមានបទពិសោធន៍ NGOឬអ្នក ផ្តល់សេវាផ្សេងទៀត ដើម្បីផ្តល់សេវាកសិកម្ម និងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងក្របខណ្ឌដោះស្រាយផលប៉ះពាល់ឱ្យបានគ្រប់គ្រាន់។

46. ស្ថាប័នដឹកនាំការអនុវត្ត និងស្ថាប័នអនុវត្តន៍ នឹងសម្របសម្រួលការអនុវត្តសកម្មភាពនៅថ្នាក់ឃុំ និងសហគមន៍ទៅតាមភាពពាក់ព័ន្ធ ព្រមទាំងត្រួតពិនិត្យលសកម្មភាពលទ្ធកម្មទាំងអស់នៅថ្នាក់ឃុំ និងសហគមន៍ផងដែរ។ ដោយសារតែមានឃុំ និងសហគមន៍កាន់តែច្រើនចូលរួមក្នុងគម្រោងនេះ ចាំបាច់ត្រូវបង្កើនសមត្ថភាពរបស់ស្ថាប័នទាំងពីរនេះក្នុងការរៀបចំផែនការ និងគ្រប់គ្រងការអនុវត្ត ដើម្បីធានានិរន្តរភាពគម្រោង។ ដូច្នេះ ដើម្បីឱ្យគម្រោងទទួលបានជោគជ័យ ស្ថាប័នដឹកនាំការអនុវត្តត្រូវដើរតួនាទីជាអ្នកសម្របសម្រួល ចំណែកស្ថាប័នអនុវត្តន៍ត្រូវដើរតួនាទីជាអ្នកផ្តល់ សេវាកសាងសមត្ថភាពដើម្បី ពង្រឹងមុខងារគ្រប់គ្រង និងមុខងាររដ្ឋបាលរបស់ឃុំ និងសហ គមន៍។ ក្នុងករណីចាំបាច់ ស្ថាប័នទាំងពីរនេះនឹងផ្តល់ការសម្របសម្រួលដល់រដ្ឋបាលថ្នាក់ខេត្ត។ គម្រោងនឹងផ្តល់ជំនួយហិរញ្ញវត្ថុគ្រប់គ្រាន់ដល់រដ្ឋបាលថ្នាក់ខេត្ត និងឃុំ ដើម្បីឱ្យស៊ីសង្វាក់គ្នានឹងការកើនឡើងនៃចំនួនអនុគម្រោងក្នុងសហគមន៍ និងឃុំក្រោមគម្រោងជំហានទី ៣។ ទន្ទឹមនឹងនេះ រដ្ឋបាលថ្នាក់ខេត្តនឹងរៀបចំយុទ្ធសាស្ត្រចាកចេញ ដើម្បីផ្ទេរ និងដាក់បញ្ចូលសកម្មភាពគម្រោងក្នុងផែនការការងារ និងថវិការបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ នៅពេលបញ្ចប់គម្រោង។

47. ក្រុមគ្រប់គ្រងគម្រោង (PMT)/ការិយាល័យសម្របសម្រួលគម្រោង (PCO)៖ ក្រុមគ្រប់គ្រងគម្រោងនឹងទទួលខុសត្រូវលើការសម្របសម្រួលជារួមលើការអនុវត្តគម្រោង និងទំនាក់ទំនងខាងក្រៅ ដូចជា ការដាក់របាយការណ៍ទៅធនាគារពិភពលោក។ ក្រុមគ្រប់គ្រងគម្រោង (PMT)/ការិយាល័យសម្របសម្រួលគម្រោង (PCO) ស្ថិតក្រោមការដឹកនាំរបស់ប្រធានគម្រោងមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ត្រីជាន់ខ្ពស់មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលចូលរួមជាសមាជិកក្រុម។ ក្រុមគ្រប់គ្រង

គម្រោង (PMT)/ការិយាល័យសម្របសម្រួលគម្រោង (PCO) នឹងមានសមាជិកមកពីអង្គភាពបច្ចេកទេសពាក់ព័ន្ធសំខាន់ៗក្នុងការអនុវត្តគម្រោង ដូចជា មន្ត្រីជាន់ខ្ពស់ទទួលបន្ទុក Financial Management (FM) លទ្ធកម្ម ការពិនិត្យតាមដាន និងវាយតម្លៃ និងទំនាក់ទំនង។ ក្នុងករណីចាំបាច់ ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យានឹងចូលរួមជាមួយក្រុមគ្រប់គ្រងគម្រោង។ ក្រុមគ្រប់គ្រងគម្រោង (PMT)/ការិយាល័យសម្របសម្រួលគម្រោង (PCO) មានទីស្នាក់ការក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ដោយសារតែគម្រោងនេះត្រូវបានអនុវត្តតាមរយៈរចនាសម្ព័ន្ធរដ្ឋាភិបាលមានស្រាប់ (ក្រសួងរៀបចំដែនដី និងក្រសួងកសិកម្ម) រួមទាំងមន្ទីរពាក់ព័ន្ធរបស់ស្ថាប័នដឹកនាំការអនុវត្ត និងស្ថាប័នអនុវត្តន៍ ការជ្រើសរើសបុគ្គលិកសម្រាប់ក្រុមគ្រប់គ្រងគម្រោង (PMT)/ការិយាល័យសម្របសម្រួលគម្រោង (PCO) គឺមានចំនួនតិច ប៉ុន្តែពោរពេញដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ គេរំពឹងថា ប្រធានគម្រោង ដែលជាប្រធានក្រុមគ្រប់គ្រងគម្រោង នឹងជានាទំនាក់ទំនងប្រកបដោយតម្លាភាព និងការធ្វើសេចក្តីសម្រេចតាមបែបជំរុញការចូលរួម។

48. ក្រុមគម្រោង ៖ ក្រុមគម្រោងនឹងត្រូវបានបង្កើតឡើងដើម្បីជួយដល់ការរៀបចំផែនការ និងការអនុវត្តសមាសភាគគម្រោង។ ក្រុមគម្រោងនៅក្រសួងរៀបចំដែនដី និងក្រសួងកសិកម្ម មានសមាសភាគបុគ្គលិកបច្ចេកទេសដែលមានតួនាទីដោះស្រាយបញ្ហាជាក់ស្តែង និងបញ្ហាឯកទេសក្នុងពេលរៀបចំផែនការ និងអនុវត្ត។ ពួកគេជាមន្ត្រីមកពីអង្គភាពរដ្ឋាភិបាលមួយចំនួននៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ ក្នុងការអនុវត្តជាក់ស្តែង គម្រោងនឹងទទួលបានការគាំទ្រ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមគម្រោងមកពីក្រសួងផ្សេងៗ អាស្រ័យទៅតាមប្រភេទហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈដែលស្ថិតក្នុងវិសាលភាពគម្រោង។ សមាជិកក្នុងក្រុមគម្រោងរួមមាន បុគ្គលិកបច្ចេកទេស បុគ្គលិក FM បុគ្គលិកលទ្ធកម្ម និងសវនករផ្ទៃក្នុង។ ពួកគេនឹងចូលរួមក្នុងការរៀបចំផែនការ និងការអនុវត្ត និងការកសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិ។ ពួកគេនឹងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការចុះតាមមូលដ្ឋាន និងសមិទ្ធផល ដាក់ជូនក្រុមគ្រប់គ្រងគម្រោង (PMT)/ការិយាល័យសម្របសម្រួលគម្រោង (PCO)។




*រូប 1 ៖ ការរៀបចំការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំហានទី ៣ (LASED III)*

49. ***ក្រសួងគាំទ្រ/សហប្រតិបត្តិការ ៖*** របចនាសម្ព័ន្ធអនុវត្តន៍ផ្លូវការគឺក្រសួងពីរដែលដើរតួនាទីជាស្ថាប័នដឹកនាំការអនុវត្ត (ក្រសួងរៀបចំដែនដី) និងស្ថាប័នអនុវត្តន៍ (ក្រសួងកសិកម្ម)។ ក្រៅពីនេះ គម្រោងនៅតែពឹងផ្អែកលើជំនាញបច្ចេកទេស និងការណែនាំពីក្រសួងពាក់ព័ន្ធផ្សេងទៀតដែលចូលរួមសហការ និងផ្តល់ការគាំទ្រដូចជា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ស្ថាប័នដឹកនាំការអនុវត្តត្រូវធានាថា បទប្បញ្ញត្តិស្តីពីហេដ្ឋារចនាសម្ព័ន្ធដែលទទួលបានហិរញ្ញប្បទានពីគម្រោង អនុលោមតាមបទដ្ឋានជាតិ និងរួមបញ្ចូលការរៀបចំផែនការរបស់ក្រសួង និងនាយកដ្ឋានពាក់ព័ន្ធ។ ក្រសួងផ្សេងទៀតដែលមានសមាសភាគក្នុង NSLCC នឹងផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពនៅតាមសហគមន៍ក្នុងតំបន់គម្រោង ដើម្បីធានាការអនុវត្តដោយរលូន។

50. **មន្ទីរបច្ចេកទេសខេត្ត ៖** ការទទួលខុសត្រូវលើការអនុវត្តនៅមូលដ្ឋាន ជាបន្ទុករបស់មន្ទីរបច្ចេកទេសពាក់ព័ន្ធនៅថ្នាក់ខេត្ត។ ក្រុមថ្នាក់ខេត្តនឹងត្រូវបានបង្កើតឡើងដើម្បីទទួលខុសត្រូវលើការអនុវត្តគម្រោង។ ក្នុងករណីចាំបាច់ ពួកគេនឹងទទួលបានជំនួយពីមន្ត្រីក្រសួងសាមីដែលមានគុណវុឌ្ឍិ អ្នកផ្តល់សេវាផ្សេងទៀតក្នុង

គម្រោង និង NGO។ សកម្មភាពចាំបាច់សម្រាប់មន្ទីរពាក់ព័ន្ធ និងឃុំ/សហគមន៍ទាំងអស់ នឹងត្រូវបានដាក់បញ្ចូលក្នុងផែនការការងាររបស់ក្រសួងរៀបចំដែនដី និងក្រសួងកសិកម្ម។

51. **អ្នកផ្តល់សេវាខាងក្រៅ** (NGO ទីប្រឹក្សា ក្រុមហ៊ុន និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត) ៖ គម្រោងមើលឃើញភាពចាំបាច់ក្នុងការបំពេញបន្ថែម និងពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជាតាម រយៈការផ្តល់ការគាំទ្រលើសកម្មភាពបច្ចេកទេស និងគ្រប់គ្រង។ សកម្មភាពទាំងនេះទាមទារជំនាញឯកទេសពាក់ព័ន្ធនឹងក្រុមគោលដៅ និង/ឬទីតាំងជាក់លាក់។ ដូច្នេះ ចាំបាច់ត្រូវជួល NGOs និង/ឬ ទីប្រឹក្សា/ក្រុមហ៊ុនដើម្បីបំពេញសមត្ថភាពដែលខ្វះខាត និងធានាការអនុវត្តដែលកាន់តែមានគុណភាព ដើម្បីឱ្យគម្រោងទទួលបានជោគជ័យ។

## ១.៧ វិធីសាស្ត្រ និងគោលបំណងនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

52. នេះជាឯកសារក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) សម្រាប់សំណើ**គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ (LASED III)**។ ឯកសារនេះរៀបរាប់ពីនីតិវិធី ការទទួលខុសត្រូវផ្នែកស្ថាប័ន និងធនធានដែលមាន ដើម្បីវាយតម្លៃសកម្មភាពគម្រោងនាពេលអនាគតដែលមិនទាន់បានកំណត់រក ក្នុងគោលបំណងធានាសង្គតភាពជាមួយនឹងក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក (ESF) រួមទាំងបទដ្ឋានបរិស្ថាន និងសង្គម (ESS) ពាក់ព័ន្ធ ដើម្បីទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក។ ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម បំពេញតាមលក្ខខណ្ឌនីតិវិធីប្រតិបត្តិស្តង់ដារ សម្រាប់គម្រោងទទួលបានជំនួយពីខាងក្រៅរបស់រាជរដ្ឋាភិបាលកម្ពុជាដែលតម្រូវឱ្យមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គម។

53. ដំណើរការក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមត្រូវអនុវត្តនៅតាមទីតាំងទាំងអស់ដែលបានកំណត់ឃើញក្នុងពេលអនុវត្តគម្រោង។ ដំណើរការទាំងនេះមានគោលបំណង ៖

- ក. ធានា (តាមរយៈដំណើរការដែលមានរៀបរាប់លម្អិតក្នុងផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ) ការចូលរួម និងការពិគ្រោះយោបល់ជាមួយសហគមន៍អ្នកទទួលផលគោលដៅ ដើម្បីធ្វើយ៉ាងណាឱ្យសកម្មភាពគម្រោងដែលស្នើឡើង បំពេញតម្រូវការរបស់ពួកគេ (រួមទាំងតម្រូវការរបស់ក្រុមផ្សេងៗក្នុងសហគមន៍ ដូចជា តម្រូវការបែងចែកតាមភេទ)
- ខ. ទប់ស្កាត់ និង/ឬកាត់បន្ថយហេតុផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតចេញពីសកម្មភាពដែលស្នើឡើង
- គ. ធានាផ្តល់អត្ថប្រយោជន៍យូរអង្វែងដល់បរិស្ថានពីសកម្មភាពដោយស្នើឡើង ដោយធានាសន្តិសុខមូលដ្ឋានធនធានធម្មជាតិ
- ឃ. សម្របសម្រួលតាមបែបប្រតិសកម្មលើសកម្មភាពដែលគេរំពឹងថា អាចបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិកាន់តែប្រសើរ ដើម្បីរក្សា ស្ថិរភាព និង/ឬធ្វើឱ្យប្រសើរឡើងនូវគុណភាពបរិស្ថានមូលដ្ឋាន និងសុខុមាលភាព មនុស្ស។

54. ក្របខណ្ឌបរិស្ថាន និងសង្គម កំណត់និយមន័យក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមជា "ឧបករណ៍ដែលត្រួតពិនិត្យហានិភ័យ និងផលប៉ះពាល់នៅពេលគម្រោងមួយមានកម្មវិធីមួយ និង/ឬអនុគម្រោងនានា ហើយគេមិនអាចកំណត់ហានិភ័យ និងផលប៉ះពាល់បាន រហូតទាល់តែបានកំណត់រកយ៉ាងច្បាស់នូវកម្មវិធី និង/

ឬអនុគម្រោងទាំងនោះ”។ ទីតាំងក្នុងគម្រោងជំហានទី ៣ នឹងត្រូវបានកំណត់នៅអំឡុងឆ្នាំដំបូងនៃការអនុវត្តគម្រោង ហើយហេដ្ឋារចនាសម្ព័ន្ធ និងអនុគម្រោងផ្សេងទៀតនឹងត្រូវបានកំណត់រក និងគ្រោងឡើងដោយផ្អែកលើការវាយតម្លៃតម្រូវការនៅតាមទីតាំងដែលបានកំណត់។ ដូច្នេះ គេមិនអាចធ្វើការវាយតម្លៃបានពេញលេញពីហានិភ័យបរិស្ថាន និងសង្គមដែលអាចកើតមានឡើងនៅដំណាក់កាលរៀបចំគម្រោងបានឡើយ។ សម្រាប់គម្រោងប្រភេទនេះ ក្របខណ្ឌបរិស្ថាន និងសង្គមកំណត់ថា ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមគួរកំណត់ច្បាស់ពី “គោលការណ៍ វិធាន គោលការណ៍ណែនាំ និងនីតិវិធីសម្រាប់វាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គម។ ក្របខណ្ឌនេះមានវិធានការ និងផែនការកាត់បន្ថយ សម្រាល និង/ឬប៉ះប៉ូវហានិភ័យ និងផលប៉ះពាល់អវិជ្ជមាន បទប្បញ្ញត្តិសម្រាប់ការប៉ាន់ស្មាន និងរៀបចំថវិកាសម្រាប់ចំណាយលើវិធានការទាំងនេះ និងព័ត៌មានស្តីពីទីភ្នាក់ងារមួយ ឬច្រើនដែលទទួលខុសត្រូវលើការដោះស្រាយហានិភ័យ និងផលប៉ះពាល់របស់គម្រោង រួមទាំងព័ត៌មានស្តីពីសមត្ថភាពរបស់ទីភ្នាក់ងារក្នុងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម។ ក្របខណ្ឌនេះមានព័ត៌មានគ្រប់គ្រាន់ស្តីពីតំបន់ដែលនឹងក្លាយជាទីតាំងរបស់អនុគម្រោង រួមទាំងភាពងាយរងគ្រោះផ្នែកបរិស្ថាន និងសង្គមដែលអាចកើតមានឡើងក្នុងតំបន់នោះ និងព័ត៌មានស្តីពីផលប៉ះពាល់ដែលអាចកើតមានឡើង និងវិធានការកាត់បន្ថយ”។

55. ដូច្នេះ ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមនឹងធ្វើការវិភាគពីហានិភ័យ និងផលប៉ះពាល់ដែលបានប៉ាន់ប្រមាណ ដោយផ្អែកលើវិសាលភាពនៃសកម្មភាពគម្រោងដែលបានព្យាករណ៍ លក្ខខណ្ឌរំពឹងទុកនៅទីតាំងគម្រោង និងបទពិសោធន៍ពីការអនុវត្តគម្រោងជំហានដំបូង និងជំហានទី ២ បូករួមនឹងគោលការណ៍ វិធាន គោលការណ៍ណែនាំ និងនីតិវិធីសម្រាប់វាយតម្លៃហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមជាក់លាក់ និងបង្កើតវិធានការគ្រប់គ្រងហានិភ័យនៅតាមទីតាំងនីមួយៗ។ គេប៉ាន់ស្មានថា ហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងជំហានទី ៣ សម្រាប់សម្បទានដីសង្គមកិច្ច នឹងមានទំហំប្រហាក់ប្រហែលគ្នានឹងហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងជំហានទី ២ ប៉ុន្តែហានិភ័យថ្មីៗ ជាពិសេសហានិភ័យពាក់ព័ន្ធនឹងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬទីតាំងសម្បទានដីសង្គមកិច្ចថ្មី ត្រូវបានពិចារណាយ៉ាងហ្មត់ចត់។ វិសាលភាពនៃការវាយតម្លៃហានិភ័យរួមបញ្ចូលលក្ខខណ្ឌតម្រូវថ្មីៗ និងការផ្តោតលើក្របខណ្ឌបរិស្ថាន និងសង្គម ដែលមិនមែនជាផ្នែកមួយនៃក្របខណ្ឌការពារសុវត្ថិភាពសម្រាប់គម្រោងជំហានទី ២។

56. ចំណុចសេសសល់ក្នុងផ្នែកទី ១ នៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ពិពណ៌នាពីក្របខណ្ឌច្បាប់ និងគតិយុត្តិជាតិ និងការវិភាគចំណុចខ្វះខាតក្នុងក្របខណ្ឌនេះ ធៀបនឹងលក្ខខណ្ឌតម្រូវក្នុងក្របខណ្ឌបរិស្ថាន និងសង្គម។ បន្ទាប់មកគឺ ការវិភាគការរៀបចំផ្នែកស្ថាប័ន និងសមត្ថភាពរបស់ស្ថាប័នអនុវត្តន៍គម្រោងក្នុងការគ្រប់គ្រងហានិភ័យបិរស្ថាន និងសង្គម។ ផ្នែកទី ២ រៀបរាប់ដោយសង្ខេបពីមេរៀនពាក់ព័ន្ធពីការអនុវត្តគម្រោងជំហានដំបូង និងជំហានទី ២។

57. ផ្នែកទី ៣ បង្ហាញខ្លឹមសារសង្ខេបស្តីពីសាវតារបរិស្ថាន និងសង្គមរបស់តំបន់គោលដៅ ដោយគូសបញ្ជាក់ពីលក្ខណៈសំខាន់ៗដែលបង្កជាហានិភ័យបរិស្ថាន និងសង្គម ដោយផ្អែកលើទិន្នន័យដែលមានស្តីពីខេត្តដែលអាចក្លាយជាខេត្តគោលដៅ ការចុះទៅទីតាំងសម្បទានដីសង្គមកិច្ចមានស្រាប់ និងទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងការពិភាក្សាជាមួយអ្នកទទួលបានដីធ្លីនៅតាមទីតាំងទាំងនោះ ការពិភាក្សាជាមួយស្ថាប័នដែលកំពុងអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការ

អភិវឌ្ឍសេដ្ឋកិច្ច និងអ្នកពាក់ព័ន្ធផ្សេងទៀត និងផ្អែកលើបទពិសោធន៍ និងមេរៀនជាច្រើនពីការអនុវត្តគម្រោងដំណាក់កាលដំបូង/គម្រោងដំណាក់កាលទី២។ សាវតារបរិស្ថាន និងសង្គមគ្រប់ជ្រុងជ្រោយ (ESP) ត្រូវបានរៀបចំជាឯកសារដាច់ដោយឡែក។ ផ្នែកទី ៤ ផ្តោតលើសាវតារបរិស្ថាន និងសង្គម ដើម្បីធ្វើការវិភាគពីហានិភ័យបរិស្ថាន និងសង្គមដែលអាចកើតឡើង និងអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរ និងលទ្ធភាពនៃការកើតឡើង ព្រមទាំងវិធានការកាត់បន្ថយហានិភ័យពាក់ព័ន្ធធៀបនឹងបទដ្ឋានបរិស្ថាន និងសង្គមនីមួយៗ។

58. ផ្នែកទី ៥ រៀបរាប់ពីក្របខណ្ឌគ្រប់គ្រងហានិភ័យ ដូចជា ៖

ក. ការពិពណ៌នា និងខ្លឹមសារសង្ខេបស្តីពីឧបករណ៍គ្រប់គ្រងហានិភ័យ ដែលមានបង្ហាញក្នុងឧបសម្ព័ន្ធនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមនេះ

ខ. ការបញ្ចៀសហានិភ័យ វិធានការកាត់បន្ថយ និងគ្រប់គ្រង សម្រាប់ជាមូលដ្ឋាននៃការរៀបចំផែនការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP) ក្នុងគម្រោង

គ. នីតិវិធីគម្រោងសម្រាប់ការពិនិត្យបឋមរកទីតាំងសម្បទានដីសង្គមកិច្ច និងទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចជាក់ស្តែង និងទីតាំងដែលអាចបម្រើឱ្យគោលបំណងទាំងនេះ ដើម្បីកំណត់រកហានិភ័យ បរិស្ថាន និងសង្គម និងរៀបចំផែនការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំង

ឃ. នីតិវិធីគម្រោងសម្រាប់ការពិនិត្យបឋមរកហេដ្ឋារចនាសម្ព័ន្ធ និងអនុគម្រោងផ្សេងទៀតដើម្បីកំណត់រកហានិភ័យបរិស្ថាន និងសង្គម ការរៀបចំផែនការគ្រប់គ្រងហានិភ័យ និងការអនុវត្តផែនការគ្រប់គ្រង ហានិភ័យក្នុងដំណើរការអនុវត្តអនុគម្រោង

ង. ការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម។

59. ផ្នែកទី ៦ ពណ៌នាពីការរៀបចំការពិគ្រោះយោបល់ក្នុងចំណោមអ្នកពាក់ព័ន្ធ (រួមទាំងការរៀបចំផែនការដែលជំរុញការចូលរួម) និងការផ្សព្វផ្សាយព័ត៌មាន។ ផ្នែកទី ៧ រៀបរាប់ពីការរៀបចំសម្រាប់ការអនុវត្តក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ដូចជា តួនាទី និងការទទួលខុសត្រូវ ផែនការកសាងសមត្ថភាព និងថវិកា។ ផ្នែកទី ៨ លើកឡើងពីយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោង (GRM) ចំណែកផ្នែកទី ៩ រៀបរាប់ពីការរៀបចំសម្រាប់ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ និងការពិគ្រោះយោបល់ស្តីពីក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម និងឧបករណ៍ពាក់ព័ន្ធនឹងបរិស្ថាន និងសង្គម។

## ១.៨ ក្របខណ្ឌគតិយុត្តិ និងក្របខណ្ឌស្ថាប័ន

### ១.៨.១ លក្ខខណ្ឌតម្រូវក្នុងក្របខណ្ឌគតិយុត្តិ និងច្បាប់ជាតិ

60. ផ្នែកនេះបង្ហាញដោយសង្ខេបពីច្បាប់ និងបទប្បញ្ញត្តិជាតិដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម លើផ្នែកមួយចំនួន ដូចជា ១) ការកាន់កាប់ និងគ្រប់គ្រងដីធ្លី ២) សិទ្ធិរបស់ជនជាតិដើមភាគតិច ៣) កិច្ចការពារបរិស្ថាន ៤) ការការពារបេតិកភណ្ឌវប្បធម៌ ៥) ច្បាប់ស្តីពីការងារ និងការការពារសិទ្ធិរបស់នយោជិត រួមទាំងសុខភាព និងសុវត្ថិភាពក្នុងការងារ និង ៦) ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

61. **ការកាន់កាប់ និងគ្រប់គ្រងដីធ្លី ៖** ក្របខណ្ឌរួមសម្រាប់ការកាន់កាប់ដីធ្លីនៅកម្ពុជាមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១។ ប្រកាសសំខាន់ៗ និងឯកសារអនុនីតិកម្មក្នុងច្បាប់ភូមិបាលរួមមាន ៖

ក. មាត្រា ១៨ និង ១៩ នៃច្បាប់ភូមិបាល ផ្តោតលើការផ្ទេរកម្មសិទ្ធិដីធ្លីដោយខុសច្បាប់ ចំណែកមាត្រា ២៩-៤៧ នៃច្បាប់ភូមិបាល ផ្តោតលើលទ្ធកម្មកម្មសិទ្ធិ។

ខ. សារាចរណែនាំលេខ ០២ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់

គ. អនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច

ឃ. ច្បាប់ស្តីពីអស្សាមិករណ៍ (២០១០) ដែលមានគោលបំណង "បញ្ជាក់ពីនិយមន័យនៃពាក្យអស្សាមិករណ៍ឱ្យបានច្បាស់លាស់ តាមរយៈការកំណត់គោលការណ៍ យន្តការ នីតិវិធីនៃការដកហូតទ្រព្យសម្បត្តិ និងសំណងសមរម្យជាថ្នូរនៃការសាងសង់សំណង់សាធារណៈ និងសំណង់ណាដែលទាក់ទងនឹងផលប្រយោជន៍ជាតិទាំងមូល"

ង. នីតិវិធីប្រតិបត្តិស្តង់ដារ សម្រាប់គម្រោងទទួលបានហិរញ្ញប្បទានពីខាងក្រៅនៅកម្ពុជា (២០១៨)។ អាចទាញយកតាមគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖ https://www.mef.gov.kh/documents/DInvestment/Document23072007/Manual%20on%20Standard%20Operating%20Procedures.pdf

ច. សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ/សង្កាត់ (សូមមើលខាងក្រោម)។

62. **សិទ្ធិរបស់ជនជាតិដើមភាគតិច ៖** ក្របខណ្ឌច្បាប់ និងគតិយុត្តិសម្រាប់សិទ្ធិជនជាតិដើមភាគតិច រួមមាន ៖

ក. ច្បាប់ភូមិបាល (២០០១) មាត្រា ២៣-២៨ ដែលចែងយ៉ាងច្បាស់ពីសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច

ខ. ច្បាប់ស្តីពីព្រៃឈើ (២០០២) ចែងពីសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ដែលត្រូវបានទទួលស្គាល់ដោយច្បាប់ភូមិបាលក្នុងការប្រើប្រាស់ធនធានព្រៃឈើ

គ. ក្រសួងអភិវឌ្ឍន៍ជនបទ, គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ២០០៩

ឃ. អនុក្រឹត្យលេខ ៨៣ (ឆ្នាំ ២០០៩) ស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច

ង. ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ សារាចរណែនាំអន្តរក្រសួងស្តីពីវិធានការការពារបណ្តោះអាសន្នដើម្បីការពារដីធ្លីរបស់ជនជាតិដើមភាគតិច (២០១១)

ច. រាជរដ្ឋាភិបាលកម្ពុជា "សេចក្តីសម្រេចលេខ ០១" ក្នុងការអនុវត្តយុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដែលត្រូវអនុវត្តដោយយុវជនស្ម័គ្រចិត្ត ក្រោមជំនួយពីអាជ្ញាធរពាក់ព័ន្ធ

ឆ. សេចក្តីណែនាំលេខ ១៥ ចុះថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០១២ និងសេចក្តីណែនាំលេខ ១៧ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២ ដើម្បីពង្រឹងការអនុវត្តការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ជនជាតិដើមភាគតិច និងសហគមន៍

ជ. សៀវភៅណែនាំស្តីពីការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ការចុះបញ្ជីនីតិបុគ្គល និងដំណើរការចុះបញ្ជីដីសហគមន៍នៅកម្ពុជា (ខែ ធ្នូ ឆ្នាំ ២០១៨) ដែលបោះពុម្ពផ្សាយដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមជំនួយរបស់ UN-OHCHR។

63. **កិច្ចការពារបរិស្ថាន៖** ការគ្រប់គ្រងទូទៅលើផ្នែកបរិស្ថានស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន (MoE) ដែលបង្កើតឡើងនៅឆ្នាំ ១៩៩៣។ ក្រសួងបរិស្ថានទទួលខុសត្រូវលើការអនុវត្តច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ នៅថ្នាក់ខេត្ត និងក្រុង មានមន្ទីរបរិស្ថានខេត្ត/ក្រុង។ មន្ទីរទាំងនេះទទួលខុសត្រូវលើការអនុវត្តច្បាប់បរិស្ថាន ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

64. **ច្បាប់ស្តីពីកិច្ចការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ** ត្រូវបានអនុម័តដោយរដ្ឋសភា ហើយត្រូវបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រម/រស-រកម-១២៩៦/៣៦។ ច្បាប់នេះត្រូវបានអនុម័តនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦។ ច្បាប់នេះមានគោលបំណងដូចខាងក្រោម៖

ក. ដើម្បីការពារ និងលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពសាធារណៈ តាមរយៈការបង្ការទប់ស្កាត់ កាត់បន្ថយ និងគ្រប់គ្រងការបំពុល

ខ. ដើម្បីវាយតម្លៃពីផលប៉ះពាល់បរិស្ថាននៃគម្រោងដែលបានស្នើឡើងទាំងអស់ មុនពេលចេញសេចក្តីសម្រេចយល់ព្រមពីរាជរដ្ឋាភិបាល

គ. ធានាការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង រប្រើប្រាស់ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយតុល្យភាព និងនិរន្តរភាព

ឃ. លើកទឹកចិត្ត និងផ្តល់នូវលទ្ធភាពដល់សាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង

ង. បង្ក្រាបរាល់អំពើទាំងឡាយណាដែលបង្កមហន្តរាយដល់បរិស្ថាន។

65. ក្របខណ្ឌច្បាប់នេះអំពាវនាវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម (IEIA) ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) អាស្រ័យលើប្រភេទនៃសកម្មភាព និងទីតាំងនៃគម្រោង (អនុក្រឹត្យស្តីពីដំណើរការ IEIA/EIA (មាត្រា ១ និងមាត្រា ២ នៃអនុក្រឹត្យ IEIA/EIA) ដែលត្រូវប្រតិបត្តិ ទោះជាគម្រោងឯកជន ឬសាធារណៈទាំងអស់។ ក្រសួងបរិស្ថានត្រូវត្រួតពិនិត្យមុននឹងបញ្ជូនទៅរាជ រដ្ឋាភិបាលដើម្បីធ្វើការសម្រេចចិត្តចុងក្រោយ។

66. **អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ចុះខែ សីហា ឆ្នាំ ១៩៩៩** និងគោលការណ៍ណែនាំ (២០០៥, ២០០៩ និង ២០១៧) ផ្តល់សេចក្តីណែនាំសម្រាប់ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានបឋម ឬការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានពេញលេញ ដោយអនុលោមតាមច្បាប់នេះ។ អនុក្រឹត្យនេះមានគោលបំណង ៖

ក. ដើម្បីកំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) លើរាល់គម្រោង ឬសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរាជរដ្ឋាភិបាលសម្រេច។

ខ. កំណត់ប្រភេទ និងទំហំគម្រោង និងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈ ដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

គ. បំផុសឱ្យមានការចូលរួមរបស់សាធារណៈជនក្នុងដំណើរការតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ព្រមទាំងទទួលយកមតិយោបល់មកពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។

67. **អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ៖** គោលបំណងនៃអនុក្រឹត្យនេះ គឺដើម្បីគ្រប់គ្រងការចោលសំណល់រឹងតាមលក្ខណៈបច្ចេកទេសសមស្រប និងដោយសុវត្ថិភាពដើម្បីធានាការពារសុខភាពមនុស្ស និងការអភិរក្សជីវចម្រុះ។ អនុក្រឹត្យនេះអនុវត្តចំពោះរាល់សកម្មភាពទាំងឡាយពាក់ព័ន្ធនឹងការចោល រក្សាទុក ប្រមូល ដឹកជញ្ជូន ប្រើប្រាស់ឡើងវិញ ចាក់សំរាម និងសំណល់ដែលបង្កឱ្យមានគ្រោះថ្នាក់។

68. **អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង** ចុះថ្ងៃទី ១០ខែ កក្កដា ឆ្នាំ ២០០០។អនុក្រឹត្យនេះមានគោលបំណងការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈពីការបំពុលខ្យល់ និងការរំខានដោយសំឡេងតាមរយៈការត្រួតពិនិត្យ និងទប់ស្កាត់សកម្មភាពកាត់បន្ថយ។ អនុក្រឹត្យនេះមានវិសាលភាពអនុវត្តន៍ និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយដែលបង្កឱ្យមានការបំពុលខ្យល់ និងការរំខានដោយសំឡេងក្នុងបរិយាកាស។

69. **កិច្ចការពារបេតិកភណ្ឌបរិស្ថាន ៖** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា "រដ្ឋមានកាតព្វកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ។ រដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារប្រាសាទ បុរាណវត្ថុ សិល្បៈបុរាណ និងកែលម្អរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ (មាត្រា ៦៩)"។ "បទល្មើសទាំងឡាយដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌសិល្បៈត្រូវផ្តន្ទាទោសជាទម្ងន់ (មាត្រា ៧០)"។ "បរិវេណបេតិកភណ្ឌជាតិក៏ដូចជាបេតិកភណ្ឌដែលបានបញ្ចូលជាបេតិកភណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត ដែលមិនឱ្យមានសកម្មភាពយោធា (មាត្រា ៧១)"។ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ (១៩៩៦) មានបទប្បញ្ញត្តិសម្រាប់ "ការថែរក្សាការពារបេតិកភណ្ឌវប្បធម៌ និងជាតិ និងសម្បត្តិវប្បធម៌ទូទៅ ប្រឆាំងនឹងការបំផ្លិចបំផ្លាញការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់។ ច្បាប់នេះមានបទប្បញ្ញត្តិសម្រាប់ការការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ដែលរកឃើញពីសកម្មភាពសាងសង់។ ការទទួលខុសត្រូវរួមជាបន្ទុករបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយសហការជាមួយមន្ទីរ និងការិយាល័យស្រុក (មួយចំនួន)។ ប៉ុន្តែក្នុងតំបន់ឧទ្យានអង្គរវត្ត និងតំបន់ជុំវិញខេត្តសៀមរាបដែលមានសំណល់វត្ថុបុរាណពីសម័យអង្គរ ស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់អាជ្ញាធរអប្សរា។ មាត្រា ១៥ នៃច្បាប់ភូមិបាល ២០០១ ចែងថា បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រជាសម្បត្តិសាធារណៈរបស់រដ្ឋ។ លិខិតុបករណ៍ច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធនឹងកិច្ចការពារបេតិកភណ្ឌវប្បធម៌រួមមាន ៖

ក. ច្បាប់ស្តីពីការរៀបចំដែនដី នគរូនីយកម្ម និងសំណង់ (១៩៩៤)

ខ. ប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូនីយកម្ម និងសំណង់ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូនីយកម្ម និងសំណង់ (១៩៩៩) រួមបញ្ចូលភារកិច្ចក្នុងការការការពារបេតិកភណ្ឌវប្បធម៌

គ. ប្រកាសរបស់គណៈរដ្ឋមន្ត្រី (១៩៩៩) ដែលហាមឃាត់កម្មសិទ្ធិឯកជនលើទីតាំងបេតិកភណ្ឌវប្បធម៌

ឃ. ច្បាប់ស្តីពីព្រៃឈើ (២០០២) ទទួលស្គាល់ និងការពារតំបន់ព្រៃឈើដែលមានសារៈសំខាន់ផ្នែកវប្បធម៌ចំពោះសហគមន៍ជនជាតិដើមភាគតិច

ង. អនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ (២០០៥) បានកំណត់ "បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ ជាសម្បត្តិសាធារណៈរបស់រដ្ឋដែលមិនអាចដកហូតបាន។ អនុក្រឹត្យនេះត្រូវបានពង្រឹងដោយសេចក្តីសម្រេចលេខ ៥២ ស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកប្រភេទដីរដ្ឋ (២០០៦)។

70. បទប្បញ្ញត្តិសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌ក្នុងតំបន់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច មានចែងក្នុងក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (ខែធ្នូ ឆ្នាំ២០០៧) ដែលរួមបញ្ចូលវិធានការដាក់លាក់សម្រាប់ការការពារបេតិកភណ្ឌបុរាណវិទ្យា និងបេតិកភណ្ឌវប្បធម៌របស់ជនជាតិដើមភាគតិច ប៉ុន្តែតម្រូវឱ្យមានការពិនិត្យឡើងវិញ និងអនុលោមពេញលេញតាមក្របខណ្ឌបរិស្ថាន និងសង្គម។

71. **ច្បាប់ស្តីពីការងារ និងមុខរបរ ៖** ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិស្តីពីការងារ និងមុខរបរនៅកម្ពុជា៖

ក. ច្បាប់ស្តីពីការងារ (១៩៩៧)៖ ច្បាប់នេះបទប្បញ្ញត្តិស្តីពីការមិនរើសអើង ការហាមឃាត់ការងារដោយបង្ខំ រួមទាំងទាសភាពបំណុល ការកំណត់លក្ខខណ្ឌការងារ ការរឹតត្បិតលើការងាររបស់អនីតិជន (ក្រោម ១៨ ឆ្នាំ) ច្បាប់ឈប់សម្រាកលំហែរមាតុភាព បទប្បញ្ញត្តិពិសេសសម្រាប់ការងាររបស់កម្មករកសិកម្ម សុខភាព និងសុវត្ថិភាព សិទ្ធិសហជីព។ល។

ខ. អនុសញ្ញាលេខ ១៣៨ របស់អង្គការអន្តរជាតិខាងការងារស្តីពីអាយុអប្បរមា និងអនុសញ្ញាលេខ ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានផ្តល់សច្ចាប័ន ដោយរាជរដ្ឋាភិបាលកម្ពុជា។

គ. ប្រកាសលេខ ១០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់ (ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៤)

72. **នីតិវិធីបណ្តឹងតវ៉ា ៖ អនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋ (២០១៧)** បានបង្កើតយន្តការសម្រាប់ទទួល និងដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយជំនួសឱ្យប្រព័ន្ធពីមុន (ក្រុមការងារគណនេយ្យភាព) ដែលត្រូវបានបង្កើតឡើងក្នុងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ **គោលការណ៍ណែនាំសម្រាប់នីតិវិធីប្រតិបត្តិស្តង់ដា ស្តីពីលទ្ធកម្មដីធ្លី និងការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត (២០១៨)** កំណត់ថាយន្តការបណ្តឹងតវ៉ាត្រូវត្រួតពិនិត្យដោយគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត ដែលឃ្លាំមើលដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

73. **ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត៖** ក្រុមប្រឹក្សាឃុំផ្អែកតាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ/សង្កាត់ ជាក្របខណ្ឌសម្រាប់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច រួមទាំងគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ សៀវភៅណែនាំនេះមានគោលការណ៍ណែនាំសម្រាប់ការរៀបចំផែនការលទ្ធកម្មដីធ្លី ការគ្រប់គ្រងហានិភ័យបរិស្ថាន និងការការពារសិទ្ធិជនជាតិដើមភាគតិច។ គោលការណ៍ណែនាំទាំងនេះត្រូវបានតាក់តែងឡើងនៅអំឡុងឆ្នាំ ២០០៣-

២០០៦ និងត្រូវបានទទួលស្គាល់ថាអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងគោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោកនៅអំឡុងពេលនោះ។ ប៉ុន្តែចាំបាច់ត្រូវពិនិត្យឡើងវិញលើឯកសារទាំងនេះដើម្បីកំណត់ថាតើនៅតែអនុលោមតាមលក្ខខណ្ឌក្របខណ្ឌបរិស្ថាន និងសង្គមបច្ចុប្បន្ន ឬទេ។ គួរកត់សម្គាល់ថា លេខាធិការដ្ឋាន គ.ជ.អ.ប ទើបតែបានអនុម័តគោលនយោបាយការពារសុវត្ថិភាពបរិស្ថាន និងសង្គម (ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងហេតុប៉ះពាល់បរិស្ថាន និងសង្គម) ដើម្បីអនុលោមតាមលក្ខខណ្ឌតម្រូវរបស់មូលនិធិអាកាសធាតុបៃតង (GCF) និងផែនការនានា ដើម្បីពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ/សង្កាត់ ឱ្យបន្ស៊ីគ្នានឹងគោលនយោបាយនេះ។ ភាគច្រើន លក្ខខណ្ឌតម្រូវរបស់មូលនិធិអាកាសធាតុបៃតង គឺប្រហាក់ប្រហែលគ្នានឹងលក្ខខណ្ឌតម្រូវក្នុងក្របខណ្ឌបរិស្ថាន និងសុវត្ថិភាពរបស់ធនាគារពិភពលោក។

### ១.៨.២ គោលនយោបាយរបស់ធនាគារពិភពលោក៖ បទដ្ឋានបរិស្ថាន និងសង្គមជាធរមាន

74. ក្នុងចំណោមបទដ្ឋានបរិស្ថាន និងសង្គមទាំង ១០ ក្នុងក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក បទដ្ឋានបរិស្ថាន និងសង្គមទី ៩ (អន្តរការីហិរញ្ញវត្ថុ) មិនពាក់ព័ន្ធនឹងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ៣ ទេ ប៉ុន្តែបទដ្ឋានបរិស្ថាន និងសង្គមផ្សេងទៀតគឺពាក់ព័ន្ធនឹងគម្រោងនេះ។ មានន័យថា ចាំបាច់ត្រូវវាយតម្លៃហានិភ័យដែលពាក់ព័ន្ធនឹងបទដ្ឋានបរិស្ថាន និងសង្គម ហើយក្នុងករណីមានហានិភ័យ គេត្រូវបង្កើតក្របខណ្ឌសម្រាប់ការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យ។ បទដ្ឋានបរិស្ថាន និងសង្គមពាក់ព័ន្ធទាំង ៩ រួមមាន ៖

- ក) បទដ្ឋានបរិស្ថាន និងសង្គមទី ១ ៖ ការវាយតម្លៃ និងគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ បរិស្ថាន និងសង្គម
- ខ) បទដ្ឋានបរិស្ថាន និងសង្គមទី ២ ៖ លក្ខខណ្ឌពលកម្ម និងការងារ
- គ) បទដ្ឋានបរិស្ថាន និងសង្គមទី ៣ ៖ ប្រសិទ្ធភាពធនធាន និងការទប់ស្កាត់ និងគ្រប់គ្រងការបំពុល
- ឃ) បទដ្ឋានបរិស្ថាន និងសង្គមទី ៤ ៖ សុខភាព និងសុវត្ថិភាពសហគមន៍
- ង) បទដ្ឋានបរិស្ថាន និងសង្គមទី ៥ ៖ លទ្ធកម្មដីធ្លី ការរឹតត្បិតលើការប្រើប្រាស់ដីធ្លី និងការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត
- ច) បទដ្ឋានបរិស្ថាន និងសង្គមទី ៦ ៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតដោយនិរន្តរភាព
- ឆ) បទដ្ឋានបរិស្ថាន និងសង្គមទី ៧ ៖ ជនជាតិដើមភាគតិច/សហគមន៍ប្រពៃណីដែលមិនទទួលបានការយកចិត្តទុកដាក់ក្នុងអនុតំបន់អាហ្វ្រិកសាហារ៉ា
- ជ) បទដ្ឋានបរិស្ថាន និងសង្គមទី ៨ ៖ បេតិកភណ្ឌវប្បធម៌ និង
- ឈ) បទដ្ឋានបរិស្ថាន និងសង្គមទី ១០ ៖ ការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌មាន។

75. តាមពិត ទីតាំងសម្បទានដីសង្គមកិច្ច ទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ ជំនួយផ្នែកកសិកម្ម និងអនុគម្រោងប្រភេទផ្សេងទៀតនៅតាមទីតាំងទាំងនេះ នឹងត្រូវបានកំណត់រកដោយផ្អែកតាមតម្រូវការក្នុងពេលអនុវត្តគម្រោង។ ដូច្នេះ ការវាយតម្លៃគម្រោងមិនអាចកំណត់រកហានិភ័យដែលអាចកើតឡើងទាំងអស់បានទេ។ ឧបករណ៍ខាង

ក្រោមត្រូវបានរៀបចំឡើង ពិគ្រោះយោបល់ និងផ្សព្វផ្សាយដោយឥណវន្តទៅតាមការវាយតម្លៃ ដើម្បីបង្ហាញពីការអនុលោមតាម និងតម្រង់ទិសការអនុវត្តបទដ្ឋានបរិស្ថាន និងសង្គមទាំង ៩ ខាងលើ។

ក. ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)
ខ. សាវតារបរិស្ថាន និងសង្គមនៃតំបន់ភាគឦសាននៅកម្ពុជា និងឧទាហរណ៍សម្បទានដីសង្គមកិច្ច និងសហគមន៍ដែលត្រូវមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច
គ. នីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ (LWCP)
ឃ. ក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី (RPF)
ង. ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច (IPPF)
ច. ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF)
ឆ. ផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP)
ជ. ផែនការការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP)។

## ១.៨.៣ ការរៀបចំ និងសមត្ថភាពផ្នែកស្ថាប័ន

76. ការទទួលខុសត្រូវលើការអនុវត្តគម្រោងជំហានទី ៣ នេះ ជាបន្ទុករបស់ស្ថាប័នធំៗពីរនៅថ្នាក់ជាតិ (ក្រសួងរៀបចំដែនដី និងក្រសួងកសិកម្ម) ចំណែកការរៀបចំការអនុវត្តមានលក្ខណៈវិមជ្ឈការ ដោយបែងចែកទៅតាមមន្ទីរបច្ចេកទេសផ្សេងៗដែលចូលរួមក្នុងក្រុមការងារថ្នាក់ខេត្ត។ នឹងមានការបង្កើតក្រុមការងារចម្រុះនៅថ្នាក់ស្រុក ចំណែកក្រុមប្រឹក្សាឃុំមានតួនាទីអនុវត្តន៍។

77. តួនាទី និងការទទួលខុសត្រូវលើការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងជំហានទី៣ នេះមានរៀបរាប់លម្អិតក្នុងផ្នែកទី ៧។ សកម្មភាពគម្រោងមានច្រើនអនេក ចាប់ពីការកំណត់អត្តសញ្ញាណ ការចុះវាស់វែង និងការរៀបចំផែនការសម្បទានដីសង្គមកិច្ច (ក្នុង LASED III, ICLT) រហូតដល់ការរៀបចំ និងអនុវត្តអនុគម្រោងគាំទ្រហេដ្ឋារចនាសម្ព័ន្ធ និងរបរចិញ្ចឹមជីវិត ដែលអាចបង្កហានិភ័យលើបរិស្ថាន និងសង្គម។ ដូច្នេះចំណុចសំខាន់គឺត្រូវធានាថា ស្ថាប័នទាំងអស់ដែលទទួលខុសត្រូវលើការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច៖ ១) មានការយល់ដឹងទូទៅពីគោលការណ៍ និងវិសាលភាពនៃបទប្បញ្ញត្តិស្តីពីបទដ្ឋានបរិស្ថាន និងសង្គ ក្នុងក្របខណ្ឌបរិស្ថាន និងសង្គម ២) មានចំណេះដឹងជ្រៅជ្រះពីបទប្បញ្ញត្តិក្នុងបទដ្ឋានបរិស្ថាន និងសង្គមដែលខ្លួនត្រូវទទួលខុសត្រូវផ្ទាល់ និង ៣) មានសមត្ថភាពធនធានមនុស្សគ្រប់គ្រាន់ក្នុងការអនុវត្តសកម្មភាពគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមដល់កម្រិតស្តង់ដារដែលអាចទទួលយកបាន រួមទាំងការចងក្រងឯកសារ និងរាយការណ៍ឱ្យបានគ្រប់គ្រាន់។ ក្រៅពីនេះ ត្រូវមានការកសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល ការកសាងការយល់ដឹង និងការរៀបចំយន្តការសមស្របសម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យបរិស្ថាន និងសង្គម។ គម្រោងនឹងដាក់បញ្ចូលបទប្បញ្ញត្តិជាក់លាក់សម្រាប់ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិក្នុងបទដ្ឋានបរិស្ថាន និងសង្គម និងសម្រាប់ឆ្លើយតបនឹងបណ្តឹងសាទុក្ខ និងបណ្តឹងដែលពាក់ព័ន្ធនឹងបទដ្ឋានបរិស្ថាន និងសង្គម។

78. ជារួម ក្រុមគម្រោងថ្នាក់ខេត្តជាអ្នកទទួលខុសត្រូវច្រើនជាងគេលើការអនុវត្តនីតិវិធីគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ។ ក្រុមប្រឹក្សាឃុំត្រូវយល់ពីគោលបំណងនៃការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម និងអាចចូលរួម

ជាមួយក្រុមគម្រោងថ្នាក់ខេត្តក្នុងការអនុវត្ត។ ក្រសួងរៀបចំដែនដី ដែលជាស្ថាប័នដឹកនាំការអនុវត្ត ជាអ្នកទទួលខុសត្រូវរួមលើការគ្រប់គ្រង គាំទ្រ និងជួយដល់ការគ្រប់គ្រងហានិភ័យ និងបំពេញមុខងារសំខាន់ៗនៅថ្នាក់ជាតិ ដូចជា ការពិនិត្យតាមដាន និងការរាយការណ៍។ ក្រសួងកសិកម្មដែលជាស្ថាប័នអនុវត្តន៍ ធានាការអនុលោមតាមការប្តេជ្ញាចិត្តក្នុងការគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គមនៅតាមតំបន់របស់ខ្លួនដែលមានការអនុវត្តសកម្មភាពគម្រោង។

79. ស្ថាប័នអនុវត្តន៍គម្រោងជំហានទី ៣ គឺជាស្ថាប័នអនុវត្តន៍ក្នុងគម្រោងជំហានទី ២ (ទោះជាមានភាពខុសគ្នាមួយចំនួនលើខ្លឹមសារលម្អិតនៃការបែងចែកការទទួលខុសត្រូវក្តី)។ ដូច្នេះ ស្ថាប័នអនុវត្តន៍ទាំងអស់សុទ្ធតែធ្លាប់មានបទពិសោធន៍ពាក់ព័ន្ធនឹងទស្សនាទាន និងការអនុវត្តក្របខណ្ឌការពារសុវត្ថិភាពសម្រាប់គម្រោងជំហានទី ២។ ស្ថាប័នអនុវត្តន៍នៅថ្នាក់ជាតិនីមួយៗ សុទ្ធតែបានចាត់តាំងមន្ត្រីបង្គោលសម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម (ពាក្យ "មន្ត្រីបង្គោលការពារសុវត្ថិភាព" នៅតែប្រើប្រាស់ជាទូទៅក្នុងបរិបទនេះ) សម្រាប់គម្រោងជំហានទី ៣។ មន្ត្រីទាំងនេះសុទ្ធតែឆ្លងកាត់ការបណ្តុះបណ្តាលមូលដ្ឋានស្តីពីទស្សនាទាននៃក្របខណ្ឌបរិស្ថាន និងសង្គម ប៉ុន្តែភាគច្រើនគ្មានជំនាញឯកទេស និងមានបទពិសោធន៍ ឬការបណ្តុះបណ្តាលតិចតួចពាក់ព័ន្ធនឹងបញ្ហាទាំងនេះ។ ក្រុមគម្រោងថ្នាក់ខេត្តនឹងចាត់តាំងមន្ត្រីបង្គោលសម្រាប់គ្រប់គ្រងហានិភ័យបរិស្ថាន និងហានិភ័យសង្គម។

80. ក្នុងគម្រោងជំហានទី ៣ ទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម/អ្នកឯកទេសបរិស្ថាន និងសង្គម នឹងត្រូវបានដាក់ពង្រាយដូចខាងក្រោម ៖

ក. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ អ្នកឯកទេសគ្រប់គ្រងហានិភ័យសង្គមម្នាក់ អ្នកឯកទេសគ្រប់គ្រងហានិភ័យបរិស្ថានម្នាក់ និងទីប្រឹក្សាម្នាក់ដែលមានចំណេះដឹងជំនាញស្តីពីបញ្ហារបស់ជនជាតិដើមភាគតិច។ ទីប្រឹក្សាទាំងនេះធ្វើការនៅទីស្នាក់ការកណ្តាល និងចុះជួយជាប្រចាំដល់ការងាររបស់ក្រុមការងារថ្នាក់ខេត្ត។

81. គម្រោងជំហានទី ២ ជួលទីប្រឹក្សាការពារសុវត្ថិភាពនៅថ្នាក់ខេត្ត ប៉ុន្តែទីប្រឹក្សាក៏ត្រូវទទួលខុសត្រូវលើ GIS ផងដែរ ៖ ដោយសារតែការងារពាក់ព័ន្ធនឹង GIS ទាមទារជំនាញបច្ចេកទេសឯកទេស ជំនាញផ្នែកនេះត្រូវបានដាក់បញ្ចូលក្នុងលក្ខខណ្ឌជ្រើសរើស។ តួនាទីចម្រុះនេះនឹងត្រូវបញ្ចប់ក្នុងគម្រោងជំហានទី ៣ ហើយអ្នកឯកទេសដែលមានជំនាញ និងបទពិសោធន៍សមស្រប នឹងត្រូវបានជ្រើសរើសឱ្យធ្វើជាទីប្រឹក្សា។

82. ក្រសួងរៀបចំដែនដី ទទួលខុសត្រូវរួមលើនិយ័តកម្មការគ្រប់គ្រង និងការចុះបញ្ជីដីធ្លី ដែលជាផ្នែកដ៏សំខាន់មួយនៃការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ក្រោមគម្រោងជំហានទី ៣។ ការ អនុវត្តឱ្យបានសមស្របនូវនីតិវិធីលម្អិតសម្រាប់ការវាស់វែងដីធ្លី និងការរៀបចំផែនការ នឹងជួយដល់ការកំណត់រកលទ្ធកម្មដីធ្លីក្នុងគម្រោង និងតម្រូវការតាំងទីលំនៅថ្មី។ ការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដី សមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវអនុលោមតាមដំណើរការលម្អិតដែលពាក់ព័ន្ធនឹងការការពារសិទ្ធិរបស់ជនជាតិដើមភាគតិច និងអ្នកប្រើប្រាស់ដីផ្សេងទៀត ក្នុងតំបន់ដែលត្រូវមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ បទពិសោធន៍ពីគម្រោងជំហានទី ២ (សម្រាប់សម្បទានដីសង្គមកិច្ច) និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច បង្ហាញថា មន្ត្រីក្រសួងរៀបចំដែនដី មានចំណេះដឹង និងសមត្ថភាពក្នុងការអនុវត្តនីតិវិធីដែលកំណត់ដោយក្របខណ្ឌគតិយុត្តិនេះ។ មន្ត្រីក្រសួងរៀបចំដែនដីច្រើនតែ

ទាមទារការបណ្តុះបណ្តាលបន្ថែមពីលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងជំហានទី ៣ ដែលលើសពីបទប្បញ្ញត្តិនៃក្របខណ្ឌគតិយុត្តិនេះ។

83. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រដល់ការអភិវឌ្ឍកសិកម្មក្នុងគម្រោងជំហានទី ២ ជាពិសេសតាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួងកសិកម្មលើកកម្ពស់ការអនុវត្តស្តង់ដារនៃការអនុវត្តកសិកម្មល្អនៅកម្ពុជា (CAMGAP) ហើយក្រសួងមានគោលបំណងនាំយកការអនុវត្តដែលស៊ីសង្វាក់គ្នាក្នុង CAMGAP ទៅអនុវត្តក្នុងគម្រោងជំហានទី ៣។ ក្រសួងបានផ្សព្វផ្សាយពីការកាត់បន្ថយ ឬការមិនប្រើប្រាស់សារធាតុគីមីនៅតាមទីតាំងសម្បទានដីសង្គមកិច្ច អាស្រ័យទៅតាមនិន្នាការភាពទីតាំង និងវត្តមានទីផ្សារផលិតផលសរីរាង្គ ឬ "អាហារសុវត្ថិភាព"។ ក្រសួងបានចាត់តាំងមន្ត្រី ១០ នាក់ឱ្យចូលរួមក្នុងគម្រោងជំហានទី ២ ហើយគ្រោងនឹងបង្កើនឱ្យបាន ២០ នាក់សម្រាប់គម្រោងជំហានទី ៣។ មន្ត្រីទាំងនេះនឹងគាំទ្រដោយអ្នកជំនាញផ្នែកសង្វាក់តម្លៃ និងការអភិវឌ្ឍជនបទ។ គម្រោងជំហានទី២ មានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់សារធាតុគីមីដោយសុវត្ថិភាព។ អាហារូបត្ថម្ភមិនមែនជាចំណុចផ្តោតនៃសកម្មភាពកសិកម្មក្នុងគម្រោងជំហានទី ២ ទេ។ ស្តង់ដារ CAMGAP មានបទប្បញ្ញត្តិស្តីពីសុវត្ថិភាពកម្មករ និងពលកម្មកុមារ[4] ប៉ុន្តែស្តង់ដារទាំងនេះមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងការបណ្តុះបណ្តាលកសិករនោះទេ។ការបណ្តុះបណ្តាលកសិកម្មក្នុងគម្រោងជំហានទី ២ មិនបានលើកឡើងពីបញ្ហានៃការប្រែប្រួលអាកាសធាតុទេ ប៉ុន្តែសកម្មភាពជាច្រើន (ការជ្រើសរើសគ្រាប់ពូជ ការគ្រាលគម្របដីការពារសំណើម ប្រតិទិនតាមរដូវកាល) សុទ្ធតែពាក់ព័ន្ធនឹងកសិកម្មដែលធន់នឹងអាកាសធាតុ។

84. នៅថ្នាក់ខេត្ត គណៈកម្មាធិការប្រើប្រាស់ និងបែងចែកការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត (PLUAC) ទទួលខុសត្រូវលើការសម្របសម្រួលដំណើរការសម្បទានដីសង្គមកិច្ច ដែលកំណត់ដោយអនុក្រឹត្យលេខ ១៩ (ពាក់ព័ន្ធនឹងការរៀបចំផែនការប្រើប្រាស់ដីការកំណត់អត្តសញ្ញាណនិងការដោះស្រាយការទាមទារដីធ្លីចម្រូងចម្រាស់ ការកំណត់អត្តសញ្ញាណ និងការការពារតំបន់ងាយរងគ្រោះដោយសារ បរិស្ថាន និងសម្បត្តិបេតិកភណ្ឌវប្បធម៌ និងការការពារសិទ្ធិសហគមន៍ជនជាតិដើមភាគតិច)។ រដ្ឋបាលខេត្តទទួលខុសត្រូវលើការត្រួតពិនិត្យការអនុវត្តអនុគម្រោង ដូចជា ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងសកម្មភាពចិញ្ចឹមជីវិត ដែលសុទ្ធតែតម្រូវឱ្យមានការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម។ ក្នុងការអនុវត្តជាក់ស្តែង ស្ថាប័នទាំងពីរខាងលើ (មើលអង្គការលេខ ក្នុងរូប ១ ខាងលើ) សហការគ្នាជា "ក្រុមគម្រោង LASED" ចម្រុះមួយនៅថ្នាក់ខេត្ត និងបំពេញការងារតាមរយៈក្រុមការងារថ្នាក់ស្រុក។

[4] ច្បាប់ស្តីពីការងារនៅកម្ពុជា 970313។ ច្បាប់នេះត្រូវបានអនុម័តនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧ ក្នុងអំឡុងសម័យប្រជុំទី ៧ នីតិកាលទី ១ របស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧។

## ២.មេរៀនពីការអនុវត្តបទដ្ឋានបរិស្ថាន និងសង្គមក្នុងគម្រោងជំហានដំបូង និងគម្រោងជំហានទី ២

### ២.១ ក្របខណ្ឌការពារសុវត្ថិភាពបរិស្ថាន និងសង្គម

85. ទោះជានឹងមានភាពខុសគ្នាសំខាន់ៗ ជាពិសេសការដាក់បញ្ចូលសកម្មភាពគាំទ្រការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចក្នុងគម្រោងជំហានទី ៣ ក្ដី ប៉ុន្តែនឹងមានការបន្តសកម្មភាពគម្រោង វិធីសាស្ត្រ ការរៀបចំផ្នែកស្ថាប័ន និងការរៀបចំបុគ្គលិកពីគម្រោងជំហានទី ២ ទៅគម្រោងជំហានទី ៣។

86. បុគ្គលិកគម្រោង និងស្ថាប័នអនុវត្តន៍ រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ និង NGO ដែលជាដៃគូរអនុវត្តន៍ សុទ្ធតែយល់ច្បាស់ពីក្របខណ្ឌការពារសុវត្ថិភាពសម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងជំហានទី ២។ ចំណុចសំខាន់គឺ បុគ្គលិកគម្រោង និងអ្នកពាក់ព័ន្ធផ្សេងទៀតច្រើនតែដឹង និងយល់ពីបទប្បញ្ញត្តិក្នុងក្របខណ្ឌបរិស្ថាន និងសង្គម/បទដ្ឋានបរិស្ថាន និងសង្គម ពោលគឺពួកគេយល់ថា វាជាការប្រែក្លាយពីមូលដ្ឋាននៃក្របខណ្ឌការពារសុវត្ថិភាព ជាជាងយល់ថា វាជាគំនិតបង្កើតថ្មីទាំងស្រុង។

87. ឧបសម្ព័ន្ធ ២ បង្ហាញការវិភាគលម្អិតពីទំនាក់ទំនងរវាងការការពារសុវត្ថិភាពដែលត្រូវបានអនុវត្តក្នុងគម្រោងជំហានទី ២ និងលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងក្របខណ្ឌបរិស្ថាន និងសង្គម/បទដ្ឋានបរិស្ថាន និងសង្គម ព្រមទាំងបទពិសោធន៍ក្នុងការអនុវត្តការការពារសុវត្ថិភាព ចំណុចខ្សោយក្នុងក្របខណ្ឌនេះ និងបញ្ហាប្រឈម។ ឧបសម្ព័ន្ធ ២ លើកឡើងច្រើនពីការរៀបចំការកសាងសមត្ថភាពស្ដីពីការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមសម្រាប់បុគ្គលិកក្នុងគម្រោងជំហានទី ៣។ មេរៀនសំខាន់ៗពីការអនុវត្តការការពារសុវត្ថិភាពក្នុងគម្រោងជំហានទី ២ ត្រូវបានដកស្រង់ចេញពីឧបសម្ព័ន្ធ ២ និងមានសង្ខេបក្នុងផ្នែកនេះ។

### ២.២ ភស្តុតាងនៃផលប៉ះពាល់របស់គម្រោងលើបរិស្ថាន

88. គ្មានភស្តុតាងបង្ហាញថា អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដោយគម្រោងជំហានដំបូង និងជំហានទី ២ បង្កផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ យូរអង្វែង ឬធំធេងនោះទេ ប៉ុន្តែទំនងជាមានផលប៉ះពាល់កម្រិតទាប/បណ្ដោះអាសន្ន (ឧ. សំឡេងរំខាន និងការបំពុលដោយធូលីក្នុងពេលសាងសង់ ការស្ទះប្រព័ន្ធបង្ហូរទឹកនៅមូលដ្ឋាន សំណឹកតិចតួចនៅជុំវិញច្រកបង្ហូរនៃកងលូ។ល។)។

89. អ្នកទទួលបានដីធ្លីក្នុងតំបន់សម្បទានដីសង្គមកិច្ចប្រើប្រាស់អុសសម្រាប់ដុតចម្អិន។ នៅដំណាក់កាលដំបូងនៃការអភិវឌ្ឍសម្បទានដីសង្គមកិច្ច តម្រូវការអុសភាគច្រើនត្រូវបានបំពេញដោយដំណើរការកាប់ឆ្ការដីកសិកម្ម។ បន្ទាប់មកទៀត អ្នករស់នៅក្នុងតំបន់សម្បទានដីសង្គមកិច្ចប្រហែលជាចាំបាច់ត្រូវទៅរកអុសនៅទីតាំងឆ្ងាយជាងមុន។ នៅតាមទីតាំងសម្បទានដីសង្គមកិច្ចចាស់មួយចំនួន ពលរដ្ឋដុតធ្យូងលក់។ ដូច្នេះ ពួកគេត្រូវការអុសយ៉ាងច្រើន។ បើគ្មានការដាក់កម្រិតគ្រប់គ្រាន់ទេ បាតុភាពនេះនឹងធ្វើឱ្យមានសកម្មភាពកាប់ឈើដែលគ្មាននិរន្តរភាពពីតំបន់ព្រៃការពារដែលស្ថិតនៅក្រៅតំបន់សម្បទានដីសង្គមកិច្ច ដើម្បីបំពេញតម្រូវការខាងលើ។ ហានិភ័យមួយទៀតគឺ ការតាំងទីលំនៅរបស់សហគមន៍ក្នុងតំបន់សម្បទានដីសង្គមកិច្ចដែលស្ថិតនៅជិតតំបន់ការពារធម្មជាតិ អាចធ្វើឱ្យមានសកម្មភាពបរបាញ់ខុសច្បាប់ ឬសកម្មភាពហាមឃាត់ ឬសកម្មភាពបំផ្លិចបំផ្លាញបរិស្ថានកាន់តែច្រើនក្នុងតំបន់ការពារ ទោះបីជាចំណុចនេះមិនត្រូវបានពិនិត្យមើលឱ្យបានច្បាស់ស្ដី។

90. មានចំណុចខ្សោយមួយចំនួនក្នុងការគ្រប់គ្រងបរិស្ថាននិងសុខភាពសហគមន៍នៅតាមទីតាំងសម្បទានដីសង្គមកិច្ច។ តំបន់រស់នៅក្នុងទីតាំងសម្បទានដីសង្គមកិច្ចមានទំហំធំ និងសំបូរមនុស្សរស់នៅ ជាងនៅភូមិកំណើតរបស់អ្នកទទួលបានដីធ្លី និងមានទម្រង់ដូចតំបន់ទីប្រជុំជនតូចមួយ។ ទម្លាប់អនាម័យ និងការគ្រប់គ្រងសំណល់ក្នុងភូមិកំណើត ហាក់បង្កជាបញ្ហាចោទនៅទីតាំងថ្មី។ គម្រោងជំហានទី ២ បានចែកសម្ភារៈសម្រាប់សាងសង់បង្គន់ដល់ពលរដ្ឋ និងអ្នកទទួលបានដីធ្លីទាំងអស់ ប៉ុន្តែការពិតបង្ហាញថា សម្ភារៈដែលប្រគល់ជូនភាគច្រើនមិនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនេះទេ ហើយការបន្ទោរបង់ពាសវាលពាសកាលនៅតែបន្ត។ គម្រោងជំហានទី ៣ នឹងពង្រឹងលើចំណុចនេះ ដោយផ្អែកលើការអនុវត្តល្អបំផុតពាក់ព័ន្ធនឹងអនាម័យជនបទ ការរៀនសូត្រពីបទពិសោធន៍របស់ UNICEF និងទីភ្នាក់ងារផ្សេងទៀត ជាពិសេសគំនិតផ្តួចផ្តើមរបស់ធនាគារពិភពលោកផ្ទាល់។

91. ការគ្រប់គ្រងសំណល់រឹងធ្វើឡើងមិនបានល្អនៅតាមតំបន់រស់នៅ ក្នុងទីតាំងសម្បទានដី សង្គមកិច្ច។ មានទីតាំងបម្រុងទុកសម្រាប់បោះចោលកាកសំណល់ ប៉ុន្តែគ្មានប្រព័ន្ធប្រមូលសំរាមទេ។ គម្រោងជំហានទី ៣ គួរដោះស្រាយបញ្ហានេះឱ្យមានប្រសិទ្ធភាព។

92. តាមរយៈការបណ្តុះបណ្តាលពីសេវាផ្សព្វផ្សាយកសិកម្ម គម្រោងខិតខំលើកកម្ពស់គោលនយោបាយស្តីពីការអនុវត្តល្អផ្នែកកសិកម្មនៅកម្ពុជា (CAMGAP) ដោយមានការប្រើប្រាស់សារធាតុគីមីកសិកម្មតិចតួចបំផុត។ CAMGAP មិនត្រឹមតែមិនហាមឃាត់កសិករមិនឱ្យធ្វើការសម្រេចចិត្តដោយសេរីក្នុងការបង្កើនផលិតផលរបស់ខ្លួនតាមរយៈការប្រើប្រាស់ធាតុចូល និងធនធានគ្រប់បែបយ៉ាងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខិតខំផ្តល់ចំណេះដឹងដល់កសិករស្តីពីទំនាក់ទំនងរវាងការប្រើប្រាស់ជាតុជីគីមី និងការធ្វើឱ្យខូចគុណភាពដី និងទំនាក់ទំនងរវាងជីគីមី និងការកើនឡើងនៃឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស ដែលធ្វើឱ្យមានការប្រែប្រួលអាកាសធាតុថែមទៀតផង។ ផ្អែកតាមលទ្ធផលរកឃើញនៅកន្លែងផ្សេងទៀត[5] ស្តីពីចំណុចខ្សោយក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មក្នុងគម្រោងជំហានទី ៣ ការសង្កេតមើលការបោះចោលសម្ភារៈផ្ទុកសារធាតុគីមីគ្រោះថ្នាក់ និងការពិភាក្សាជាមួយកសិករនៅទីតាំងសម្បទានដីសង្គមកិច្ច បង្ហាញថា ការបណ្តុះបណ្តាលពី CAMGAP មិនទាន់ផ្តល់ការយល់ដឹងគ្រប់គ្រាន់ស្តីពីការរៀបចំទុកដាក់ ការប្រើប្រាស់ និងការបោះចោលដោយសុវត្ថិភាពនោះទេ។

## ២.៣ ភស្តុតាងនៃផលប៉ះពាល់របស់គម្រោងលើសង្គម

93. នីតិវិធីកំណត់អត្តសញ្ញាណទីតាំងដីសម្បទានដីសង្គមកិច្ចដែលបានអនុវត្តបន្តពីគម្រោងជំហានទី ២ ហាក់ទទួលបានជោគជ័យភាគច្រើនក្នុងការបញ្ចៀសផលប៉ះពាល់អវិជ្ជមានលើអ្នកប្រើប្រាស់ដីមានស្រាប់ (ទោះបីជាដំណើរការនេះធ្វើឱ្យមានការដាក់បណ្តឹងជាលក្ខណៈបុគ្គលយ៉ាងច្រើនក្តី)។ ដីធ្លីដែលធ្លាប់មានការទាមទារពីមុន រួមទាំងការទាមទារក្រៅផ្លូវការដោយគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ត្រូវបានគូសផែនទីជាប្រព័ន្ធ និងផាត់ចេញពីសម្បទានដីសង្គមកិច្ច តាមរយៈដំណើរការដែលមានតម្លាភាព និងឆ្លងកាត់ការពិគ្រោះយោបល់។ ក្នុងករណីមួយចំនួនអ្នកប្រើប្រាស់ដីមានស្រាប់ យល់ព្រមបោះបង់ការទាមទាររបស់ខ្លួនជាថ្នូរនឹងការបែងចែកដី ក្នុងទីតាំងសម្បទានដីសង្គមកិច្ច។

94. គម្រោងបានបញ្ចៀសផលប៉ះពាល់អវិជ្ជមាននៃលទ្ធកម្មដីធ្លី ដោយសារអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធលើអ្នកប្រើប្រាស់ដី តាមរយៈការរៀបចំផែនការប្រើប្រាស់ដីធ្លី ដែលបែងចែកដីទំនេរសម្រាប់តម្រូវការហេដ្ឋា

---

[5] សូមមើល LASED-III PAD កថាខណ្ឌ ៣៧។

រចនាសម្ព័ន្ធ។ ប៉ុន្តែមានករណីមួយដែលផ្លូវមួយខ្សែ (នៅទីតាំងសម្បទានដី សង្គមកិច្ចក្នុងខេត្តកំពង់ឆ្នាំងដែលជាការវិនិយោគហេដ្ឋារចនាសម្ព័ន្ធដោយគម្រោង IPLR) ត្រូវបានកសាងឡើងនៅទីតាំងខុសពីទីតាំងដែលបានកំណត់ក្នុងផែនការប្រើប្រាស់ដី។ ដូច្នេះ ចាំបាច់ត្រូវមានការចរចា និងអនុវត្តការដោះដូរដីធ្លីដោយរលូនដើម្បីប៉ះប៉ូវដល់អ្នកប្រើប្រាស់ដីមួយចំនួនតូច។

95. គេមិនច្បាស់ថាតើមានការពិចារណាពីផលប៉ះពាល់ ដែលអាចកើតមានលើប្រជាជនដែលប្រើប្រាស់ដីសម្រាប់គោលបំណងនៃធនធានទ្រព្យសម្បត្តិរួម (CPR) ដូចជា វាលស្មៅសម្រាប់ចិញ្ចឹមសត្វ ឬការប្រមូលអនុផលព្រៃឈើ ឬយ៉ាងណានោះទេ។

96. គម្រោងអនុវត្តដោយជោគជ័យក្នុងការធានាសន្តិសុខសិទ្ធិកាន់កាប់សម្រាប់អ្នកទទួលបានដីធ្លីក្នុងតំបន់សម្បទានដីសង្គមកិច្ច ប៉ុន្តែមានផ្ទៃដីតូចៗជាច្រើនដែលកំពុងប្រឈមនឹងការទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅតាមព្រំប្រទល់តំបន់សម្បទានដីសង្គមកិច្ច និងករណីមួយចំនួននៃជម្លោះព្រំប្រទល់រវាងអ្នកទទួលបានដីផ្ទាល់ ដោយសារកំហុសផ្នែកបច្ចេកទេស ឬកំហុសដោយអចេតនារបស់អ្នកវាស់ដី។

97. ផ្នែកសំខាន់ៗក្នុងក្របខណ្ឌបរិស្ថាន និងសង្គម/បទដ្ឋានបរិស្ថាន និងសង្គមសម្រាប់គម្រោងជំហានទី ៣ ដែលមិនសមស្រប ឬមិនត្រូវបានលើកឡើងដោយជោគជ័យក្នុងគម្រោងជំហានទី ២ រួមមាន ៖

ក. លក្ខខណ្ឌពលកម្ម និងការងារ ជាពិសេសពាក់ព័ន្ធនឹងកម្មករជាប់កិច្ចសន្យាក្នុងអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ

ខ. បញ្ហាសុវត្ថិភាពតាមផ្លូវចេញចូលតំបន់សម្បទានដីសង្គមកិច្ច (និងទីតាំងសម្រាប់ ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងគម្រោងជំហានទី ៣)

គ. សិទ្ធិរបស់ជនជាតិដើមភាគតិចជាពិសេសនៅទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ប៉ុន្តែទីតាំងសម្បទានដីសង្គមកិច្ចក្នុងគម្រោងជំហានទី៣ អាចស្ថិតក្នុងតំបន់ដែលមានសហគមន៍ជនជាតិដើមភាគតិចរស់នៅច្រើន។

## ២.៤ ការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងជំហានទី ២

98. **យន្តការដោះស្រាយបណ្តឹងតវ៉ា**ក្នុងគម្រោងជំហានទី ២ មិនទាន់អាចដោះស្រាយ និងឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងបណ្តឹងយ៉ាងច្រើន ដូចជា បណ្តឹងដែលលេចឡើងនៅពេលយន្តការនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅទីតាំងសម្បទានដីសង្គមកិច្ចដុងនោះទេ។ គួរកត់សម្គាល់ថា ដំណើរការកំណត់អត្តសញ្ញាណ និងបែងចែកដីធ្លី មិនថាអនុវត្តបានល្អ ឬយ៉ាងណានោះទេ នឹងធ្វើឱ្យមានបណ្តឹងយ៉ាងច្រើន។ ដូច្នេះ ចាំបាច់ត្រូវមានយន្តការដោះស្រាយបណ្តឹងតវ៉ាដែលមានសមត្ថភាពគ្រប់គ្រាន់។

## ២.៥ ការវិភាគចំណុចខ្វះខាត

99. ផ្នែកនេះមានគោលបំណងសង្ខេបពីលក្ខខណ្ឌតម្រូវសំខាន់ៗនៃបទដ្ឋានបរិស្ថាន និងសង្គមនីមួយៗខាងលើ និងកម្រិតដែលលក្ខខណ្ឌតម្រូវទាំងនេះបន្ស៊ីគ្នានឹងបទប្បញ្ញត្តិក្នុងក្របខណ្ឌច្បាប់ជាតិ។ ដើម្បីឱ្យខ្លី និងងាយយល់ ផ្នែកនេះសង្ខេបតែចំណុចសំខាន់ៗបំផុតប៉ុណ្ណោះ។ ខ្លឹមសារលម្អិតមានបង្ហាញក្នុងឧបករណ៍គ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម។ និយាយរួម ការវិភាគពេញលេញស្តីពីចំណុចខ្វះខាតក្នុងបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌពលកម្ម និងការងារ មានបង្ហាញក្នុងនីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ។

100. តារាង ៣ ខាងក្រោមសង្ខេបពីលក្ខខណ្ឌតម្រូវសំខាន់ៗសម្រាប់បទដ្ឋានបរិស្ថាន និងសង្គមទាំង ៩ និង បទប្បញ្ញត្តិប្រហាក់ប្រហែលគ្នាក្នុងក្របខណ្ឌច្បាប់ និងគតិយុត្តិជាតិ ។ តារាងខាងស្តាំដៃបង្ហាញពីគម្លាតសំខាន់ៗ។

| តារាង ៣ ៖ ការវិភាគចំណុចខ្វះខាតក្នុងក្របខណ្ឌច្បាប់ និងគតិយុត្តិ ធៀបនឹងលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គម | | | |
|---|---|---|---|
| **លក្ខខណ្ឌតម្រូវសំខាន់ៗ** | **ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ** | **គម្លាតសំខាន់ៗ** | **របៀប/ចំណុចដែលត្រូវបានលើកឡើងក្នុង ឧបករណ៍បរិស្ថាន និងសង្គម** |
| **បទដ្ឋានបរិស្ថាន និងសង្គមទី ១ ៖ ការវាយតម្លៃ និងគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម** | | | |
| ក.ធ្វើការវាយតម្លៃបរិស្ថាន និងសង្គមលើទីតាំងគម្រោងដែលស្នើសុំ រួមទាំងការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ<br>ខ.អនុវត្តការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ និងផ្សព្វផ្សាយព័ត៌មានសមស្របដោយផ្អែកតាមបទដ្ឋាន បរិស្ថាន និងសង្គមទី ១០<br>គ.រៀបចំផែនការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP) និងអនុវត្តវិធានការ និងចំណាត់ការទាំងអស់ដែលមានចែងក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ រួមទាំង ESCP និង<br>ឃ.ពិនិត្យតាមដាន និងរាយការណ៍ពីដំណើរការបរិស្ថាន និងសង្គមរបស់គម្រោងធៀបនឹងបទដ្ឋានបរិស្ថាន និងសង្គម។ | អនុក្រឹត្យលេខ ៧៤ អនក.បក ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គម្រោងទទួលបានជំនួយពីខាងក្រៅ (SOP, ២០១២) តម្រូវឱ្យមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (រួមទាំងសង្គម) និងការរៀបចំផែនការគ្រប់គ្រងបរិស្ថាន/ក្របខណ្ឌគ្រប់គ្រងបរិស្ថាន។ នីតិវិធីនេះផ្អែកតាមគោលការណ៍ណែនាំទូទៅរបស់ក្រសួងបរិស្ថាន ប៉ុន្តែគេជឿថា មិនទាន់រៀបចំរួចរាល់នោះទេ។ | នីតិវិធីនេះមិនបានកំណត់ស្តង់ដារសម្រាប់ការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ ឬការផ្សព្វផ្សាយព័ត៌មានក្នុងការរៀបចំ ឬការអនុវត្តគម្រោងឡើយ។ | ESMF<br>LWCP<br>RPF<br>IPPF<br>CHPF<br>SEP<br>ESMP និង SEP តាមទីតាំងដែលត្រូវរៀបចំឡើងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចទាំងអស់។ ឧបករណ៍បន្ថែម (IPPP, RP) ត្រូវតែរៀបចំឡើងសម្រាប់ទីតាំងនីមួយៗទៅតាមភាពចាំបាច់។ |
| **បទដ្ឋានបរិស្ថាន និងសង្គមទី ២ ៖ លក្ខខណ្ឌពលកម្ម និងការងារ (មើលផងដែរ LWCP)** | | | |
| បទដ្ឋានសង្គម និងបរិស្ថានទី ២ ចែងពីបទដ្ឋានអប្បបរមាលើផ្នែកខាងក្រោម ៖<br>• លក្ខខណ្ឌការងារ<br>• ការមិនរើសអើង និងឱកាសស្មើភាព<br>• សិទ្ធិបង្កើតសហជីព/សមាគម | ច្បាប់ស្តីពីការងារ (១៩៩៧) មានបទប្បញ្ញត្តិភាគច្រើន ឬទាំងស្រុងដែលបន្សុីគ្នានឹងលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ២ លើផ្នែកខាងក្រោម ៖<br>• លក្ខខណ្ឌការងារ<br>• ការមិនរើសអើង និងឱកាសស្មើភាព | គ្មានលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ឱ្យនិយោជកអនុវត្តយន្តការបណ្តឹងតវ៉ា។<br>សុវត្ថិភាពនៅកន្លែងធ្វើការ គឺជាកាតព្វកិច្ចទូទៅរបស់និយោជក | នីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារមាន ៖<br>• នីតិវិធីទប់ស្កាប់ពលកម្មកុមារ និងការងារដោយបង្ខំ (PPCLFL) |

| | | | |
|---|---|---|---|
| • ការទប់ស្កាត់/ការរឹតត្បិតពលកម្មកុមារ<br>• ការទប់ស្កាត់ការងារដោយបង្ខំ<br>• យន្តការបណ្ដឹងតវ៉ា<br>• ការកំណត់អត្តសញ្ញាណមុខសញ្ញាគ្រោះថ្នាក់<br>• ការផ្ដល់វិធានការទប់ស្កាត់ និងការពារ<br>• ការបណ្ដុះបណ្ដាលកម្មករ និងកំណត់ត្រាវគ្គបណ្ដុះបណ្ដាល<br>• ការចងក្រងឯកសារ និងរាយការណ៍ពីគ្រោះថ្នាក់ ជំងឺ និងឧប្បត្តិហេតុក្នុងការងារ<br>• ការត្រៀមខ្លួនទប់ទល់នឹងគ្រោះអាសន្ន<br>• ការផ្ដល់សំណងសម្រាប់ផលប៉ះពាល់អវិជ្ជមាន។ | • សិទ្ធិបង្កើតសហជីព/សមាគម<br>• ការទប់ស្កាត់/ការរឹតត្បិតពលកម្មកុមារ<br>• ការទប់ស្កាត់ការងារដោយបង្ខំ<br>• ការទទួលខុសត្រូវរបស់និយោជក (សំណងលើផលប៉ះពាល់អវិជ្ជមាន) មានចែងក្នុងលក្ខខណ្ឌទូទៅ។ | ប៉ុន្តែមិនបានចែងលម្អិតទេ។<br>គ្មានការបណ្ដុះបណ្ដាលពីសុវត្ថិភាពរបស់ កម្មករ។<br>ការចងក្រងឯកសារ និងការរាយការណ៍ពីឧប្បត្តិហេតុមិនត្រូវបានកំណត់ច្បាស់ជាកាតព្វកិច្ច។<br>ការត្រៀមខ្លួនទប់ទល់នឹងគ្រោះអាសន្នមិនត្រូវបានកំណត់ច្បាស់ជាកាតព្វកិច្ច។ | • យន្តការបណ្ដឹងតវ៉ារបស់កម្មករក្នុងគម្រោង។<br><br>នីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ កំណត់ពីលក្ខខណ្ឌតម្រូវឱ្យមានវិធានការបន្ថែមដើម្បីអនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមទី ២ ដែលនឹងរួមបញ្ចូល ៖<br>• យុទ្ធសាស្ត្រសុខភាព និងសុវត្ថិភាពក្នុងការងាររបស់កម្មករដែលធ្វើការផ្ទាល់ក្នុងគម្រោង<br>• លក្ខខណ្ឌការងារសម្រាប់កម្មករដែលធ្វើការផ្ទាល់ក្នុងគម្រោង<br>• បទដ្ឋានបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព (ESHSS) ក្នុងកិច្ចសន្យា<br>• នីតិវិធីគ្រប់គ្រងការងារក្នុង សហគមន៍<br>• បទប្បញ្ញត្តិក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមស្ដីពីទីតាំង និងអនុគម្រោង<br>• ផែនការ (ការងារ) សុខភាព និងសុវត្ថិភាពក្នុងការងារតាមទី តាំង។ |
| **បទដ្ឋានបរិស្ថាន និងសង្គមទី ៣ ៖ ប្រសិទ្ធផលធនធាន និងការទប់ស្កាត់ និងការគ្រប់គ្រងការបំពុល** | | | |
| ពិចារណាពីលក្ខខណ្ឌជុំវិញ និងអនុវត្តវិធានការបច្ចេកទេស និងហិរញ្ញវត្ថុដែលអាចអនុវត្តបាន ដោយអនុលោមតាមឋានានុក្រម | | | ESMF |

| | | | |
|---|---|---|---|
| កាត់បន្ថយផលប៉ះពាល់ សមាមាត្រទៅតាម ហានិភ័យ និងផលប៉ះពាល់ដែលពាក់ព័ន្ធនឹងគម្រោង និងស៊ីសង្វាក់គ្នានឹង GIIP ក្នុង EHSGs ដំបូង។<br>ប្រសិទ្ធភាពធនធានរួមមាន ៖<br>• ការប្រើប្រាស់ថាមពល<br>• ការប្រើប្រាស់ទឹក<br>• ការប្រើប្រាស់វត្ថុធាតុដើម.<br><br>ការទប់ស្កាត់ និងគ្រប់គ្រងការបំពុល រួមមាន ៖<br>• ការគ្រប់គ្រងការបំពុលខ្យល់<br>• ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់មិនគ្រោះថ្នាក់<br>• ការគ្រប់គ្រងសារធាតុគីមី និងសារធាតុគ្រោះថ្នាក់<br>• ការគ្រប់គ្រងថ្នាំសម្លាប់សត្វល្អិត។ | | | |
| **បទដ្ឋានបរិស្ថាន និងសង្គមទី ៤ ៖ សុខភាព និងសុវត្ថិភាពសហគមន៍** | | | |
| វាយតម្លៃហានិភ័យ និងផលប៉ះពាល់លើសុខភាព និងសុវត្ថិភាពរបស់សហគមន៍រងផលប៉ះពាល់ និងស្នើវិធានការកាត់បន្ថយផលប៉ះពាល់លើផ្នែកខាងក្រោម ៖<br>• ការរៀបចំ និងសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារ<br>• សុវត្ថិភាពនៃការផ្តល់សេវា<br>• សុវត្ថិភាពចរាចរណ៍ និងផ្លូវថ្នល់<br>• សេវាប្រព័ន្ធអេកូឡូស៊ី<br>• ការប្រឈមរបស់សហគមន៍ទៅនឹងបញ្ហាសុខភាព<br>• ការគ្រប់គ្រង និងសុវត្ថិភាពសារធាតុគ្រោះថ្នាក់<br>• ការត្រៀមខ្លួនទប់ទល់នឹងគ្រោះអាសន្ន និងការឆ្លើយតប។ | • មាត្រា ២១ នៃអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច បង្ហាញពីសមាសភាគគណៈកម្មាធិការជាតិទទួលបន្ទុកសម្បទានដីសង្គម រួមទាំងសមាជិក។ គណៈកម្មាធិការនេះធ្វើកិច្ចការពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពសហគមន៍ (ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី) ប៉ុន្តែមិនសូវមានតួនាទី និងការទទួលខុសត្រូវដែលពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពសហគមន៍ទេ។<br>• យុទ្ធសាស្ត្រទី ៤ ស្តីពីសុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់សហគមន៍ ក្នុងគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន និង | • គ្មានការកំណត់តួនាទី និងការទទួលខុសត្រូវជាក់លាក់របស់ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកិច្ចការនារីពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពសហគមន៍។<br>• កង្វះការចូលរួមរបស់ក្រសួងសុខាភិបាលក្នុងសមាសភាគគណៈកម្មាធិការជាតិទទួលបន្ទុកសម្បទានដីសង្គមកិច្ច។ | • ការពិនិត្យបឋមលើទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗ។<br>• ការកំណត់រកហានិភ័យដោយផ្អែកលើលទ្ធផលរកឃើញពីការពិនិត្យបឋម<br>• ដាក់បញ្ចូលវិធានការពាក់ព័ន្ធក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង |

| | | | |
|---|---|---|---|
| ក្រៅពីនេះ គឺបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងដោយសុវត្ថិភាពលើបុគ្គលិកសន្តិសុខ។<br>ឧបសម្ព័ន្ធ ១ រៀបរាប់លម្អិតពីបទប្បញ្ញត្តិស្តីពីសុវត្ថិភាព ទំនប់។ | សង្គមក្នុងគម្រោង នៃក្របខណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជា ធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចុះខែ មេសា ឆ្នាំ ២០១៩។<br>• រដ្ឋធម្មនុញ្ញកម្ពុជា (១៩៩៣) ជានាថា គ្មានការរំលោភបំពានរាងកាយលើបុគ្គលណាម្នាក់។<br>• គោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព (២០១០) លើកឡើងពីការរំលោភសេពសន្ថវៈ អំពើហិង្សាផ្អែកលើយេនឌ័រ និងការប្រឆាំងការជួញដូរជាចំណុចអាទិភាពសម្រាប់ក្រុមប្រឹក្សាឃុំ ក្រុង ស្រុក និងខេត្ត។<br><br>ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ទី ២ (NAPVAW II) ២០១៤-២០១៨ លើកកម្ពស់អន្តរាគមន៍ទប់ស្កាត់ ការឆ្លើយតប ការទទួលបានសេវាដែលមានគុណភាព និងការសម្របសម្រួល និងកិច្ចសហការអន្តរវិស័យ ដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី។ | គ្មានជំពូកជាក់លាក់ក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ/សង្កាត់ដែលពាក់ព័ន្ធនឹងសុខភាព សុវត្ថិភាព និងសុខុមាលភាព សហគមន៍។ | • ការផ្ទៀងផ្ទាត់ការផ្គត់ផ្គង់ទឹកពិសាគ្រប់គ្រាន់តាមទីតាំងទាំងអស់<br>• វិធានការរបស់គម្រោងដើម្បីដោះស្រាយហានិភ័យនៃអំពើហិង្សាផ្អែកលើយេនឌ័រតាមទីតាំងទាំងអស់។ |
| **បទដ្ឋានបរិស្ថាន និងសង្គមទី ៥ ៖ លទ្ធកម្មដីធ្លី ការរឹតត្បិតលើការប្រើប្រាស់ដី និងការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត (មើលផងដែរ RPF)** | | | |
| ជាទូទៅ ៖ ការគ្រប់គ្រងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត ដោយផ្អែកតាមឋានានុក្រមនៃការកាត់បន្ថយផលប៉ះពាល់ (បញ្ចៀស កាត់បន្ថយ ឬកាត់បន្ថយឱ្យនៅតិចបំផុត សម្រាល ប៉ះប៉ូវ)។<br>ជាក់លាក់ ៖<br>• កំណត់អត្តសញ្ញាណអ្នកដែលរងផលប៉ះពាល់ទាំងអស់ និងវាយតម្លៃលក្ខណៈសម្បត្តិក្នុងការទទួលបានសំណង<br>• បញ្ចៀសការជម្លៀសដោយបង្ខំ | • អនុក្រឹត្យលេខ ២២ ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅថ្មី (SOP LAR) ចែងពីក្របខណ្ឌគ្រប់ជ្រុងជ្រោយសម្រាប់ការរៀបចំ និងអនុវត្តផែនការតាំងទីលំនៅថ្មី។ | នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅថ្មី មិន ផ្តោតសំខាន់លើការបញ្ចៀសការតាំងទីលំនៅថ្មីជាជម្រើសអាទិភាព។<br>សិទ្ធិរបស់អ្នកប្រើប្រាស់ដីធ្លីដោយគ្មានប័ណ្ណកម្មសិទ្ធិផ្លូវការ ដែលមានកំណត់ក្នុងបទដ្ឋានបរិស្ថាន | • បញ្ចៀស និង/ឬកាត់បន្ថយជាអតិបរមានូវតម្រូវការលទ្ធកម្មដីធ្លីតាមរយៈការរៀបចំផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួមក្នុងការកំណត់អត្តសញ្ញាណដីសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគ តិច។ |

| | | | |
|---|---|---|---|
| • ផ្ដល់សំណងទាន់ពេលវេលាដោយផ្អែកតាមថ្លៃជំនួស<br>• ជួយដល់ជនបាត់បង់ទីលំនៅដើម្បីស្ដារ ឬកែលម្អជីវភាពរបស់ខ្លួន<br>• ការពារជនក្រីក្រ និងជនរងផលប៉ះពាល់ដែលងាយរងគ្រោះ<br>• គ្រោង និងអនុវត្តសកម្មភាពតាំងទីលំនៅថ្មីក្នុងទម្រង់ជាកម្មវិធីអភិវឌ្ឍន៍ដែលមាននិរន្តរភាព។<br><br>ធ្វើយ៉ាងណាឱ្យមានការរៀបចំផែនការ និងអនុវត្តការតាំងទីលំនៅថ្មីដោយមានការផ្សព្វផ្សាយព័ត៌មានសមស្រប ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងការចូលរួមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវពីសំណាក់អ្នករងផលប៉ះពាល់។ | | និងសង្គមទី ៥ ប្រហែលជាមិនត្រូវបានលើកឡើងពេញលេញក្នុងបទប្បញ្ញត្តិនៃនីតិវិធីនេះ។ មិនច្បាស់ថាតើមានការផ្ដល់សំណងទៅតាមតម្លៃជំនួស ឬយ៉ាងណានោះទេ ("តម្លៃទីផ្សារ" មានចែងក្នុងនីតិវិធីនេះ)។ នីតិវិធីនេះចែងពីសកម្មភាពស្ដារបេរចិញ្ចឹមជីវិត និងការការពារបន្ថែមសម្រាប់គ្រួសារក្រីក្រ ប៉ុន្តែបទប្បញ្ញត្តិទាំងនេះប្រហែលជាមិនបំពេញលក្ខខណ្ឌតម្រូវក្នុងបទដ្ឋាន បរិស្ថាន និងសង្គមទី ៥<br><br>បទប្បញ្ញត្តិសម្រាប់ការផ្សព្វផ្សាយព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួមដោយផ្អែកលើព័ត៌មានត្រឹមត្រូវប្រហែលជាមិនបំពេញលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៥។ | • ស្វែងរកជម្រើសផ្សេងៗសម្រាប់ការបរិច្ចាគដីដោយស្ម័គ្រចិត្ត (អនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមទី ៥) និង/ឬការដាក់បញ្ចូលអ្នកប្រើប្រាស់ដីបច្ចុប្បន្នជាអ្នកទទួលបានដីពីសម្បទានដី សង្គមកិច្ច ឬសមាជិកសហគមន៍ដែលមានលក្ខណៈសម្បត្តិទទួលបានប័ណ្ណកម្មសិទ្ធិដី<br>សមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច<br>• ស្វែងរកជម្រើសផ្សេងៗសម្រាប់ការផ្ដល់សំណងដល់អ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួមលើដីធ្លី ដូចជា លទ្ធភាពផ្សេងទៀតអត្ថប្រយោជន៍សំណងពីគម្រោង ឬការទូទាត់តម្លៃស្មើនឹងទំហំនៃការបាត់បង់<br>• ក្នុងករណីចាំបាច់ សូមរៀបចំ និងអនុវត្តផែនការតាំងទីលំនៅថ្មីដោយបន្សុីគ្នានឹងក្របខណ្ឌគោលនយោបាយស្ដីពីការតាំងទីលំនៅថ្មី (RPF)។ |
| **បទដ្ឋានបរិស្ថាន និងសង្គមទី ៦ ៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតដោយនិរន្តរភាព** | | | |
| ពិចារណាពីផលប៉ះពាល់ផ្ទាល់ ប្រយោល និងជាបន្តបន្ទាប់លើដែនជម្រក និងជីវចម្រុះ (ក្នុង ESA) និងបញ្ចៀសផលប៉ះពាល់អវិជ្ជ | សេចក្ដីប្រកាសឆ្នាំ ២០១០ ស្ដីពីគោលនយោបាយដីធ្លីដផ្ដោតសំខាន់លើអនុវិស័យ ៣។ | ច្បាប់ស្ដីពីកិច្ចការពារបរិស្ថានកំណត់ពីការបែងចែកតំបន់ការពារជា ៤ ប្រភេទសម្រាប់ការ | ESMF |

| | | | |
|---|---|---|---|
| មាន។ ក្នុងករណីដែលមានហានិភ័យ និងផលប៉ះពាល់អវិជ្ជមានខ្លាំង សូមរៀបចំ និងអនុវត្តផែនការគ្រប់គ្រងជីវចម្រុះ។ | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភា និងប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម/នស-រកម-១២៩៦/៣៦។<br><br>អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ចុះខែ សីហា ឆ្នាំ ១៩៩៩ និងគោលការណ៍ណែនាំ (២០០៥, ២០០៩ និង ២០១៧) មានការណែនាំសម្រាប់ IEIA និង EIA ដោយយោងតាមច្បាប់នេះ។ | គ្រប់គ្រង ប៉ុន្តែមិនបានដាក់បញ្ចូលតំបន់វប្បធម៌ និងបេតិកភណ្ឌទេ។ ច្បាប់នេះចែងតែពីលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់អត្តសញ្ញាណព្រំប្រទល់តំបន់ ប៉ុន្តែគ្មាននីតិវិធី និងគោលការណ៍ណែនាំទេ។ ម្យ៉ាងទៀតគ្មានគោលការណ៍ណែនាំ ឬយន្តការសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិទេ។ ច្បាប់នេះមិនគ្របដណ្តប់លើផ្នែកណាមួយនៃតំបន់ការពារសហគមន៍នៅក្រៅព្រំប្រទល់តំបន់ការពារធម្មជាតិទេ។ | |
| **បទដ្ឋានបរិស្ថាន និងសង្គមទី ៧ ៖ ជនជាតិដើមភាគតិច/សហគមន៍ប្រពៃណីដែលមិនទទួលបានការយកចិត្តទុកដាក់ក្នុងអនុតំបន់អាហ្វ្រិកសាហារ៉ា (មើលផងដែរ IPPF)** | | | |
| ធានាថា ជនជាតិដើមភាគតិចដែលមានវត្តមានក្នុង ឬមានទំនាក់ទំនងនឹងតំបន់គម្រោង ត្រូវបានពិគ្រោះយោបល់ពេញលេញ និងអាចចូលរួមក្នុងការរៀបចំគម្រោង និងការកំណត់ការរៀបចំអនុវត្តន៍<br>• ប៉ាន់ប្រមាណពីលក្ខណៈ និងកម្រិតនៃផលប៉ះពាល់រំពឹងទុកលើជនជាតិដើមភាគតិច<br>• រៀបចំយុទ្ធសាស្ត្រពិគ្រោះយោបល់<br>• រៀបចំផែនការវិធានការ និងចំណាត់ការដោយមានពេលវេលាច្បាស់លាស់<br>• បញ្ចៀសផលប៉ះពាល់អវិជ្ជមានតាមដែលអាចធ្វើទៅបាន | ច្បាប់ភូមិបាលឆ្នាំ ២០០១ ទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការកាន់កាប់ដីប្រពៃណី និងអនុវត្តវប្បធម៌ និងប្រពៃណីរបស់ខ្លួន។ មាត្រា ២៥ និង ២៦ នៃច្បាប់ភូមិបាល ចែងពីការផ្តល់សិទ្ធិកាន់កាប់ដីជនជាតិដើមភាគតិចក្នុងទម្រង់ជាកម្មសិទ្ធិសមូហភាព។<br>• អនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច (២០០៩) មាត្រា ៦ កំណត់ពីដី ៥ ប្រភេទ ដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគ | គួរធ្វើវិសោធនកម្មអនុក្រឹត្យនេះ និងដាក់បញ្ចូលប្រភេទដីធ្លីផ្សេងទៀតដែលសហគមន៍បានប្រើប្រាស់។<br>គួររៀបចំវិធានផ្ទៃក្នុងភ្លាមៗ បន្ទាប់ពីការគូសផែនទី បឋម។<br><br>ការគូសផែនទីបឋមដែលគាំទ្រដោយ NGO គួរធ្វើឡើងឱ្យបាន | ចំណុចខ្វះខាតទី ១ ៖ ការផ្ទៀងផ្ទាត់ថាតើដំណាក់កាលទី ១ និងទី ២ ពិតជាអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ សម្រាប់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យពាក់ព័ន្ធនឹងធាតុចេញពីដំណាក់កាលទាំង ២ នេះ ឬយ៉ាងណា (គណៈកម្មាធិការតំណាងសហគមន៍ |

| | | | |
|---|---|---|---|
| • កំណត់រកវិធានការកាត់បន្ថយ និងអត្ថប្រយោជន៍អភិវឌ្ឍន៍ រួមទាំងសំណង<br>• ក្នុងករណីដែលមាន ១) ផលប៉ះពាល់អវិជ្ជមានលើដីធ្លី និងធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច ២) ការផ្លាស់ទីលំនៅរបស់ជនជាតិដើមភាគតិច ឬ ៣) ផលប៉ះពាល់លើបេតិកភណ្ឌវប្បធម៌របស់ជនជាតិដើមភាគតិ សូមធានាការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ (FPIC)។ | តិច ១) ដីលំនៅដ្ឋាន ២) ដីព្រៃអារក្ស ៣) ដីកប់ខ្មោច ៤) ដីធ្វើកសិកម្មដាក់ស្លែង និង ៥) ដីបម្រុងទុកសម្រាប់រដូវវេនដំណាំ។ | ច្បាស់លាស់ ដោយមន្ត្រីសុរិយោដី និងពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិច។<br>មិនចាំបាច់ស្នើសុំការអនុម័តពីក្រសួងកសិកម្ម និងក្រសួងបរិស្ថានលើសំណើសុំការបែងចែកប្រភេទដីឡើងវិញទេ ព្រោះមន្ទីរតាមខេត្តសុទ្ធតែជាសមាជិកគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។ | ដែលគិតគូរពី យេនឌ័រ និងបរិយាប័ន្នសង្គម និងលក្ខន្តិកៈសហគមន៍ ដែលលើកឡើងពីផលប្រយោជន៍របស់ស្ត្រី និងជនក្រីក្រ)។ មិនដូច្នោះទេ សូមលើកឡើងពីចំណុចរាំងស្ទះតាមរយៈដំណើរការដែលទាមទារការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ (FPIC)។<br>ចំណុចខ្វះខាតទី ២ ៖ សម្រាប់ដំណាក់កាលទី ២.៥ និងទី ៣ គួររៀបចំផែនការសម្រាប់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ រួមទាំង FPIC ដែលធានា និងចងក្រងជាឯកសារពី ៖<br>• បរិយាប័ន្នសង្គម យេនឌ័រ និងបរិយាប័ន្នតាមជំនាន់ ដែលពាក់ព័ន្ធនឹងការពិគ្រោះយោបល់ ភាពជាតំណាងក្នុងស្ថាប័នធ្វើសេចក្តីសម្រេច និងការទទួលបានអត្ថប្រយោជន៍<br>• បញ្ចៀសផលប៉ះពាល់អវិជ្ជមានដែលពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់តំបន់សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ហើយប្រសិនបើមិនអាចបញ្ចៀសបាន គួររៀបចំការផ្តល់សំណង និងវិធានការកាត់បន្ថយផលប៉ះពាល់។ |

| | | | |
|---|---|---|---|
| | | | • ការបញ្ចៀសផលប៉ះពាល់អវិជ្ជមានលើបេតិកភណ្ឌវប្បធម៌ដោយអនុលោមតាមក្របខណ្ឌកិច្ចការពារបេតិកភណ្ឌវប្បធម៌។<br>ចំណុចខ្វះខាតទី ៣ ៖<br>• ធ្វើការវាយតម្លៃសង្គម (ឧបសម្ព័ន្ធ ក នៃបទដ្ឋាន បរិស្ថាន និងសង្គម ទី ៧) ដើម្បី ផ្តល់មូលដ្ឋានព័ត៌មានដល់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងផែនការជនជាតិដើមភាគតិច។<br>ចំណុចខ្វះខាតទី ៤ ៖<br>• ផែនការសម្រាប់ជនជាតិដើមភាគតិចសម្រាប់សកម្មភាពនៅកម្រិតទីតាំងតាមរយៈដំណាក់កាលទី ២.៥ និងទី ៣ និងពាក់ព័ន្ធនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាបន្តបន្ទាប់ និងសកម្មភាពប្រកបរបរចិញ្ចឹមជីវិត។<br>ចំណុចខ្វះខាតទី ៥ ៖<br>• យន្តការដោះស្រាយបណ្តឹងតវ៉ាដែលអាចប្រើប្រាស់បានដោយសមាជិកសហគមន៍ជនជាតិដើមភាគតិចដែលជាអ្នកទទួលផល និងសមាជិកឮសហគមន៍ក្បែរខាងដែលអាចរងផលប៉ះពាល់ដោយសារសកម្មភាពអនុគម្រោង។ |

| | | | |
|---|---|---|---|
| | | | ចំណុចខ្វះខាតទី ៦ ៖ ក្រុមជាតិពន្ធុឡាវ និងចាម នឹងត្រូវបានគ្រប ដណ្តប់ដោយក្របខណ្ឌផែនការជនជាតិដើមភាគតិចសម្រាប់ទីតាំងសម្បទានដីសង្គមកិច្ច និងផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងលើសមាជិកសហគមន៍ដែលគ្មានលក្ខណៈសម្បត្តិទទួលបានការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅតាមទីតាំងទាំងនោះ។ ចំណុចខ្វះខាតទី ៧ ៖ លើកឡើងពីសង្គតភាពរវាងច្បាប់ និងបទប្បញ្ញត្តិរបស់ក្រសួងកសិកម្ម និងក្រសួងបរិស្ថានពាក់ព័ន្ធនឹងដីតំបន់ការពារធម្មជាតិ តាមរយៈគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។ |
| **បទដ្ឋានបរិស្ថាន និងសង្គមទី ៨ ៖ បេតិកភណ្ឌវប្បធម៌ (មើលផងដែរ CHPF)** | | | |
| ពិចារណាពីហានិភ័យផ្ទាល់ ប្រយោល និងជាបន្តបន្ទាប់លើបេតិកភណ្ឌវប្បធម៌។ បញ្ចៀសផលប៉ះពាល់តាមដែលអាចធ្វើទៅបាន ឬកំណត់រក និងអនុវត្តវិធានការដោយអនុលោមតាមឋានានុក្រមកាត់បន្ថយផលប៉ះពាល់ ៖<br>• ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ និងការកំណត់អត្តសញ្ញាណបេតិកភណ្ឌវប្បធម៌<br>• កំណត់ និងរៀបរាប់ពីតំបន់ការពារបេតិកភណ្ឌវប្បធម៌<br>• កំណត់ច្បាស់ពីប្រភេទជាក់លាក់នៃបេតិកភណ្ឌវប្បធម៌ ទាំងចលនវត្ថុ និងអចលនវត្ថុ | **ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ (១៩៩៦)** មានបទប្បញ្ញត្តិសម្រាប់ "ការថែរក្សាការពារបេតិកភណ្ឌវប្បធម៌ និងជាតិ និងសម្បត្តិវប្បធម៌ទូទៅប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់។".<br><br>• **សេចក្តីប្រកាសរបស់គណៈរដ្ឋមន្ត្រីលេខ ០៦** ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីវិធានការលុបបំបាត់ | ក្របខណ្ឌច្បាប់នេះផ្តោតសំខាន់តែលើបេតិកភណ្ឌ វប្បធម៌រូបីយ តែមិនសូវ ផ្តោតលើបេតិកភណ្ឌវប្បធម៌អរូបីទេ។ ក្របខណ្ឌច្បាប់នេះមិនដាក់បញ្ចូលលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៨ សម្រាប់ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធទេ។ | CHPF |

| | | | |
|---|---|---|---|
| • ការរឹតត្បិតលើការប្រើប្រាស់បេតិកភណ្ឌវប្បធម៌សម្រាប់គោលបំណងពាណិជ្ជកម្ម។ | ភាពអនាធិបតេយ្យក្នុងការទន្ទ្រានកាន់កាប់ដី ហាមឃាត់សិទ្ធិឯកជនលើទីតាំងបេតិកភណ្ឌវប្បធម៌។ | | |
| **បទដ្ឋានបរិស្ថាន និងសង្គមទី ១០ ៖ ការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌មាន (មើលផងដែរ SEP)** | | | |
| ជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងវដ្តគម្រោង ដោយមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ការផ្សព្វផ្សាយទាន់ពេលវេលានូវព័ត៌មានដែលពាក់ព័ន្ធ អាចយល់បាន និងអាចប្រើប្រាស់បាន ធ្វើការពិគ្រោះយោបល់តាមរបៀបសមស្របក្នុងវប្បធម៌ ដែលពាក់ព័ន្ធនឹង ៖<br>• ការវិភាគ និងការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ<br>• ការរៀបចំផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ<br>• ការផ្សព្វផ្សាយព័ត៌មាន<br>• ការលើកឡើង និងឆ្លើយតបនឹងបណ្តឹងតវ៉ា<br>• ការរាយការណ៍ទៅអ្នកពាក់ព័ន្ធ។<br><br>បង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោង និងផ្សព្វផ្សាយពីកំណត់ត្រានៃការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងដំណើរការ ESA។ | អនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច កំណត់ពីដំណើរសមស្របសម្រាប់ការកំណត់អត្តសញ្ញាណ ការគូសផែនទី និងការរៀបចំផែនការប្រើប្រាស់ដីធ្លីនៅតំបន់សម្បទានដីសង្គមកិច្ច និងការជ្រើសរើសអ្នកទទួលបានដីធ្លី ដោយមានការផ្សព្វផ្សាយព័ត៌មាន និងការចូលរួមពេញលេញរបស់អ្នកពាក់ព័ន្ធ និងអ្នកទទួលបានដីធ្លីក្នុងដំហានសំខាន់ៗនីមួយៗ។<br>ដំណើរការរៀបចំការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ផ្អែកតាមតម្រូវការសហគមន៍ និងរួមបញ្ចូលបទប្បញ្ញត្តិតឹងរ៉ឹងស្តីពីការផ្សព្វផ្សាយព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួម។ | នីតិវិធិប្រតិបត្តិស្តង់ដារនេះ (អនុក្រឹត្យលេខ ៧៤) មិនដាក់បញ្ចូលបទប្បញ្ញត្តិជាកាតព្វកិច្ចសម្រាប់ជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ ឬការផ្សព្វផ្សាយព័ត៌មានក្នុងការរៀបចំគម្រោងឡើយ។<br>នីតិវិធិប្រតិបត្តិស្តង់ដារនេះ (អនុក្រឹត្យលេខ ៧៤) ពិភាក្សាពីការដោះស្រាយបណ្តឹងតវ៉ា ប៉ុន្តែមិនបានតម្រូវឱ្យមានយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងឡើយ។ | គោលការណ៍ និងលក្ខខណ្ឌតម្រូវឱ្យមានការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ ការផ្សព្វផ្សាយព័ត៌មាន និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP)។<br>ត្រូវរៀបចំ SEP តាមទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ សហគមន៍ជនជាតិដើមភាគតិចនីមួយៗ។ |

# ៣.សាវតារបរិស្ថាន និងសង្គមរបស់ខេត្តគោលដៅសំខាន់ៗ

101. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ៣ (LASED III) ជាគម្រោងដែលមានវិសាលភាពទូទាំងប្រទេស ហើយនឹងរួមបញ្ចូលសកម្មភាពតាមបណ្តាខេត្តដែលជាទីតាំងសម្បទានដីសង្គមកិច្ចបច្ចុប្បន្ន (កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ក្រចេះ ត្បូងឃ្មុំ និងក្រចេះ) និងគាំទ្រដល់ទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចថ្មី និងមានស្រាប់ ដែលគេរំពឹងថានឹងស្ថិតក្នុងខេត្តក្រចេះ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងព្រះវិហារ។ គេរំពឹងថា ទីតាំងសម្បទានដីសង្គមកិច្ច និងទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចថ្មីនឹងស្ថិតនៅភាគច្រើន ឬទាំងស្រុងក្នុងខេត្តភាគឦសាននៃប្រទេសកម្ពុជា ដូចជា កំពង់ធំ ក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី និងស្ទឹងត្រែង។ ខេត្តទាំងនេះមានដង់ស៊ីតេប្រជាជនទាប និងសំបូរដើមទំនេរ និងជាទីតាំងប្រមូលផ្តុំសហគមន៍ជនជាតិដើមភាគតិច។

102. សាវតារបរិស្ថាន និងសង្គម (ESP) ត្រូវបានរៀបចំឡើងជាឯកសារដាច់ដោយឡែក ដោយផ្អែកលើទិន្នន័យបន្ទាប់បន្សំ និងការចុះសង្កេតមើលតាមទីតាំង។ ផ្នែកបន្តបន្ទាប់នៃក្របខណ្ឌគ្រប់គ្រង បរិស្ថាន និងសង្គមនឹងបង្ហាញដោយសង្ខេបពីចំណុចសំខាន់នៃសាវតារបរិស្ថាន និងសង្គមដែលជាមូលដ្ឋានសម្រាប់ការវិភាគហានិភ័យ (ផ្នែកទី ៤)។ សាវតារបរិស្ថាន និងសង្គម ផ្តោតលើខេត្តភាគឦសានទាំង ៦ (សូមមើលកថាខណ្ឌខាងដើម)។ ចំណុចសំខាន់គឺលក្ខខណ្ឌក្នុងបណ្តាខេត្តផ្សេងទៀត ជាពិសេសនៅតាមតំបន់ដែលមានដង់ស៊ីតេប្រជាជនទាប ដែលអាចនឹងក្លាយជាទីតាំងសម្បទានដី សង្គមកិច្ច និងទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច សុទ្ធតែត្រូវគ្នានឹងលក្ខខណ្ឌដែលលេចឡើងនៅតំបន់ភាគឦសានរបស់កម្ពុជា។ ដោយសារគម្រោងនឹងធ្វើការពិនិត្យបឋមលើហានិភ័យបរិស្ថាន និងសង្គម និងការវាយតម្លៃហានិភ័យនៅកម្រិតទីតាំងសម្រាប់ទីតាំងថ្មីទាំងអស់ វិធីសាស្ត្រនេះនឹងអាចផ្តល់ទិដ្ឋភាពរួមយ៉ាងសុក្រឹតស្តីពីលក្ខខណ្ឌបរិស្ថាន និងសង្គម និងហានិភ័យដែលអាចកើតឡើងក្នុងតំបន់គោលដៅនៃគម្រោងជំហានទី ៣។

103. ខេត្តទាំង ៦ ដែលនឹងត្រូវដាក់បញ្ចូលក្នុងសាវតារបរិស្ថាន និងសង្គម មានបង្ហាញក្នុងផែនទីខាងក្រោម (រូប ២)។




*រូប ២ ៖ បណ្តាខេត្តក្នុងប្រទេសកម្ពុជា*

104. **រចនាសម្ព័ន្ធរដ្ឋបាល ៖** ខេត្តទាំង ៦ នេះត្រូវបានបែងចែកជា ៦ ក្រុង (ទីរួមខេត្ត) និង ៣៧ ស្រុក (មានរចនាសម្ព័ន្ធរដ្ឋបាល និងមុខងារស្រដៀងគ្នានឹងរចនាសម្ព័ន្ធ និងមុខងាររបស់ថ្នាក់ក្រុង)។ រដ្ឋាភិបាលថ្នាក់មូលដ្ឋាននៅកម្រិតខ្ពស់ទាំងនេះត្រូវបានបែងចែកជា ២៨៤ ឃុំ (ក្នុងស្រុក) និងសង្កាត់ (ក្នុងក្រុង) ដែលគ្រប់គ្រងផ្ទាល់ដោយក្រុមប្រឹក្សាដែលត្រូវបានបោះឆ្នោតជ្រើសតាំង និងធ្វើជាប្រធានដោយមេឃុំ/ចៅសង្កាត់ និងស្មៀនឃុំ/សង្កាត់។ ឃុំ/សង្កាត់ទាំងនេះត្រូវបានបែងចែកជា ១.៧២០ ភូមិ ដែលមិនត្រូវបានចាត់ទុកជាកម្រិតផ្លូវការនៃរដ្ឋាភិបាលមូលដ្ឋាន ប៉ុន្តែមានមេភូមិដែលត្រូវរាយការណ៍ទៅក្រុមប្រឹក្សាឃុំ/សង្កាត់។

105. **ប្រជាសាស្ត្រ ៖** ខេត្តទាំង ៦ នេះមានចំនួនប្រជាជនសរុបប្រមាណ ១,៧៥ លាននាក់ ឬស្មើនឹង ១១% នៃចំនួនប្រជាជនទូទាំងប្រទេស (លទ្ធផលជំរឿនឆ្នាំ ២០១៩)។ ក្នុងនោះ ប្រជាជន ៦០% រស់នៅក្នុងខេត្តកំពង់ធំ និងក្រចេះ។ ខេត្តទាំងនេះមានផ្ទៃដីសរុបទំហំ ៧៥.០០០ គីឡូម៉ែត្រការ៉េ និងដង់ស៊ីតេប្រជាជនមធ្យម ២៣ នាក់/គីឡូម៉ែត្រការ៉េ។ ប្រជាជនប្រមាណ ២១% រស់នៅក្នុងឃុំ/សង្កាត់ ដែលមានដង់ស៊ីតេប្រជាជន ២០០ នាក់/គីឡូម៉ែត្រការ៉េ។

106. សមាមាត្រជាមធ្យមគឺ ស្ត្រី ១០២ ធៀបនឹងបុរស ១០០ នាក់។ ប្រជាជនទាំងនេះមានវ័យក្មេង និងមានអាយុជាមធ្យម ២២ ឆ្នាំ ហើយប្រជាជនប្រហែល ៨% មានអាយុលើស ៦០ ឆ្នាំ។

107. កំណើនប្រជាជនក្នុងជំរឿននៅចន្លោះឆ្នាំ ២០០៨ និង ២០១៩ គឺប្រមាណ ១,៨% ក្នុងមួយឆ្នាំ។ នេះជាអត្រាខ្ពស់ជាងអត្រាប្រចាំឆ្នាំទូទាំងប្រទេស (១,២%)។ មានអត្រាខុសគ្នាយ៉ាងខ្លាំង ដោយក្នុងនោះ ខេត្តព្រះវិហារមានអត្រាកំណើនរហូតដល់ ៣,៦% ក្នុងមួយឆ្នាំ ចំណែកខេត្តកំពង់ធំ និងក្រចេះ មានអត្រាកំណើនជិតស្មើ ឬក្រោមមធ្យមភាគថ្នាក់ជាតិ។ ភាពខុសគ្នាទាំងនេះអាចបណ្ដាលមកពីការធ្វើចំណាកស្រុកពីខេត្តភាគខាងជើង និងភាគកណ្ដាលដែលមានប្រជាជនរស់នៅច្រើន។

108. ជនជាតិដើមភាគតិចមានប្រមាណ ១៤% នៃចំនួនប្រជាជនសរុបនៅតាមខេត្តគោលដៅ ជាពិសេសនៅខេត្តរតនគិរី (៦០%) និងមណ្ឌលគិរី (៤៦%) ប៉ុន្តែមានអត្រាត្រឹមតែ ១% នៃចំនួនប្រជាជនសរុបទូទាំងប្រទេស។ គ្មានទិន្នន័យស្ដីពីសមាជិករបស់ក្រុមជាតិពន្ធុផ្សេងទៀត (ចិន វៀតណាម និងចាម) ដែលមានប្រមាណ ៨% នៃចំនួនប្រជាជនសរុបនៅកម្ពុជា ប៉ុន្តែមិនសូវប្រមូលផ្ដុំនៅតាមខេត្តគោលដៅឡើយ។

109. ***ភាពក្រីក្រ*** ៖ អត្រាភាពក្រីក្រនៅតាមខេត្តគោលដៅ មានបង្ហាញក្នុងមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មជនក្រីក្ររបស់ក្រសួងផែនការ។ គួរកត់សម្គាល់ថា ទោះបីជាអត្រាភាពក្រីក្រសរុបដែលកំណត់ដោយមធ្យោបាយនេះហាក់ប្រហាក់ប្រហែលគ្នានឹងអត្រាភាពក្រីក្រដែលប៉ាន់ស្មានដោយការអង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជាដែលធ្វើឡើងតាមដំណាក់កាលក្ដី ប៉ុន្តែវិធីសាស្ត្រដែលប្រើប្រាស់គឺខុសគ្នា ចំណែកកម្រងគ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណជាគ្រួសារក្រីក្រដោយមធ្យោបាយនីមួយៗក៏មិនដូចគ្នាដែរ។ គ្រួសារប្រមាណ ១៧% ក្នុងខេត្តគោលដៅត្រូវបានកំណត់អត្តសញ្ញាណជាគ្រួសារក្រីក្រ និងមានអត្រាប្រែប្រួលខុសគ្នាតិចបំផុតនៅតាមខេត្តនីមួយៗ។ ឃុំដែលសំបូរដោយជនជាតិដើមភាគតិច មានអត្រាភាពក្រីក្រខ្ពស់ជាងឃុំផ្សេងទៀត (១៩%)។ ភាពក្រីក្រហាក់មានកម្រិតទាបក្នុង បណ្ដាឃុំដែលមានដង់ស៊ីតេប្រជាជនទាប។

110. **ការអប់រំ** ៖ អត្រាអក្ខរកម្មជារួមគឺប្រមាណ ៨៥% ក្នុងក្រុមអាយុ ១៨-៤៥ ឆ្នាំ ប៉ុន្តែមានអត្រាទាបក្នុងខេត្តមណ្ឌលគិរី និងរតនគិរី និងក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច។ សេចក្ដីរាយការណ៍បង្ហាញថា ក្រុមកុមារគ្រប់អាយុចូលរៀនបឋមសិក្សាប្រហែល ៨១% (៧-១១ ឆ្នាំ) និងក្រុមអាយុ ១២-១៧ ឆ្នាំ ប្រមាណ ៦៥% បានចុះឈ្មោះចូលរៀន។ អត្រាចុះឈ្មោះចូលរៀនមានកម្រិតទាបក្នុងខេត្តមណ្ឌលគិរី និងរតនគិរី និងតាមបណ្ដាឃុំដែលមានចំនួនជនជាតិដើមភាគតិចរស់នៅច្រើន ប៉ុន្តែកម្រិតខុសគ្នាគឺទាបជាងកម្រិតខុសគ្នាសម្រាប់អត្រាអក្ខរកម្ម។

111. **របរចិញ្ចឹមជីវិត ការងារ និងពលកម្ម** ៖ ប្រជាជនភាគច្រើន (ប្រមាណ ៦៤% នៃមនុស្សពេញ វ័យ) ប្រឡូកក្នុងការងារកសិកម្ម ប៉ុន្តែក្នុងករណីជាច្រើន ពួកគេក៏ប្រកបរបរចិញ្ចឹមជីវិតផ្សេងទៀតដែរ (ឧ. ពលកម្មចំណាកស្រុក ការងារស៊ីឈ្នួលតាមថ្ងៃ អាជីវកម្មខ្នាតតូចៗ។ល។)។ មនុស្សពេញវ័យតែ ៧% ប៉ុណ្ណោះដែលមានការងារផ្លូវការ។ ស្ត្រីមិនសូវមានការងារក្នុងវិស័យសេដ្ឋកិច្ច (៨៤% ធៀបនឹង ៩៩%) និងមិនសូវធ្វើការក្នុងវិស័យឯកជន និងវិស័យសាធារណៈទេ។ មានការលើកឡើងថា បុរស ១២% និងស្ត្រី ១០% បានធ្វើចំណាកស្រុករកការងារធ្វើក្នុង ឬក្រៅប្រទេស។ អត្រាធ្វើចំណាកស្រុក ហាក់មានកម្រិតទាបនៅតាមបណ្ដាឃុំដែលមានជនជាតិដើមភាគតិចរស់នៅច្រើន។

112. អត្រាទាបនៃការប្រឡូកក្នុងការងារផ្លូវការ ធ្វើឱ្យប្រជាជនភាគច្រើននៅតាមបណ្ដាខេត្តគោលដៅទាំងនេះមិនសូវយល់ដឹងពីទស្សនាទាន និងការអនុវត្តសិទ្ធិរបស់និយោជិត និងការការពារលក្ខខណ្ឌពលកម្ម និងការងារ ដែលមានចែងក្នុងច្បាប់របស់កម្ពុជា។

113. **សុខភាព សុវត្ថិភាព និងសុខុមាលភាព៖** គ្មានស្ថិតិលម្អិតផ្លូវការស្តីពីសុខភាពទេ។ ដូច្នេះ សាវតារបរិស្ថាន និងសង្គមបានប្រើប្រាស់ទិន្នន័យពីមូលដ្ឋានទិន្នន័យឃុំ (CDB) ដែលចងក្រងឡើងដោយមេភូមិ និងកំណត់ត្រាមូលហេតុមរណភាព។ និន្នាការគួរឱ្យកត់សម្គាល់ក្នុងទិន្នន័យទាំងនេះរួមមានការធ្លាក់ចុះយ៉ាងគំហុកនៃការស្លាប់ដោយសារមេរោគអេដស៍ និងការកើនឡើងនៃការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍។

114. អត្រាមរណៈទារកត្រូវបានគណនាចេញពីទិន្នន័យក្នុងមូលដ្ឋានទិន្នន័យឃុំ (ស្លាប់ ៧ នាក់ក្នុងចំណោមកំណើតរស់ ១.០០០ នាក់) និងមានកម្រិតខ្ពស់ក្នុងខេត្តរតនគីរី និងក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច (ត្រូវប្រុងប្រយ័ត្នចំពោះសុក្រឹតភាពនៃទិន្នន័យនេះ)។ អត្រាមរណៈមាតាគឺ ៣ នាក់ក្នុងចំណោមកំណើតរស់ ១.០០០ នាក់។ ក្នុងនោះ ជំងឺរបេងជាមូលហេតុចម្បងនៃការស្លាប់ដោយសារជំងឺឆ្លង (ស្លាប់ ៤,៣ នាក់ក្នុងចំណោមប្រជាជន ១០.០០០ នាក់) ចំណែកជំងឺគ្រុនចាញ់មានអត្រាស្លាប់ ១,៥ នាក់ក្នុងចំណោមប្រជាជន ១០.០០០ នាក់ ហើយជំងឺគ្រុនឈាមមានអត្រាស្លាប់ ១,៥ នាក់ក្នុងចំណោមប្រជាជន ១០.០០០ នាក់។

115. គ្មានតួលេខស្តីពីបញ្ហាអាហារូបត្ថម្ភចំពោះកុមារនៅតាមខេត្តគោលដៅទេ ប៉ុន្តែគេដឹងថា វាជាបញ្ហាទូទាំងប្រទេស។ ក្នុងនោះ កុមារ ២២% មានបញ្ហាក្រិន និង ៧% មានបញ្ហាស្គមស្គាំង (តួលេខរបស់ UNICEF)។

116. ខេត្តគោលដៅប្រឈមនឹងបញ្ហាជាច្រើនពាក់ព័ន្ធនឹងសំណល់អាវុធជាតិផ្ទុះបន្សល់ពីសង្គ្រាម (ERW) ដោយសារជម្លោះនៅអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ជាពិសេសគ្រាប់បែកចង្កោម និងគ្រាប់រំសេវផ្សេងទៀតដែលត្រូវបានដាក់ពង្រាយដោយចៃដន្យ និងអាចមានវត្តមានក្នុងទីតាំងដែលមិនទាន់មានមនុស្សចូលដល់តាំងពីពេលកើតជម្លោះ។ ប៉ុន្តែអត្រាឧប្បត្តិហេតុនៃសំណល់អាវុធជាតិផ្ទុះបន្សល់ពីសង្គ្រាម និងអត្រាស្លាប់/របួសបានថយចុះគួរឱ្យកត់សម្គាល់។ មូលដ្ឋានទិន្នន័យឃុំកត់ត្រាតែករណីផ្ទុះ ៥ និងករណីស្លាប់ ១ ដោយសារសំណល់អាវុធជាតិផ្ទុះបន្សល់ពីសង្គ្រាម នៅអំឡុងឆ្នាំ ២០១៨ នៅតាមខេត្តគោលដៅ។

117. មូលដ្ឋានទិន្នន័យឃុំ មានទិន្នន័យស្តីពីប្រជាជនដែលស្ថិតក្នុងក្រុមងាយរងគ្រោះ ដោយគណនាជាភាគរយនៃចំនួនប្រជាជនសរុប ៖ ប្រជាជនគ្មានទីលំនៅ ០,០៣%, កុមារកំព្រា ០,៣៤%, កុមារដែលមានអាណាព្យាបាលឈឺ ០,២៦%, ជនពិការ ០,០៣%, មនុស្សចាស់រស់នៅតែម្នាក់ឯង ០,១%។

118. អំពើហិង្សាផ្អែកលើយេនឌ័រគឺជាបញ្ហាចម្បងមួយក្នុងតំបន់ជនបទនៅកម្ពុជា។ UNICEF (ការអង្កេតឆ្នាំ ២០១៥) បង្ហាញថា ស្ត្រីកម្ពុជា ២១% ធ្លាប់ប្រឈមនឹងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ។ ក្នុងនោះ ស្ត្រី ៨% ធ្លាប់ប្រឈមនឹងឧប្បត្តិហេតុនេះកាលពី ១២ ខែមុន។

119. **ជម្លោះ និងសន្តិសុខ៖** ខេត្តគោលដៅមានសន្តិសុខល្អប្រសើរ និងមិនសូវមានជម្លោះហិង្សាទេ។ មានការប្រឈមមុខដាក់គ្នា ប៉ុន្តែច្រើនពាក់ព័ន្ធនឹងជម្លោះដណ្តើមធនធាន ដូចជា សិទ្ធិដីធ្លី និងការបង្ក្រាបសកម្មភាពល្មើសច្បាស់ ដូចជា ការកាប់ឈើ និងបរបាញ់។ សមត្ថភាពពង្រឹងការអនុវត្តច្បាប់មានកម្រិតទាប និងបម្រើឱ្យផលប្រយោជន៍ឯកជន។ ក្នុងនោះ ទាំងសកម្មភាពស្របច្បាប់ (កសិកម្ម ការរុករករ៉ែដោយមានអាជ្ញាប័ណ្ណ) និងសកម្មភាពខុសច្បាប់ (ការកាប់ឈើ) ច្រើនត្រូវបានការពារដោយកងសន្តិសុខប្រដាប់អាវុធឯកជន ដែលអាចជាកងកម្លាំងយោធា។

120. **សេវាមូលដ្ឋាន៖** តំបន់ជនបទមានសាលាបឋមសិក្សា និងមណ្ឌលសុខភាព និងការិយាល័យរដ្ឋបាលឃុំ។ ក្រៅពីនេះ ក៏មានប៉ុស្តិ៍នគរបាលនៅតាមឃុំនីមួយៗផងដែរ។ ដង់ស៊ីតេប្រជាជនទាប ធ្វើឱ្យប្រជាជនត្រូវធ្វើដំណើរផ្លូវឆ្ងាយដើម្បីទៅរកសេវាទាំងនេះ។ ចម្ងាយផ្លូវជាមធ្យមពីភូមិទៅសាលាបឋមសិក្សា (គណនាចេញពីទិន្នន័យក្នុងមូលដ្ឋានទិន្នន័យឃុំ) គឺ ២ គីឡូម៉ែត្រ ប៉ុន្តែមានចម្ងាយជិត ៦ គីឡូម៉ែត្រក្នុងបណ្តាឃុំដែលមានដង់ស៊ីតេប្រជាជនក្រោម ២០ នាក់/គីឡូម៉ែត្រការ៉េ។ ចម្ងាយជាមធ្យមទៅកាន់មណ្ឌលសុខភាពគឺជិត ៩ គីឡូម៉ែត្រ។ សហគមន៍ជនជាតិដើមភាគតិចអាចប្រើប្រាស់សេវានៅសាលាបឋមសិក្សា ប៉ុន្តែមិនសូវអាចប្រើប្រាស់សេវានៅសាលាមធ្យមសិក្សា មណ្ឌលសុខភាព សាលាឃុំ និងសាលាស្រុកទេ។ ដង់ស៊ីតេបណ្តាញផ្លូវក្រាល (កៅស៊ូ បេតុង ឬគ្រួស) មានអត្រាទាបត្រឹមតែ ០,១២ គីឡូម៉ែត្រ/គីឡូម៉ែត្រការេ។

121. ទិន្នន័យក្នុងមូលដ្ឋានទិន្នន័យឃុំបង្ហាញថា គ្រួសារ ៤១% អាចប្រើប្រាស់ប្រភពទឹកដែលមានចម្ងាយ ១៥០ ម៉ែត្រពីផ្ទះពេញមួយឆ្នាំ ប៉ុន្តែតួលេខនេះបានធ្លាក់ចុះមកត្រឹម ២៧% នៅតាមបណ្តាឃុំដែលមានជនជាតិដើមភាគតិចរស់នៅច្រើន និងមានអត្រាត្រឹម ២៦% ក្នុងបណ្តាឃុំដែលមានដង់ស៊ីតេប្រជាជនទាប។ ការផ្គត់ផ្គង់ទឹក (ពីប្រភេទផ្សេងៗ ដូចជា អណ្តូងលូ អណ្តូងរាក់ និងទឹកលើដី) មិនសូវផ្តល់ទឹកពិសាដែលមានគុណភាពទេ។

122. គ្រួសារ ៦៩% ក្នុងខេត្តកំពង់ធំ មានបង្គន់ប្រើប្រាស់ ប៉ុន្តែអត្រានេះមានត្រឹមតែ ៣៣% នៅខេត្តរតនគិរី និង ២៣% នៅតាមឃុំដែលមានជនជាតិដើមភាគតិចរស់នៅច្រើន។ នៅកម្ពុជា គេមិនប្រើប្រាស់បង្គន់សាធារណៈនៅទីជនបទទេ ប៉ុន្តែគេបន្ទោរបង់ពាសវាលពាសកាល។ នៅទីតាំងសម្បទានដីសង្គមកិច្ចបច្ចុប្បន្ន គេសង្កេតឃើញថា ទោះបីជាមានការផ្តល់សម្ភារៈសង់បង្គន់ដល់គ្រួសារនីមួយៗក្តី ប៉ុន្តែភាគច្រើននៃសម្ភារៈទាំងនេះមិនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនេះទេ។ នេះជាចំណុចសំខាន់តែត្រូវកែលម្អក្នុងគម្រោងជំហានទី ៣ តាមរយៈការប្រកាន់ខ្ជាប់ការអនុវត្តល្អបំផុតក្នុងយុទ្ធនាការអនាម័យជនបទ។

123. បណ្តាញអគ្គិសនីត្រូវពង្រីកយ៉ាងឆាប់រហ័ស ហើយគ្រោងនឹងគ្របដណ្តប់ដល់ភូមិទាំងអស់នៅឆ្នាំ ២០២០ (ប៉ុន្តែគ្រួសារយ៉ាងច្រើនប្រហែលជានៅតែគ្មានបណ្តាញអគ្គិសនីប្រើប្រាស់)។ ភាពអាចទុកចិត្តបាននៃការផ្គត់ផ្គង់អគ្គិសនីក៏ជាបញ្ហាចោទផងដែរ។ ទិន្នន័យក្នុងមូលដ្ឋានទិន្នន័យឃុំ (២០១៨) បង្ហាញថា គ្រួសារ ៤៣% ក្នុងបណ្តាខេត្តគោលដៅមានអគ្គិសនីប្រើប្រាស់ ប៉ុន្តែអត្រានេះគឺត្រឹមតែ ២១%-២២% ប៉ុណ្ណោះសម្រាប់ឃុំដាច់ស្រយាល និងឃុំដែលមានជនជាតិដើមភាគតិចរស់នៅច្រើន។ អ្វីដែលអាចទៅរួចគឺគ្រួសារដែលមករស់នៅក្នុងតំបន់សម្បទានដីសង្គមកិច្ច ធ្លាប់ទទួលបានការផ្គត់ផ្គង់អគ្គិសនីនៅទីតាំងចាស់ ប៉ុន្តែបែរជាគ្មានអគ្គិសនីប្រើប្រាស់នៅទីតាំងថ្មីទៅវិញ។

124. ជាទូទៅ បណ្តាញទូរស័ព្ទគឺល្អប្រសើរ ហើយមនុស្សពេញវ័យភាគច្រើនមានទូរស័ព្ទប្រើ។ ការប្រើប្រាស់ទូរស័ព្ទ smartphone (និងបណ្តាញអ៊ីនធឺណិត) កាន់តែមានច្រើនឡើងនៅតំបន់ជនបទ ប៉ុន្តែត្រូវប្រឈមនឹងបញ្ហាដោយសារកង្វះបណ្តាញអគ្គិសនីសម្រាប់មុខងារមួយចំនួន ដូចជា សម្រាប់បញ្ចូលថ្ម។ល។

125. **ភាពគ្មានដីធ្លី និងការទន្ទ្រានកាន់កាប់៖** ច្បាប់ភូមិបាលឆ្នាំ ២០០១ បែងចែកដីធ្លីទាំងអស់នៅកម្ពុជាជាដីសាធារណៈរបស់រដ្ឋ (មិនអាចផ្ទេរកម្មសិទ្ធិបាន) ដីឯកជនរបស់រដ្ឋ (អាចផ្ទេរកម្មសិទ្ធិបាន) និងដីឯកជន។ ប៉ុន្តែគ្មានការវាស់វែងផ្នែកសុរិយោដីឱ្យបានគ្រប់ជ្រុងជ្រោយទេ។ ដូច្នេះអាចមានភាពមិនប្រាកដប្រជាអំពីប្រភេទដីនីមួយៗ។ តាំងពីមុនអំឡុងពេលកើតមានជម្លោះនៅទសវត្សរ៍ឆ្នាំ ១៩៧០ គ្មានការទាមទារដីឯកជនគួរឱ្យកត់

សម្គាល់ទេ។ កម្មសិទ្ធិដីឯកជនភាគច្រើនលើដីកសិកម្មប្រពៃណី (មិនគិតដីដែលទើបតែត្រូវបានបម្លែងពីព្រៃឈើ ឬតំបន់ដីសើម) គឺទទួលបានពីការបែងចែកដីកាលពីឆ្នាំ ១៩៨៩។ ការបែងចែកនេះបានផ្តល់សិទ្ធិប្រើប្រាស់ដីធ្លីជាលក្ខណៈគ្រួសារនៅជនបទ ប៉ុន្តែមិនមែនសុទ្ធតែជាកម្មសិទ្ធិផ្លូវការនោះទេ។ ពេលគឺមានដីកសិកម្មភាគតិចប៉ុណ្ណោះដែលមានប័ណ្ណកម្មសិទ្ធិផ្លូវការ ចំណែកដីកសិកម្មភាគច្រើនមានប័ណ្ណកម្មសិទ្ធិក្រៅផ្លូវការដែលចេញដោយអាជ្ញាធរមូលដ្ឋាន (ប្លង់ទន់) ដែលអាចប្រើប្រាស់សម្រាប់ដាក់បញ្ចាំខ្ចីប្រាក់ និងអាចជួញដូរ បាន។ ម្ចាស់ដីដែលពាក់ព័ន្ធនឹងការបែងចែកដីកាលពីឆ្នាំ ១៩៨៩ តែងយល់ថា ការកាន់កាប់របស់ខ្លួនមានសន្តិសុខ។ តាំងពីឆ្នាំ ១៩៨៩ រហូតមកទល់បច្ចុប្បន្ន ផ្ទៃដីយ៉ាងច្រើននៃដីព្រៃពីមុន ជាពិសេសផ្ទៃដីក្នុងបណ្តាខេត្តគោលដៅនៃគម្រោងជំហានទី ៣ ត្រូវបានបម្លែងសម្រាប់ការប្រើប្រាស់កសិកម្មក្រោមការរៀបចំចម្រុះ ដូចជា ១) សម្បទានដីសេដ្ឋកិច្ចដែលចេញដោយរដ្ឋាភិបាលថ្នាក់ជាតិ ឬខេត្ត ២) សម្បទានដីសង្គមកិច្ច ៣) ដីសម្រាប់លំនៅដ្ឋាន ឬទទួលបានដោយគ្មានការផ្ទេរស្របច្បាប់ ប៉ុន្តែក្នុងករណីភាគច្រើនមានការទទួលស្គាល់បែបអសកម្មពីអាជ្ញាធរមូលដ្ឋាន។ ច្បាប់ភូមិបាលបានផ្តល់សិទ្ធិឱ្យជនជាតិដើមភាគតិចកាន់កាប់ជាសមូហភាពលើដីប្រពៃណីរបស់ខ្លួន។ ព្រំប្រទល់មិនត្រូវបានកំណត់ច្បាស់ និងជាហេតុធ្វើឱ្យមានការទាមទារត្រួតគ្នា និងការកាន់កាប់ ឬប្រើប្រាស់ដីធ្លីដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់។ យុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីក្រោម "សេចក្តីសម្រេចលេខ ០១" របស់លោកនាយករដ្ឋមន្ត្រី (២០១២) គឺជាការប៉ុនប៉ងដោះស្រាយទំនាស់ដីធ្លីដែលកើនឡើងជាលំដាប់ តាម រយៈការចុះវាស់វែង និងចុះបញ្ជីដីធ្លីដែលជាកម្មសិទ្ធិក្រៅផ្លូវការ ប៉ុន្តែមិនអាចដោះស្រាយបញ្ហានេះបានទាំងស្រុងឡើយ។

126. ការបែងចែកដីធ្លីឆ្នាំ ១៩៨៩ ហាក់ធ្វើឡើងប្រកបដោយសមធម៌ បើធៀបនឹងចំនួនគ្រួសារដែលមាននៅពេលនោះ និងធ្វើឱ្យមានការបែងចែកដីធ្លីដោយសមភាព។ ការអនុវត្តដូច្នេះបានផ្លាស់ប្តូរ និងធ្វើឱ្យគ្រួសារកាន់តែច្រើនក្លាយជាអ្នកគ្មានដីធ្លី ឬមានដីធ្លីតិចតួច (គ្មានដីធ្លីគ្រប់គ្រាន់សម្រាប់ធ្វើស្រែទុកបរិភោគក្នុងគ្រួសារ)។ កត្តារួមចំណែកមានជាអាទិ៍ ក) ការវិលត្រឡប់របស់គ្រួសារជនភៀសខ្លួននៅអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ ដែលជាទូទៅមិនអាចទទួលបានដីកសិកម្មគ្រប់គ្រាន់ ខ) ការលក់ដីធ្លី រួមទាំងការលក់ដោយសារជាប់បំណុល ឬវិបត្តិគ្រួសារ និង គ) កំណើនប្រជាជន និងការកកើតគ្រួសារថ្មី។ ការដកហូតដោយផ្ទាល់តាមផ្លូវច្បាប់ហាក់មានចំនួនតិចតួច។

127. គ្រួសារប្រមាណ ២១% ក្នុងបណ្តាខេត្តគោលដៅមានប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការ (ប្លង់រឹង)។ ក្នុងនោះសេចក្តីរាយការណ៍បង្ហាញថា គ្រួសារប្រមាណ ១៤% ជាគ្រួសារកសិករដែលគ្មានដីស្រែ និងគ្រួសារ ១៣% ទៀតជាគ្រួសារកសិករដែលមានដីស្រែតិចជាង ១ ហិចតា (ទំហំដីដែលគ្រួសារអាចធ្វើស្រែសម្រាប់សល់ផលច្រើនទុកលក់ ដោយសន្មតការដាំដុះតែម្តង/ឆ្នាំ)

128. យោងតាមទិន្នន័យក្នុងមូលដ្ឋានទិន្នន័យឃុំ ដីធ្លី ៦% នៃដីធ្លីសរុបក្នុងបណ្តាខេត្តគោលដៅ ជាដីលំនៅដ្ឋាន, ១១% ជាដីស្រែ និង ១២% ជាដីដាំដំណាំមិនមែនស្រូវរយៈពេលខ្លី និងរយៈពេលវែង។ ដីនៅសល់ ៧០% ទៀតជាដៃព្រៃ ប៉ុន្តែមួយចំនួនតូចនៃដីនេះនៅតែជាព្រៃធម្មជាតិដែលគ្មានមនុស្សប៉ះពាល់។ តារាងមួយក្នុងសៀវភៅស្ថិតិប្រចាំឆ្នាំ ២០១១ របស់កម្ពុជាបង្ហាញថា មានតំបន់ការពារធម្មជាតិ ១៣ ដែលស្ថិតនៅទាំងស្រុង ឬមួយផ្នែកក្នុងបណ្តាខេត្តគោលដៅ (ទំហំសរុប ៣៩.៤៥២ គីឡូម៉ែត្រការេ ឬប្រមាណ ៥០% នៃទំហំផ្ទៃដីសរុប)។ ប្រសិទ្ធភាពនៃការការពារប្រែប្រួលដូចកម្រិតនៃការការពារដោយច្បាប់ដែរ (សកម្មភាពខ្លះអាច

អនុញ្ញាតឱ្យធ្វើទៅបានក្នុងតំបន់ទ្រនាប់) ហើយគេដឹងថា តំបន់ការពារធម្មជាតិត្រូវបានទន្ទ្រានកាន់កាប់ដើម្បីផលប្រយោជន៍កសិកម្ម និងអាជីវកម្មផ្សេងទៀត។

129. **អាកាសធាតុ៖** តំបន់ភាគឦសាននៃប្រទេសកម្ពុជារងឥទ្ធិពលខ្យល់មូសុងត្រូពិច ដែលរដូវវស្សាគឺចាប់ពីខែឧសភា ដល់ខែ តុលា)។ តំបន់ខ្ពស់រាបនៃខេត្តមណ្ឌលគិរី និងរតនគិរី សំបូរភ្លៀងធ្លាក់ និងមានធាតុអាកាសត្រជាក់នៅពេលយប់ជាងតំបន់ផ្សេងទៀតក្នុងប្រទេស។

130. **ធនធានទឹក** ក្នុងបណ្តាខេត្តគោលដៅ ពឹងផ្អែកលើទឹកភ្លៀង និងលំហូរទឹកទន្លេពីប្រទេសឡាវ និងវៀតណាម។ លំហូរទឹកទាំងនេះផ្តល់បរិមាណទឹកសាបកកើតឡើងវិញប្រមាណ ៧៥% សម្រាប់ប្រទេសកម្ពុជាទាំងមូល។ នៅអំឡុងរដូវប្រាំងឆ្នាំនេះ (ឆ្នាំ ២០១៩-២០២០) កម្រិតទឹកក្នុងប្រព័ន្ធទន្លេមេគង្គបានធ្លាក់ចុះដល់កម្រិតទាបបំផុតមិនធ្លាប់មានពីមុនមក ដែលបណ្តាលមកគ្រោះរាំងស្ងួត និងផលប៉ះពាល់ដោយសារការសាងសង់ទំនប់នៅខ្សែទឹកខាងលើ និងតាមដៃទន្លេ។ ជាទូទៅ សហ គមន៍មូលដ្ឋានមិនប្រឈមនឹងការខ្វះខាតទឹកទាំងស្រុងនោះទេ ប៉ុន្តែអាចមានទម្លាប់ពឹងផ្អែកលើទឹកទន្លេ និងស្ទឹងបឹងបួរសម្រាប់គោលបំណងគ្រប់បែបយ៉ាងរួមទាំងការពិសា ៖ ប្រភពទឹកទាំងនេះងាយរងគ្រោះបំផុតដោយសារការបំផ្លិចបំផ្លាញដែលបណ្តាលមកពីការទាញយកផលហួសកម្រិត និងការបំពុលនៅខ្សែទឹកខាងលើ។ គេអាចទាញយកទឹកក្រោមដីដោយជីកអណ្តូងលូនៅតំបន់ភាគច្រើន និងអណ្តូងរាក់នៅតាមតំបន់មួយចំនួន។ ទឹកចេញពីសិលាជ្រាបទឹកនៅស្រទាប់ដីជ្រៅ អាចមានកម្រិតសារធាតុអាសេនិកដែលបង្កគ្រោះថ្នាក់ ជាពិសេសក្នុងតំបន់ដែលស្ថិតនៅជិតទន្លេមេគង្គ។ ការប្រមូលទឹកភ្លៀងធ្វើឡើងជាទូទៅ ប៉ុន្តែត្រូវមានសមត្ថភាពខ្ពស់ និងការគ្រប់គ្រងដោយប្រុងប្រយ័ត្នដើម្បីផ្តល់ការផ្គត់ផ្គង់ទឹកពេញមួយឆ្នាំ។

131. **ការសាងសង់ទំនប់វារីអគ្គិសនី** បានបង្កផលប៉ះពាល់អវិជ្ជមានលើសហគមន៍នៅខ្សែទឹកខាងក្រោម រួមទាំងផលប៉ះពាល់ឆ្លងដែនដោយសារទំនប់ដែលស្ថិតក្នុងប្រទេសវៀតណាម។ ផលប៉ះពាល់អវិជ្ជមាន (ក្រៅពីការតាំងទីលំនៅថ្មីចេញពីតំបន់អាងស្តុកទឹក) រួមមានផលប៉ះពាល់លើការរកបាន និងគុណភាពទឹក សត្វព្រៃ និងបរិមាណត្រី និងផលប៉ះពាល់ដោយសារការបើកទ្វារទំនប់បង្ហូរទឹកចេញភ្លាមៗ។

132. **បរិយាស្ថានជីវសាស្ត្រ ៖** តំបន់ភាគឦសាននៃប្រទេសកម្ពុជាគឺជាតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសម្រាប់ជីវៈចម្រុះ និងពូជសត្វកម្រ ប៉ុន្តែតំបន់ទាំងនេះរងសម្ពាធពីការកាប់ឈើមូល និងការអភិវឌ្ឍ និងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ។ សហគមន៍ជនជាតិដើមភាគតិចជាច្រើន និងទីតាំងសម្បទានដីសង្គមកិច្ចមួយចំនួនស្ថិតនៅជិតតំបន់ដែលសំបូរដោយជីវចម្រុះ (មើលឧបសម្ព័ន្ធ ២ នៃ ESP)។ សហគមន៍រស់នៅក្នុងតំបន់ព្រៃ ជាពិសេសសហគមន៍ដែលមិនសូវមានដីផលិតកម្មកសិកម្ម ឬស្ថិតនៅដាច់ស្រយាលពីទីផ្សារកសិកម្ម ច្រើនពឹងផ្អែកលើផលិតផលព្រៃឈើដើម្បីប្រកបរបរចិញ្ចឹមជីវិត។ ក្រៅពីសកម្មភាពស្របច្បាប់ ដូចជា ការប្រមូលអនុផលព្រៃឈើ សម្ពាធសេដ្ឋកិច្ចអាចធ្វើឱ្យមានសកម្មភាពកាប់ឈើខុសច្បាប់ជាច្រើន និងការជួញដូរសត្វព្រៃរួមទាំងពពួកសត្វជិតផុតពូជ (ឧ.ពង្រូល)។ ការជុតយកត្បូងកើតមានជាទូទៅរួមទាំងនៅតាមទីតាំងសម្បទានដីសង្គមកិច្ចបច្ចុប្បន្នមួយចំនួន និងអាចបង្កជាការបំផ្លិចបំផ្លាញបរិស្ថានយ៉ាងខ្លាំង។

133. **ការព្យាករណ៍ពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ ៖** ការប្រែប្រួលអាកាសធាតុត្រូវបានព្យាករណ៍ថានឹងបង្កផលប៉ះពាល់យ៉ាងខ្លាំងលើប្រព័ន្ធទន្លេមេគង្គ ធ្វើឱ្យរដូវប្រាំងកាន់តែហួតហែង និងអូសបន្លាយ ហើយរដូវវស្សាកាន់តែជោរជន់ និងបង្កជាកំណើនសីតុណ្ហភាព និងការកើនឡើងនៃភាពញឹកញាប់ និង

អាំងតង់ស៊ីតេនៃព្រឹត្តិការណ៍ធ្ងន់ធ្ងរ។ ការរៀបចំផែនការបន្សាំនឹងការ ប្រែប្រួលអាកាសធាតុនៅមូលដ្ឋាន ហាក់ផ្ដោតលើគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ប៉ុន្តែផលប៉ះពាល់នៃកំណើនសីតុណ្ហភាពអាចចោទជាបញ្ហាខ្លាំងក្នុងរយៈពេលវែង និងអាចធ្វើឱ្យទិន្នផលដំណាំថយចុះ កើតសត្វចង្រៃច្រើន និងជំងឺសត្វ និងកំណើននៃការឆ្លងជំងឺមនុស្សមួយចំនួន។ ហានិភ័យគ្រោះ អគ្គីភ័យអាចបង្កឡើងដោយកំណើនសីតុណ្ហភាព។ កសិករយល់ថា អាកាសធាតុកាន់តែប្រែប្រួលមិនទៀង ហើយនេះជាបញ្ហាចោទ។ ឧ. កសិករពន្យារពេលដាំដុះព្រោះត្រូវចាំរហូតដល់មានទឹកភ្លៀងគ្រប់គ្រាន់តាំងពីដំបូងសម្រាប់វដ្តដំណាំ ប៉ុន្តែក្រោយមក ពួកគេងាយប្រឈមនឹងការបំផ្លិចបំផ្លាញដោយសារទឹកជំនន់។ ការព្យាករណ៍បង្ហាញថា តំបន់ភាគឦសានរបស់កម្ពុជានឹងរងគ្រោះដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុកាន់តែខ្លាំងឡើង។

134. **ការកាប់បំផ្លាញព្រៃឈើ ៖** តំបន់ភាគឦសានរបស់កម្ពុជាប្រឈមនឹងការបាត់បង់គម្របព្រៃធម្មជាតិយ៉ាងលឿនក្នុងរយៈពេលប៉ុន្មានទសវត្សរ៍នេះ។ ការធ្វើអាជីវកម្មឈើមូលទ្រង់ទ្រាយធំ ត្រូវបានហាមឃាត់រយៈពេល ១៥ ឆ្នាំ ប៉ុន្តែច្បាស់ណាស់ថា សកម្មភាពកាប់ឈើជាច្រើននៅតែបន្ត មិនថាធ្វើឡើងដោយខុសច្បាប់ ឬស្ថិតក្រោមការរៀបចំការកាប់ឆ្ការសម្រាប់សម្បទានដីសេដ្ឋកិច្ចនោះទេ។

135. **ការរុករករ៉ែ ៖** តំបន់ភាគឦសានរបស់កម្ពុជាមានធនធានរ៉ែមាស និងធនធានរ៉ែផ្សេងទៀត។ បច្ចុប្បន្នមានសកម្មភាពចុះរុករក និងធ្វើអាជីវកម្មធនធានទាំងនេះកាន់តែច្រើនឡើង រួមទាំងសម្បទានដែលទទួលបានដោយក្រុមហ៊ុនរុករករ៉ែអន្តរជាតិ ប្រតិបត្តិការដែលគ្មានលិខិតស្នាមច្បាស់ លាស់ ប៉ុន្តែមានទ្រង់ទ្រាយធំដែលគ្រប់គ្រងដោយជនជាតិខ្មែរ និងការរុករករ៉ែសម្រាប់សិប្បកម្ម (ច្រើនតែខុសច្បាប់ ឬពាក់កណ្តាលស្របច្បាប់)។ សកម្មភាពរុករករ៉ែបានបង្កជាជម្លោះជាមួយសហគមន៍នៅជិតទីតាំងរុករករ៉ែ ពាក់ព័ន្ធនឹងការដណ្តើមដីធ្លី និងការចោទប្រកាន់ពីករណីបំពុលទឹក។

136. **ប្រភពបំពុល ៖** មានរបាយការណ៍ស្តីពីការបំពុលទឹកទន្លេ និងស្ទឹងបឹងបួរ ដោយសារជាតុគីមីដែលគេប្រើប្រាស់ក្នុងសកម្មភាពរុករករ៉ែ (ឧ. Cyanide) និងសារជាតុគីមីពីការធ្វើកសិកម្មក្នុងចម្ការធំៗដែលហូរចូលក្នុងទឹក។ គ្មានព័ត៌មានលម្អិតស្តីពីករណីទាំងនេះទេ ប៉ុន្តែវាជាបញ្ហាដែលអាចបង្ក ហានិភ័យចំពោះសហគមន៍នៅខ្សែទឹកខាងក្រោម។ យ៉ាងណាមិញ នៅតែមានការអភិវឌ្ឍឧស្សាហកម្មតិចតួចក្នុងបណ្តាខេត្តគោលដៅ ទោះបីជាខេត្តទាំងនេះមានរោងចក្រកែច្នៃផលិតផលកសិកម្មធំៗក្តី។ ការគ្រប់គ្រងសំណល់រឹងមានតែនៅទីប្រជុំជនធំៗ ប៉ុន្តែគ្មានសកម្មភាពនៅកន្លែងផ្សេងទៀតទេ។ ចំណុចនេះធ្វើឱ្យមានការបំពុលដី និងប្រភពទឹកក្នុងមូលដ្ឋាន។

# ៤.ហានិភ័យ និងផលប៉ះពាល់របស់គម្រោងលើបរិស្ថាន និងសង្គម

## ៤.១ វិធីសាស្ត្រ

137. ជំពូកនេះកំណត់ពីហានិភ័យបរិស្ថាន និងសង្គមដែលអាចកើតឡើងក្នុងពេលអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជំហានទី ៣ (LASED III)។ សម្រាប់វិធានការ ប្រុងប្រយ័ត្ន ជំពូកនេះលើកឡើងពីហានិភ័យដែលមិនងាយនឹងកើតឡើង ដោយផ្អែកលើបទពិសោធន៍ពីគម្រោងជំហានដំបូង និងគម្រោងជំហានទី ២ ប៉ុន្តែជាហានិភ័យដែលមិនអាចមើលរំលងបាន និងផលប៉ះពាល់ដែលអាចកើតមានឡើងដោយសារហានិភ័យដែលងាយនឹងកើតឡើង។ ការវិភាគហានិភ័យត្រូវបានធ្វើឡើងបន្តពីជំពូកមុនៗ ដើម្បី

កំណត់រកមេរៀនពីគម្រោងជំហានដំបូង/ជំហានទី ២ និងផ្អែកលើសាវតារបរិស្ថាន និងសង្គមរបស់បណ្តាខេត្តគោលដៅអាទិភាព។

138. ការវិភាគហានិភ័យត្រូវបានធ្វើឡើងទៅតាមបទដ្ឋានបរិស្ថាន និងសង្គមដែលផ្តោតទាំងលើផ្នែកបរិស្ថាន និងផ្នែកសង្គម។ ដូច្នេះ ការវិភាគហានិភ័យនឹងផ្តោតលើផ្នែកទាំងពីរនេះតែម្តង។

139. ក្របខណ្ឌគ្រប់គ្រងហានិភ័យត្រូវបានពណ៌នាលម្អិត (ក្នុងជំពូក ៥) ដោយបង្ហាញពីនីតិវិធីចាំបាច់សម្រាប់ការកំណត់រក និងគ្រប់គ្រងហានិភ័យបរិស្ថាន និងគម្រោងនៅកម្រិតគម្រោង កម្រិតទីតាំង និងកម្រិតអនុគម្រោង។ វិធានការកាត់បន្ថយហានិភ័យដែលបន្សុីគ្នានឹងគោលការណ៍សមាមាត្រ និងឋានានុក្រមនៃការកាត់បន្ថយផលប៉ះពាល់ មានបង្ហាញក្នុងតារាង ១១ នៅផ្នែកបញ្ចប់នៃជំពូកនេះ។

## ៤.២ ហានិភ័យបរិស្ថាន និងសង្គមដែលអាចកើតឡើង

140. គម្រោងជំហានទី៣[6] បានកំណត់ថា ផលប៉ះពាល់ និងហានិភ័យបរិស្ថាន និងសង្គមធំៗ និងអាចកើតមានឡើងក្នុងគម្រោងជំហានទី ៣ អាចបណ្តាលមកពី ក) ដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីដែលបង្កផលប៉ះពាល់លើជីវចម្រុះ ព្រោះទីតាំងគម្រោងថ្មីដែលស្នើឡើងអាចរួមបញ្ចូល ឬស្ថិតនៅជិតតំបន់ដែនជម្រកធម្មជាតិសំខាន់ៗ។ ចំណុចនេះអាចជាលក្ខណៈវិនិច្ឆ័យផាត់ចេញក្នុងដំណើរការពិនិត្យបឋម ខ) ផលប៉ះពាល់ ឬហានិភ័យពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងសកម្មភាពសាងសង់ ដូចជា សំឡេងរំខាន ធូលីហុយ កំទេចកំទី សំណឹក ការបោះចោលកាកសំណល់ ការគ្រប់គ្រងទឹកភ្លៀងជន់លិច សុខភាព និងសុវត្ថិភាពរបស់សហគមន៍ និងកម្មករ និង គ) ការអភិវឌ្ឍរបរចិញ្ចឹមជីវិត និងកសិកម្ម ដែលអាចបង្កផលប៉ះពាល់លើសុខភាព និងសុវត្ថិភាពរបស់សហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោងក្នុងអំឡុងវដ្តគម្រោង ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់ និងការរៀបចំទុកដាក់ថ្នាំសម្លាប់សត្វល្អិត និងជីគីមីឱ្យបានសមស្រប/សុវត្ថិភាព។ គម្រោងជំហានទី ៣ នឹងមិនផ្តល់ហិរញ្ញប្បទានសម្រាប់ការទិញថ្នាំសម្លាប់សត្វល្អិត និងជីគីមីទេ ប៉ុន្តែការផ្លាស់ប្តូរកម្មសិទ្ធិដីធ្លីអាចជំរុញឱ្យកសិករថ្មីប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត។ ផលប៉ះពាល់បរិស្ថានអាចកើតចេញពីការប្រើប្រាស់ថង់ផ្លាស្ទិកយ៉ាងច្រើនសម្រាប់បណ្តុះរុក្ខជាតិ/កូនដំណាំ/គ្រាប់ពូជ។

141. គម្រោងជំហានទី ៣ បានកំណត់ថា ផលប៉ះពាល់ និងហានិភ័យអវិជ្ជមានដែលអាចកើតឡើងក្នុងគម្រោង អាចបណ្តាលមកពីប្រភេទ និងទំហំនៃសកម្មភាពគម្រោង ដូចជា តំបន់ងាយរងគ្រោះ (ឧ. សហគមន៍ជនជាតិដើមភាគតិច)។ គួរកត់សម្គាល់ថា "ការរឹតត្បិតលើលទ្ធភាពប្រើប្រាស់ធនធានដីធ្លី ធម្មជាតិ និងវប្បធម៌ដែលបណ្តាលមកពីសកម្មភាពទាំងនេះ អាចផលប៉ះពាល់លើរបរចិញ្ចឹមជីវិតដែលពឹងផ្អែកលើធម្មជាតិ និងសិទ្ធិកាន់កាប់របស់គ្រួសារ និងសហគមន៍ងាយរងគ្រោះ ឬជួបការលំបាក ក្នុងករណីដែលសេចក្តីសម្រេចមិនត្រូវបានធ្វើឡើងដោយមានការចូលរួម។ ផលប៉ះពាល់សង្គមអវិជ្ជមានដែលអាចកើតឡើងដោយសារគម្រោង និងវិធានការកាត់បន្ថយផលប៉ះពាល់ អាចបង្កជាជម្លោះក្នុងសង្គម ឬគ្រោះថ្នាក់ដល់ផ្នែកមួយចំនួននៃសហគមន៍រងផលប៉ះពាល់[7]"។

[6] សូមមើលផងដែរ ខ្លឹមសារសង្ខេបស្តីពីការពិនិត្យឡើងវិញលើទស្សនាទានបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក (ESRS)។

[7] ខ្លឹមសារសង្ខេបស្តីពីការពិនិត្យឡើងវិញលើបរិស្ថាន និងសង្គម

142. បទពិសោធន៍ពីគម្រោងដំហានដំបូង និងដំហានទី ២ បានផ្តល់មូលដ្ឋានចំណេះដឹងយ៉ាងរឹងមាំសម្រាប់ការប៉ាន់ប្រមាណហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងដំហានទី ៣ ព្រោះហានិភ័យទាំងនោះនឹងមានវិសាលភាពប្រហាក់ប្រហែលគ្នា ប៉ុន្តែគម្រោងថ្មីនឹងផ្តោតបន្ថែមលើទីតាំងសម្រាប់ការ ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ចាំបាច់ត្រូវពិចារណាពីលទ្ធភាពដែលការផ្លាស់ប្តូរផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គមអាចធ្វើឱ្យហានិភ័យមួយចំនួនកាន់តែបង្កការព្រួយបារម្ភ។ ក្របខណ្ឌបរិស្ថាន និងសង្គមតម្រូវឱ្យមានការពិចារណាពីហានិភ័យជាច្រើនដែល ត្រូវបានលើកមកពិចារណាក្រោមក្របខណ្ឌគោលនយោបាយការពារសុវត្ថិភាព OP/BP ដែលជាមូលដ្ឋាននៃការរៀបចំគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

143. ក្នុងកថាខណ្ឌខាងក្រោម ហានិភ័យត្រូវបានកំណត់ឡើងចេញពីសកម្មភាពសំខាន់ៗរបស់គម្រោង ដូចជា ១) ការកំណត់អត្តសញ្ញាណដី ការគូសផែនទី និងការផ្តល់ប័ណ្ណកម្មសិទ្ធិលើដីរដ្ឋសម្រាប់ទីតាំងសម្បទានដីសង្គមកិច្ច ២) ដំណើរការបែងចែកដីនៅទីតាំងសម្បទានដីសង្គមកិច្ច ៣) ការតាំងទីលំនៅថ្មីរបស់អ្នកទទួលបានដីធ្លីពីសម្បទានដីសង្គមកិច្ចនៅតាមទីតាំងទាំងនោះ ៤) ការកំណត់ អត្តសញ្ញាណដីសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ការគូសផែនទី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ ៥) អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានហានិភ័យជាក់លាក់ពាក់ព័ន្ធនឹង ក) អនុគម្រោងផ្លូវថ្នល់ និង ខ) អនុគម្រោងធារាសាស្ត្រ និង ៦) អនុគម្រោង គាំទ្រវបរចិញ្ចឹមជីវិតកសិកម្ម។ លក្ខណៈ និងទំហំនៃផលប៉ះពាល់បរិស្ថានសំខាន់ៗ និងវិធានការដោយផ្អែកតាមការបែងចែកប្រភេទគម្រោង និងបទដ្ឋានបរិស្ថាន និងសង្គមមានសង្ខេបក្នុងឧបសម្ព័ន្ធ ៧។

144. គម្រោងប្រើប្រាស់ប្រព័ន្ធធម្មតាបែបគុណភាពមួយ ដើម្បីកំណត់ប្រភេទនៃកម្រិតផលប៉ះពាល់របស់ហានិភ័យ (មើលតារាង ៤-១០)។ នេះជាពាក្យដែលមិនចង់ប្រើ ព្រោះវាអាចធ្វើឱ្យច្រឡំនឹងពាក្យដែលធនាគារពិភពលោកប្រើសម្រាប់ការកំណត់ផ្លូវការលើកម្រិតហានិភ័យរបស់គម្រោង។ ក្នុងប្រព័ន្ធនេះ កម្រិតទី ១ សម្គាល់ផលប៉ះពាល់អាក្រក់បំផុត និងគួរកាត់បន្ថយជាអតិបរមា។ កម្រិតទី ២ គឺផលប៉ះពាល់ធ្ងន់ធ្ងរ និងយូរអង្វែងលើបុគ្គល គ្រួសារ ឬសហគមន៍ ឬនិរន្តរភាពនៃអត្ថប្រយោជន៍ គម្រោង។ កម្រិតទី ៣ សម្គាល់ផលប៉ះពាល់ដែលអាចមានទ្រង់ទ្រាយធំ (ប៉ះពាល់ដល់បុគ្គល គ្រួសារ ឬសហគមន៍ជាច្រើន) ធ្ងន់ធ្ងរ និងយូរអង្វែង និងអាចគំរាមកំហែងដល់ភាពអាចអនុវត្តបាននៃគម្រោងទាំងមូល។

145. គម្រោងប្រើប្រាស់ប្រព័ន្ធស្រដៀងគ្នាមួយដើម្បី កំណត់ប្រភេទលទ្ធភាពនៃការកើតមានព្រឹត្តិការណ៍ដែលបង្កជាផលប៉ះពាល់។ "អាចកើតឡើង និងត្រូវមានវិធានការបញ្ចៀស" សម្គាល់ព្រឹត្តិការណ៍ដែលបង្កជាផលប៉ះពាល់ ដែលមិនរំពឹងថានឹងកើតឡើងក្នុងពេលអនុវត្តគម្រោង ប៉ុន្តែលទ្ធភាពនៃការកើតឡើងគឺខ្ពស់គ្រប់គ្រាន់ក្នុងការទាមទារឱ្យមានការបញ្ចៀស និង/ឬវិធានការកាត់បន្ថយ។ ប្រសិនបើមានការពិនិត្យបឋម និងវិធានការបញ្ចៀសហានិភ័យ លទ្ធភាពបន្ទាប់បន្សំនៃការកើតមានព្រឹត្តិការណ៍ទាំងនេះ និងបង្កជាផលប៉ះពាល់ នឹងមានទំហំតូច។ "ងាយនឹងកើតឡើង និងត្រូវមានវិធានការកាត់បន្ថយ" សម្គាល់ព្រឹត្តិការណ៍ដែលងាយ ឬរំពឹងថានឹងកើតឡើងក្នុងពេលអនុវត្តគម្រោង និងចាំបាច់ត្រូវមានវិធានការកាត់បន្ថយផលប៉ះពាល់។

## ៤.៣ ហានិភ័យបរិស្ថាន និងសង្គមដែលរកឃើញ

### ៤.៣.១ បទដ្ឋានបរិស្ថាន និងសង្គមទី ១ ៖ ការវាយតម្លៃ និងគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ បរិស្ថាន និងសង្គម

146. នៅពេលរៀបចំក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម គេមិនបានដឹងពីខ្លឹមសារលម្អិតនៃទីតាំងគម្រោង ជំហានទី ៣ ទេ។ ដូច្នេះ ប្រហែលជា ១) ហានិភ័យបន្ថែមទៀត (ដែលមិនបានកំណត់រកក្នុងផ្នែកនេះ) អាចកើតឡើងនៅតាមទីតាំងមួយចំនួន ឬ ២) វិធានការកាត់បន្ថយសមស្របនៅទីតាំងណាមួយអាចខុសពីវិធានការទូទៅដែលលើកឡើងក្នុងផ្នែកនេះ។ ហេតុនេះ នៅពេលចាប់ផ្តើមសកម្មភាពនៅតាមទីតាំងសម្បទានដីសង្គមកិច្ច ឬទីតាំងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗ គម្រោងនឹងធ្វើការពិនិត្យបឋម និងវាយតម្លៃហានិភ័យនៃទីតាំងដែលលើកឡើង ហើយនឹងបញ្ចូលផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង ដែលមានបង្ហាញក្នុងឧបសម្ព័ន្ធ ៤។

147. ដោយពិចារណាពីលក្ខណៈរបស់គម្រោង ដែលអាចបង្កផលប៉ះពាល់យ៉ាងច្រើនពីសកម្មភាពចម្រុះក្នុងតំបន់ណាមួយ (តំបន់ប្រជុំជន តំបន់ជនបទ ទីជម្រាល តំបន់ឆ្នេរ។ល។) ប្រហែលជាត្រូវមានការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមដោយផ្អែកលើលទ្ធផលនៃការពិនិត្យបឋម។ ប្រសិន បើគម្រោងធ្វើការវាយតម្លៃនេះនៅថ្នាក់តំបន់ លទ្ធផលពីការវាយតម្លៃនឹងត្រូវបានដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង។ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមថ្នាក់តំបន់គួររួមមាន ៖

- ក) ការវាយតម្លៃពីហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមសំខាន់ៗ ដែលពាក់ព័ន្ធនឹងការរៀបចំផែនការប្រើប្រាស់ដីក្នុងទីតាំងគម្រោង ដូចជា ១) លក្ខខណ្ឌនៃការផ្គត់ផ្គង់ទឹក និងការអភិរក្សគុណភាព និងបរិមាណទឹកលើដី/ក្រោមដី ២) ការគ្រប់គ្រងការប្រមូល និងបោះចោលកាកសំណល់ (វិធីសាស្ត្រថ្នាក់តំបន់នឹងត្រូវបានបង្កើតឡើង) ៣) ការរៀបចំផែនការដឹកជញ្ជូនដោយគិតគូរពីសុខភាព និងសុវត្ថិភាពរបស់សហគមន៍។
- ខ) ការវាយតម្លៃជម្រើស និងលើកឡើងពីវិធានការយ៉ាងច្រើនដើម្បីពង្រឹងការគ្រប់គ្រងបរិស្ថាន និងសង្គម។

148. ការអនុវត្តសកម្មភាពគម្រោង ជាពិសេសការអភិវឌ្ឍសម្បទានដីសង្គមកិច្ចដែលធ្វើឱ្យមាន បំលាស់ទី និងការតាំងទីលំនៅរបស់ប្រជាជនសំខាន់ៗ អាចបង្កផលប៉ះពាល់លើក្រុមងាយរងគ្រោះ និងក្រុមមិនទទួលបានការយកចិត្តទុកដាក់ដែលមានវត្តមានក្នុងតំបន់គម្រោង ក្រៅពីផលប៉ះពាល់ដែលបានព្យាករក្នុងឯកសារនេះ។ ដូច្នេះ នៅពេលរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម គម្រោងនឹងកំណត់អត្តសញ្ញាណក្រុមងាយរងគ្រោះ និងក្រុមមិនទទួលបានការយកចិត្តទុកដាក់ ធានាការពិគ្រោះយោបល់ជាមួយពួកគេ កំណត់រកផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើង និងដាក់បញ្ចូលវិធានការកាត់បន្ថយផលប៉ះពាល់ក្នុងផែនការនេះ។

149. គម្រោងអាចនឹងគាំទ្រដល់ការផ្លាស់ប្តូរសិទ្ធិកាន់កាប់ដីធ្លី និងការប្រើប្រាស់ដីនៅទីតាំងសំខាន់ៗ។ កត្តានេះអាចបង្កផលប៉ះពាល់លើលទ្ធភាពរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ដី និងធនធានធម្មជាតិ។ ផលប៉ះពាល់ទាំងនេះមិនកើតឡើងដោយផ្ទាល់ពីលទ្ធកម្មដីធ្លីទេ (ឧ.ការបាត់បង់លទ្ធភាពចេញចូលតំបន់នានាដើម្បីយកសត្វទៅស៊ីស្មៅ ប្រមូលអនុផលព្រៃឈើ ឬនេសាទ ផលប៉ះពាល់លើធនធានទឹក ផលប៉ះពាល់លើលទ្ធភាពចេញចូលដោយសារការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ)។ ផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងទាំងនេះនឹង

ត្រូវលើកមកពិចារណាក្នុងការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។ គម្រោងនឹងពិគ្រោះយោបល់ជាមួយក្រុមទទួលរងផលប៉ះពាល់អវិជ្ជមាន និងអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ឱ្យបានសមស្រប។

150. គម្រោងនឹងធានាការអនុលោមតាមតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមរបស់ក្រុមហ៊ុនម៉ៅការដែលធ្វើការក្នុងគម្រោង តាមរយៈ ៖

- ក) ការវាយតម្លៃហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមដែលពាក់ព័ន្ធនឹងកិច្ចសន្យា ជាពិសេសអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ
- ខ) ការបញ្ជាក់ថា ក្រុមហ៊ុនម៉ៅការដែលពាក់ព័ន្ធក្នុងគម្រោង ជាសហគ្រាសស្របច្បាប់ និងអាចទុកចិត្តបាន និងមានចំណេះដឹង និងជំនាញក្នុងការបំពេញកិច្ចការក្នុងគម្រោងដោយអនុលោមតាមការប្តេជ្ញាចិត្តក្នុងកិច្ចសន្យា
- គ) ឯកសារដេញថ្លៃទាំងអស់ត្រូវមាន ១) ការពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាពទូទៅ និង ២) ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់អនុគម្រោង ដែលបង្ហាញពីកាតព្វកិច្ចជាក់លាក់របស់ក្រុមហ៊ុនម៉ៅការក្នុងអនុគម្រោង
- ឃ) ការត្រួតពិនិត្យដើម្បីធានាថា ក្រុមហ៊ុនម៉ៅការអនុលោមតាមការប្តេជ្ញាចិត្តក្នុងកិច្ចសន្យា និង
- ង) ប្រសិនបើជាការម៉ៅការបន្ត សូមតម្រូវឱ្យក្រុមហ៊ុនម៉ៅការធ្វើការរៀបចំសមមូលជាមួយក្រុមហ៊ុនម៉ៅការបន្តរបស់ខ្លួន។

151. ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងកិច្ចសន្យា នឹងសម្រេចបានតាមរយៈ ១) កាតព្វកិច្ចក្នុងកិច្ចសន្យាស្តង់ដារសម្រាប់បទដ្ឋាននៃលក្ខខណ្ឌពលកម្ម និងការងារ និង ២) ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់អនុគម្រោង មានទម្រង់ជាតារាងធម្មតាដែលរៀបរាប់លម្អិតពីវិធានការដែលត្រូវអនុវត្តដោយក្រុមហ៊ុនម៉ៅការ និងសម្របសម្រួលការត្រួតពិនិត្យដោយវិស្វករត្រួតពិនិត្យ។

152. ទោះបីជាលក្ខខណ្ឌតម្រូវជាច្រើនក្នុងបទដ្ឋានបរិស្ថាន និងសង្គមសម្រាប់ក្រុមហ៊ុនម៉ៅការ ដូចគ្នានឹងបទប្បញ្ញត្តិក្នុងច្បាប់កម្ពុជាក្តី ប៉ុន្តែលក្ខខណ្ឌតម្រូវទាំងនោះគ្របដណ្តប់លើសពីការអនុវត្តទូទៅក្នុងឧស្សាហកម្មសំណង់កម្ពុជា។ ក្រុមហ៊ុនម៉ៅការ ជាពិសេសក្រុមហ៊ុនម៉ៅការនៅមូលដ្ឋាន អាចមិនសូវយល់ ឬលំបាកអនុលោមតាមបទប្បញ្ញត្តិទាំងអស់។ ដូច្នេះ គម្រោងនឹងរៀបចំការកសាងការយល់ដឹង និងសម្ភារបណ្តុះបណ្តាល ព្រមទាំងផ្តល់វគ្គបណ្តុះបណ្តាលខ្លីស្តីពីការអនុលោមតាមបទដ្ឋាន បរិស្ថាន និងសង្គម ដល់ក្រុមហ៊ុនម៉ៅការ។ ក្រុមហ៊ុនម៉ៅការ ឬអ្នកត្រួតពិនិត្យតាមទីតាំងរបស់ខ្លួន ត្រូវចូលរួមក្នុងវគ្គទាំងនេះ ឬពុំនោះទេ ត្រូវបង្ហាញការយល់ច្បាស់ពីលក្ខខណ្ឌតម្រូវទាំងនោះ។ តារាង ៣ បង្ហាញពីការវិភាគចំណុចខ្វះខាតរវាងលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គម និងបទប្បញ្ញត្តិក្នុងច្បាប់កម្ពុជា និងវិធានការលុបបំបាត់ចំណុចខ្វះខាតផងដែរ។ គម្រោងបានរៀបចំនីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ (LWCP) ដើម្បីលើកឡើងពីចំណុចខុសគ្នាដើម្បីធានាការអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ២។

## ៤.៣.២ បទដ្ឋានបរិស្ថាន និងសង្គមទី ២ ៖ លក្ខខណ្ឌពលកម្ម និងការងារ

153. ហានិភ័យពាក់ព័ន្ធនឹងលក្ខខណ្ឌពលកម្ម និងការងារសម្រាប់កម្មករដែលធ្វើការក្នុងគម្រោង ត្រូវបានវិភាគក្នុងនីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ (LWCP) ដែលបង្ហាញពីវិធានការកាត់បន្ថយហានិភ័យ។ លទ្ធផលរកឃើញសំខាន់ៗ និងវិធានការគ្រប់គ្រងហានិភ័យដែលលើកឡើងក្នុង LWCP មានសង្ខេបក្នុងផ្នែកនេះ។

154. នីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ (LWCP) នឹងអនុវត្តចំពោះ ១) កម្មករដែលធ្វើការក្នុងគម្រោងផ្ទាល់ ពោលគឺទីប្រឹក្សាសេវា និងបុគ្គលិកគាំទ្រដែលចុះហត្ថលេខាផ្ទាល់លើកិច្ចសន្យាជាមួយទីភ្នាក់ងារ និងដៃគូអនុវត្តន៍គម្រោង ២) កម្មករជាប់កិច្ចសន្យាដែលជួលដោយតតីយជនឱ្យបំពេញការងារពាក់ព័ន្ធនឹងមុខងារសំខាន់ៗរបស់គម្រោង ៣) កម្មករផ្គត់ផ្គង់បឋមដែលជួលដោយក្រុមហ៊ុនផ្គត់ផ្គង់ដែលកំពុងផ្តល់ទំនិញ ឬសម្ភារៈចាំបាច់ដល់គម្រោងសម្រាប់មុខងារសំខាន់ៗរបស់គម្រោង។ ចំណុចសំខាន់គឺ កម្មករផ្គត់ផ្គង់របស់ក្រុមហ៊ុនម៉ៅការសាងសង់ ប្រហែលជាចាត់ចូលក្នុងក្រុមប្រភេទនេះ និង ៤) កម្មករសហគមន៍ដែលពាក់ព័ន្ធក្នុងការងារក្នុងសហគមន៍ដោយទទួលបាន ឬមិនទទួលបានប្រាក់ឈ្នួល ដែលពាក់ព័ន្ធនឹងគម្រោង។ LWCP មានកាលវិភាគរបស់កម្មករដែលធ្វើការក្នុងគម្រោង និងចំនួនប៉ាន់ស្មានទៅតាមប្រភេទនីមួយៗ។

155. **ហានិភ័យសុខភាព និងសុវត្ថិភាពក្នុងការងារ** ដែលបានកំណត់ក្នុង LWCP រួមមានហានិភ័យដែលពាក់ព័ន្ធនឹងការធ្វើដំណើរទៅមក និងធ្វើការនៅការដ្ឋានដាច់ស្រយាល ដូចជា គ្រោះថ្នាក់ចរាចរណ៍ ហានិភ័យសន្តិសុខ ហានិភ័យជំងឺ ពស់ចឹក និងសត្វល្អិតទិច/ខាំ និងសំណល់អាវុធជាតិផ្ទុះបន្សល់ពីសង្គ្រាម។ ហានិភ័យទាំងនេះនឹងត្រូវបានប៉ាន់ប្រមាណក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង។

156. ការគ្រប់គ្រងការងារទូទៅសម្រាប់ការគ្រប់គ្រងពលករ និងកម្មករ ជាពិសេសក្នុងឧស្សាហកម្មសំណង់អាចធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យមួយចំនួន ដូចជា ក) លក្ខខណ្ឌការងារមិនច្បាស់លាស់ ឬដាក់លាក់ ខ) ការរើសអើងដែលអាចកើតមានលើស្ត្រី ឬសមាជិករបស់ក្រុមផ្សេងទៀត គ) ការបដិសេធសិទ្ធិបង្កើតសហជីព/សមាគមរបស់កម្មករ និង ឃ) គ្មានលទ្ធភាពទទួលបានយន្តការដោះស្រាយបណ្តឹងតវ៉ា។ ការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព (ESHS) នឹងបញ្ជាក់ច្បាស់ពីបទដ្ឋានចាំបាច់សម្រាប់ចំណុចនីមួយៗទាំងនេះ ហើយនឹងមានការត្រួតពិនិត្យការអនុលោមតាមនៅពេលត្រួតពិនិត្យដំណើរការសាងសង់។

157. ពលករ និងកម្មករជាប់កិច្ចសន្យា ជាពិសេសក្នុងការងារសាងសង់ អាចប្រឈមនឹងហានិភ័យមួយចំនួនដូចជា គ្រោះថ្នាក់នៅកន្លែងការងារ ការប្រឈមនឹងសារធាតុគ្រោះថ្នាក់ ហានិភ័យពាក់ព័ន្ធនឹងលក្ខខណ្ឌរស់នៅក្នុងការដ្ឋាន និងហានិភ័យនៃការប្រឈមនឹងសំណល់អាវុធជាតិផ្ទុះបន្សល់ពីសង្គ្រាមក្នុងពេលសាងសង់។

158. ជារួម កិច្ចការការងារសហគមន៍នឹងមិនបង្កគ្រោះថ្នាក់ទេ ប៉ុន្តែអាចមានលក្ខខណ្ឌដែលបង្កគ្រោះថ្នាក់នៅការដ្ឋាន ហានិភ័យតាមទីតាំង ដូចជា ពស់ចឹក និងសត្វល្អិតទិច/ខាំ និងសំណល់អាវុធជាតិផ្ទុះបន្សល់ពីសង្គ្រាម។

159. សកម្មភាពជួលកម្មកររបស់ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនផ្គត់ផ្គង់ អាចបង្កការរំលោភលើគោលការណ៍នៃ**ការប្រព្រឹត្តចំពោះដោយយុត្តិធម៌ និងការមិនរើសអើង** ដែលជាលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ២។

160. អាចមាន**ពលកម្មកុមារ និង/ឬការងារដោយបង្ខំ** ជាពិសេសដោយសារតែបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការងាររបស់កម្ពុជា មិនទាន់បំពេញបានទាំងស្រុងតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋាន បរិស្ថាន និងសង្គមទី២។ កម្រិតខ្ពស់បំផុតនៃហានិភ័យត្រូវបានប៉ាន់ប្រមាណថានឹងកើតឡើងសង្វាក់ផ្គត់ផ្គង់សម្ភារៈសាងសង់ (ឥដ្ឋ និងក្បឿង) និងជាតុចូលកសិកម្ម។

161. **សិទ្ធិរបស់កម្មករក្នុងការបង្កើតសហជីព/សមាគម** ត្រូវបានការពារដោយច្បាប់ស្តីពីការងារនៅកម្ពុជា ប៉ុន្តែការអនុវត្តប្រហែលជាគ្មានការគោរពបានល្អទេ។ ច្បាប់នេះមិនតម្រូវឱ្យនិយោជកបង្កើតយន្តការបណ្តឹងតវ៉ាផ្លូវការសម្រាប់កម្មករទេ។

162. កម្មករដែលធ្វើការក្នុងគម្រោងនៅតាមទីតាំងមួយចំនួន អាចប្រឈមនឹងហានិភ័យដោយសារមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ដូចជា ទឹកជំនន់ភ្លាមៗ ខ្យល់ព្យុះ និងរន្ទះបាញ់។

163. ហានិភ័យ **អំពើហិង្សាផ្អែកលើយេនឌ័រ** ចំពោះកម្មករដែលធ្វើការក្នុងគម្រោង អាចរួមមាន ហានិភ័យចំពោះកម្មករជាស្ត្រីធ្វើការក្នុងគម្រោង ដែលធ្វើដំណើរទៅមកទីតាំងដាច់ស្រយាល និងហានិភ័យអំពើហិង្សាផ្អែកលើយេនឌ័រ ដែលប្រព្រឹត្តដោយកម្មកររបស់ក្រុមហ៊ុនម៉ៅការ ជាពិសេសកម្មករ ដែលរស់នៅអចិន្ត្រៃយ៍ក្នុងការដ្ឋាន។

164. នីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ មានឧបករណ៍សម្រាប់ការអនុវត្តក្នុងគម្រោង និងការអនុវត្តដោយក្រុមហ៊ុនម៉ៅការ ដូចខាងក្រោម ៖

ក) នីតិវិធីទប់ស្កាត់ពលកម្មកុមារ និងការងារដោយបង្ខំ (PPCLFL) ដើម្បីធានា និងផ្ទៀងផ្ទាត់ការអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ២

ខ) យន្តការបណ្តឹងតវ៉ាសម្រាប់កម្មករដែលធ្វើការក្នុងគម្រោង (PWGM)។

165. នីតិវិធីទប់ស្កាត់ពលកម្មកុមារ និងការងារដោយបង្ខំ ហាមឃាត់មិនឱ្យកុមារអាយុក្រោម ១៥ ឆ្នាំធ្វើជាកម្មករក្នុងគម្រោង ទោះជាការងារប្រភេទអ្វី និងស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ កុមារអាយុ ១៥-១៧ ឆ្នាំនឹងមិនត្រូវបានជួលឱ្យធ្វើជាកម្មករធ្វើការក្នុងគម្រោងផ្ទាល់ទេ។ កុមារអាយុ ១៥-១៧ ឆ្នាំនឹងមិនត្រូវបានជួលជាកម្មករជាប់កិច្ចសន្យាតាមរបៀបដែលអាចបង្កគ្រោះថ្នាក់ ឬរំខានដល់ការអប់រំ ឬបង្កគ្រោះថ្នាក់ដល់សុខភាព ឬការអភិវឌ្ឍរាងកាយ សតិបញ្ញា ស្មារតី សីលធម៌ ឬការអភិវឌ្ឍផ្នែកសង្គមរបស់កុមារឡើយ។ កុមារអាយុ ១៥-១៧ ឆ្នាំនឹងមិន ១) ធ្វើការដោយគ្មានការត្រួតពិនិត្យ ២) ធ្វើការងារសាងសង់អគារ និងគ្រោងនានា ឬការងារដែលតម្រូវឱ្យមានការចុះរណ្តៅការដ្ឋានលើសពីជម្រៅត្រឹមស្មា និង ៣) ធ្វើការងារដែលតម្រូវឱ្យមានការរៀបចំទុកដាក់សម្ភារសំណង់ដែលអាចបង្កគ្រោះថ្នាក់ ដូចជា ស៊ីម៉ង់ត៍។ កុមារអាយុ ១៥-១៧ ឆ្នាំ ដែលបានចុះឈ្មោះចូលរៀន មិនត្រូវបានជួលឱ្យធ្វើការក្នុងម៉ោងសិក្សាឡើយ។ បទប្បញ្ញត្តិទាំងនេះនឹងត្រូវបានពង្រឹងក្នុងពេលត្រួតពិនិត្យកិច្ចសន្យា។

166. កុមារអាយុ ១៥-១៧ ឆ្នាំដែលបានចុះឈ្មោះចូលរៀន នឹងមិនត្រូវបានអនុញ្ញាតឱ្យធ្វើកិច្ចការការងារសហគមន៍ដែលពាក់ព័ន្ធនឹងគម្រោង ក្នុងម៉ោងសិក្សាឡើយ។ កុមារអាយុ ១៥-១៧ ឆ្នាំប្រហែលជាមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចការការងារសហគមន៍ដោយគ្មានការត្រួតពិនិត្យទេ។

167. នីតិវិធីគ្រប់គ្រងលក្ខខណ្ឌពលកម្ម និងការងារ រៀបរាប់ពីឧបករណ៍ដែលនឹងត្រូវរៀបចំឡើងក្នុងពេលចាប់ផ្តើមគម្រោង និងត្រូវអនុវត្តដោយគម្រោង រួមទាំងក្រុមហ៊ុនម៉ៅការ ដូចខាង ក្រោម ៖

ក) យុទ្ធសាស្ត្រសុខភាព និងសុវត្ថិភាពការងារ (OHSS) សម្រាប់កម្មករដែលធ្វើការក្នុងគម្រោងផ្ទាល់

ខ) លក្ខខណ្ឌការងាររបស់កម្មករដែលធ្វើការក្នុងគម្រោងផ្ទាល់ ដែលអនុលោមតាមបទដ្ឋាន បរិស្ថាន និងសង្គមទី ២

គ) ការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព (ESHSS) ដែលនឹងរួមបញ្ចូលលក្ខខណ្ឌកិច្ចសន្យាសមស្របសម្រាប់ការងារ ការគ្រប់គ្រង និងសុខភាព និងសុវត្ថិភាពការងាររបស់កម្មករជាប់កិច្ចសន្យា

ឃ) នីតិវិធីគ្រប់គ្រងការងារក្នុងសហគមន៍ដែលអនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមទី ២។

168. វិធានការខាងក្រោមនឹងត្រូវបានរៀបចំឡើង សម្រាប់អនុគម្រោងនីមួយៗទៅតាមភេទចាំបាច់ ៖

ក) ការកំណត់អត្តសញ្ញាណហានិភ័យតាមទីតាំង និងវិធានការកាត់បន្ថយហានិភ័យក្នុងតំបន់សម្បទានដីសង្គមកិច្ច តំបន់សម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់អនុគម្រោង

ខ) ក្រុមហ៊ុនម៉ៅការនឹងត្រូវបានតម្រូវឱ្យរៀបចំផែនការសុខភាព និងសុវត្ថិភាពក្នុងការងារតាមទីតាំង។

169. ហានិភ័យសំខាន់ៗក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ២ ដែលពាក់ព័ន្ធនឹងផ្នែកសកម្មភាពគម្រោង រួមទាំងកម្រិតផលប៉ះពាល់ និងលទ្ធភាពកើតឡើង មានសង្ខេបក្នុងតារាង ៤។ ឧបករណ៍ពាក់ព័ន្ធសម្រាប់ការកាត់បន្ថយហានិភ័យមានបង្ហាញក្នុងតារាងខាងស្តាំដៃ។

**តារាង ៤ ៖ ខ្លឹមសារសង្ខេបហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ២**

| ហានិភ័យ | ផ្នែកសកម្មភាព | កម្រិតផលប៉ះពាល់ | លទ្ធភាពដែលអាចកើតឡើង | ឧបករណ៍កាត់បន្ថយហានិភ័យ |
|---|---|---|---|---|
| ហានិភ័យសុខភាព និងសុវត្ថិភាព ចំពោះកម្មករធ្វើការក្នុងគម្រោងដែលធ្វើដំណើរទៅមកតំបន់ដាច់ស្រយាល | គ្រប់ផ្នែក | កម្រិតទី ២ | អាចកើតឡើង និងត្រូវមានវិធានការបញ្ចៀស | OHSS |
| ហានិភ័យសុខភាព និងសុវត្ថិភាពក្នុងការងារចំពោះកម្មករជាប់កិច្ចសន្យា | អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ | កម្រិតទី ២ | ងាយកើតឡើង និងត្រូវមានវិធានការកាត់បន្ថយផលប៉ះពាល់ | ESHSS<br>OHSP តាមទីតាំង |
| ការប្រព្រឹត្តដោយលម្អៀងចំពោះកម្មករជាប់កិច្ចសន្យា | អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ | កម្រិតទី ១ | ងាយកើតឡើង និងត្រូវមានវិធានការកាត់បន្ថយផលប៉ះពាល់ | ESHSS |

| | | | | |
|---|---|---|---|---|
| លក្ខខណ្ឌរស់នៅមិនគ្រប់គ្រាន់នៅការដ្ឋាន | អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ | កម្រិតទី ១ | ងាយកើតឡើង និងត្រូវមានវិធានការកាត់បន្ថយផលប៉ះពាល់ | ESHSS OHSP តាមទីតាំង |
| គ្មានការគោរពសិទ្ធិបង្កើតសមាគម/សហជីពរបស់កម្មករ និងលទ្ធភាពប្រើប្រាស់យន្តការបណ្តឹងតវ៉ា | អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ | កម្រិតទី ១ | ងាយកើតឡើង និងត្រូវមានវិធានការកាត់បន្ថយផលប៉ះពាល់ | ESHSS PWGM |
| ពលកម្មកុមារ/ការងារដោះបំណុលដែលច្រើនកើតឡើងនៅកន្លែងការងាររបស់ក្រុមហ៊ុនផ្គត់ផ្គង់បន្ទាប់បន្សំ (ឡឥដ្ឋ សម្ភារៈដាំដុះ) | អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្ម | កម្រិតទី ២ | អាចកើតឡើង និងត្រូវមានវិធានការបញ្ចៀស | CLFLP ESHSS |
| ហានិភ័យនៃព្រឹត្តិការណ៍អាសន្ន/មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិនៅការដ្ឋាន | អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ | កម្រិតទី ២ | អាចកើតឡើង និងត្រូវមានវិធានការបញ្ចៀស | OHSP តាមទីតាំងដើម្បីដាក់បញ្ចូលផែនការឆ្លើយតបគ្រោះអាសន្ន |
| ការប្រើប្រាស់ពលកម្មកុមារហួសកម្រិត ឬមិនសមស្របក្នុងកសិកម្ម ឬគម្រោងសហគមន៍ | ការតាំងទីលំនៅថ្មីនៅទីតាំងសម្បទានដីសង្គមកិច្ច | កម្រិតទី ១ | អាចកើតឡើង និងត្រូវមានវិធានការបញ្ចៀស | ការកសាងការយល់ដឹង (ក្រុមគម្រោងថ្នាក់ខេត្ត) |

### ៤.៣.៣ បទដ្ឋានបរិស្ថាន និងសង្គមទី ៣ ៖ ប្រសិទ្ធភាពធនធាន និងការទប់ស្កាត់ និងការគ្រប់គ្រងការបំពុល

170. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ (LASED III) នឹងតម្រូវឱ្យមានការទាញយកធនធានទឹកក្រោមដី និងធនធានទឹកលើដីសម្រាប់ការផ្គត់ផ្គង់ទឹកក្នុងមូលដ្ឋាន និងកសិកម្ម។ តម្រូវការទឹកសម្រាប់ជាវាសាស្ត្រ អាចមានទំហំធំធេងធៀបនឹងធនធានដែលមាននៅតាមទីតាំងមួយចំនួន។ អាចមានហានិភ័យនៃការប្រើប្រាស់ធនធានទឹកដោយគ្មាននិរន្តរភាព ការបង្វែរបស់ផ្គត់ផ្គង់ពីអ្នកប្រើប្រាស់បច្ចុប្បន្ន (ខ្សែទឹកខាងក្រោម) និងការធ្វើឱ្យស្ងួតបឹងបួរ និងប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមគ្មានទឹកគ្រប់គ្រាន់។

171. LASED III មិនត្រូវបានគេរំពឹងថានឹងបណ្តាលឱ្យមានប្រភពចំណុចសំខាន់ៗនៃការបំពុល បរិស្ថាន ឬការបំភាយឧស្ម័នផ្ទះកញ្ចក់ទេ។ ជាធម្មតាកសិករប្រើម៉ាស៊ីនម៉ាស៊ូតដែលគ្មានប្រសិទ្ធភាពដើម្បីបូមទឹកប្រព័ន្ធជាវាសាស្ត្រដែលនាំឱ្យមានការបំពុលបរិយាកាស និងការបំភាយឧស្ម័នផ្ទះកញ្ចក់ដ៏គួរឱ្យកត់សម្គាល់តិចតួចដែរ ដូច្នេះបច្ចេកវិទ្យាថាមពលសូឡាអគ្គិសនីគឺជាជម្រើសជំនួសមួយដែលចំណេញកាន់តែច្រើន។ គម្រោង LASED III នឹងមិនទិញសារធាតុគីមីកសិកម្មទេ ហើយតាមរយៈវគ្គ បណ្តុះបណ្តាលបន្ថែមនឹងគាំទ្រដល់ការអនុម័តស្តង់ដាការអនុវត្តកសិកម្មល្អ (GAP) ដែលចៀសវាង ឬកាត់បន្ថយការប្រើប្រាស់គីមី ប៉ុន្តែការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិតមួយចំនួន ដោយកសិករទទួលផលត្រូវតែរំពឹងទុក ខណៈការប្រើប្រាស់ខ្នាតធំត្រូវគេដឹងថាកើតឡើងនៅចម្ការដំណាំពាណិជ្ជកម្មក្នុងតំបន់គម្រោង។ ការប្រើប្រាស់សារធាតុគីមីក្នុងការគ្រប់គ្រងមិនបានល្អ មានសក្តានុពលក្នុងការបំពុលការផ្គត់ផ្គង់ទឹកតាមរយៈការហូរចូលទឹកហូរ និងចរន្តទឹកដែលធ្វើឱ្យទឹកកខ្វក់ (វាក៏មាន

ហានិភ័យនៃការប្រើប្រាស់សារធាតុគីមីទ្រង់ទ្រាយធំដោយ ប្រតិបត្តិការកសិកម្មពាណិជ្ជកម្មនៅក្បែរនោះ ដែលជះឥទ្ធិពលដល់ទីតាំងគម្រោងផងដែរសូមមើល ESS4 ខាងក្រោម)។ សកម្មភាពកសិកម្មនៅតាមទីតាំងគម្រោងក៏អាចបណ្តាលឱ្យមានបរិមាណសំណល់រឹងដែលមិនបំបែកបាន (ថង់ប្លាស្ទិកត្រូវប្រើសម្រាប់ផ្គត់ផ្គង់សម្ភារៈច្រើន ជី ជាដើម ។ល។ សំណល់ជ័រប្លាស្ទិកដែលបានបោះចោល សំណាញ់ជាដើម)។

172. ការគ្រប់គ្រងសំណល់រឹង ក៏ជាបញ្ហាមួយនៅតាមទីតាំងសម្បទានដីសង្គមកិច្ច ដែលភ្ជាប់ទៅនឹងលំនាំនៃការតាំងទីលំនៅដ៏ក្រាស់ក្រែល និងការបង្កើតទីផ្សារផងដែរ។ ការចម្លងរោគទៅក្នុងទឹកដោយសារសំណល់រឹងរួមទាំងប្លាស្ទិក គឺជាហានិភ័យមួយដែលបណ្តាលមកពីការគ្រប់គ្រងសំណល់រឹងពុំបានល្អ។ ការដុតសំរាម(ជាក់ស្តែងគឺវិធីសាស្រ្តនៃការចោលសំរាមតែមួយគត់) ក៏បង្កគ្រោះថ្នាក់ដល់សុខភាពពីប្លាស្ទិកដែលផងផេះដែរ។

173. ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងអនុគម្រោង LASED III នឹងនាំឱ្យមានហានិភ័យនៃការបំពុលបរិស្ថានដែលទាក់ទងនឹងការងារ និងផលប៉ះពាល់បរិស្ថានអវិជ្ជមានផ្សេងទៀត។ ការបំពុលអាចកើតឡើងពីការដោះស្រាយមិនសមស្រប ឬការចោលប្រេង ស៊ីម៉ងត៍ សំណល់ប្លាស្ទិក និងប្រភេទសំណល់រឹង ផ្សេងៗទៀតដោយមិនបានត្រឹមត្រូវ។ ប្រភពទឹកអាចត្រូវបានបំពុលដោយទឹកសម្អុយ ឬការបង្ហូរទឹកមិនល្អ និងការគ្រប់គ្រងទឹកភ្លៀងពុំបានល្អ។ ការងារសាងសង់អាចបណ្តាលឱ្យមានការរំខានដោយធូលី ហើយក្នុងករណីធ្ងន់ធ្ងរអាចគ្រោះថ្នាក់ដល់សុខភាពសហគមន៍ដែលនៅជិតនោះ។ លើសពីនេះការរចនាប្លង់ហេដ្ឋារចនាសម្ព័ន្ធមិនល្អ ឬការអនុវត្តមិនបានត្រឹមត្រូវក្នុងពេលសាងសង់ អាចបណ្តាលឱ្យខូចខាតដល់បណ្តាញបង្ហូរទឹកធម្មជាតិ ការហូរច្រោះដី ការមិនមានស្ថិរភាពនៃជម្រាលដីធម្មជាតិ ជាដើម។

174. ហានិភ័យសំខាន់ៗក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៣ អាចពាក់ព័ន្ធនឹងតំបន់សកម្មភាពគម្រោង, ដោយកម្រិតផលប៉ះពាល់ដែលបានវាយតម្លៃ លទ្ធភាព និងគ្រោងយុទ្ធសាស្ត្រកាត់បន្ថយត្រូវបាន សង្ខេបនៅក្នុងតារាងទី ៥។

| **តារាង ៥៖ខ្លឹមសារសង្ខេបនៃហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៣** | | | | |
|---|---|---|---|---|
| ហានិភ័យ | តំបន់សកម្មភាព | កម្រិតនៃផលប៉ះពាល់ | ប្រូបាបដែលនឹងអាចកើតឡើង | យុទ្ធសាស្ត្រកាត់បន្ថយ |
| ការថយចុះនៃទឹកក្រោមដី ឬប្រភពទឹកលើដីដោយការធ្វើអាជីវកម្មគ្មានប្រសិទ្ធភាព ឬគ្មាននិរន្តរភាព | ជាពសាស្ត្រ s-p<br>កសិកម្ម s-p | កម្រិត ២ | អាចកើតឡើង, ត្រូវការវិធានការបញ្ចៀស | ការធ្វើផែនការធនធានទឹក |
| ការបំពុលខ្យល់ពីការប្រើប្រាស់ម៉ាស៊ីនបូមម៉ាស៊ូត | កសិកម្ម s-p | កម្រិត ១ | អាចកើតឡើង, ត្រូវការវិធានការបញ្ចៀស | ការលើកកម្ពស់ការយល់ដឹង |
| ការចម្លងរោគទៅក្នុងទឹកពីការប្រើប្រាស់សារធាតុគីមីកសិកម្មមិនសមស្រប | កសិកម្ម s-p | កម្រិត ២ | អាចកើតឡើង, ត្រូវការវិធានការបញ្ចៀស | ការបណ្តុះបណ្តាលអនុលោមតាម CamGAP អំពីការប្រើប្រាស់ និងចោលសំណល់គីមីដោយសុវត្ថិភា |

| | | | | |
|---|---|---|---|---|
| | | | | ៣។ កសិករមានឱកាសស្មើគ្នាក្នុងការទទួលបានទីផ្សារសុវត្ថិភាពគ្មានជាតិគីមី / ប្រព័ន្ធដំណាំសរីរាង្គ |
| ការបំពុលបរិស្ថានពីសំណល់រឹងដែលមិនអាចបំបែកបានពីសកម្មភាពកសិកម្ម | កសិកម្ម s-p | កម្រិត ១ | អាចកើតឡើង, ត្រូវការវិធានការបញ្ចៀស | ការលើកកម្ពស់ការយល់ដឹង និងវិធានការគ្រប់គ្រងសំណល់រឹង |
| ការបំពុលខ្យល់ (ដោយការដុត) ការបំពុលទឹក និងការបំពុលដីដែលបណ្តាលមកពីការគ្រប់គ្រងសំណល់រឹងមិនបានល្អនៅទីតាំងលំនៅដ្ឋានសម្បទានដីសង្គមកិច្ច | សម្បទានដីសង្គមកិច្ច | កម្រិត ១ | អាចនឹងកើតឡើង | បង្កើតនិងអនុវត្តវិធានការគ្រប់គ្រងសំណល់រឹងប្រកបដោយប្រសិទ្ធភាព |
| ការបំពុលខ្យល់ ទឹក ដី ពីសកម្មភាពការងារ | ជាពសាស្ត្រ s-p | កម្រិត ១ | អាចនឹងកើតឡើង | បញ្ញត្តិសមស្របនៅក្នុងសេចក្តីពិពណ៌នា ESHS |

## ៤.៣.៤ បទដ្ឋានបរិស្ថាន និងសង្គមទី៤ – សុខភាព និងសុវត្ថិភាពសហគមន៍

175. មានសក្តានុពលនៃហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពដែលអាចប៉ះពាល់ដល់អ្នកទទួលផលពីគម្រោង និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅទីតាំង LASED III SLC និង ICLT។ ហានិភ័យជាច្រើនគឺជាប់ទាក់ទងនឹងរបៀបរស់នៅ ការប្រកបរបរចិញ្ចឹមជីវិត និងជីវភាពរស់នៅតាមជនបទនៃប្រទេសកម្ពុជា ហើយគម្រោងនឹងមិនចាំបាច់បង្កើនលទ្ធភាព ឬភាពធ្ងន់ធ្ងរនៃហានិភ័យទាំងនេះទេ។ ទោះយ៉ាងណា ហានិភ័យមួយចំនួន នឹងត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរដោយដំណើរការនៃការផ្លាស់ប្តូរទៅកាន់ទីតាំងសម្បទានដីសង្គមកិច្ច ខណៈពេលដែលការរៀបចំគម្រោង និងការគ្រប់គ្រងទិដ្ឋភាពអភិវឌ្ឍន៍សហគមន៍មានសក្តានុពលក្នុងការកាត់បន្ថយហានិភ័យសុខភាព និងសុវត្ថិភាពមួយចំនួនដែលអ្នកទទួលផលបានបង្ហាញពីមុន។

176. គម្រោង LASED III នឹងគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រខ្នាតតូច រួមទាំងការស្តាបនា ឬការស្តារទំនប់ទឹក ខ្នាតតូច ដែលបរាជ័យពីការងារទាំងនេះទំនងជាមិនបង្កគ្រោះថ្នាក់ធំដល់អាយុជីវិតមនុស្សឡើយ។ ទំនប់ត្រូវនឹងលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៤ ឧបសម្ព័ន្ធ១ ដែលតម្រូវឱ្យមានសុវត្ថិភាពទំនប់នឹងមិនត្រូវបានអនុញ្ញាត (រាប់បញ្ចូលក្នុងបញ្ជីផលប៉ះពាល់អវិជ្ជមាន)។ ទោះយ៉ាងណា LASED II ត្រូវបានគេចាត់ទុកថាបង្កឱ្យមាន OP / BP ៤.៣៧ ស្តីពីសុវត្ថិភាពទំនប់ទឹក និង LASED III គួរតែបន្តតាមដាន និងគ្រប់គ្រងហានិភ័យនេះក្រោមក្របខណ្ឌបទដ្ឋានបរិស្ថាន និងសង្គមទី ៤។ ហេដ្ឋារចនាសម្ព័ន្ធទាំងអស់ គួរតែត្រូវបានរចនាឡើងសម្រាប់ភាពធន់នឹងអាកាសធាតុ ដោយគិតគូរពីការព្យាករល្អបំផុតដែលមានសម្រាប់លើការប្រែប្រួលអាកាស ធាតុ។

177. ខេត្តគោលដៅរបស់គម្រោងក៏ជាទីតាំងនៃគម្រោងទំនប់វារីអគ្គិសនីដែលមានស្រាប់ ឬដែលបានស្នើ ឬមានតំបន់នៅក្រោមខ្សែទឹកដែលជះឥទ្ធិពលដោយគម្រោងវារីអគ្គិសនី ដែលមានទីតាំងនៅប្រទេសវៀតណាម ឬប្រទេសឡាវ។ វត្តមាននៃគ្រោងការណ៍វារីអគ្គិសនីជាក់ស្តែង ឬដែលមាន សក្តានុពល នៅទីតាំងខាងលើខ្សែទឹកដែលបានបម្រុងទុកសម្រាប់ទីតាំងសម្បទានដីសង្គមិច្ច ឬទីតាំង ICLT អាចបង្កើតហានិភ័យដែលមានសក្តានុពល រួមទាំងហានិភ័យដែលមិនត្រូវបានកំណត់ដោយការវិភាគផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងវារីអគ្គិសនីដែលបានធ្វើឡើងមុនពេលដែលទីតាំងសម្បទានដីសង្គមកិច្ចត្រូវបានស្នើឡើង។ ហានិភ័យអាចរាប់បញ្ចូលការប៉ះពាល់ទៅនឹងលំហូរទឹកហូរដែលជាប់ទាក់ទងទៅនឹងប្រតិបត្តិការទំនប់វារីអគ្គិសនី ក៏ដូចជាហានិភ័យ (តូចតាច) នៃការបាក់រលំទំនប់វារីអគ្គិសនី។

178. ការតាំងទីលំនៅថ្មីនៅលើតំបន់សម្បទានដីសង្គមកិច្ច នឹងធ្វើឱ្យអ្នកទទួលដីមានហានិភ័យពីគ្រោះមហន្តរាយធម្មជាតិ ឧទាហរណ៍ប្រសិនបើសម្បទានដីសង្គមកិច្ច ស្ថិតនៅក្នុងតំបន់ដែលអាចប្រឈមនឹងទឹកជំនន់។ ការផ្លាស់ប្តូរទៅរកការចិញ្ចឹមជីវិត ដោយផ្អែកលើផលិតកម្មកសិកម្មតាម កសិដ្ឋានផ្ទាល់ខ្លួន អាចបង្កហានិភ័យពីការខូចខាតនៃដំណាំ ឧទាហរណ៍ដោយសារតែគ្រោះរាំងស្ងួត។ ហានិភ័យទាំងពីរនេះអាចមានភាពកាន់តែធ្ងន់ធ្ងរដោយសារការប្រែប្រួលអាកាសធាតុ។ ភ្លើងឆេះព្រៃមិនមែនជាគ្រោះថ្នាក់ដ៏ធំមួយនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះទេ ប៉ុន្តែប្រសិនបើការផ្លាស់ប្តូរអាកាសធាតុនាំឱ្យមានស្ថានភាពស្ងួតនៅតំបន់ព្រៃធម្មជាតិវាក៏អាចក្លាយជាហានិភ័យផងដែរ។ រន្ទះ គឺជាហានិភ័យមួយដែលត្រូវបានគេមើលឃើញ សម្រាប់កម្មករនៅតាមមូលដ្ឋានរបស់ប្រទេស កម្ពុជា ទោះជាយ៉ាងណាក៏ដោយការកាត់បន្ថយហានិភ័យដ៏មានប្រសិទ្ធភាពនៅតែអាចធ្វើទៅបានប្រសិនបើគម្រោងនេះអាចផ្តល់ឱ្យពួកគេនូវឧបករណ៍ការពាររន្ទះដើម្បីការពារពួកគេខ្លួនបាន។

179. សំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) ដែលបណ្តាលមកពីជម្លោះក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ នៅតែបន្តបង្កគ្រោះថ្នាក់នៅក្នុងប្រទេសកម្ពុជា ទោះបីអត្រាគ្រោះថ្នាក់ត្រូវបានកាត់បន្ថយយ៉ាងសន្ធឹកដោយសារការបោសសម្អាតមីន និងការលើកកម្ពស់ការយល់ដឹងជាបន្តក៏ដោយ។ ចម្ការមីនដែលដាក់ដោយចេតនាត្រូវបានគេស្គាល់ និងសម្គាល់ភាគច្រើនហើយដូច្នេះមិនវាបានបង្កើតឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរនោះឡើយ ទោះបីពេលខ្លះមីនត្រូវបានជួបប្រទះនៅក្នុងទីតាំងដែលមិនបានរំពឹងទុកក៏ដោយ។ ទោះយ៉ាងណានៅភាគឥសាន្តនៃប្រទេសកម្ពុជា រួមទាំងខេត្តដែលមានអាទិភាពនៃគម្រោង LASED III គ្រោះថ្នាក់ដ៏ធំកើតឡើងពីគ្រាប់បែកពីលើអាកាសមិនទាន់ផ្ទុះ និងគ្រាប់បែកចង្កោមដែលបានរាយប៉ាយមិនអាចប៉ាន់ស្មានបាន និងជាពិសេសទំនងជាត្រូវបានជួបប្រទះនៅពេលឈូសឆាយដីថ្មីសម្រាប់ការដាំដុះដូចជានៅទីតាំងសម្បទានដីសង្គមកិច្ច។

180. ទីតាំងសម្បទានដីសង្គមកិច្ច និងដីកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មានទីតាំងស្ថិតនៅតំបន់ដាច់ស្រយាលរួមទាំងព្រៃដែលអាចមានហានិភ័យខ្ពស់នៃ ជំងឺដែលបណ្តាលមកពីភ្នាក់ងារចម្លង រួមមាន គ្រុនចាញ់ និងគ្រុនឈាម។ សមាជិកសហគមន៍ ICLT បានរស់នៅក្នុងតំបន់ទាំងនេះរួចហើយប៉ុន្តែអ្នកទទួលសម្បទានដីសង្គមកិច្ច អាចនឹងផ្លាស់ប្តូរពីតំបន់ដែលមានហានិភ័យទាប និងអាចមានភាពធន់តិចជាងមុន។

181. ទីតាំងលំនៅដ្ឋានរបស់ប្រជាជននៅសម្បទានដីសង្គមកិច្ច ជាទូទៅមានទំហំធំជាង និងមានប្រជាជនច្រើនជាងភូមិដែលអ្នកទទួលដីកំពុងរើចេញ។ ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ គឺជាគន្លឹះក្នុងការការពារជំងឺ

ដែលបង្កដោយទឹក។ ថ្វីត្បិតតែគម្រោង LASED និង LASED II បានផ្តល់សម្ភារសម្រាប់សាងសង់បង្គន់អនាម័យដល់គ្រួសារនីមួយៗក៏ដោយ ក៏សម្ភារៈទាំងនេះភាគច្រើនហាក់ដូចជាមិនត្រូវបានប្រើប្រាស់ ឬប្រើប្រាស់សម្រាប់គោលបំណងជំនួស ខណៈដែលគ្រួសារនៅតែខ្វះបង្គន់ អនាម័យ និងអនុវត្តការបន្ទោបង់ដោយចំហ ដែលហានិភ័យនៃការចម្លងជំងឺមានច្រើនជាងនៅក្នុងការតាំងទីលំនៅបែបប្រពៃណីដែលមានដង់ស៊ីតេប្រជាជនទាប។

ការបំពុលប្រភពទឹកលើដី (និងអាចមានទឹកក្រោមដីផងដែរ) ដោយសារជាតិគីមីកសិកម្មចេញពីចម្ការដំណាំធំៗ ត្រូវបានគេនិយាយថាជាបញ្ហានៅតំបន់ខ្លះនៃប្រទេសកម្ពុជារួមទាំងខេត្តគោលដៅអាទិភាពនៃគម្រោង LASED III ទោះបីជាវាមានការលំបាកក្នុងការរកភស្តុតាងច្បាស់លាស់អំពីរឿងនេះ។ ប្រភពសក្តានុពលមួយទៀតនៃការបំពុលទឹកគឺមកពីប្រតិបត្តិការរុករករ៉ែ រួមទាំងសកម្មភាពខុសច្បាប់ក្នុងករណីខ្លះ។ នៅតំបន់ខ្លះនៃប្រទេសកម្ពុជាសារធាតុអាសេនិកនៅក្នុងទឹកក្រោមដី គឺជាគ្រោះថ្នាក់ដល់សុខភាពចំពោះអ្នកប្រើប្រាស់ទឹកពីអណ្តូងស្នប់។ ដោយសារគម្រោងនេះនឹងគាំទ្រការផ្លាស់ទីលំនៅរបស់សហគមន៍ទៅតំបន់ដែលការផ្គត់ផ្គង់ទឹកអាចត្រូវបានបំពុលចេញពីប្រភពទាំងនេះ គ្រោះថ្នាក់ទាំងនេះត្រូវបានគេចាត់ទុកថាជាការបង្កើតហានិភ័យសុខភាព និងសុវត្ថិភាពសហគមន៍ដែលជាប់ទាក់ទងនឹងគម្រោង។ ក្នុងករណីទាំងអស់ដែលគម្រោងនឹងផ្តល់ការដំឡើងការផ្គត់ផ្គង់ទឹកក្នុងស្រុកដោយផ្ទាល់ ឬនឹងធ្វើឱ្យប្រជាជនផ្លាស់ប្តូរទីលំនៅ (ឧទាហរណ៍នៅសម្បទានដីសង្គមកិច្ច) ទៅតំបន់ដែលពួកគេនឹងប្រើប្រាស់ការផ្គត់ផ្គង់ទឹកដែលមានស្រាប់ គម្រោងនឹងធ្វើការសាកល្បងដើម្បីធានាថាការផ្គត់ផ្គង់ទឹកមានគុណភាពទឹកអាចធ្វើទៅបាន។

182. គម្រោងនេះក៏នឹងធ្វើតេស្តតាមដានសម្រាប់ការចម្លងរោគបាក់តេរីនៃការដំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកជារៀងរាល់ឆ្នាំក្នុងអំឡុងពេលគម្រោង។ នៅកន្លែងដែលមានការចម្លងរោគ ត្រូវបានកំណត់ ការផ្គត់ផ្គង់ទឹកនឹងត្រូវបានសម្លាប់មេរោគ ហើយសហគមន៍នឹងត្រូវបានបណ្តុះបណ្តាលដើម្បីអនុវត្តនីតិវិធីនេះ។

183. នៅតំបន់ខ្លះនៃប្រទេសកម្ពុជា សារធាតុអាសេនិកធម្មជាតិនៅក្នុងទឹកក្រោមដី គឺជាគ្រោះថ្នាក់ដល់សុខភាពចំពោះអ្នកប្រើប្រាស់ទឹក។ វិធានការកាត់បន្ថយហានិភ័យ គឺត្រូវការជាចាំបាច់ដើម្បីធានាថាអ្នកទទួលផលពីគម្រោងជាពិសេសអ្នកទទួលដីដែលផ្លាស់ទៅទីតាំងសម្បទានដីសង្គមកិច្ច មិនត្រូវបានទទួលរងប៉ះពាល់ពីការផ្គត់ផ្គង់ទឹកកខ្វក់សម្រាប់ហេតុផលណាមួយនោះឡើយ។ ការផ្គត់ផ្គង់ទឹកក្រោមដីដែលមានទឹកជ្រៅ ត្រូវការធ្វើតេស្តអាសេនិក។ អនុលោមតាមបទដ្ឋានជាតិ (ពិធីសារ MRD) វិធានការខាងក្រោមនឹងត្រូវអនុវត្តៈ (i) អនុគម្រោងផ្គត់ផ្គង់ទឹកថ្មីធ្វើតេស្តទឹករួមមានអាសេនិក និងផ្ទៀតផ្ទាត់នឹងស្តង់ដាជាតិ (ii) ទំនាក់ទំនងលទ្ធផលតេស្តគុណភាពទឹកទៅអ្នកភូមិ និងជូនដំណឹងដល់ពួកគេថាតើទឹកនេះសមស្របសម្រាប់ផឹកឬអត់ (iii) ផ្តល់ដំបូន្មានលើជម្រើសប្រព្រឹត្តកម្មទឹកមូលដ្ឋានក្នុងករណីដែលប៉ារ៉ាម៉ែត្រលើសកម្រិតកំណត់ និង (iv) ក្នុងករណីដែលសារធាតុអាសេនិកខ្ពស់ជាងកម្រិតសុវត្ថិភាព ការធ្វើប្រព្រឹត្តកម្មទឹកដើម្បីបញ្ចេញនូវសារធាតុអាសេនិក មិនត្រូវបានណែនាំទេដោយសារតែថ្លៃដំឡើងខ្ពស់ ហើយតម្រូវការថែទាំខ្ពស់ ក៏ដូចជាកង្វះសមត្ថភាពក្នុងការដំណើរការ និងថែរក្សាប្រព័ន្ធផងដែរ។ ការផ្គត់ផ្គង់ជំនួសនូវទឹកដែលអាចបរិភោគបាននិងមានសុវត្ថិភាព នឹងត្រូវបានផ្តល់ជូនមុនពេលប្រជាជនផ្លាស់ប្តូរទីលំនៅទៅទីតាំងនោះ។

184. ប្រទេសកម្ពុជាមានអត្រាគ្រោះថ្នាក់ចរាចរណ៍ខ្ពស់ ដែលបណ្តាលមកពីការកើនឡើងយ៉ាងរហ័សនៃភាពជាម្ចាស់យានយន្ត យានជំនិះពុំមានលក្ខណៈពេញលេញ កង្វះចំណេះដឹង និងការប្រតិបត្តិច្បាប់ចរាចរណ៍ផ្លូវគោកដោយអ្នកប្រើប្រាស់ផ្លូវ ហើយពេលខ្លះហេដ្ឋារចនាសម្ព័ន្ធផ្លូវបានរចនា និងសាងសង់ឡើងដោយមានគុណភាពមិនសមស្រប។ គម្រោង ASED III នឹងគាំទ្រដល់ការអភិវឌ្ឍផ្លូវចូលទៅកាន់ទីតាំងដីសម្បទាន និងកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាផ្លូវនៅក្នុងតំបន់នោះ។ នេះបង្កើតជាហានិភ័យនៃការស្លាប់ និងរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍ និងតម្រូវការសម្រាប់យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ។

185. កង្វះអាហារូបត្ថម្ភរបស់កុមារគឺជាបញ្ហាដែលកំពុងបន្តកើតមាននៅតាមជនបទនៃប្រទេសកម្ពុជា និងមានមូលហេតុស្មុគស្មាញ រួមមានរបបអាហារប្រពៃណីការអនុវត្តការផ្តល់ចំណីដល់ទារក ក៏ដូចជាការទទួលបានអាហារបំប៉នដល់គ្រួសារក្រីក្រ។ ការផ្លាស់ប្តូរទៅទីតាំងសម្បទានដីសង្គមកិច្ចទំនងជាមានផលប៉ះពាល់គួរឱ្យកត់សម្គាល់លើរបបអាហាររបស់អ្នកទទួលដី ដែលអាចមានលក្ខណៈវិជ្ជមានសម្រាប់អាហារូបត្ថម្ភ ប៉ុន្តែអាចមានផលប៉ះពាល់អវិជ្ជមាននៅក្នុងកាលៈទេសៈខ្លះផ្សេង ទៀត។ ការបង្កើតសម្បទានដីសង្គមកិច្ច និងសកម្មភាពអភិវឌ្ឍន៍សហគមន៍នៅទីតាំងសម្បទានដី សង្គមកិច្ច និងកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចគឺជាឱកាសមួយដើម្បីដោះស្រាយបញ្ហាអាហារូបត្ថម្ភតាមរយៈការលើកកម្ពស់ការយល់ដឹង និងគាំទ្រដល់ការផលិតអាហារមានជីវជាតិនៅក្នុងសួនច្បារតាមផ្ទះ។

186. នៅតាមតំបន់ភាគច្រើនការថែរក្សាសុខភាពបឋមត្រូវបានបញ្ជូនតាមរយៈមណ្ឌលសុខភាពឃុំ ដែលជាធម្មតាស្ថិតនៅក្នុងតំបន់ដែលមានប្រជាជនច្រើនបំផុត និងអាចចូលទៅដល់បាន។ ទីតាំងសម្បទានដីសង្គមកិច្ច និង កម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច ច្រើនតែនៅឆ្ងាយពីមណ្ឌលសុខភាព ហើយលទ្ធភាពចូលប្រើប្រាស់អាចជួបការលំបាក។ គម្រោងLASED III មានជម្រើសក្នុងការកសាងប៉ុស្តិ៍សុខភាពនៅតាមទីតាំងគម្រោងនានា ប៉ុន្តែវាអាចជាការលំបាកក្នុងការទាក់ទាញបុគ្គលិកសុខាភិបាលដែលមានសមត្ថភាពមកធ្វើការនៅទីតាំងទាំងនេះ។ ការបង្កើនចម្ងាយពីសេវាកម្មសុខភាព នឹងបង្កើនផលប៉ះពាល់ដែលអាចកើតមានឡើងនៃគ្រោះថ្នាក់សុខភាព និងសុវត្ថិភាពដែលបានពិភាក្សាខាងលើ។

187. នៅក្នុងវិសាលភាពនៃបទដ្ឋានបរិស្ថាន និងសង្គមទី៤ ទីតាំងនានារួមមានមណ្ឌលសុខភាព សាលារៀន ការផ្គត់ផ្គង់ទឹក និងសេវាកម្មផ្សេងៗទៀតអាចជាការលំបាកសម្រាប់ជនពិការ ឬមនុស្សចាស់ក្នុងការចូលប្រើប្រាស់ លើកលែងតែមានវិធានការដាក់លាក់ណាមួយដើម្បីធានាដល់លទ្ធភាពចូលប្រើប្រាស់ទាំងអស់គ្នា។

188. អំពើហិង្សាផ្អែកលើយេនឌ័រ គឺជាបញ្ហាសង្គមដែលត្រូវបានគេទទួលស្គាល់នៅតាមជនបទនៃប្រទេសកម្ពុជា។ វិធានការបង្ការ និងកាត់បន្ថយគ្រោះថ្នាក់ជាទូទៅផ្អែកលើអន្តរាគមន៍របស់អាជ្ញាធរឬដោយគណៈកម្មាធិការស្ត្រី និងកុមារឃុំ (CWCC)។ ការកំណត់ទីតាំងគ្រួសារឡើងវិញទៅកាន់ទីតាំងសម្បទានដីសង្គមកិច្ច អាចធ្វើឱ្យការធ្វើអន្តរាគមន៍ទាំងនេះកាន់តែលំបាក ក៏ដូចជាការបង្កើតលទ្ធភាពដែលគ្រួសារមួយត្រូវបានគេដឹងថាមានហានិភ័យនៃអំពើហិង្សាផ្អែកលើយេនឌ័រ តាមការកំណត់ទីតាំងឡើងវិញ គឺត្រូវបានដកចេញពីក្របខណ្ឌនៃការគាំទ្រដែលមានស្រាប់។ ដូច្នេះគម្រោង LASED III នឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងយុទ្ធនាបង្កើនការយល់ដឹង ការបណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាន និងការគាំទ្រដល់ជន

រងគ្រោះតាមរយៈ គណៈកម្មាធិការស្ត្រី និងកុមារ ឃុំ នៅគ្រប់ទីតាំងដីសម្បទាន និងកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច។

189. គម្រោង LASED III នឹងគាំទ្រដល់ការងារសំខាន់ៗសម្រាប់ការឈូសឆាយដី និងសំណង់ហេដ្ឋារចនាសម្ព័ន្ធ។ ប្រសិនបើមិនត្រូវបានគ្រប់គ្រងឱ្យបានត្រឹមត្រូវទេ ការងារសាងសង់អាចនឹងបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់ប្រជាជនទូទៅ ឧទាហរណ៍ហានិភ័យដែលកើតឡើងនៅពេលកុមារកំពុងលេងនៅកន្លែងសំណង់ ឬនៅជុំវិញគ្រឿងម៉ាស៊ីនសំណង់។

190. ហានិភ័យសំខាន់ៗក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៤ ទាក់ទងនឹងតំបន់សកម្មភាពគម្រោង ដោយកម្រិតផលប៉ះពាល់ដែលបានវាយតម្លៃ លទ្ធភាពនិងគ្រោងយុទ្ធសាស្ត្រកាត់បន្ថយត្រូវបានសង្ខេបក្នុងតារាងទី ៦។

**តារាង ៦៖ខ្លឹមសារសង្ខេបនៃហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៤**

| ហានិភ័យ | តំបន់សកម្មភាព | កម្រិតផលប៉ះពាល់ | ប្រូបាបដែលនឹងអាចកើតមាន | យុទ្ធសាស្ត្រកាត់បន្ថយ |
|---|---|---|---|---|
| ការខូចខាតដោយទឹកជំនន់បណ្តាលមកពីការបាក់រលំទំនប់ទឹកគាំទ្រគម្រោង | ជាវាសាស្ត្រ ៤-p | កម្រិត ១ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ជានាការរៀបចំដោយសុវត្ថិភាព |
| ការខូចខាតដោយទឹកជំនន់បណ្តាលមកពីការបាក់រលំទំនប់ទឹកធំនៅខាងលើនៃទីតាំងគម្រោង | ការតាំងទីលំនៅ | កម្រិត ២/ កម្រិត ៣ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ការពិនិបឋមតាមទីតាំង<br>ការវាយតម្លៃហានិភ័យ<br>វិធានការកាត់បន្ថយផលប៉ះពាល់ |
| ការទទួលរងគ្រោះរបស់អ្នកទទួលផលគម្រោងដោយសារ ហានិភ័យអាកាសធាតុ (ទឹកជំនន់ និងគ្រោះរាំងស្ងួត) | ការតាំងទីលំនៅ | កម្រិត ២ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ការពិនិត្យបឋមតាមទីតាំង<br>ការវាយតម្លៃហានិភ័យ<br>វិធានការកាត់បន្ថយផលប៉ះពាល់ |
| ការរងរបួសជាលទ្ធផលពី ERW | សកម្មភាពគ្រប់ផ្នែក | កម្រិត ២ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ការពិនិត្យបឋមតាមទីតាំង និងវាយតម្លៃ ហានិភ័យ<br>នៅទីណាដែលសង្ស័យថាមាន ERW តំបន់នោះត្រូវតែបានសម្អាត និងបញ្ជាក់ថាមានសុវត្ថិភាពដោយភ្នាក់ងារមានសមត្ថកិច្ច មុនពេលចាប់ ផ្តើមសកម្មភាព<br>គម្រោងមានពិធីសារ ដែលត្រូវបានចែកផ្សាយទៅកាន់អ្នកទទួលផល និងអ្នកម៉ៅការ សម្រាប់ដោះ |

| | | | | |
|---|---|---|---|---|
| | | | | ស្រាយបញ្ហា ERW ដែលពួកគេបានជួបប្រទះដោយមិនបានរំពឹងទុក |
| ការឆ្លងរោគពីភ្នាក់ងារចម្លងជំងឺ | ការតាំងទីលំនៅថ្មី | កម្រិត ២ | ទំនងនឹងកើតឡើង តម្រូវឱ្យមានវិធានកាត់បន្ថយ | ការពិនិត្យបឋមតាមទីតាំង និងវាយតម្លៃ ហានិភ័យ<br>ការលើកកម្ពស់ការយល់ដឹង<br>ការលើកកម្ពស់ការយល់ដឹងសុខភាពសម្រាប់អ្នកទទួលផលគម្រោង រួមានការកាត់បន្ថយ ហានិភ័យភ្នាក់ងារចម្លងជំងឺ WASH, អាហា រូបត្ថម្ភ |
| ការឆ្លងរោគពីជំងឺចម្លងនៅក្នុងទឹក | ការតាំងទីលំនៅថ្មី | កម្រិត ២ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ការពិនិត្យបឋមតាមទីតាំង<br>វាយតម្លៃហានិភ័យ គ្រប់ប្រភពទឹកដែលបានធ្វើតេស្តសម្រាប់ As, ការបំពុលដោយសារជាតុគីមី និងការចម្លងរោគជីវសាស្ត្រ ការផ្គត់ផ្គង់ទឹកបរិភោគបានគ្រប់គ្រាន់ ត្រូវបានធានានៅគ្រប់ទីកន្លែង ការលើកកម្ពស់ការយល់ដឹង សកម្មភាព WASH យុទ្ធនាការអនាម័យការ អនុវត្តល្អប្រកបដោយប្រសិទ្ធភាពនៅគ្រប់ទីតាំង |
| ផលប៉ះពាល់សុខភាពដោយការផ្គត់ផ្គង់ទឹកដែលចម្លងរោគដោយសកម្មភាពនៅខាងលើ (ការជីករុករ៉ែ និងសារជាតុគីមីកសិកម្ម) ឬជាតិអាសេនិកដែលកើតមានដោយធម្មជាតិ | ការតាំងទីលំនៅថ្មី | កម្រិត ២/ កម្រិត ៣ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ការពិនិត្យបឋមតាមទីតាំង , ការធ្វើតេស្តផ្គត់ផ្គង់ទឹក, អនុវត្តពិធីសារ MRD, ធានាថាមានទឹកបរិភោគបាននៅគ្រប់ទីតាំង |
| ការរងរបួសពីគ្រោះថ្នាក់ចរាចរណ៍តាមផ្លូវ | ហេដ្ឋារចនាសម្ព័ន្ធផ្លូវ s-p<br>ការតាំងទីលំនៅថ្មី | កម្រិត ២ | ទំនងនឹងកើតឡើង តម្រូវឱ្យមានវិធានកាត់បន្ថយ | ផែនការសុវត្ថិភាពចរាចរណ៍ per s-p<br>ការលើកកម្ពស់ការយល់ដឹង |
| លើអាហារូបត្ថម្ភរបស់កុមារ | ការតាំងទីលំនៅថ្មី | កម្រិត ២ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ការបណ្តុះបណ្តាលអាហារូបត្ថម្ភ |
| ផលប៉ះពាល់អវិជ្ជមានដោយលទ្ធភាពចូលប្រើសេវាសុខាភិបាលត្រូវបានកាត់បន្ថយដោយសារទីតាំងឆ្ងាយ | ការតាំងទីលំនៅថ្មី | កម្រិត ២ | ទំនងនឹងកើតឡើង តម្រូវឱ្យមានវិធានកាត់បន្ថយ | ផ្តល់មណ្ឌលសុខភាពនៅទីណាដែលផ្តល់បាន |
| សេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដោយគម្រោងមិនអាចចូលទៅ | ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម s-p | កម្រិត ១ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ធានាបាននូវការចូលប្រើជាសកលនូវសេវាកម្មគម្រោងទាំងអស់ |

| | | | | |
|---|---|---|---|---|
| ដល់ដោយមនុស្សចាស់ ឬជនពិការបានឡើយ | | | | |
| លទ្ធភាពត្រូវបានកាត់បន្ថយក្នុងការគាំទ្រជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ | ការតាំងទីលំនៅថ្មី | កម្រិត ១ | ទំនងនឹងកើតឡើង តម្រូវឱ្យមានវិធានកាត់បន្ថយ | គាំទ្រ (បង្កើតបើចាំបាច់) CWCC ក្នុងការធ្វើយុទ្ធនាការអំពីអំពើហិង្សាផ្អែកលើយេនឌ័រ និងបង្កើតបណ្ដាញគាំទ្រជនរងគ្រោះ |
| ការរងរបួសដោយ ចៃដន្យដល់សាធារណៈជនរួមទាំងកុមារអំឡុងពេលសាងសង់សំណង់ | ហេដ្ឋារចនាសម្ព័ន្ធ s-p | កម្រិត ២ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ការគ្រប់គ្រងប្រកបដោយសុវត្ថិភាពនៅការពិពណ៌នាលម្អិត ESHS ផែនការសុវត្ថិភាពត្រូវបានរួមបញ្ចូលនៅក្នុងលក្ខណៈបច្ចេកទេស ESHS សម្រាប់ការងារ សំណង់។ នៅកន្លែងដែលមិនមានឧបសគ្គជាក់ស្តែងក្នុងការចូល អ្នកបញ្ជាសញ្ញាគួរតែមានវត្តមានជានិច្ចដើម្បីបញ្ចៀសសាធារណជន និងដាស់តឿនប្រតិបត្តិករម៉ាស៊ីនអំពីហានិភ័យ |

## ៤.៣.៥ បទដ្ឋានបរិស្ថាន និងសង្គមទី ៥ - លទ្ធកម្មដីធ្លី ការរឹតត្បិតលើការប្រើប្រាស់ដីធ្លី និងការតាំងទីលំនៅថ្មីដោយបង្ខំ

191. ហានិភ័យទាក់ទងនឹងការទទួលបានដី ការរឹតត្បិតការប្រើប្រាស់ដីធ្លី និងការតាំងទីលំនៅថ្មីដោយបង្ខំ ត្រូវបានវិភាគយ៉ាងលម្អិតជាមួយនឹងវិធានការកាត់បន្ថយហានិភ័យនៅក្នុង ក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង (RPF)។ ជាពិសេសគេកត់សម្គាល់ថានីតិវិធីប្រតិបត្តិការស្តង់ដាររបស់រាជរដ្ឋាភិបាលដើម្បីទទួលបានដី និងការតាំងទីលំនៅថ្មី (SOP-LAR) មិនមានភាពបន្សុីលើតម្រូវការនៃបទដ្ឋានបរិស្ថាន និងសង្គមទី ១, ទី ៥ និង ទី៧ទេ។

192. ក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង (RPF) បង្ហាញថាបទពិសោធន៍ដែលទទួលបានគម្រោង LASED និង LASED II ក្របខណ្ឌច្បាប់សម្រាប់ LAR និងការវិភាគគម្លាតនៃតំបន់ដែល SOP-LAR មិនបានធានាបាននូវការអនុលោមតាមបទដ្ឋានបរិស្ថាន និងសង្គមទី ១, ទី ៥ និង ទី៧។ ការពិពណ៌នាជាបន្តបន្ទាប់នៅក្នុង ក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង (RPF) នៃវិធានការដើម្បីបញ្ចៀស ឬកាត់បន្ថយ LAR ហើយចំណុចដែលមិនអាចរៀបចំ និងអនុវត្ត LAR រួមបញ្ចូលការវិភាគគម្លាតរវាងតម្រូវការ SOP-LAR និង បទដ្ឋានបរិស្ថាន និងសង្គមទី ១, ទី ៥ និង ទី៧។ កិច្ចព្រមព្រៀងហិរញ្ញប្បទាន LASED III នឹងយោងទៅតាមក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង (RPF) ដែលត្រូវបានទូទាត់ដោយធនាគារពិភពលោក ហើយបាន ឯកភាពជាមួយរដ្ឋាភិបាលកម្ពុជា ថាជាឧបករណ៍ដែលអាចអនុវត្តបានទាក់ទងនឹងការទទួលបានដី និងការតាំងទីលំនៅថ្មីសម្រាប់គម្រោងនេះ។ ប្រសិនបើគម្រោងសម្បទានដីសង្គមកិច្ច ជាក់លាក់ណាមួយ ឬអនុគម្រោងផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានរកឃើញថាតម្រូវឱ្យមានផែនការតាំងទីលំនៅថ្មីដើម្បីដោះស្រាយផលប៉ះពាល់នៃ LAR ផែនការទាំងនេះនឹងត្រូវបានរៀបចំឡើងដោយពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធ និងធនាគារពិភពលោ

ក។ សកម្មភាពគម្រោងដែលនឹងបង្កឱ្យមានការផ្លាស់ទីលំនៅនិង / ឬការផ្លាស់ទីលំនៅផ្នែកសេដ្ឋកិច្ចនឹងមិនចាប់ផ្តើមទេ រហូតដល់ផែនការជាក់លាក់បែបនេះត្រូវបានបញ្ចប់ពេញលេញ និងអនុម័តដោយធនាគារពិភពលោក។

193. ក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង (RPF) ពិពណ៌នាអំពីវិធានការរបស់គម្រោងដើម្បីបញ្ចៀស ឬកាត់បន្ថយនូវរាល់តម្រូវការសម្រាប់ការកាន់កាប់ដី និងការតាំងទីលំនៅថ្មីដោយបង្ខំ។ ដំណើរការជ្រើសសម្បទានសង្គមកិច្ច មានគោលបំណងដើម្បីកំណត់ដីរដ្ឋទំនេរដែលអាចត្រូវបានបម្រុងទុកសម្រាប់គ្រួសារក្រីក្រ។ ដូច្នេះដីដែលជាកម្មសិទ្ធិឯកជននិង / ឬការប្រើប្រាស់ ត្រូវបានដកចេញពីតំបន់សម្បទានដីសង្គមកិច្ច។ ស្រដៀងគ្នានេះដែរ ដំណើរការផ្តល់កម្មសិទ្ធិដី សមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច កំណត់ និងមិនរាប់បញ្ចូលដីកាន់កាប់ជាលក្ខណៈឯកជនពីតំបន់ ដើម្បីបញ្ចូលទៅក្នុងកម្មសិទ្ធិសមូហភាពសហគមន៍។

194. ជាគោលការណ៍ ការទទួលបានដី និងការតាំងទីលំនៅថ្មីដោយបង្ខំនៅក្នុងវិសាលភាពនៃ បទដ្ឋានបរិស្ថាន និងសង្គមទី ៥ អាចបណ្តាលមកពីសកម្មភាពគម្រោង LASED III នៅក្នុងស្ថានភាពដូចខាងក្រោម៖

(a) ដីដែលជាកម្មសិទ្ធិឯកជន កាន់កាប់ ឬប្រើប្រាស់ ទោះបីជាមានកម្មសិទ្ធិស្របច្បាប់ ឬអត់ ត្រូវបានចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ និងរួមបញ្ចូលក្នុងសម្បទានដីសង្គមកិច្ច ឬ ការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ។

(b) ដីសាធារណៈរបស់រដ្ឋដែលត្រូវបានប្រើសម្រាប់ប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម ដូចជាសកម្មភាពអនុផលព្រៃឈើ (NTFP) ត្រូវបានចាត់ថ្នាក់ឡើងវិញជាដីឯកជនរបស់រដ្ឋ និងត្រូវបានដាក់បញ្ចូលទៅក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬកម្មសិទ្ធិដី សមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ។ គេរំពឹងថាភាគច្រើននៃអ្នកដែលប្រើធនធានទ្រព្យសម្បត្តិរួម នៅពេលវាជាដីសាធារណៈរបស់រដ្ឋនឹងបន្តធ្វើដូច្នោះ ក្នុងនាមជាអ្នកទទួលសម្បទានដីសង្គមកិច្ច ឬសមាជិកសហគមន៍នៃកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច។ទោះយ៉ាងជាណាក៏ដោយ សម្រាប់ការចូលប្រើមួយចំនួនអាចត្រូវបានដាក់កម្រិត ឧទាហរណ៍អ្នកដែលមិនចង់ចូលរួមជាមួយសម្បទានដីសង្គមកិច្ច ឬអ្នកដែលមិនបំពេញតាមលក្ខណៈវិនិច្ឆ័យដែលក្នុងការទទួលបានសិទ្ធិ ឬក្នុងករណីការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច មិនមែនជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច។

(c) ដីដែលជាកម្មសិទ្ធិឯកជន កាន់កាប់ ឬប្រើប្រាស់ទោះបីជាកម្មសិទ្ធិស្របច្បាប់ ឬអត់ គឺចាំបាច់សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ ក្នុងករណីខ្លះ បញ្ហានេះអាចរួមបញ្ចូលទាំងដីនៅក្រៅព្រំដែននៃសម្បទានដីសង្គមកិច្ច ឬកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ដូចជាដីដែលត្រូវការសម្រាប់ការសាងសង់ ឬពង្រីកផ្លូវចូល ឬសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រ។

195. ដូចដែលបានរៀបរាប់នៅក្នុង ក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង (RPF) សំណើសុំការផ្តល់សម្បទានដីសង្គមកិច្ច និងការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច នឹងត្រូវបានត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នដើម្បីកំណត់អត្តសញ្ញាណដីដែលជាកម្មសិទ្ធិឯកជននិង / ឬប្រើប្រាស់។

ក្នុងករណីភាគច្រើន ដីបែបនេះនឹងត្រូវបានដកចេញពីតំបន់សម្បទានដីសង្គមកិច្ច ឬនិងកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច។ នៅពេលដែលវាត្រូវបានគេកំណត់ថាដីត្រូវបានប្រើសម្រាប់គោលបំណងធនធានទ្រព្យសម្បត្តិរួម គម្រោងនឹងកំណត់អ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម និងធានាថាពួកគេអាចទទួលបានសំណងដោយ (១) ការផ្តល់សិទ្ធិទទួលបានធនធាន និងធនធានជំនួស (២) ដោយបញ្ចូលជាអ្នកទទួលសម្បទានដីសង្គមកិច្ច ឬសមាជិកសហគមន៍នៃការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ឬ (៣) សំណងផ្សេងទៀតដែលស្មើនឹងការខាតបង់។

196. គម្រោង LASED III ក៏អាចទទួលបានដីតិចតួចតាមរយៈកិច្ចព្រមព្រៀងដែលអ្នកប្រើប្រាស់ដីដែលមានស្រាប់ ក្នុងការក្លាយជាអ្នកទទួលសម្បទានដីសង្គមកិច្ច ឬសមាជិកសហគមន៍នៃការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ឬតាមរយៈកិច្ចព្រមព្រៀងវិភាគទានដីធ្លីដោយស្ម័គ្រចិត្តស្របតាមបទដ្ឋានបរិស្ថាន និងសង្គមទី៥។

197. ក្នុងករណីដែលការទទួលបានដី និងការតាំងលំនៅថ្មីដោយបង្ខំមិនអាចបញ្ចៀសបាន (ឧទាហរណ៍ កន្លែងសម្បទានដីសង្គមកិច្ច ឬការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចមិនអាចសម្រេចទៅបាន) ផែនការដោះស្រាយផលប៉ះពាល់លើការផ្លាស់ទីលំនៅដោយសារគម្រោង (RP) នឹងត្រូវបានរៀបចំ និងអនុវត្តស្របតាមតម្រូវការនៃបទដ្ឋានបរិស្ថាន និងសង្គមទី៥។ នេះត្រូវបានពិភាក្សាបន្ថែមនៅក្នុងផ្នែកទី ៥ ខាងក្រោម។

198. ហានិភ័យសំខាន់ៗក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ ទាក់ទងនឹងតំបន់សកម្មភាពគម្រោង ដោយកម្រិតផលប៉ះពាល់ដែលបានវាយតម្លៃលទ្ធភាពនិងគ្រោងយុទ្ធសាស្ត្រកាត់បន្ថយត្រូវបានសង្ខេបក្នុងតារាងទី ៧។

| តារាង ៧៖ខ្លឹមសារសង្ខេបហានិភ័យនៃក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ | | | | |
|---|---|---|---|---|
| ហានិភ័យ | ផ្នែកសកម្មភាព | កម្រិតផលប៉ះពាល់ | ប្រូបាប | យុទ្ធសាស្ត្រកាត់បន្ថយ |
| ម្ចាស់កម្មសិទ្ធិដី / អ្នកប្រើប្រាស់ដីធ្លីពីមុនមក ដែលមានសិទ្ធិទទួលស្គាល់ដោយច្បាប់ភូមិបាលកម្ពុជាឆ្នាំ ២០០១ និង / ឬដោយ ESS5 (កាន់តែទូលំទូលាយនៅក្នុងករណីខ្លះ) បាត់បង់ដីដោយគ្មាននីតិវិធីផ្លូវច្បាប់ត្រឹមត្រូវ (ការពិគ្រោះយោបល់ ការព្រមព្រៀងដែលបានជូនដំណឹង) និង / ឬដោយគ្មានសំណងគ្រប់គ្រាន់ចំពោះបទដ្ឋានដែលតម្រូវដោយ ESS5 | SLC<br>ICLT | កម្រិត ២ | អាចកើតឡើង តម្រូវឱ្យមានវិធានការបញ្ចៀស | ការត្រួតពិនិត្យនិងវាយតម្លៃយ៉ាងហ្មត់ចត់ ចំពោះការទាមទារដីធ្លីដែលមានស្រាប់ |
| ប្រភេទអ្នកប្រើប្រាស់ដីផ្សេងទៀត ដែលមិនមែនជាម្ចាស់ ឬអ្នកកាន់កាប់ផ្ទាល់ (រួមទាំងអ្នកដែលប្រើដីសម្រាប់ | SLC<br>ICLT | កម្រិត ១ | អាចកើតឡើង តម្រូវឱ្យមាន | ប្រភេទនៃបណ្តឹងទាមទារសំណងដែលត្រូវបានទទួលស្គាល់ការផ្តល់ជូនតាមរយៈ (១) ការផ្តល់លទ្ធភាពទទួលបាន |

| | | | | |
|---|---|---|---|---|
| CPR) បាត់បង់លទ្ធភាពទទួលបាន និងមុខរបរចិញ្ចឹមជីវិត ដែលជាលទ្ធផលនៃការផ្ទេរទៅជាដី SLC។ | | | វិធានការបញ្ចៀស | ធនធានជំនួស (២) ចែករំលែកអត្ថប្រយោជន៍នៃគម្រោង ឬ (៣) សំណងផ្សេងទៀតដែលស្មើនឹងការខាតបង់ |
| ដី SLC ដែលត្រូវបែងចែកតាមរបៀបអយុត្តិធម៌ ឬមិនមានតម្លាភាព | SLC | កម្រិត ១ | អាចកើតឡើងតម្រូវឱ្យមានវិធានការបញ្ចៀស | ការអនុវត្តប្រកបដោយភាពប្រុងប្រយ័ត្ន និងតម្លាភាពនៃដំណើរការ SLC |
| សហគមន៍ជនជាតិដើមភាគតិចបាត់បង់ភាពជាម្ចាស់កម្មសិទ្ធិ/លទ្ធភាពទទួលបានដីដែលពួកគេគិតថាជាដីរបស់ពួកគេតាមបែបប្រពៃណី និងប្រើប្រាស់សម្រាប់មុខរបរចិញ្ចឹមជីវិត និងគោលបំណងវប្បធម៌ ដែលមិនត្រូវបានដាក់បញ្ចូលក្នុង ICLT | ICLT | កម្រិត ២ | អាចកើតឡើងតម្រូវឱ្យមានវិធានការបញ្ចៀស | ដំណើរការទៅមុខជាមួយ FPIC នៃជនជាតិដើមភាគតិច |
| ICLT ដំណើរការលទ្ធផលក្នុងការបែងចែកសិទ្ធិប្រើប្រាស់ឡើងវិញនៅក្នុងដីសហគមន៍ដោយមានផលប៉ះពាល់អវិជ្ជមានដល់អ្នកប្រើប្រាស់មួយចំនួន | ICLT | កម្រិត ១ | អាចកើតឡើងតម្រូវឱ្យមានវិធានការបញ្ចៀស | ជនជាតិដើមភាគតិចត្រូវបានគាំទ្រដោយស្មើភាពក្នុងការបែងចែកដី ប្រើប្រាស់សិទ្ធិតាមរយៈដំណើរការផ្ទៃក្នុង |
| ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនៅខាងក្រៅព្រំប្រទល់ SLC ឬ ICLT តម្រូវឱ្យមានការតាំងទីលំនៅថ្មីដោយបង្ខំ | Road s-p | កម្រិត ២ | អាចកើតឡើងតម្រូវឱ្យមានវិធានការបញ្ចៀស | រៀបចំនិងអនុវត្តផែនការតាំងទីលំនៅថ្មីក្រោមក្របខណ្ឌនៃនីតិវិធី SOP-LAR ប៉ុន្តែធានាបាននូវការអនុលោមតាមលក្ខខណ្ឌតម្រូវ ESS5 |

### ៤.៣.៦ បទដ្ឋានបរិស្ថាន និងសង្គមទី ៦ - ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតដោយនិរន្តរភាព

199. ទីតាំងសម្បទានដីសង្គមកិច្ច ត្រូវបានគេកំណត់អត្តសញ្ញាណនៅលើដីទំនេរ និងព្រៃល្បោះ ក្នុងភាពជាម្ចាស់កម្មសិទ្ធិសាធារណៈ ដែលក្នុងនោះឈើដែលមានតម្លៃត្រូវបានគេប្រមូលផល។ វាអាចទៅរួច ដែលដី ដែលត្រូវបានស្នើសុំសម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ច រាប់បញ្ចូលទាំងព្រៃដែលនៅសេសសល់ ដីសើម និងជម្រកសត្វព្រៃរួមទាំងដីដែលត្រូវបានគេទទួលស្គាល់ថាមានសារសំខាន់ចំពោះជីវចម្រុះ និងធនធានធម្មជាតិរស់នៅ ប៉ុន្តែមិនត្រូវបានទទួលស្គាល់ជាផ្លូវការនោះឡើយ។ តំបន់ទាំងនេះត្រូវបានកំណត់អត្តសញ្ញាណតាមរយៈការធ្វើផែនទីហាតស្ពត និងត្រូវបានដកចេញពីការផ្តល់សម្បទានដីសង្គមកិច្ច ដែលជាផ្នែកមួយនៃដំណើរការចុះបញ្ជីដីធ្លីរបស់រដ្ឋ ដោយប្រើនីតិវិធីដែលត្រូវបានបង្កើតឡើង និងបង្ហាញថាទទួលបានជោគជ័យក្រោមគម្រោង LASED និង LASED II។

200. ដីដែលបានស្នើសម្រាប់ការផ្តល់កម្មសិទ្ធដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ក៏អាចរាប់បញ្ចូលទាំងតំបន់សកម្មភាពសំខាន់ៗដែលមានសារសំខាន់សម្រាប់ជីវចម្រុះ និងការអភិរក្សធនធានធម្មជាតិ។ ជាទូទៅទីតាំងសំខាន់ៗ ទាំងនេះក៏នឹងត្រូវបានដកចេញពីកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគ

តិច នៅលើមូលដ្ឋានដូចគ្នានឹងការផ្តល់សម្បទានដីសង្គមកិច្ច។ ទោះយ៉ាងណាក៏ដោយករណី អាចកើតឡើងនៅតំបន់ដែលត្រូវបានចាត់ទុកថាជាទីតាំងសំខាន់របស់ក្រសួងដែលទទួលខុសត្រូវ ( ឧ. ក្រសួងបរិស្ថាន ) ប៉ុន្តែត្រូវបានសហគមន៍ជនជាតិដើមភាគតិចចាត់ទុកជាផ្នែកសំខាន់មួយនៃបេតិកភណ្ឌរបស់ពួកគេ។

| ជំហាន ៤៖ ការកំណត់អត្តសញ្ញាណដីរដ្ឋ, ការធ្វើផែនទី, ការធ្វើចំណាត់ថ្នាក់ និងចុះបញ្ជី | 4.1. រៀបចំផែនទីនៃ SLC ដែលបានស្នើឡើងនិងតំបន់ជុំវិញ៖<br>• ផែនទី LUP ផ្អែកលើ GIS<br>• ផែនទី 'ហតស្ពត' បរិស្ថាន<br>4.2. អនុវត្តការសិក្សាបច្ចេកទេស<br>4.3. ការស្ទង់មតិលម្អិត និងការធ្វើផែនទីនៃតំបន់ SLC ដែលបានស្នើឡើង<br>4.4. ផ្អែកលើផែនទី និងរូបភាពផ្កាយរណប ដោយប្រើប្រាស់ GPS, ក្រុមការងារនឹងកំណត់ព្រំដែននៃ និងនៅក្នុងតំបន់ SLC ដែលបានស្នើឡើង<br>4.5. ទម្រង់ត្រួតពិនិត្យការពារសុវត្ថិភាពត្រូវបានធ្វើបច្ចុប្បន្នភាព<br>4.6. កិច្ចប្រជុំថ្នាក់ខេត្ត ជាមួយមន្ទីរខេត្ត ពាក់ព័ន្ធ ដើម្បីពិនិត្យផែនទី របាយការណ៍ និងទម្រង់ការពារសុវត្ថិភាព។<br>4.7. នាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រធ្វើការស្ទង់មតិត្រឹមត្រូវអំពីព្រំដែនខាងក្រៅនិងខាងក្នុង<br>4.8. ការពិនិត្យបន្ថែម<br>• សវនកម្មផ្នែកបរិស្ថានដែលឯករាជ្យដើម្បីពិនិត្យមើលឡើងវិញលើ LUP ចុងក្រោយ<br>• អ្នកជំនាញផ្នែកបរិស្ថាននៃធនាគារពិភពលោក រៀបចំឡើងនូវការត្រួត ពិនិត្យភាពត្រឹមត្រូវ តាមរយៈការពិនិត្យបឋមតាមទីតាំងដោយចៃដន្យមុនពេលបញ្ចប់ដំណើរការ LUP។<br>4.9. សម្រេចចិត្តថាតើត្រូវយល់ព្រម ឬបដិសេធតំបន់ SLC ដែលបានស្នើឡើង<br>4.10. ផែនទីចុងក្រោយបានផ្ញើទៅ GDCG ដើម្បីពិនិត្យនិងបញ្ចប់។ | សម្រាប់ ESMP និង SEP តាមទីតាំង ត្រូវបានធ្វើបច្ចុប្បន្នភាពផ្អែកលើការវាយតម្លៃបរិស្ថានដែលរួមបញ្ចូលផែនទី និងការសិក្សាបច្ចេកទេសផ្សេងទៀត និងលទ្ធផលពីសវនកម្មបរិស្ថានឯករាជ្យ, ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និង (ប្រសិនបើអាចធ្វើទៅបាន)ការវាយតម្លៃផលប៉ះពាល់ថ្នាក់តំបន់/ជារួម។ |
| ជំហាន ៥. ការប្រើប្រាស់ដីធ្លី និងផែនការហេដ្ឋារចនាសម្ព័ន្ធដែលមានការចូលរួម | 5.1. អនុវត្ត SLC AEA លម្អិតដែលរាប់បញ្ចូលទាំងកត្តាការពារសុវត្ថិភាពបរិស្ថាន និងបង្កើនគុណភាពនៃការត្រួតពិនិត្យការការពារសុវត្ថិភាព និងសមត្ថភាពអនុវត្ត របស់ SLC<br>5.2. អនុវត្តការវាយតម្លៃតម្រូវការហេដ្ឋារចនា សម្ព័ន្ធ | • កំណត់តំបន់ទ្រនាប់រវាងតំបន់គម្រោង និងហតស្ពតដែលបានកំណត់ (ក្នុងករណីទីទាំងទាំងនោះស្ថិតនៅជាប់នឹងហតស្ពតទាំងនេះ)<br>• ធ្វើបច្ចុប្បន្នភាព ESMP តាមទីតាំងដោយដាក់បញ្ចូល AEA លម្អិត, សមត្ថភាពអនុ |

| តារាង ១៣. កៈ ការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំងសម្រាប់ SLCs ថ្មីៈដំណើរការ និងការវិនិយោគ SLC | | |
|---|---|---|
| | 5.3. ក្រុមការងារថ្នាក់ស្រុក និង ក្រុមប្រឹក្សាឃុំពិនិត្យផែនទី SLC ដើម្បីដោះស្រាយៈ ផលប៉ះពាល់ដែលអាចកើតមានលើការប្រើប្រាស់ដីធ្លីបច្ចុប្បន្ន និងតំបន់ជុំវិញ<br>5.4. ទម្រង់ពិនិត្យការពារសុវត្ថិភាពត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីធានាថាការរកឃើញពី AEA ឆ្លុះបញ្ចាំងពីបញ្ហាដែលបានកំណត់នៅក្នុងទម្រង់ | វត្តន៍បរិស្ថាន, និងលទ្ធផលពីការវាយតម្លៃតម្រូវការហេដ្ឋារចនា សម្ព័ន្ធ<br>• ផ្អែកលើលទ្ធផលនៃការវាយតម្លៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធនៅក្នុងទីតាំងនីមួយៗ អនុវត្តនីតិវិធីត្រួតពិនិត្យបឋមបរិស្ថានសម្រាប់អនុគម្រោង។<br>• បញ្ជូនលទ្ធផលទម្រង់ត្រួតពិនិត្យនៃអនុគម្រោងសម្រាប់ទីតាំងនីមួយៗទៅធនាគារដោយសម្រេចគ្មានការជំទាស់ |
| ជំហាន ៦. ការពិនិត្យ និងសម្រេចនៃរបាយការណ៍ SLC ឃុំ | 6.1. ការបែងចែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសេវាកម្ម<br>6.2. របាយការណ៍ SLC ក្នុងការដាក់បញ្ចូលបញ្ហាការពារសុវត្ថិភាព | 1. បញ្ចប់សេចក្តីព្រាងនៃ ESMP ទីតាំងជាក់លាក់ រួមបញ្ចូលប្រភេទហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទដែលបានកំណត់សម្រាប់ SLC និង SEP នីមួយៗសម្រាប់ទីតាំងដែលបានកំណត់នីមួយៗ និង ឧបករណ៍ផ្សេងទៀត (បើចាំបាច់) ផ្អែកលើលទ្ធផលនៃការជ្រើសរើសអនុគម្រោង។<br>2. ដាក់ស្នើកំណែចុងក្រោយនៃ ESMP ទៅធនាគារដើម្បីសម្រេចដោយគ្មានការជំទាស់<br>3. សម្រាប់ទីតាំង SLC ដែលជាប់នឹង ហតស្តុតជីវជម្រុះ៖<br>• បង្កើតតំបន់ទ្រនាប់<br>• យន្តការ និងការគាំទ្រដើម្បីគ្រប់គ្រង NR មូលដ្ឋានប្រកបដោយចីរភាព<br>• ការលើកកម្ពស់ការយល់ដឹងសម្រាប់ការអភិរក្សជីវចម្រុះ<br>• ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍឃុំ<br>• ការដាំដើមឈើក្នុងតំបន់រួម។ |
| ជំហាន ៧.ការជ្រើសរើសអ្នកទទួលដី | | |
| ជំហាន ៨. ការរៀបចំផែនការ SLC ពេញលេញ | 8.1. ដីឡូតិ៍ SLC បែងចែកទៅតាមគ្រួសារ<br>8.2. កិច្ចប្រជុំថ្នាក់ឃុំដើម្បីពិភាក្សា<br>• ផែនទីចុងក្រោយបង្ហាញពីតំបន់ដែលត្រូវបានកំណត់សម្រាប់ការប្រើប្រាស់កសិកម្ម ការអភិរក្ស / ព្រៃសហគមន៍ / របៀងជីវចំរុះ តំបន់ទ្រនាប់<br>• ការការពារសុវត្ថិភាពបរិស្ថាន | 1. រៀបចំឧបករណ៍ ES សម្រាប់អនុគម្រោង / ការវិនិយោគ (រួមបញ្ចូលការរកឃើញពីការសិក្សា និងការវាយតម្លៃដែលបានធ្វើឡើងនៅក្នុងជំហាន មុន ៗ)<br>• ប្រសិនបើ EIA៖អ្នកជំនាញផ្នែក បរិស្ថានអន្តរជាតិនឹងត្រូវចូលរួម។ |

| តារាង ១៣. កៈ ការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំងសម្រាប់ SLCs ថ្មីៈដំណើរការ និងការវិនិយោគ SLC | | |
|---|---|---|
| | • ការប៉ាន់ស្មានសមត្ថភាពអនុវត្តន៍ | • ប្រសិនបើ ESMP/ECoP នៃអនុគម្រោងៈ ធ្វើតាមទម្រង់តាមប្រភេទដែលបានពិពណ៌នានៅក្នុងឧបសម្ព័ន្ធទី៦ និងឧបសម្ព័ន្ធទី ៧<br>2. ការយល់ព្រមៈ<br>• ប្រសិនបើ EIAៈ TOR និងឯកសារព្រាងនឹងត្រូវបានត្រួតពិនិត្យនិងសម្រេចដោយធនាគារពិភព លោក។<br>• ប្រសិនបើ ESMP/ECoPៈទីប្រឹក្សាផ្នែកគ្រប់គ្រងហានិភ័យបរិស្ថាននៃគម្រោង LASED-III នឹងត្រូវពិនិត្យ និងសម្រេចលើឯកសារ។<br>3. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មានៈ<br>• ប្រសិនបើ EIAៈ ២ ដង(សេចក្តីព្រាង និងឯកសារកំណែដំណាក់កាលចុងក្រោយ)<br>• ប្រសិនបើ ESMP/ECoPៈ១ ដង (ឯកសារកំណែដំណាក់កាលចុងក្រោយ) |
| ជំហាន ៩. ការរៀបចំការកម្មសិទ្ធិផ្ទេរដី | 9.1. ព្រំប្រទល់ដីឡូតិ៍ SLC ត្រូវបានកំណត់<br>9.2. ការរៀបចំទីតាំង និងហេដ្ឋារចនា សម្ព័ន្ធមូលដ្ឋាន | |
| ជំហាន ១០. ជំនួយក្នុងការដោះស្រាយ និងការអភិវឌ្ឍជនបទរយៈពេលវែង | ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទបានផ្តល់ជូន | អនុវត្តការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម<br>ឧបករណ៍ទាក់ទងនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ(សមាសភាព២) និងការអភិវឌ្ឍកសិកម្ម និងមុខរបរចិញ្ចឹមជីវិត (សមាសភាព ៣) |

231. សម្រាប់ទីតាំង *SLC* ដែលមានស្រាប់ចំនួន១៤, បច្ចុប្បន្នគ្របដណ្តប់ដោយគម្រោង LASED II ( សូមមើលតារាង ២ក ), គម្រោងនេះនឹងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍរួមមាន ប្រព័ន្ធធារាសាស្រ្តខ្នាតតូច និងផ្លូវចូលទៅធ្វើកសិកម្ម។ ការគាំទ្រការអភិវឌ្ឍនឹងត្រូវអនុវត្តតាមតារាង ១៣. ខ។

**តារាង ១៣. ខ៖ ការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំងសម្រាប់ SLCs ដែលមានស្រាប់៖ ការគាំទ្រ/ការវិនិយោគការអភិវឌ្ឍ**

| ដំណើរ | ឧបករណ៍គ្រប់គ្រងហានិភ័យ | កំណត់សម្គាល់ |
|---|---|---|
| 1. ការពិនិត្យបឋមកម្រិតទីតាំង | ការពិនិត្យបឋមកម្រិតទីតាំងដោយប្រើទម្រង់ដូចគ្នានឹងទម្រង់សម្រាប់ទីតាំង SLC ថ្មី។ | លទ្ធផលនៃការពិនិត្យបឋមនឹងត្រូវបានប្រើដើម្បីកំណត់ហានិភ័យ សំខាន់ៗដែលមិនត្រូវបានដោះស្រាយដោយសកម្មភាព LASED មុនៗនៅតាមទីតាំងនីមួយៗ។<br>វាមិនត្រូវបានគេរំពឹងថាការរៀបចំ ESMP តាមទីតាំងជាក់លាក់នឹងត្រូវការជាចាំបាច់នោះទេ ប៉ុន្តែនេះនឹងត្រូវបានផ្ទៀងផ្ទាត់សម្រាប់ទីតាំងនីមួយៗដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យដោយទីប្រឹក្សាគ្រប់គ្រងហានិភ័យថ្នាក់ជាតិ។ |
| 2. ការពិនិត្យបឋមកម្រិត អនុគម្រោង | 2.1. ការពិនិត្យបញ្ជីប៉ះពាល់អវិជ្ជមាន | មិនរាប់បញ្ចូលសកម្មភាពនៅក្នុងបញ្ជីផលប៉ះពាល់អវិជ្ជមាន។ សូមមើលតារាងទី ១៥ ស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការងារជាសាស្ត្រ |
| | 2.2. ទម្រង់បែបបទនៃការពិនិត្យបឋមសម្រាប់កម្រិតអនុគម្រោង (ឧបសម្ព័ន្ធទី ៦) ដើម្បីកំណត់អត្តសញ្ញាណឧបករណ៍ES ដោយផ្អែកលើផលប៉ះពាល់ដែលអាចកើតមាន | EIA / ESMP / ECoP(ថ្នាក់តំបន់)<br>សូមមើលឧបករណ៍គ្រប់គ្រង ហានិភ័យES |
| 3. រៀបចំឧបករណ៍ ES | ប្រសិនបើ EIA៖ អ្នកជំនាញផ្នែក បរិស្ថានអន្តរជាតិនឹងត្រូវចូលរួមដើម្បីគាំទ្រការអភិវឌ្ឍ EIA (ថ្នាក់តំបន់)។<br>ប្រសិនបើអនុគម្រោង ESMP/ECoP៖ តាមទម្រង់តាមប្រភេទដែលបានពិពណ៌នានៅក្នុងឧបសម្ព័ន្ធទី៦ និង ឧបសម្ព័ន្ធទី ៧ | ដាក់បញ្ចូល៖<br>• ESMP តាមទីតាំង<br>• ការសិក្សាបច្ចេកទេសដែលមានស្រាប់ក្នុងអំឡុងពេលដំណើរការ ១០ ជំហានដែលធ្វើឡើងនៅក្នុងគម្រោង LASED-II។ |
| 4. ការយល់ព្រម/សម្រេច | EIA៖ TOR និងឯកសារព្រាងនឹងត្រូវបានត្រួតពិនិត្យនិងសម្រេចដោយធនាគារពិភពលោក។<br>ESMP/ECoP៖ទីប្រឹក្សាផ្នែកគ្រប់គ្រងហានិភ័យបរិស្ថាននៃគម្រោង LASED-III នឹងត្រូវពិនិត្យ និងសម្រេចលើ ឯកសារ។ | |

| | | |
|---|---|---|
| 5. ការពិគ្រោះយោបល់ និងផ្សព្វផ្សាយ | EIA៖ ២ ដង(សេចក្តីព្រាង និងឯកសារកំណែចុងក្រោយ)<br><br>ESMP/ECoP៖១ ដង (ឯកសារកំណែចុងក្រោយ) | សូមមើល ESF និងការណែនាំ EIA ថ្នាក់ជាតិរបស់ធនាគារពិភពលោក |
| 6. ការចូលរួមរបស់អ្នកម៉ៅការ | បញ្ញត្តិគ្រប់គ្រងបរិស្ថានត្រូវបានដាក់បញ្ចូលនៅក្នុងឯកសារដេញថ្លៃ | ទីប្រឹក្សាផ្នែកគ្រប់គ្រងហានិភ័យបរិស្ថាននៃគម្រោង LASED-III នឹង ពិនិត្យដំណាក់កាល។<br><br>អ្នកជំនាញផ្នែកបរិស្ថាននៃធនាគារពិភពលោកដែលត្រូវបានចាត់តាំងសម្រាប់គម្រោងនឹងពិនិត្យឡើងវិញឯកសារចៃដន្យសម្រាប់ការធានាគុណភាព។ |
| 7. ការអនុវត្តៈការពិនិត្យតាមដាន និងរបាយការណ៍ | លទ្ធផលនៃការពិនិត្យតាមដានផ្នែកបរិស្ថាននឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធរបាយការណ៍ជាប្រចាំរបស់គម្រោង។ | បុគ្គលិកបង្គោល ES, អ្នកជំនាញ ES RM ថ្នាក់ខេត្ត, និងទីប្រឹក្សាគ្រប់គ្រងហានិភ័យបរិស្ថាន នឹងពិនិត្យតាមដានការអនុវត្តនៃវិធានការកាត់បន្ថយផលប៉ះពាល់ជាប្រចាំ។ |

*228.* គម្រោងនេះក៏នឹងគាំទ្រដល់សកម្មភាពនានា ដើម្បីដោះស្រាយហានិភ័យទាក់ទងនឹងសុខភាពរបស់សហគមន៍សំខាន់ៗ (ការផ្គត់ផ្គង់ទឹកស្អាត អនាម័យ ការគ្រប់គ្រងសំណល់រឹងការកាត់បន្ថយអំពើហិង្សាផ្អែកលើយេនឌ័រ) ទៅតាមបទដ្ឋានដូចគ្នានឹងត្រូវបានអនុវត្តនៅក្នុងការផ្តល់សម្បទានដីសង្គមកិច្ចថ្មី។ ការពិនិត្យបឋមតាមទីតាំង សម្រាប់ហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នឹងត្រូវអនុវត្តនៅតាមទីតាំងដែលមានស្រាប់ដោយប្រើទម្រង់ដូចគ្នានឹងទីតាំងថ្មី ហើយលទ្ធផលនឹងត្រូវបានប្រើដើម្បីកំណត់ហានិភ័យសំខាន់ៗដែលមិនត្រូវបានដោះស្រាយដោយសកម្មភាព LASED មុននៅទីតាំងនោះ។ វាមិនត្រូវបានគេរំពឹងថាការរៀបចំ ESMP តាមទីតាំងនឹងត្រូវការជាចាំបាច់នោះទេ ប៉ុន្តែនេះនឹងត្រូវបានផ្ទៀងផ្ទាត់សម្រាប់ទីតាំងនីមួយៗ ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ ដោយទីប្រឹក្សាគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមថ្នាក់ជាតិ។ វិធានការគ្រប់គ្រងហានិភ័យហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម លម្អិតនឹងត្រូវបានបង្កើតឡើងក្នុងបរិបទនៃ (១) អនុគម្រោងដែលត្រូវការដោះស្រាយហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម ដែលបានកំណត់ដោយផ្ទាល់ និង (២) ការត្រួតពិនិត្យទាក់ទងនឹងបរិស្ថាន និងសង្គម ការវាយតម្លៃហានិភ័យ និងការរៀបចំ ESMP តាមដែលត្រូវការសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងមុខរបរចិញ្ចឹមជីវិត។ វិធានការពិនិត្យ និងគ្រប់គ្រងហានិភ័យសម្រាប់ទីតាំងដែលមានស្រាប់នឹងរួមបញ្ចូលៈ

(a) ធានាថាសកម្មភាពដែលបានស្នើមិនមាននៅក្នុងបញ្ជីផលប៉ះពាល់អវិជ្ជមានឡើយ

(b) វិធានការគ្រប់គ្រងហានិភ័យផ្សេងទៀតដែលពាក់ព័ន្ធនឹងសកម្មភាពដែលបានស្នើឡើង

(c) វិធានការដែលមានបច្ចុប្បន្នភាពសម្រាប់ធានាការផ្គត់ផ្គង់ទឹកក្នុងស្រុកប្រកបដោយសុវត្ថិភាព អនាម័យ និងការគ្រប់គ្រងសំណល់រឹង។

### ៥.៣.២ ការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច (ICLT)

229. ដំណើរការទូទៅសម្រាប់ជនជាតិដើមភាគតិចដើម្បីទទួលបានបណ្ណកម្មសិទ្ធិសមូហភាព រួមមាន ៣ ដំណាក់កាលសំខាន់ៗ (សូមមើលតារាង ១ ខ)៖ (១) ការទទួលស្គាល់ក្រុមមនុស្សជាក់លាក់មួយដែលជាសហគមន៍ជនជាតិដើមភាគតិច ឬ IC ដោយក្រសួងអភិវឌ្ឍន៍ជនបទ / MRD (២) ផ្តល់ឋានៈស្របច្បាប់ដោយក្រសួងមហាផ្ទៃ / MOI និង (៣) ការចុះបញ្ជីដីធ្លីដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)។ ដំណើរការនេះត្រូវចំណាយពេលប្រហែល ២៤ ខែដើម្បីបញ្ចប់។

230. ***សម្រាប់ទីតាំងនៃការផ្តល់សម្បទានដីសង្គមកិច្ចចំនួន ១៥*** គម្រោង LASED III នឹងផ្តល់ការគាំទ្រដល់ដំណើរការផ្តល់កម្មសិទ្ធិ និងការអភិវឌ្ឍ ដែលមានសិទ្ធិទទួលបានការគាំទ្រនេះ នឹងឈានដល់ទីបញ្ចប់នៃដំណាក់កាលទី ២.៥ (ឧទាហរណ៍ពាក្យសុំ ICLT ត្រូវបានបញ្ជូនទៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - សូមមើលតារាង ១ ខ) ប៉ុន្តែមិនទាន់បានទទួលបណ្ណកម្មសិទ្ធិដីធ្លីនៅឡើយ។ ផ្អែកលើតួលេខពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រហូតដល់ខែមករាឆ្នាំ២០២០ វាបង្ហាញថាអាចមាន IC/ICLT ចំនួន ១១១ ហើយដែលបានស្ថិតនៅក្នុងដំណាក់កាលទី៣ និងមានសិទ្ធិទទួលបានការគាំទ្រ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងទាក់ទងសហគមន៍ជនជាតិដើមភាគតិច ដែលមានសិទ្ធិទាំងអស់ហើយអញ្ជើញពួកគេឱ្យស្នើសុំជំនួយគម្រោង។ ICLT ចំនួន១៥ ដែលត្រូវគាំទ្រនឹងត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរួមទាំងការចាប់អារម្មណ៍ក្នុងការចូលរួមក្នុងគម្រោង និងដីដែលមាន។

231. សម្រាប់ ICLT នីមួយៗ ដែលបានកំណត់ជាបណ្តោះអាសន្នសម្រាប់ការគាំទ្រគម្រោង គម្រោងនឹងធ្វើការត្រួតពិនិត្យដោយយកចិត្តទុកដាក់លើលទ្ធផលនៃជំហាន នៃដំណើរការរបស់ ICLT ដែលបានបញ្ចប់រួចរាល់នៅទីតាំងនោះ។ នេះនឹងរួមបញ្ចូល (i) ភាពតំណាងសង្គម និងបរិយាប័ន្ននៃគណៈ កម្មាធិការសហគមន៍ជនជាតិដើមភាគតិច (IPCC) (ii) ថាតើច្បាប់សហគមន៍ទទួលបានផលប្រយោជន៍ពីសំណុំរងនៃសង្គមផ្សេងៗគ្នានៃសហគមន៍ជនជាតិដើមភាគតិច (ដំណាក់កាលទី ២ ជំហានទី ៣) ឬអត់ និង (iii) ការវាយតម្លៃប្រហាក់ប្រហែលនៃវិធានផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិច (បានបង្កើតឡើងនៅដំណាក់កាលទី ២.៥, ជំហានទី ១)។ ផ្អែកលើការរកឃើញនៃការត្រួតពិនិត្យដោយយកចិត្តទុកដាក់ គម្រោងនឹងត្រូវបានកំណត់ថាតើសហគមន៍ជនជាតិដើមភាគតិចចាំបាច់ត្រូវចូលរួមក្នុងដំណើរការពិគ្រោះយោបល់ / FPIC ដើម្បីពិនិត្យ និងកែសម្រួលច្បាប់និងគណៈកម្មាធិការសហគមន៍ជនជាតិដើម ភាគតិច (IPCC) ដើម្បីធានាបាននូវសំឡេង និងការទទួលបានអត្ថប្រយោជន៍ពីគម្រោងដោយសមធម៌។ ប្រសិនបើការប្តេជ្ញាចិត្តនេះត្រូវបានធ្វើឡើងបន្ទាប់មកការដាក់បញ្ចូល ICLT នៅក្នុងគម្រោង នឹងមានលក្ខខណ្ឌដែលសហគមន៍យល់ព្រមនឹងការពិនិត្យ និងកែសម្រួលឡើងវិញ។

232. ការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នឹងរួមបញ្ចូលធាតុស្រដៀងនឹងធាតុដែលបានអនុវត្តក្រោមការផ្តល់ទីតាំងនៃការផ្តល់សម្បទានដីសង្គមកិច្ចថ្មី ( ឧ. ការពិនិត្យបឋមកម្រិតទីតាំង, EA, ផែនការសម្រាប់គ្រប់គ្រងបរិស្ថាននិងសង្គមតាមទីតាំង, ការពិនិត្យបឋមកម្រិតអនុគម្រោង )។ផ្អែកលើទម្រង់នៃការត្រួតពិនិត្យទាក់ទងនឹងបរិស្ថាន និងសង្គម និងនៅលើការគូសផែនទី រួមទាំងការកំណត់អត្តសញ្ញាណនៃហតស្ពតបរិស្ថាន នៅតាមតំបន់ ICLT នីមួយៗ គម្រោងនឹងកំណត់ធនធានធម្មជាតិក្នុងតំបន់ និងតំបន់អភិរក្សសំខាន់ៗ។ នៅពេលដែលបានកំណត់អត្តសញ្ញាណ គម្រោងនឹងជួយសម្រួលដល់ការពិភាក្សាជាមួយអាជ្ញាធរ ដើម្បីយល់ព្រមលើតួនាទីរបស់ជនជាតិដើមភាគតិច ក្នុងការគ្រប់គ្រងតំបន់ទាំងនេះ។ ផែនការសម្រាប់គ្រប់គ្រងបរិស្ថាន និងសង្គម តាមទីតាំង នឹងគូសបញ្ជាក់ពីការផ្តល់នូវយន្តការ និងការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ដើម្បីគ្រប់គ្រងតំបន់អភិរក្សសំខាន់ៗ ក្នុងតំបន់ក៏ដូចជាកម្មវិធីលើកកម្ពស់ការយល់ដឹងសម្រាប់ការអភិរក្សជីវចម្រុះ។

| **តារាងទី ១៤៖ វិធានការគ្រប់គ្រងហានិភ័យកម្រិតទីតាំងសម្រាប់ការផ្តល់បណ្ណកម្មសិទ្ធិដីសហគមន៍ថ្មី** | |
|---|---|
| ដំណាក់កាលទី ៣៖ ការចុះបញ្ជីដីធ្លី | វិធានការគ្រប់គ្រងហានិភ័យ (សម្រាប់គម្រោង LASED III ដែលបានស្នើសុំ) |
| ការចាប់ផ្តើមចូលរួមគម្រោង (អាចជាជំហានណាមួយក្នុងដំណាក់កាលទី ៣) | ការត្រួតពិនិត្យដោយមានការយកចិត្តទុកដាក់ដើម្បីផ្ទៀងផ្ទាត់ថាតើលទ្ធផលដំណាក់កាលទី ១ និងទី ២ អនុលោមតាមតម្រូវការ ESS៧ សម្រាប់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យទាក់ទងនឹងលទ្ធផលនៃដំណាក់កាលទាំង ២ នោះគឺ គណៈកម្មាធិការតំណាងសហគមន៍ (CRC) រួមបញ្ចូលនូវបរិយាប័ន្នយេនឌ័រ និងសង្គម និងច្បាប់សហគមន៍ និងវិធានផ្ទៃក្នុងដែលដោះស្រាយផលប្រយោជន៍របស់ស្ត្រី និងអ្នកក្រ។ បើមិនដូច្នោះទេ សូមពិនិត្យឡើងវិញនូវសមាសភាពរបស់ CRC និង / ឬខ្លឹមសារនៃច្បាប់សហគមន៍ និងវិធានផ្ទៃក្នុងដោយផ្អែកលើ FPIC។ |
| **ជំហានទី ១៖** ការវាស់វែងនិងការប្រមូលទិន្នន័យព្រំដែនព្រំដែនតាមប្រភេទការប្រើប្រាស់ ការកំណត់ព្រំដែន និងការកំណត់អត្តសញ្ញាណដីរដ្ឋ | ដំណើរការត្រួតពិត្យដោយប្រើឧបករណ៍ដូចខាងក្រោម:<br>• ផែនទីខេត្ត 'ហតស្ពត' ដែលបង្ហាញអំពីព្រំប្រទល់ដីតំបន់ជុំវិញតំបន់ ខ្សែទឹក ខាងលើនិងខាងក្រោម<br>• គម្រោងដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធពីឃ្លាំងទិន្នន័យជីវចម្រុះដែលមាន ( ឧ. IBAT )<br>ផ្អែកលើផែនទី GIS និងរូបភាពផ្កាយរណប ក្រុមការងារគម្រោងនឹងកំណត់តំបន់សម្រាប់ការពិចារណាលើផលប៉ះពាល់លើជីវចម្រុះ<br>ក្រុមវាយតម្លៃវាយតម្លៃទៅ៖ (១) ផ្ទៀងផ្ទាត់ដីធ្លីនិងព្រំដែនរបស់វា (២) កំណត់តំបន់អភិរក្សនិងតំបន់ការពារសំខាន់ៗនិង (៣) សម្រេចចិត្តថាតើ ESIA ក្នុងតំបន់នឹងត្រូវការឬអត់<br>នាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រដើម្បីធ្វើការស្ទង់មតិអំពីព្រំដែនខាងក្រៅនិងខាងក្នុង |
| ជំហានទី ២៖ ការបង្ហាញជាសាធារណៈនូវឯកសារវាយតម្លៃដីធ្លី | |
| ជំហានទី ៣៖ ការរាយការណ៍អំពីលទ្ធផលនៃការបង្ហាញឯកសារវាយតម្លៃ ដីធ្លី | |
| ជំហានទី ៤ ៖ ប្រជុំជាមួយគណៈកម្មការដីធ្លីខេត្តរបស់រដ្ឋដើម្បីសម្រេចលើរបាយការណ៍ស្តីពីលទ្ធផលនៃការបង្ហាញជាសា | |

| | |
|---|---|
| ជារណៈនៃការវាយតម្លៃដីធ្លីនិងស្នើសុំឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញ បណ្ណកម្មសិទ្ធិដីធ្លីដល់សហគមន៍ IP។ | |
| ជំហានទី ៥៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញលិខិតមួយទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទដោយស្នើសុំការត្រួតពិនិត្យនិងការយល់ព្រមពីដីពាក់ព័ន្ធ។ | • រៀបចំឧបករណ៍គ្រប់គ្រងហានិភ័យ ES: ESMP ទីតាំងជាក់លាក់។<br>• ឧបករណ៍នឹងត្រូវបានរៀបចំដោយផ្អែកលើការសិក្សាបច្ចេកទេស ផែនទី និងការវាយតម្លៃដែលពាក់ព័ន្ធ (ឧទាហរណ៍ការវាយតម្លៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធ។ល។)។ សម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន ESMPនេះ នឹងគ្របដណ្ដប់ក្នុងចំណោមឧបករណ៍ដទៃទៀតប៉ុន្តែមិនមានកំណត់ត្រឹមនេះទេ៖<br>• ការកំណត់អត្តសញ្ញាណធនធានធម្មជាតិក្នុងតំបន់និងតំបន់អភិរក្ស សំខាន់ៗក្នុងព្រំដែន ICLT និងជាប់នឹងទីតាំងគម្រោង។<br>• ផែនការគ្រប់គ្រងព្រៃឈើឬ PA, កិច្ចព្រមព្រៀងពាក់ព័ន្ធព្រៃឈើ ឬ នេសាទរបស់សហគមន៍ ឬការរៀបចំការគ្រប់គ្រងធនធានស្រដៀងគ្នាផ្សេងទៀត។<br>• បញ្ញត្តិនៃយន្តការនិងការគាំទ្រដល់ ICs ដើម្បីគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនឹងត្រូវបានពិពណ៌នាយ៉ាងច្បាស់នៅក្នុង ឧបករណ៍។<br>• ធនាគារពិភពលោកនឹងពិនិត្យឡើងវិញ និងអនុញ្ញាតឧបករណ៍ ES ទាំង អស់។<br>• ក្រសួងបរិស្ថាន និងMoFF នឹងត្រូវបានចូលរួមក្នុងអំឡុងពេលរៀបចំឧបករណ៍។<br>• សម្របសម្រួលការពិភាក្សាជាមួយអាជ្ញាធរដែលមានអាណត្តិដើម្បីយល់ព្រមលើតួនាទីរបស់ ជនជាតិដើមភាគតិច ក្នុងការគ្រប់គ្រងតំបន់អភិរក្ស សំខាន់ៗ។<br>• បង្កើតតំបន់អភិរក្សសម្រាប់តំបន់ទាំងនោះដែលនៅជាប់នឹងចំណុច ជីវចម្រុះ<br>• បង្កើតយន្តការនិងការគាំទ្រដើម្បីគ្រប់គ្រងធនធានធម្មជាតិក្នុង មូលដ្ឋានប្រកបដោយចីរភាព (ដូចដែលបានពិពណ៌នានៅក្នុង ESMP ទីតាំងជាក់លាក់) |
| ជំហានទី ៦៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញលិខិតមួយទៅទីស្តីការគណៈរដ្ឋមន្ត្រីស្នើសុំការធ្វើបែងចែកដីដើម្បីចុះបញ្ជីជាដីសមូហភាពស្របតាមសេចក្តីសម្រេចរបស់ក្រសួងបរិស្ថាននិងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ | |
| ជំហានទី ៧៖ ចេញបណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច។ | |

233. បន្ទាប់ពីការបញ្ចប់ជំហានទី ៧ នៃដំណាក់កាលទី ៣ គម្រោងនឹងផ្តល់ការគាំទ្រលើសកម្មភាពអភិវឌ្ឍន៍តាមរយៈវិធីសាស្ត្រជំរុញតម្រូវការ។ ដំណើរការនេះនឹងប្រហាក់ប្រហែលទៅនឹងទីតាំងដែលត្រូវបានរចនាឡើងសម្រាប់ទីតាំង ICLT ចំនួន ៣០ ដែលមានស្រាប់ (សូមមើលកថាខណ្ឌខាងក្រោម)។ នៅដំណាក់កាលនេះ គម្រោងនឹងបញ្ចប់ការត្រួតពិនិត្យសម្រាប់អនុគម្រោងដែលមានចែងក្នុងផ្នែកទី ៥.៧.១ និងឧបសម្ព័ន្ធទី ៥។

234. *សម្រាប់ទីតាំង ICLT ដែលមានស្រាប់ (រំពឹងថានឹងមាន ៣០ កន្លែង)* គម្រោងនឹងផ្តល់ការ គាំទ្រលើសកម្មភាពអភិវឌ្ឍន៍ ដូចជាហេដ្ឋារចនាសម្ព័ន្ធ និងការគាំទ្រសេវាកម្មតាមរយៈវិធីសាស្ត្រជំរុញតម្រូវការ ដំណើរ

ការត្រួតពិនិត្យ និងការវាយតម្លៃ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងជូនដំណឹងរាល់បណ្ណកម្មសិទ្ធិដែលមាននៅគ្រប់ទីកន្លែង ដែលអាចមានលទ្ធភាពនៃជំនួយអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសដែលត្រូវប្រើ ហើយនឹងស្នើសុំការបង្ហាញចំណាប់អារម្មណ៍។ អ្នកដែលបង្ហាញចំណាប់អារម្មណ៍ នឹងត្រូវបានពិនិត្យតាមវិធីដូចគ្នានឹងអ្នកដែលបង្ហាញចំណាប់អារម្មណ៍លើការគាំទ្ររបស់ ICLT និងការត្រួតពិនិត្យដោយយកចិត្តទុកដាក់នឹងត្រូវបានអនុវត្តដើម្បីផ្ទៀងផ្ទាត់ថាលទ្ធផលនៃដំណើរការ ICLT ស្របតាមតម្រូវការ បទដ្ឋានបរិស្ថាន និងសង្គមទី ៧ សម្រាប់ការពិគ្រោះយោបល់ដែលមានអត្ថន័យ ដូចជាគណៈកម្មាធិការតំណាងសហគមន៍ដែលមានបរិយាប័ន្ន យេនឌ័រនិងសង្គម និងច្បាប់សហគមន៍ និងវិធានផ្ទៃក្នុងដែលនិយាយពីផលប្រយោជន៍របស់ស្ត្រី និងប្រជាជនក្រីក្រផងដែរ។ ប្រសិនបើបញ្ហានេះមិនត្រូវបានគេរកឃើញថាជាករណីនោះទេ សហគមន៍ជនជាតិដើមភាគតិច នឹងត្រូវបានស្នើសុំជាលក្ខខណ្ឌសម្រាប់ការគាំទ្រគម្រោង ដើម្បីកែសម្រួលសមាសភាពគណៈកម្មាធិការតំណាងសហគមន៍ និង/ឬខ្លឹមសារនៃច្បាប់សហគមន៍ និងវិធានផ្ទៃក្នុងដោយផ្អែកលើ ការសម្រេចចិត្តដោយសេរី បានដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (FPIC)។

235. សម្រាប់ ICLT នីមួយៗ រាល់ការត្រួតពិនិត្យ និងការវាយតម្លៃហានិភ័យនៃទីតាំងនឹងត្រូវបានអនុវត្តមុនពេល ESMP ត្រូវបានរៀបចំឡើង។ សកម្មភាព (ឧទាហរណ៍ការធ្វើផែនទីហតស្ពត) ដែលបានបញ្ចប់អំឡុងពេលដំណើរការ ICLT មិនត្រូវធ្វើម្តងទៀតទេ។ ភាពខុសគ្នាសំខាន់រវាង ICLT ដែលមានស្រាប់ និង ICLT ថ្មី គឺហានិភ័យដែលកើតឡើងពីការកំណត់អត្តសញ្ញាណដីធ្លី និងការចេញបណ្ណកម្មសិទ្ធិ នឹងលែងអនុវត្ត ដោយហេតុថាដំណាក់កាលនេះត្រូវបានបញ្ចប់។

### ៥.៣.៣ ការពិនិត្យបឋមហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម

236. ការពិនិត្យបឋមតាមទីតាំង ដើម្បីកំណត់ហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមនឹងត្រូវបានធ្វើឡើងនៅពេលចាប់ផ្តើមសកម្មភាពគម្រោងនៅទីតាំង SLC និងទីតាំង ICLT ដែលបានដាក់ស្នើឡើង។ ការពិនិត្យបឋមតាមទីតាំង នឹងត្រូវបានអនុវត្តដោយការវាយតម្លៃហានិភ័យ និងការសិក្សានិងសកម្មភាពតាមដានសមស្រប (សូមមើលផ្នែក ៥.៥ ខាងក្រោម)។ ការពិនិត្យបឋមប្រហែលជាត្រូវការធ្វើបច្ចុប្បន្នភាពនៅពេលដំណើរការកំណត់ព្រំដែន និងការធ្វើផែនការប្រើប្រាស់នៃ SLC និង ICLT មានដំណើរការ។ ការពិនិត្យបឋម នឹងប្រើប្រាស់ទ្រង់ទ្រាយនៅក្នុងឧបសម្ព័ន្ធទី ៣។ ការពិនិត្យបឋមនឹងវាយតម្លៃផ្អែកលើព័ត៌មានដែលអាចរកបានល្អបំផុត លទ្ធភាពនៃព្រឹត្តិការណ៍ហានិភ័យដែលបានកំណត់នីមួយៗនឹងកើតឡើងនៅទីតាំង និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដែលរំពឹងទុក។ ការពិនិត្យបឋមនឹងនាំឱ្យមានការកំណត់អត្តសញ្ញាណ នៃវិធានការគ្រប់គ្រងហានិភ័យដោយផ្អែកលើឋានានុក្រមកាត់បន្ថយ និងសមាមាត្រទៅនឹងធម្មជាតិនិងទំហំនៃហានិភ័យ។ ទោះបីជាឧបសម្ព័ន្ធ ៣ ជាវិធីសាស្ត្រត្រួតពិនិត្យយ៉ាងសំខាន់ក៏ដោយវាចាំបាច់ណាស់ដែលបុគ្គលិកត្រូវបានបណ្តុះបណ្តាលដើម្បីពិចារណាអំពីលទ្ធភាពនៃហានិភ័យផ្សេងទៀតដែលមិនមាននៅក្នុងបញ្ជីត្រួតពិនិត្យ។

237. ក្នុងករណីទាំងអស់ ការពិនិត្យបឋមតាមទីតាំង និងការវាយតម្លៃហានិភ័យជាបន្តបន្ទាប់នឹងត្រូវបានធ្វើឡើងដោយពិគ្រោះយោបល់ជាមួយសហគមន៍ និងថ្នាក់ដឹកនាំជាពិសេសក្រុមប្រឹក្សាឃុំ និងប្រជាជនក្នុងតំបន់

សម្រាប់ SLC និងគណៈកម្មាធិការតំណាងសហគមន៍ និងសមាជិកសហគមន៍ជនជាតិដើមភាគតិចសម្រាប់ ICLT។

238. ទំហំនៃកម្រងសំណួរនៃការវាស់ស្ទង់ទីតាំងរួមមាន:

(ក) ការវាយតម្លៃដំបូងនៃធនធានទឹកនៅទីតាំងនោះរាប់បញ្ចូលទាំងសក្តានុពលដែលអាចកើតមានលើធនធានទឹកដែលអាចកើតចេញពីការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ;

(ខ) វត្តមាននៃហតស្ពតបរិស្ថាន (សូមមើលផ្នែក ៥.៤ ស្តីពីការគូសផែនទី) ទាំងនៅក្នុងតំបន់បណ្តាញដែលបានស្នើសុំ និងនៅខាងក្រៅប៉ុន្តែអាចរងផលប៉ះពាល់ដោយសារតែការចូលពីទីតាំងសម្បទានដីសង្គមកិច្ច

(គ) ផលប៉ះពាល់ថ្នាក់តំបន់ និងជារួមដែលអាចកើតមាន

(ឃ) ហានិភ័យ ERW នៅក្នុងទីតាំង

(ង) វត្តមាននៃទំនប់វារីអគ្គិសនីដែលមានស្រាប់ឬដែលបានដាក់ស្នើ ឬទំនប់វារីអគ្គិសនីផ្សេងទៀតដែលស្ថិតនៅផ្នែកខាងលើនៃទីតាំង

(ច) សកម្មភាពរុករករ៉ែនៅតំបន់ជាប់នោះ(ស្របច្បាប់ ឬខុសច្បាប់)

(ឆ) សក្តានុពលដែលទីតាំងអាចនឹងរងផលប៉ះពាល់ដោយគ្រោះមហន្តរាយបង្កឡើងពីអាកាសធាតុ ឬផលប៉ះពាល់រយៈពេលវែងជាអវិជ្ជមានដោយសារការប្រែប្រួលអាកាសធាតុ។

(ជ) ហានិភ័យនៃជំងឺគ្រុនចាញ់ឬជំងឺចម្លងតាមភ្នាក់ងារចម្លងជំងឺផ្សេងទៀតនៅក្នុងទីតាំង

(ឈ) គុណភាពនៃទឹកលើដី និងទឹកក្រោមដីដែលត្រូវបានកំណត់ដោយការធ្វើតេស្តមន្ទីរពិសោធន៍ និងដើម្បីរួមបញ្ចូលការរកឃើញ (i) សារធាតុអាសេនិកធម្មជាតិនៅក្នុងទឹកក្រោមដី និង (ii) ការបំពុលដោយសារធាតុគីមីជាពិសេសនៅក្នុងទឹកលើដីដោយសារតែសារជាតិគីមីកសិកម្មដែលហូរទៅ សកម្មភាពរុករករ៉ែ ឬប្រភពផ្សេងទៀត

(ញ) តម្រូវការសម្រាប់ការទទួលបានដី / ការតាំងទីលំនៅថ្មីរបស់អ្នកប្រើប្រាស់ដីដែលមានស្រាប់នៅក្នុងទីតាំង

(ប) ផលប៉ះពាល់អវិជ្ជមានដល់អ្នកប្រើប្រាស់ដីធ្លីដែលមិនមែនជាអ្នកកាន់កាប់ដីធ្លីដោយផ្ទាល់រួមមានទាំងអ្នកប្រើប្រាស់ដែលជីវភាពរបស់ពួកគេអាចរងផលប៉ះពាល់ដោយការបាត់បង់លទ្ធភាពទទួលបាន CPR (ស្មៅជាចំណីសត្វ, អនុផលព្រៃឈើ, នេសាទជាដើម) និងអ្នកជួល និងនិយោជិកលើដីកាន់កាប់ដោយអ្នកដទៃរួមតាំងដីដែលកាន់កាប់ដោយខុសច្បាប់

(ផ) វត្តមាននៃបេតិកភណ្ឌវប្បធម៌រូបីដែលមិនអាចផ្លាស់ទីបាន

(ព) វត្តមាននៃបេតិកភណ្ឌវប្បធម៌អរូបី ដែលអាចរងផលប៉ះពាល់ជាពិសេស ទោះបីមិនមែនមានតែនៅក្នុងសហគមន៍ជនជាតិដើមភាគតិចក៏ដោយ

(ភ) វត្តមានសហគមន៍ជនជាតិដើមភាគតិចដែលអាចរងផលប៉ះពាល់ជាវិជ្ជមាន ឬជាអវិជ្ជមានពីគម្រោង

## ៥.៤ ការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំង ៖ ការគូសផែនទីថ្នាក់ខេត្ត

239. ការកំណត់ទីតាំង ការរៀបចំផែនការ និងដំណើរការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ SLC និង ICLT ប្រើប្រាស់ផែនទីតាមខេត្តដែលត្រូវបានរៀបចំឡើងដោយប្រើប្រាស់ឧបករណ៍ជាច្រើនរួមមានទិន្នន័យដែលមានស្រាប់

ចំណេះដឹងក្នុងមូលដ្ឋាន ការស្ទង់មតិនៅនឹងកន្លែង និងការចាប់យករូបភាពចម្ងាយតាមផ្កាយរណប (remote sensing)។ ផែនទីចុងក្រោយត្រូវបានផលិតឱ្យមានស្តង់ដាខ្ពស់ដូចដែលបានទាមទារ ដើម្បីគាំទ្រដល់ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី និងការបែងចែកដីធ្លីក៏ដូចជាការធ្វើផែនការប្រើប្រាស់ដីធ្លី។ ហានិភ័យផ្នែកបរិស្ថាន និងសង្គមជាច្រើនត្រូវបានផ្សារភ្ជាប់ជាមួយនឹងទីតាំងជាក់លាក់ ហើយដូច្នេះការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការចៀសវាង ឬការកាត់បន្ថយហានិភ័យទាំងនេះអាចត្រូវបានរួមបញ្ចូលជាមួយនឹងសកម្មភាពធ្វើផែនទី និងផែនការប្រើប្រាស់ដីធ្លី។

240. ក្នុងនាមជាឧបករណ៍គ្រប់គ្រងហានិភ័យ ផែនទីខេត្តគឺជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យនៅដំណាក់កាលនៃការកំណត់ទីតាំង និងជាផ្នែកមួយនៃ ESMP ទីតាំងជាក់លាក់មួយ និងគំរូមួយនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ។

241. ផែនទីក្នុងដំណើរការផ្តល់សម្បទានដីសង្គមកិច្ចរួមមាន៖

(a) ផែនទីបង្ហាញប្រភេទរូបភាពរៀបចំដោយក្រុមប្រឹក្សាឃុំដើម្បីគាំទ្រសំណើរបស់ SLC

(b) ផែនទី "ហតស្ពត" របស់ខេត្តដែលបានពិចារណានៅឯកិច្ចប្រជុំត្រួតពិនិត្យដំបូង

(c) ផែនទីការធ្វើផែនការប្រើប្រាស់ដីឃុំសង្កាត់ដែលមានមូលដ្ឋានលើ GIS និងផែនទីហតស្ពតបរិស្ថាន

(d) ផែនទីបង្ហាញប្រភេទរូបភាពដែលបានកែសម្រួលដោយផ្អែកលើការស្ទង់មតិ និងការធ្វើផែនទីលម្អិតនៃទីតាំង SLC ដែលបង្ហាញពីព្រំដែននៃទីតាំងនិងការចង្អុលបង្ហាញតំបន់ដែលមានកម្មសិទ្ធិឯកជននៃការប្រើប្រាស់ ឬដែលជា "ហតស្ពត" នៃសារសំខាន់ខាង បរិស្ថានឬវប្បធម៌។ ផែនទីនេះត្រូវបានបង្ហាញនៅសាលាឃុំសង្កាត់រយៈពេលយ៉ាងតិច ៣០ ថ្ងៃ។

(e) ការស្ទង់មតិយ៉ាងត្រឹមត្រូវដោយប្រើជីភីអេស (GPS) ផ្សេងៗគ្នា (ធ្វើដោយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងដែនដី នគរូបនីយកម្ម និងសំណង់) ដែលជាលទ្ធផលផែនទីសម្បទានដីសង្គមកិច្ចដែលត្រូវបង្ហាញនៅសាលាឃុំរយៈពេល ៣០ ថ្ងៃ។

(f) ផែនទីប្រើប្រាស់ដីធ្លីរៀបចំដោយផ្អែកលើការធ្វើផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួម និងចង្អុលបង្ហាញអំពីការបែងចែកទីតាំងការផ្តល់សម្បទានដីសង្គមកិច្ចចំពោះដីលំនៅឋាន ដីកសិកម្ម និងដីដែលបម្រុងទុកសម្រាប់សហគមន៍ ឬគោលបំណងសាធារណៈរួមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ (ប្រភព៖ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង នៃ LASED II)

242. ផែនទី 'ហតស្ពត' ខេត្ត គឺជាផែនទី GIS ដែលអនុញ្ញាតឱ្យបង្ហាញស្រទាប់ផែនទីទាក់ទងនឹងតំបន់បរិស្ថានដែលងាយរងគ្រោះរួមមាន៖

| | | |
|---|---|---|
| • តំបន់ការពារ និងអភិរក្សសត្វព្រៃ | • ការអភិរក្ស ឬទីជម្រាល | • ព្រៃការពារ |
| • ព្រៃសហគមន៍ | • សម្បទានព្រៃឈើ | • ការប្រែប្រួលគម្របព្រៃឈើ ១៩៩៣-១៩៩៧ |
| • ជម្រកសត្វព្រៃ | • ការរំខានដល់ប្រព័ន្ធអេកូឡូស៊ីព្រៃឈើ (IFSR); | • គម្របព្រៃឈើ ១៩៧៦, ១៩៩៧, ២០០២, ២០០៦ |

| | | |
|---|---|---|
| • ទីតាំងបេតិកភណ្ឌវប្បធម៌ | • គ្រោះថ្នាក់នៃ UXO និងគ្រាប់មីននៅលើដី | • គម្របដី ២០០២ |
| • គ្រោះថ្នាក់នៃសារធាតុអាសេនិក | • ប្រព័ន្ធអេកូឡូស៊ីស្រូវ | • អាងធម្មជាតិតូចៗ (Sub-catchments) |
| • សម្បទានសេដ្ឋកិច្ច | • ដី និងដីវាលតិដី | • ដីសើម |
| • អាងទឹកជ្រៅ និងដែនជម្រកមច្ឆជាតិ | • តំបន់វាលភក់ | • ទំនប់វារីអគ្គិសនីដែលមានស្រាប់/ដែលដាក់ស្នើឡើង |
| • ជម្រកមច្ឆាជាតិ | • ការផ្លាស់ទីរបស់មច្ឆាជាតិ | • ចំណោទ និងកម្ពស់ |

243. លើសពីនេះ វារួមបញ្ចូលទាំងប្លង់ផែនទីស្តង់ដា ដូចជាផ្លូវថ្នល់ ទន្លេ ស្ទឹង ដងទឹក និងព្រំដែនរដ្ឋបាល។ ផែនទី 'ហាតស្ពត' ខេត្ត ត្រូវបានប្រើដើម្បីៈ

(a) កំណត់តំបន់សើបសម្រាប់ការមិនរាប់បញ្ចូលក្នុងការផ្តល់សម្បទានដីសង្គមកិច្ចនិងការពិចារណាលើផលប៉ះពាល់លើតំបន់ដែលនៅខាងក្រៅការផ្តល់សម្បទានដីសង្គមកិច្ច
(b) គូសផែនទីអំពីការប្រើប្រាស់ដីទំនៀមទម្លាប់ និងទីតាំង ឬវត្ថុតំណាងវប្បធម៌ ឬវិញ្ញាណ អារក្ស ក្នុងអំឡុងពេលដំណើរការធ្វើអត្តសញ្ញាណកម្មដីធ្លី និងផែនការប្រើប្រាស់ដីធ្លី
(c) កំណត់គម្របដីជាប្រវត្តិសាស្ត្រនិងថ្មីៗនៅក្នុង និងនៅជិតការផ្តល់សម្បទានដីសង្គមកិច្ច ដោយមានការស្វែងមតិទាក់ទងនឹងព្រៃឈើ
(d) ផ្តល់ភស្តុតាងជាប្រវត្តិសាស្ត្រនៃការកាន់កាប់ និងការប្រើប្រាស់ដីធ្លីដែលអនុញ្ញាតឱ្យមានការកំណត់អត្តសញ្ញាណនៃការរំលោភយកដីថ្មី
(e) បោះទង់សម្គាល់តំបន់ដែលមានយុទ្ធភណ្ឌមិនទាន់ផ្ទុះ(UXO/ERW) និងទីតាំងដែលមានមីន ជាទីតាំងគ្រោះថ្នាក់
(f) កំណត់ទីតាំង និងទំហំនៃការបោសសម្អាតដីយ៉ាងតឹងរឹង និងសម្គាល់តំបន់ដែលមានត្រូវការជាពិសេសសម្រាប់ការអភិរក្ស

244. អ្នកចូលរួមក្នុងការប្រជុំត្រួតពិនិត្យនៅថ្នាក់ខេត្តរួមមានៈ

(a) ក្រុមការងារថ្នាក់ស្រុក (DWG)
(b) ក្រុមប្រឹក្សាឃុំសង្កាត់
(c) មន្ទីរបច្ចេកទេសខេត្តៈ ដី ព្រៃឈើ កសិកម្ម ធនធានទឹក បរិស្ថាន វប្បធម៌ និងបេតិកភណ្ឌរ៉ែ និងថាមពល មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMA)
(d) អ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងខេត្ត។

245. ក្នុងអំឡុងពេលសកម្មភាពគូសផែនទីទាំងនេះ ទីតាំងដែលទាក់ទងទៅនឹងហានិភ័យដែលបានកំណត់នៅ ESMP ទីតាំងជាក់លាក់ នឹងត្រូវបានកត់សម្គាល់នៅលើផែនទី ហើយនឹងត្រូវយកមកពិចារណាក្នុងការកំណត់ព្រំប្រទល់នៃការផ្តល់សម្បទានដីសង្គមកិច្ច (ឧទាហរណ៍ ការផាត់ចេញនូវដីដែលមានកម្មសិទ្ធឯកជន

ហាតស្ថតបរិស្ថាន តំបន់បេតិកភណ្ឌ ឬដីទាក់ទងនឹងហានិភ័យដូចជា ERW) និងក្នុងការកំណត់ការប្រើប្រាស់ដីសមស្របដើម្បីចៀសវាង ឬកាត់បន្ថយហានិភ័យ។

## ៥.៥ នីតិវិធីវាយតម្លៃហានិភ័យ

246. សម្រាប់ SLC និង ICLT នីមួយៗ ការវាយតម្លៃហានិភ័យនឹងត្រូវធ្វើឡើងផ្អែកលើលទ្ធផលនៃការពិនិត្យបឋមតាមទីតាំង។ ការវាយតម្លៃហានិភ័យនឹងត្រូវបានណែនាំដោយទីប្រឹក្សាគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមថ្នាក់ជាតិ។

247. ការវាយតម្លៃហានិភ័យនឹងផ្អែកលើការរកឃើញនៃការត្រួតពិនិត្យ និងការគូសផែនទី (សូមមើលជំហានទី ១ នៅក្នុងដំណើរការ SLC និងសកម្មភាពដែលមានតម្លៃស្មើក្នុង ICLT)។ ដោយផ្អែកលើលក្ខណៈសង្គម និងរូបវន្តដែលត្រូវបានកំណត់តាមរយៈការត្រួតពិនិត្យ និងប្រៀបធៀបជាមួយ ហានិភ័យដែលបានកំណត់នៅក្នុងផ្នែកទី ៤ និងតារាងទី ១១ នៃ ក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម (ESMF) នេះ ទីប្រឹក្សាគ្រប់គ្រងហានិភ័យនឹងណែនាំក្រុមការងារគម្រោងខេត្តដើម្បីកំណត់ហានិភ័យនៅកម្រិតទីតាំង និងរៀបចំផែនការសិក្សាបន្ថែមដែលត្រូវការដើម្បីវាយតម្លៃបន្ថែមទៀតអំពីហានិភ័យ។ ការសិក្សាទាំងនេះនឹងរួមបញ្ចូលទាំងការសិក្សាបច្ចេកទេសដែលបានអនុវត្តជាប្រចាំនៅជំហានទី ២ នៃដំណើរការការផ្តល់សម្បទានដីសង្គមកិច្ច (AEA ការស្ទង់មតិសារពើ ភ័ណ្ឌអំពីព្រៃឈើ ការស្ទង់មតិអំពីធនធានទឹក ការស្ទង់មតិអំពីដី)។ ទោះយ៉ាងណាក៏ដោយ តម្រូវការសម្រាប់ការសិក្សាបន្ថែមអាចត្រូវបានកំណត់អត្តសញ្ញាណ។ ការសិក្សាបន្ថែមអាចរាប់បញ្ចូលប៉ុន្តែមិនត្រូវបានកំណត់ចំពោះ៖

(a) ការវាយតម្លៃហានិភ័យពី ERW;
(b) ការវាយតម្លៃហានិភ័យពីលក្ខណៈពិសេសនៅខ្សែទឹកខាងលើដងទន្លេ (ទំនប់វារី អគ្គិសនីធំៗ ប្រភពនៃការបំពុលបរិស្ថាន)
(c) ការវាយតម្លៃហានិភ័យសក្តានុពលចំពោះហាតស្ថតជីវចម្រុះដែលមានទីតាំងនៅក្រៅតំបន់ទីតាំង (ពីសកម្មភាពសហគមន៍សម្បទានដីសង្គមកិច្ច)
(d) ហានិភ័យសុខភាពទាក់ទងនឹងការរើទៅលំនៅរបស់អ្នកទទួលដីទៅកាន់ទីតាំង
(e) ហានិភ័យសង្គមរួមមានអំពើហិង្សាផ្អែកលើយេនឌ័រ។

248. ទីប្រឹក្សាផ្នែកគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម ក៏នឹងកំណត់ផងដែរថា តើមានតម្រូវការចាំបាច់ណាខ្លះក្នុងការអនុវត្ត ESIA ក្នុងតំបន់ដែរឬទេ។

249. ការសិក្សាទាំងនេះនឹងត្រូវអនុវត្ត និងប្រើប្រាស់ដើម្បីធ្វើបច្ចុប្បន្នភាពការវាយតម្លៃហានិភ័យ។ លទ្ធផលនៃការពិនិត្យ ការវាយតម្លៃហានិភ័យ និងការសិក្សានឹងត្រូវបានប្រើដើម្បីរៀបចំ ESMP តាមទីតាំង។

## ៥.៦ ការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំង ៖ ឧបករណ៍ពាក់ព័ន្ធនឹងបរិស្ថាន និងសង្គម

### ៥.៦.១ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង

250. សម្រាប់ទីតាំងដីសម្បទាន និងកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចថ្មីទាំងអស់ (មិនថាបានការផ្តល់បណ្ណកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច បញ្ចប់ឬអត់) ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមជាក់លាក់ទីតាំង នឹងត្រូវបង្កើតឡើងដោយផ្អែកលើការវាយតម្លៃហានិភ័យ។ ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ ក៏នឹងត្រូវបានរៀបចំសម្រាប់ទីតាំងទាំងនេះផងដែរ។ ផែនការជនជាតិដើមភាគតិចនឹងត្រូវបានរៀបចំសម្រាប់ទីតាំងដីសម្បទាន និងកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច និងកន្លែងដែលបានចង្អុលបង្ហាញសម្រាប់ដីសម្បទានសង្គមកិច្ច ស្របតាមក្របខណ្ឌផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិច ។ ក្នុងករណីណាក៏ដោយដែលមិនអាចចៀសផុតពីការតាំងទីលំនៅថ្មីដោយបង្ខំ ផែនការដោះស្រាយផលប៉ះពាល់លើការផ្លាស់ទីលំនៅដោយសារគម្រោង នឹងត្រូវរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ-អគ្គនាយកដ្ឋានលំនៅដ្ឋាន។ ផែនការតាំងទីលំនៅថ្មីនឹងគោរពតាម SOP-LAR និងមានវិធានការបន្ថែមដែលមានលម្អិតនៅក្នុងក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង។

251. ក្នុងករណីទាំងអស់ ការវាយតម្លៃហានិភ័យ និងការរៀបចំ ESMP និងឧបករណ៍ផ្សេងទៀតនឹងត្រូវបានអនុវត្តដោយពិគ្រោះយោបល់ជាមួយសហគមន៍ និងថ្នាក់ដឹកនាំ ជាពិសេសក្រុមប្រឹក្សាឃុំ និងប្រជាជនក្នុងទីតាំងដីសម្បទានសង្គមកិច្ចនិង គណៈកម្មាធិការតំណាងសហគមន៍ និងសមាជិកសហគមន៍ជនជាតិដើមភាគតិចសម្រាប់ការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច។

252. ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង នឹងត្រូវបានរៀបចំ ពិគ្រោះយោបល់ និងផ្សព្វផ្សាយ (សូមមើលជំពូក៦ ស្តីពីដំណើរការពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈ) នៅដំណាក់កាលដំបូងនៃការកំណត់អត្តសញ្ញាណទីតាំងដោយផ្អែកលើទិន្នន័យដែលមានហើយ នឹងត្រូវពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពនៅជំហាននីមួយៗនៃការធ្វើផែនទីទីតាំង ការធ្វើផែនការប្រើប្រាស់ដីធ្លី និងហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពរៀបចំផែនការចិញ្ចឹមជីវិត តាមតម្រូវការ។ ដូច្នេះសេចក្តីព្រាង ESMP នឹងជួយក្នុងការណែនាំដំណើរការរៀបចំផែនការទីតាំងជាជាងលេចចេញនៅទីបញ្ចប់នៃដំណើរការដែលសម្រេចរួចរាល់។

253. វិសាលភាពនៃផែនការសម្រាប់គ្រប់គ្រងបរិស្ថាននិងសង្គម នេះនឹងរួមបញ្ចូលទាំងវិធានការគ្រប់គ្រងហានិភ័យដោយផ្អែកលើឋានានុក្រមកាត់បន្ថយហានិភ័យ ចំពោះហានិភ័យដែលត្រូវបានកំណត់ថាមានកម្រិតមធ្យម ឬធ្ងន់ធ្ងរផ្អែកលើទម្រង់ត្រួតពិនិត្យ ឬបញ្ជីត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធទី ៣។ ការត្រួតពិនិត្យមានគោលបំណង៖

(a) កំណត់ក្រុមងាយរងគ្រោះ ឬជួបការលំបាកដែលទាមទារវិធានការពិសេសដើម្បីធានាការដាក់បញ្ចូល
(b) កំណត់ប្រភេទកម្មករនៅទីតាំង (កម្មករផ្ទាល់ កម្មករជាប់កិច្ចសន្យា កម្មករផ្គត់ផ្គង់បឋម និងកម្មករសហគមន៍) ស្របតាមបញ្ញត្តិ ESS2 និងកំណត់គោលការណ៍ណែនាំ ឬពិធីសារសម្រាប់ធានាការអនុលោមតាម ESS2 ទាក់ទងនឹងប្រភេទនីមួយៗ។
(c) ធានានូវសម្ភារសំណង់ ជាពិសេសឈើត្រូវបានយកចេញពីប្រភពស្របច្បាប់ និងមាននិរន្តរភាព

(d) ធានាបាននូវការចូលប្រើជាសកលនូវរាល់ទីតាំងដែលបានគាំទ្រដោយគម្រោង (ឧទាហរណ៍ សាលារៀន គ្លីនិក អាគារសហគមន៍)
(e) កំណត់វិធានការដែលត្រូវការដើម្បីធានាបាននូវការចូលប្រើប្រាស់ធនធានធម្មជាតិ
(f) វិធានការនានាដើម្បីធានានូវការទទួលយកអនាម័យ (ការប្រើប្រាស់បង្គន់អនាម័យ) នៅនឹងទីតាំង
(g) ការគ្រប់គ្រងបរិស្ថាន និងការចោលសំរាមនៅនឹងកន្លែង
(h) ការយល់ដឹងអំពីការប្រើប្រាស់ និងការចោលសារធាតុគីមីកសិកម្មដោយសុវត្ថិភាព
(i) វិសាលភាពសម្រាប់ការអនុម័តបច្ចេកវិទ្យាថាមពលកកើតឡើងវិញនៅទីតាំងនោះ
(j) វិធានការសម្រាប់ការពារបេតិកភណ្ឌវប្បធម៌រួមទាំងបេតិកភណ្ឌវប្បធម៌អរូបី ដែលពាក់ព័ន្ធ។

254. ដំណាក់កាលចុងក្រោយនៃការអភិវឌ្ឍផែនការសម្រាប់គ្រប់គ្រងបរិស្ថាននិងសង្គម នេះរួមមាន៖

(a) ការពិនិត្យឡើងវិញលើកម្រងសំណួរផែនទី ការសិក្សានិងវាយតម្លៃហានិភ័យ និងការកំណត់អត្តសញ្ញាណហានិភ័យដែលអាចត្រូវបានលុបចោល
(b) ការបញ្ជាក់ថាហានិភ័យត្រូវបានចៀសវាង ឧទាហរណ៍ ដោយការមិនរាប់បញ្ចូលហតស្ថតបរិស្ថានដីដែលបានប្រើប្រាស់រួចហើយ ទីតាំងដែលបង្ហាញពីគ្រោះថ្នាក់ដល់សុខភាពនិងសុវត្ថិភាពសហគមន៍ (តំបន់ដែលគេស្គាល់ថាមានគ្រាប់មីន) និងតំបន់បេតិកភណ្ឌវប្បធម៌ពីព្រំដែនតំបន់នោះ។ ក្នុងករណីនេះមិនចាំបាច់មានសកម្មភាពបន្ថែមទៀតទេ ប៉ុន្តែហានិភ័យនៅតែត្រូវបានកំណត់នៅក្នុង ESMP រួមជាមួយវិធានការបញ្ចៀសក្នុងគោលបំណងតាមដាន។
(c) ការវាយតម្លៃប្រសើរឡើងនៃផលប៉ះពាល់ដែលអាចកើតមាន និងលទ្ធភាពនៃការកើតឡើងនៃហានិភ័យដែលនៅសេសសល់។
(d) វិធានការកាត់បន្ថយផលប៉ះពាល់ដោយផ្អែកលើឋានានុក្រមកាត់បន្ថយ និងស្របទៅនឹងផែនការប្តេជ្ញាចិត្តសម្រាប់គ្រប់គ្រងបរិស្ថាន និងសង្គម (ESCP)។

255. សម្រាប់ ICLT ដែលគម្រោង LASED III នឹងគាំទ្រដល់ដំណើរការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ការពិនិត្យបឋមតាមទីតាំង ការវាយតម្លៃហានិភ័យ និងផែនការសម្រាប់គ្រប់គ្រងបរិស្ថាននិងសង្គមតាមទីតាំង នឹងត្រូវរៀបចំឡើងដោយពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិច និងថ្នាក់ដឹកនាំហើយ នឹងបញ្ចូលការព្រួយបារម្ភសំខាន់ៗរបស់ក្របខណ្ឌផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិច (IPPF)។ អ្នកសម្របសម្រួលសហគមន៍នឹងជួយសហគមន៍ជនជាតិដើមភាគតិចឱ្យយល់ និងវាយតម្លៃហានិភ័យ បទដ្ឋានបរិស្ថាននិងសង្គមទី៧ ដែលបានកំណត់នៅក្នុងតារាងទី១១ យល់ព្រមវិធានការកាត់បន្ថយហានិភ័យសមស្របនិងឯកភាពលើតម្រូវការសម្រាប់ ការសម្រេចចិត្តដោយសេរី បានដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (FPIC)។

256. សម្រាប់ ICLT ដែលអន្តរាគមន៍ដោយគម្រោង ចាប់ផ្តើមបន្ទាប់ពីការចេញបណ្ណកម្មសិទ្ធិដីធ្លីចប់សព្វគ្រប់ ការត្រួតពិនិត្យ ការវាយតម្លៃហានិភ័យ និងការរៀបចំ ESMP តាមទីតាំង ក៏នឹងត្រូវឆ្លងកាត់ការពិគ្រោះយោបល់ជាមួយសហគមន៍ផងដែរ ប៉ុន្តែនឹងត្រូវរួមបញ្ចូលជាមួយនឹងការរៀបចំផែនការចិញ្ចឹមជីវិត និងផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទីតាំងនោះ។ ការផ្តោតអារម្មណ៍នឹងសង្កត់ធ្ងន់លើផលប៉ះពាល់ជាសក្តានុពលនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និងការប្រកបរបរចិញ្ចឹមជីវិត រួមទាំងផលប៉ះពាល់អវិជ្ជមានលើរចនាសម្ព័ន្ធសង្គមតាមបែបប្រពៃណី និងបេតិកភណ្ឌវប្បធម៌។

257. សម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ច ដែលការត្រួតពិនិត្យបង្ហាញថាសហគមន៍ជនជាតិដើមភាគតិចនឹងរងផលប៉ះពាល់ ផែនការជនជាតិដើមភាគតិច (IPP) នឹងត្រូវបានរៀបចំជាឯកសារដាច់ដោយឡែកមួយតាមតម្រូវការរបស់ ក្របខណ្ឌផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិច (IPPF)។ ផែនការជនជាតិដើមភាគតិច (IPP) គួរតែត្រូវបានរៀបចំជាសេចក្តីព្រាងនៅដំណាក់កាលដំបូង នៃការធ្វើផែនការសកម្មភាពនៅនឹងកន្លែង ហើយអាចត្រូវបានធ្វើបច្ចុប្បន្នភាពតាមតម្រូវ ការ។ គម្រោងគួរតែប្រើអន្តរការីដែលមានជំនាញ (អ្នកជំនាញ ឬអង្គការក្រៅរដ្ឋាភិបាល ដែលធ្លាប់ធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច) ដើម្បីជួយរៀបចំផែនការជនជាតិដើមភាគតិច តាមទីតាំង។

### ៥.៦.២ ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP)

258. សម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ចថ្មី ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធតាមទីតាំងនឹងត្រូវបានរៀបចំបន្ទាប់ពីជំហានទី ១ នៃដំណើរការការផ្តល់សម្បទានដីសង្គមកិច្ចថ្មី។ សម្រាប់ ការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចថ្មី និងដែលមានស្រាប់ដែលគម្រោង LASED III កំពុងចាប់ផ្តើមការចូលរួម ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធនឹងត្រូវបានរៀបចំមុនពេលសកម្មភាពគម្រោងសំខាន់ៗ (ក្រៅពីការកំណត់អត្តសញ្ញាណដំបូង និងវិសាលភាព) ចាប់ ផ្តើម។ ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ នឹងណែនាំការចូលរួមរបស់ភាគីពាក់ព័ន្ធ តាមរយៈការរៀបចំផែនការ និងដំណើរការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីក៏ដូចជាតាមរយៈការអនុវត្តអនុគម្រោង។ តម្រូវការអប្បបរមា សម្រាប់ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ តាមទីតាំងត្រូវបានពិពណ៌នានៅក្នុងគម្រោងផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ ហើយនឹងរួមមាន:

- (a) កំណត់ក្រុមដែលរងផលប៉ះពាល់ពីគម្រោង
- (b) ការកំណត់អត្តសញ្ញាណរបស់អ្នកពាក់ព័ន្ធផ្សេងទៀត (ឧទាហរណ៍អង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រសហគមន៍)
- (c) ផែនការសម្រាប់ការផ្សព្វផ្សាយព័ត៌មាននៅដំណាក់កាលនីមួយៗនៃដំណើរការ
- (d) ផែនការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធស្តីពីការកំណត់អត្តសញ្ញាណនិងការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម;
- (e) ផែនការសម្រាប់ការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ និងការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពគម្រោង

(f) បញ្ញត្តិពិសេសដើម្បីធានានិងផ្ទៀងផ្ទាត់ការសម្រេចចិត្តដោយសេរី បានដឹងជាមុន និងទទួលបានព័ត៌មានពេញលេញពីជនជាតិដើមភាគតិច

(g) នីតិវិធីបណ្តឹងតវ៉ា។

259. ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ តាមទីតាំងនឹងត្រូវដាក់ជូនធនាគារពិភពលោកដោយគ្មានការជំទាស់បន្ទាប់ពីការរៀបចំដំបូង (ឧទាហរណ៍ បន្ទាប់ពីជំហានទី ១ នៃដំណើរការផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ ឬសមមូល) ហើយនឹងត្រូវដាក់ជូនឡើងវិញសម្រាប់ការមិនជំទាស់ក្នុងករណីមានការផ្លាស់ប្តូរជាបន្តបន្ទាប់។

## ៥.៦.៣ ផែនការដោះស្រាយផលប៉ះពាល់លើការផ្លាស់ទីលំនៅដោយសារគម្រោង (RP)

260. ដូចដែលបានរៀបរាប់នៅក្នុងក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅ ដោយសារគម្រោង(RPF) គម្រោង LASED III នឹងចៀសវាងការតាំងទីលំនៅថ្មីដោយបង្ខំ តាមរយៈការត្រួតពិនិត្យ និងការដកចេញនូវដីដែលត្រូវបានរកឃើញថាជាកម្មសិទ្ធិឯកជនស្របច្បាប់ ហើយនៅពេលចាំបាច់ និង សមរម្យតាមរយៈការរៀបចំដោយស្ម័គ្រចិត្ត រួមទាំងការផ្លាស់ប្តូរដីជាមួយសម្បទានដីសង្គមកិច្ច និងការស្ម័គ្រចិត្ត ការបរិច្ចាគដីដោយអ្នកប្រើប្រាស់ដីដែលនឹងក្លាយជាអ្នកទទួលផលពីគម្រោង។ នេះគឺជាវិធីសាស្ត្រដូចគ្នានឹងគម្រោង LASED និង LASED II ដែលផែនការដោះស្រាយផលប៉ះពាល់លើការផ្លាស់ទីលំនៅដោយសារគម្រោង (RP) ត្រូវបានទាមទារ។ តម្រូវការសម្រាប់ការតាំងទីលំនៅថ្មីដោយបង្ខំអាចកើតឡើងក្នុងករណីដូចខាងក្រោម៖

(a) ត្រូវការទិញដីមួយចំណែកជាកម្មសិទ្ធិឯកជន ដោយមិនចាំបាច់មានការផ្តល់សម្បទានដីសង្គមកិច្ច ឬការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ទាំងមូលអាចសម្រេចបាន (ឧទាហរណ៍ សម្រាប់តែផ្លូវសម្រាប់ផ្លូវចូលកាត់ដីឯកជន)

(b) ការស្តារឡើងវិញ និងកែលម្អផ្លូវចូលទីតាំង (ដីការផ្តល់សម្បទានដីសង្គមកិច្ច ឬការ ផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច) ទាមទារការកាន់កាប់ដី លើសពីចំនួនតិចតួចដែលអាចត្រូវបានដោះស្រាយតាមរយៈកិច្ចព្រមព្រៀងស្ម័គ្រចិត្ត។

261. ក្នុងករណីដែលលទ្ធកម្មដីមានភាពចាំបាច់ ផែនការតាំងទីលំនៅថ្មីនឹងត្រូវបានរៀបចំនិងអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ-អគ្គនាយកដ្ឋានលំនៅដ្ឋាន ដោយអនុលោមតាមនីតិវិធីដែលបានពិពណ៌នានៅក្នុងក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង (RPF)។

## ៥.៦.៤ ផែនការសម្រាប់ជនជាតិដើមភាគតិច(IPP)

262. សម្រាប់ការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ដែលគម្រោងគាំទ្រការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី (ជាមួយ ក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម (ESMF) បញ្ចូលនូវផែនការជនជាតិដើមភាគតិច ត្រូវបានរៀបចំនៅដំណាក់កាលដំបូងនៃដំណើរការចេញបណ្ណកម្មសិទ្ធិ) ESMF និងជាពិសេសវិធានការពាក់ព័ន្ធនឹងហានិភ័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ នឹងត្រូវបានត្រួតពិនិត្យ

ឡើងវិញ និងធ្វើសុពលកម្មជាមួយសហគមន៍ជនជាតិដើមភាគតិច ការធ្វើផែនការប្រើប្រាស់ដីធ្លី និងការកំណត់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងមុខរបរចិញ្ចឹមជីវិតបានបញ្ចប់។

263. សម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ច ជាមួយសហគមន៍ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ (ដែលត្រូវការផែនការជនជាតិដើមភាគតិចដាច់តែឯង) ផែនការជនជាតិដើមភាគតិចនឹងត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើសុពលកម្មជាមួយសហគមន៍ជនជាតិដើមភាគតិច ការធ្វើផែនការប្រើប្រាស់ដីធ្លី និងការកំណត់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងមុខរបរចិញ្ចឹមជីវិតបានបញ្ចប់។

### ៥.៦.៥ ការរៀបចំផែនការដែលជំរុញការចូលរួម

264. ជំហានទី ៥ នៃដំណើរការផ្តល់សម្បទានដីសង្គមកិច្ច គឺការប្រើប្រាស់ដីធ្លី និងការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធដែលមានការចូលរួម និងរួមមានអនុសកម្មភាព ជាច្រើនរួមមានការវិភាគកសិ-ប្រព័ន្ធអេកូឡូស៊ី ការវាយតម្លៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងសិក្ខាសាលារៀបចំផែនការដែលមានការចូលរួមពីអ្នកទទួលផលពីគម្រោង និងភាគីពាក់ព័ន្ធផ្សេងទៀត។ តម្រូវការសម្រាប់សិក្ខាសាលានេះរួមមាន (១) សិក្ខាសាលាដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយដែលប្រជាជនមូលដ្ឋាន និងអង្គការសង្គមស៊ីវិល។ល។ អាចចូលរួម (២) របាយការណ៍ព្រាង នៃការផ្តល់សម្បទានដីសង្គមកិច្ច ត្រូវបានបង្ហាញ ពិភាក្សា និងឯកភាពជាមួយអ្នកចូលរួម (៣) ការប្រជុំត្រូវបានថតជាសំឡេង ឬវីដេអូ។

265. ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង នឹងត្រូវបានពិចារណាអំឡុងពេលអនុសកម្មភាពនីមួយៗនៃការធ្វើផែនការដែលមានការចូលរួម ដូច្នេះហានិភ័យដែលបានកំណត់អាចត្រូវបានចៀសវាង កាត់បន្ថយ ឬធ្វើឱ្យធូរស្រាលនៅក្នុងផែនការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ (នេះគឺជាការផ្លាស់ប្តូរពីដំណើរការ LASED II ដែលការការពារសុវត្ថិភាព ត្រូវបានពិចារណាតែនៅដំណាក់កាលចុងក្រោយនៃការធ្វើផែនការប្រើប្រាស់ដីប៉ុណ្ណោះ)។ ការរកឃើញនៃការវាយតម្លៃនេះ នឹងបង្កើតជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងហានិភ័យនៅកម្រិតអនុគម្រោង។

## ៥.៧ ការគ្រប់គ្រងហានិភ័យនៅកម្រិតអនុគម្រោង

### ៥.៧.១ ប្រភេទអនុគម្រោង ការពិនិត្យបឋម និងតារាងបង្ហាញផលប៉ះពាល់អវិជ្ជមាន

266. គម្រោង LASED III អាចគាំទ្រប្រភេទអនុគម្រោងជាច្រើននៅកម្រិតការផ្តល់សម្បទានដី សង្គមកិច្ច និងការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច រួមមាន (១) ហេដ្ឋារចនាសម្ព័ន្ធជនបទ (២) អនុគម្រោងជីវភាពរស់នៅកសិកម្ម (៣) អនុគម្រោងអភិវឌ្ឍន៍សហគមន៍ដែលត្រូវការដើម្បីដោះស្រាយហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម ជាពិសេសទាក់ទងនឹងសុខភាព និងសុវត្ថិភាពសហគមន៍ (អនាម័យ យេនឌ័រផ្តេកលើអំពើហិង្សា ការគ្រប់គ្រងសំណល់រឹង)។

267. អនុគម្រោងទាំងអស់នឹងត្រូវឆ្លងកាត់ការត្រួតពិនិត្យហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម (សូមមើលឧបសម្ព័ន្ធទី ៤)។ នីតិវិធីនៃការត្រួតពិនិត្យមានពីរដំណាក់កាលៈ (ក) ការជ្រើសរើសអនុគម្រោងដែលបានដាក់ស្នើ ស្ថិតនៅក្រោមបញ្ជីផលប៉ះពាល់អវិជ្ជមានរបស់គម្រោងនិង (ខ) ការត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមាន និងហានិភ័យដោយប្រើទម្រង់ត្រួតពិនិត្យអនុគម្រោងនៅក្នុងឧបសម្ព័ន្ធទី ៤។ លទ្ធផលនៃដំណើរការជ្រើសរើសនេះ នឹងកំណត់អនុគម្រោងដែលមានសិទ្ធទទួលបាន និងឧបករណ៍គ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមដែលត្រូវប្រើ សម្រាប់អនុគម្រោងនីមួយៗ។ ការត្រួតពិនិត្យនឹងគិតគូរពីហានិភ័យបន្ថែមដែលបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង និងមានសក្តានុពលពាក់ព័ន្ធនឹងប្រភេទអនុគម្រោង និងសកម្មភាពដែលជាប់ទាក់ទងនិងគ្រឿងបរិក្ខារបន្ទាប់បន្សំ ក៏ដូចជាផលប៉ះពាល់ជាបន្តបន្ទាប់។ លទ្ធផលនៃការត្រួតពិនិត្យនឹងត្រូវដាក់ជូនធនាគារដោយគ្មានការជំទាស់ មុនពេលចាប់ផ្តើមការងារ។

268. ការត្រួតពិនិត្យដំបូងនឹងរួមបញ្ចូលការប្តេជ្ញាចិត្តថា តើអនុគម្រោង រួមបញ្ចូលសកម្មភាព ឬលទ្ធផលនៅលើបញ្ជីផលប៉ះពាល់អវិជ្ជមាននៃគម្រោងឬអត់។ គម្រោងនេះនឹងមិនផ្តល់ហិរញ្ញប្បទានដល់អនុគម្រោង ដែលមានលក្ខណៈដូចខាងក្រោម៖

**តារាង ១៥៖ បញ្ជីផលប៉ះពាល់អវិជ្ជមាន**

| បញ្ជីផលប៉ះពាល់អវិជ្ជមាន | បញ្ជីផលប៉ះពាល់អវិជ្ជមានបន្ថែម |
|---|---|
| • ការចំណាយណាមួយដែលមានគោលបំណងផ្នែកយោធា ឬយោធាប្រតិព័ន្ធ<br>• ការងារស៊ីវិលសម្រាប់រដ្ឋបាលរដ្ឋាភិបាល ឬគោលបំណងសាសនា<br>• ផលិត ឬប្រើប្រាស់ទំនិញគ្រោះថ្នាក់ផ្នែកបរិស្ថាន អាវុធ ឬគ្រឿងញៀន<br>• ផលិតកម្ម ឬការប្រើប្រាស់ឱសថ/ឌីណាមិក<br>• ការផ្តល់ហិរញ្ញប្បទានដល់ប្រាក់ខែរបស់រដ្ឋាភិបាល<br>• ផលិតកម្ម កែចម្លង កាន់កាប់ រក្សាទុក ឬលក់ថ្នាំជក់ ឬផលិតផល និងភេសជ្ជៈ ដែលមានផ្ទុកថ្នាំជក់<br>• សកម្មភាពក្នុងតំបន់អភិរក្សធម្មជាតិឬតំបន់ផ្សេងទៀតដែលត្រូវបានកំណត់សម្រាប់ការអភិរក្សជីវចម្រុះលើកលែងតែមានការលើកលែងជាមុន<br>• ការជីកយករ៉ែ ឬជីករកផ្កាថ្ម<br>• ការអភិវឌ្ឍធនធានធនធានទឹកតាមដងទន្លេដែលហូរចូលប្រទេសមួយផ្សេងទៀត<br>• ការប្រែប្រួលដល់ការហូរទឹកទន្លេចូលសមុទ្រ | • ផ្លូវធំជាតិ និងតាមខេត្ត<br>• ទំនប់វារីអគ្គិសនីដែលធំ និងមានហានិភ័យខ្ពស់ (ដូចបានបញ្ជាក់នៅក្នុង ESS3 ឧបសម្ព័ន្ធ ១)<br>• អគារសាសនា និងសន្តិសុខសម្រាប់គោលបំណងតែមួយមុខ<br>• បច្ចេកទេសកសិកម្មដែលតម្រូវមានការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់ច្រើនហួស<br>• អគារ ឬរចនាសម្ព័ន្ធផ្សេងៗដែប្រើប្រាស់សារធាតុអាបេស្តូស ជាសម្ភារសំណង់<br>• អគារ ឬរចនាសម្ព័ន្ធផ្សេងៗដែលប្រើប្រាស់ឈើមកពីការកាប់ឈើខុសច្បាប់ |

| | |
|---|---|
| • ការផ្តល់ជូនការងារ ឬសេវាកម្មទំនិញដោយអ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ដែលត្រូវបានប្រកាសថាមិនមានសិទ្ធិគ្រប់គ្រាន់ដោយធនាគារពិភពលោក | |

*ប្រភព៖ សម្រួលពី PIM នៃ LASED II*

269. ***ការត្រួតពិនិត្យផ្អែកលើផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមាន និងហានិភ័យដោយប្រើទម្រង់ស្តង់ដា។*** ដំណាក់កាលទី ២ នៃដំណើរការពិនិត្យ សម្រាប់សកម្មភាព និងការវិនិយោគដែលនឹងកំណត់ប្រភេទឧបករណ៍បរិស្ថាន និងសង្គម ដែលត្រូវរៀបចំ ពិគ្រោះយោបល់ និងផ្សព្វផ្សាយដោយគម្រោង។ ទម្រង់នៃការតាមដានទាំងនេះ បង្ហាញពីប្រភេទហានិភ័យទូទៅដែលទាក់ទងនឹងអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងមុខរបរចិញ្ចឹមជីវិតផ្អែកលើកសិកម្ម។ ទោះយ៉ាងណាក៏ដោយ វាចាំបាច់ក្នុងការត្រួតពិនិត្យហានិភ័យបន្ថែមទៀតដែលបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង និង / ឬក្នុងអំឡុងពេលរៀបចំផែនការដែលមានការចូលរួម។ ប្រភេទហានិភ័យសំខាន់ៗដែលត្រូវពិចារណារួមមាន៖

(a) លក្ខខណ្ឌការងារ និងពលកម្មរបស់បុគ្គលិកនៃអ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់ និងរបស់កម្មករសហគមន៍ រួមទាំងការធានានូវលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព និងការចៀសវាងគ្រោះថ្នាក់ពី ERW ដែលទាំងត្រូវបានកំណត់ថាជាហានិភ័យ

(b) ផលប៉ះពាល់បរិស្ថានអវិជ្ជមានដែលអាចកើតមាននៃអនុគម្រោង ដែលរួមមានការចោលសំណល់រឹងមិនអាចបំបែកបានដែលបង្កើតដោយអនុគម្រោងកសិកម្ម (ថង់ប្លាស្ទិកប៉ូលី ។ល។)

(c) ផលប៉ះពាល់សុខភាពនិងសុវត្ថិភាពសហគមន៍ដែលអាចកើតមាន។ ទាំងនេះរួមបញ្ចូល៖

(d) សម្រាប់គម្រោងផ្លូវថ្នល់ សុវត្ថិភាពចរាចរណ៍ផ្លូវគោក

(e) ចំពោះអនុគម្រោងកសិកម្ម ការប្រើប្រាស់ និងបោះចោលនូវសារជាតុគីមីកសិកម្មដោយសុវត្ថិភាពនៅទីណាសមស្រប

(f) ចំពោះកិច្ចសន្យាសំណង់ គ្រោះថ្នាក់សុវត្ថិភាពដល់សាធារណជនក្នុងពេលសាងសង់

(g) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើអនុគម្រោង

(h) ការផ្លាស់ទីលំនៅរបស់អ្នកប្រើប្រាស់ដីធ្លីដោយសារទីលំនៅ ឬបញ្ហាសេដ្ឋកិច្ច

(i) ផលប៉ះពាល់អវិជ្ជមានលើលទ្ធភាពទទួលបានដីនិងធនធានធម្មជាតិ;

(j) ផលប៉ះពាល់លើបេតិកភណ្ឌវប្បធម៌រូបី / អចលនវត្ថុ

(k) ហានិភ័យ និងផលប៉ះពាល់លើ និងវិធានការបន្ថែមដើម្បីការពារ និងផ្តល់ផលប្រយោជន៍វប្បធម៌សមស្របតាមដល់ជនជាតិដើមភាគតិច។

270. ***ការអនុម័តការពិនិត្យបឋម*** ជនបង្គោលផ្នែកគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នឹងធ្វើការពិនិត្យតាមដាន ដោយមានការគាំទ្រពីទីប្រឹក្សាផ្នែកគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមនៅថ្នាក់ខេត្ត។ ផ្អែកលើការត្រួតពិនិត្យ ហានិភ័យជាក់លាក់នៃអនុគម្រោងនឹងត្រូវបានចុះបញ្ជីនៅក្នុងជួរឈរខាងឆ្វេងនៃម៉ាទ្រីសផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៃអនុគម្រោងធម្មតា (ឧបសម្ព័ន្ធ១) ដោយមានការប៉ាន់ស្មាននៃផលប៉ះពាល់ និងប្រូបាបដែលអាចកើត មាន។ នៅដំណាក់កាលនេះការសិក្សាបន្ថែមដែលត្រូវអនុវត្តជា

ផ្នែកនៃការសិក្សា និងរចនាលទ្ធភាពសមិទ្ធិលទ្ធភាពនៃអនុគម្រោង នឹងត្រូវបានចុះនៅក្នុងជួរឈរដែលមានចំណងជើងថា "វិធានការកាត់បន្ថយផលប៉ះពាល់"។ ការសិក្សាទាំងនេះនឹងត្រូវធ្វើឡើងក្នុងអំឡុងពេលរៀបចំអនុគម្រោង ជាពិសេសដោយវិស្វករចនានៅក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ដែលនាំឱ្យមាន ម៉ាទ្រីសផែនការគ្រប់គ្រងបរិស្ថាន និងសង្គមកំពុងត្រូវបានធ្វើបច្ចុប្បន្នភាពជាមួយនឹងវិធានការបញ្ចៀស ឬវិធានការកាត់បន្ថយហានិភ័យ (ឬហានិភ័យត្រូវបានលុបចោលដោយផ្អែកលើលទ្ធផលនៃការសិក្សា)។ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៃអនុគម្រោង នឹងត្រូវពិនិត្យឡើងវិញ និងធ្វើសុពលកម្មដោយទីប្រឹក្សាគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នៅថ្នាក់ជាតិ។

### ៥.៧.២ ឧបករណ៍គ្រប់គ្រងហានិភ័យសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ

271. ឧបករណ៍ និងនីតិវិធីខាងក្រោមនេះនឹងត្រូវបានប្រើដើម្បីគ្រប់គ្រងហានិភ័យទាក់ទងនឹង បរិស្ថាន និងសង្គមនៃអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

- (l) ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៃអនុគម្រោង (ESMP)
- (m) ការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាពស្តង់ដា (ESHSS) ដែលត្រូវបញ្ចូលទៅក្នុងឯកសារកិច្ចសន្យាការងារទាំងអស់
- (n) ប្រសិនបើចាំបាច់ ផែនការតាំងទីលំនៅថ្មីនៃអនុគម្រោង ឬផែនការទទួលយកដីដោយស្ម័គ្រចិត្ត

272. ឧបករណ៍គ្រប់គ្រងហានិភ័យប្រតិបត្តិការទាំងនេះនឹងត្រូវរៀបចំឡើងក្នុងអំឡុងពេលអនុវត្តគម្រោង (សូមមើលខាងក្រោម) ប៉ុន្តែនឹងគោរព និងអនុលោមតាមក្រមប្រតិបត្តិបរិស្ថាន (ECOP) ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦។

### ៥.៧.៣ ការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព

273. ការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព (EHSS) នឹងត្រូវបង្កើត និងដាក់បញ្ចូលនៅក្នុងឯកសារកិច្ចសន្យាសម្រាប់កិច្ចសន្យាការងារ និងសេវាកម្ម។ បញ្ញត្តិដែលពាក់ព័ន្ធនឹងក្រមប្រតិបត្តិបរិស្ថាននឹងត្រូវបានដាក់បញ្ចូល។ វាត្រូវបានរំពឹងទុកថាកំណែទាំង ៣ នៃការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព (EHSS) នឹងត្រូវការៈ

- (a) កិច្ចសន្យាពេញលេញសម្រាប់កិច្ចសន្យាការងារដែលបានធ្វើលទ្ធកម្មទូទាំងប្រទេស (ទាំងនេះនឹងជាកិច្ចសន្យាដែលមានវិសាលភាពធំជាង និងស្មុគស្មាញជាងនេះ)
- (b) កំណែសមាមាត្រសម្រាប់កិច្ចសន្យាការងារដែលបានធ្វើដោយក្រុមប្រឹក្សាឃុំ (ទាំងនេះនឹងជាកិច្ចសន្យាមានវិសាលភាពតូចជាង និងមិនសូវស្មុគស្មាញ)
- (c) កំណែសម្រាប់អ្នកម៉ៅការសេវាកម្ម។

274. វិសាលភាពនៃការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព នឹងរួមបញ្ចូលកាតព្វកិច្ចរបស់អ្នកម៉ៅការទាក់ទងនឹង៖

(a) លក្ខខណ្ឌការងារ;
(b) ការមិនរើសអើង និងឱកាសស្មើគ្នា
(c) សិទ្ធិរបស់កម្មករក្នុងការរៀបចំ
(d) ការការពារពលកម្មដោយបង្ខំ និងការដាក់កំហិតលើពលកម្មកុមារ
(e) ការបញ្ជាក់ការផ្គត់ផ្គង់ ពីអ្នកផ្គត់ផ្គង់ដែលអនុលោមស្របតាមច្បាប់ការងារកម្ពុជា ស្តីពីពលកម្មដោយបង្ខំនិងពលកម្មកុមារ
(f) លទ្ធភាពចូលប្រើយន្តការបណ្តឹងរ៉ាវរបស់កម្មករ
(g) នីតិវិធីធ្វើការប្រកបដោយសុវត្ថិភាពលើការដ្ឋានសំណង់ រួមទាំងការផ្តល់សម្លៀកបំពាក់ និងឧបករណ៍សុវត្ថិភាព
(h) ស្តង់ដាសម្រាប់កន្លែងស្នាក់នៅស្អាតនិងមានអនាម័យនៅជុំការដ្ឋាន
(i) ការរាយការណ៍អំពីឧប្បត្តិហេតុ
(j) សំណងរបស់កម្មករ (ការធានារ៉ាប់រងជាកាតព្វកិច្ច)
(k) ការការពារការបំពុលបរិយាកាស ការបំពុលទឹក ការបំពុលសំឡេងក្នុងពេលធ្វើការនៅនឹងទីតាំង
(l) ការគ្រប់គ្រងសំណល់ប្រកបដែលគ្រោះថ្នាក់ និងមិនបង្កគ្រោះថ្នាក់
(m) ការការពារគ្រោះថ្នាក់ដល់សាធារណៈជនពីការងារសំណង់
(n) នីតិវិធីសុវត្ថិភាព ERW;
(o) នីតិវិធីនៃកំនាយដោយចៃដន្យអំឡុងពេលគម្រោង។

275. លក្ខខណ្ឌតម្រូវនៃការពិពណ៌នាលម្អិតពីបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព (EHSS) ភាគច្រើនត្រូវនឹងតម្រូវការនៃច្បាប់កម្ពុជា ប៉ុន្តែលើសពីបទដ្ឋានដែលបានអនុវត្តនៅក្នុងឧស្សាហកម្មសំណង់កម្ពុជា ជាពិសេសអ្នកម៉ៅការកម្រិតមូលដ្ឋាន។ ដើម្បីដោះស្រាយបញ្ហានេះ និងបញ្ចៀសលទ្ធផលដែលមិនចង់បាន ដែលអ្នកម៉ៅការក្នុងស្រុកត្រូវបានដកចេញ ជាលទ្ធផលនៃភាពគ្មានបទពិសោធន៍ជាមួយនឹងលក្ខខណ្ឌតម្រូវទាំងនេះ គម្រោងនឹងរៀបចំកូនសៀវភៅដែលមានរូបភាពសាមញ្ញពន្យល់ពីលក្ខខណ្ឌតម្រូវរបស់ESHSS។កូនសៀវភៅនេះនឹងត្រូវបានប្រើជាមូលដ្ឋានសម្រាប់បណ្តុះបណ្តាលអ្នកមើលការខុសត្រូវទីតាំងរបស់ អ្នកម៉ៅការ។ អ្នកម៉ៅការនឹងត្រូវបង្ហាញថា អ្នកមើលការខុសត្រូវទីតាំងបានបញ្ចប់ការបណ្តុះបណ្តាលនេះ ឬមានការបណ្តុះបណ្តាល ឬបទពិសោធន៍ដែលមានតម្លៃស្មើ ក្នុងការអនុលោមតាមលក្ខខណ្ឌតម្រូវ។ កូនសៀវភៅនេះក៏នឹងត្រូវចែកចាយផងដែរ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់កម្មករជាប់កិច្ចសន្យាក្រោម ESS2។

### ៥.៧.៤ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ

276. អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធទាំងអស់នឹងមានផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ដោយប្រើទម្រង់ម៉ាទ្រីសសាមញ្ញ ដែលអាចយល់ និងប្រើប្រាស់ដោយអ្នកម៉ៅការ និងមន្ត្រីមូលដ្ឋាន។ ទម្រង់ទូទៅនេះ

ត្រូវបានផ្តល់ជាឧបសម្ព័ន្ធ ៥។ ក្នុងអំឡុងពេលនៃការចាប់ផ្តើមគម្រោង ទម្រង់នេះនឹងត្រូវបានអភិវឌ្ឍបន្ថែមទៀតដើម្បីរួមបញ្ចូលបញ្ញត្តិស្តង់ដាទាក់ទងទៅនឹងប្រភេទហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ ។ល។) ក៏ដូចជាកន្លែងសម្រាប់បន្ថែមបញ្ញត្តិជាក់លាក់របស់អនុគម្រោង។

277. ប្បញ្ញត្តិផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៃអនុគម្រោងជាក់លាក់ នឹងត្រូវបានទាញចេញក្រមប្រតិបត្តិបរិស្ថាន (ECOP) ក្នុងនោះ (១) ការគ្រប់គ្រងសំឡេងរំខាន ធូលី និងការបំពុល ផ្សេងៗពីសកម្មភាពការងារ (២) បញ្ញត្តិសម្រាប់ការប្រើប្រាស់ដីផ្លីបណ្តោះអាសន្នដែលត្រូវការដោយអ្នកម៉ៅការ (៣) បញ្ញត្តិសម្រាប់ការគ្រប់គ្រងប្រកបដោយសុវត្ថិភាពនៃការងារបង្ហូរទឹកបណ្តោះអាសន្ន (៤) បញ្ញត្តិស្តីពីសុវត្ថិភាពផ្លូវថ្នល់ក្នុងពេលសាងសង់ និង (៥) បញ្ញត្តិសម្រាប់ធានាសុវត្ថិភាពដល់សាធារណជនពីគ្រោះថ្នាក់សំណង់ (គ្រឿងម៉ាស៊ីនដំណើរការ ។ល។)។

278. ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៃអនុគម្រោង នឹងត្រូវបញ្ចូលក្នុងឯកសារកិច្ចសន្យា។ វិស្វករត្រួតពិនិត្យ នឹងត្រូវបានតម្រូវឱ្យ ពិនិត្យតាមដាននិងរាយការណ៍អំពីការអនុវត្តនៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។

### ៥.៧.៥ បញ្ញត្តិគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមបន្ថែមតាមប្រភេទអនុគម្រោង

279. ចំពោះអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធទាំងអស់ វិស្វកររចនានឹងទទួលខុសត្រូវក្នុងការធានាថាការរចនានេះឆ្លុះបញ្ចាំងពីបញ្ញត្តិពាក់ព័ន្ធរបស់ក្រមប្រតិបត្តិបរិស្ថាន (ECOP)។

280. ការរចនាប្លង់ផ្លូវចូលទីតាំង នឹងត្រូវការផែនការសុវត្ថិភាពផ្លូវថ្នល់។ ផែនការសុវត្ថិភាពចរាចរណ៍នឹងត្រូវរៀបចំឡើងដោយវិស្វកររចនាប្លង់ ហើយនឹងបង្ហាញ (១) ថាសក្តានុពលនៃគ្រោះថ្នាក់ចរាចរណ៍ត្រូវបានពិចារណា និង (២) វិធានការពាក់ព័ន្ធដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍អប្បបរមាត្រូវបានដាក់បញ្ចូលក្នុងការរចនាប្លង់។ ការរចនាប្លង់ផ្លូវទាំងអស់ត្រូវតែបង្ហាញពីការអនុវត្តស្តង់ដាបង្ហាញពីភស្តុតាងអាកាសធាតុដែលពាក់ព័ន្ធ។

281. ចំពោះការងារធារាសាស្ត្រទាំងអស់ វិស្វកររចនាប្លង់នឹងតម្រូវឱ្យបង្ហាញ (១) ភាពមានទឹកគ្រប់គ្រាន់ (ផ្អែកលើគំរូដំណាំលម្អិត និងការគណនាតុល្យភាពទឹក) ហើយការបូមទឹកចេញបន្ថែមនឹងមិនមានផលប៉ះពាល់អវិជ្ជមានដល់អ្នកប្រើប្រាស់ពីមុនស្រាប់ ឬលើសេវាកម្មអេកូឡូស៊ីឡើយ។ (២) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុត្រូវបានពិចារណានៅក្នុងការរចនាប្លង់ និង (៣) សម្រាប់ការងាររួមទាំងទំនប់វារីអគ្គិសនីដែល (១) ទំនប់មិនស្ថិតក្នុងលក្ខណៈវិនិច្ឆ័យដែលអាចអនុវត្តបាននៃបទដ្ឋាន បរិស្ថាន និងសង្គម ទី ៤ ឧបសម្ព័ន្ធ១ ស្តីពីការពិនិត្យសុវត្ថិភាពទំនប់វារីអគ្គិសនី។

### ៥.៧.៦ លទ្ធកម្មដីសម្រាប់អនុគម្រោង

282. គម្រោង LASED III នឹងព្យាយាមចៀសវាង ឬកាត់បន្ថយជាអប្បបរមាការទិញដី ក្នុងករណីទាំងអស់។ ក្នុងករណីដែលការពិនិត្យបឋមការផ្តល់សម្បទានដីសង្គមកិច្ច ឬការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍

ជនជាតិដើមភាគតិច បញ្ជាក់ថាការទិញដី នឹងត្រូវការជាចាំបាច់ ផែនការតាំងទីលំនៅថ្មី នឹងត្រូវបានរៀបចំ និងអនុវត្តដូចដែលបានពិពណ៌នានៅក្នុង ក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង(RPF)។ ដំណើរការនេះជាធម្មតានឹងធានាថាមានដីគ្រប់គ្រាន់សម្រាប់អនុគម្រោងរួមទាំងផ្លូវចូលទីតាំងដោយមិនចាំបាច់ទិញដីបន្ថែមទៀត។

283. ក្នុងករណីពិសេស (ឧទាហរណ៍តម្រូវការផ្លាស់ប្តូរផ្លូវដែលបានស្នើឡើងនៃផ្លូវចូលទីតាំង) វាចាំបាច់ត្រូវធ្វើការទិញដីបន្ថែមសម្រាប់អនុគម្រោងជាក់លាក់។ នៅកន្លែងដែលត្រូវការដោយ ក្របខណ្ឌគោលនយោបាយសម្រាប់តាំងទីលំនៅថ្មី (RPF) ផែនការការតាំងទីលំនៅថ្មីនឹងត្រូវបានរៀបចំ និងអនុវត្តសម្រាប់អនុគម្រោង។

284. ក្នុងករណីខ្លះ គម្រោងអាចស្វែងរកវិភាគទានដោយស្ម័គ្រចិត្តនៃចំនួនដីតិចតួចសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ ពីអ្នកប្រើប្រាស់ដីនៅជាប់នឹងហេដ្ឋារចនាសម្ព័ន្ធដែលបានស្នើសុំ។ ក្នុងករណីភាគច្រើន អ្នកប្រើប្រាស់ដីទាំងនេះនឹងទទួលបានអត្ថប្រយោជន៍ពីអនុគម្រោង និង / ឬនឹងក្លាយជាអ្នកទទួលផលពីគម្រោងទាំងមូល។ ក្នុងករណីដែលត្រូវការការទិញដីដោយស្ម័គ្រចិត្ត ដំណើរការនេះរួមទាំងការព្រមព្រៀងដែលបានជូនដំណឹងពីអ្នកប្រើប្រាស់ដីនឹងត្រូវបានចងក្រងជាឯកសារនៅក្នុងផែនការវិភាគទានដីដោយស្ម័គ្រចិត្ត (Voluntary Land Contribution Plan)។ ទម្រង់ និងដំណើរការសម្រាប់ការណ៍នេះត្រូវបានបញ្ចូលក្នុង សៀវភៅណែនាំការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ C/SF PIM)។

### ៥.៧.៧ ឧបករណ៍គ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមសម្រាប់អនុគម្រោងកសិកម្ម

285. អនុគម្រោងកសិកម្មរួមមានការបណ្តុះបណ្តាលកសិករ ការបង្ហាញ ការផ្គត់ផ្គង់សម្ភារដាំដុះ ការគាំទ្រក្រោយការប្រមូលផលនិងទីផ្សារ និងការគាំទ្រដល់ការបង្កើតក្រុមកសិករ និងសហករណ៍។

286. គម្រោងនេះនឹងគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមនៃអនុគម្រោងកសិកម្ម ក្នុងក្របខណ្ឌនៃគោលនយោបាយនៃការអនុវត្តកសិកម្មល្អកម្ពុជា (CamGAP)។ នៅក្នុងក្របខណ្ឌនេះ គម្រោងនឹងធានាថា៖

- (a) អនុគម្រោង ត្រូវបានពិនិត្យដើម្បីធានាថាវានឹងមិនបណ្តាលឱ្យខូចខាតដល់បរិស្ថាន
- (b) អនុគម្រោង ត្រូវបានពិនិត្យដើម្បីធានាថាវានឹងមិនផ្តល់នូវតម្រូវការទឹកគ្មាននិរន្តរភាព (ទោះបីជា អនុគម្រោង មិនគាំទ្រការងារធារាសាស្ត្រដោយផ្ទាល់ក៏ដោយ)
- (c) អនុគម្រោង ត្រូវបានពិនិត្យដើម្បីធានាថាវានឹងមិនបណ្តាលឱ្យមានការប្រើប្រាស់សារធាតុគីមីកសិកម្មហួសកម្រិត ឬគ្មានសុវត្ថិភាព
- (d) ទោះយ៉ាងណាក៏ដោយ (c) ខាងលើ, រាល់ការបណ្តុះបណ្តាលកសិកររួមបញ្ចូលទាំងការណែនាំស្តីពីការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ការប្រើប្រាស់ និងការបោះចោលសារធាតុគីមីកសិកម្ម
- (e) សំណល់ប្លាស្ទិក និងសំណល់ដែលមិនអាចបំបែកបាន ដែលផលិតចេញពីសកម្មភាពកសិកម្មដែលត្រូវបានផ្សព្វផ្សាយ ត្រូវបានគេបោះចោលយ៉ាងត្រឹមត្រូវ

(f) អនុគម្រោងមិនជំរុញឱ្យកុមារធ្វើការនៅកសិដ្ឋានគ្រួសារដោយផ្ទុយនឹងបទដ្ឋាន បរិស្ថាន និងសង្គមទី២

(g) បញ្ញត្តិពាក់ព័ន្ធនៃ ECOP ត្រូវបានអនុវត្តតាម។

287. អនុគម្រោងកសិកម្មទាំងអស់នឹងត្រូវបានពិនិត្យសម្រាប់ហានិភ័យទាំងនេះ។ សម្រាប់អនុគម្រោងកសិកម្មភាគច្រើន ក្របខណ្ឌគ្រប់គ្រងហានិភ័យដែលមានមូលដ្ឋានលើគោលនយោបាយនៃការអនុវត្តកសិកម្មល្អកម្ពុជា នឹងមានភាពគ្រប់គ្រាន់។ ក្នុងករណីដែលមានហានិភ័យបន្ថែមដែលមិនត្រូវបានដោះស្រាយ ដោយក្របខណ្ឌនេះត្រូវបានកំណត់អត្តសញ្ញាណ ផែនការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមនឹងត្រូវបានត្រូវបានរៀបចំឡើង។

288. អនុគម្រោងកសិកម្មអាចត្រូវបានអនុវត្តដោយ PDAFF ដោយអង្គការក្រៅរដ្ឋាភិបាលដៃគូ ឬដោយស្ថាប័នឯកជន។ ក្នុងករណីទាំងអស់ អ្នកអនុវត្តនឹងទទួលខុសត្រូវក្នុងការធានាការអនុវត្តវិធានការគ្រប់គ្រងហានិភ័យរួមទាំងការរាយការណ៍ស្តីពីការអនុវត្តត្រឹមត្រូវនៃផែនការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម តាមដែលពាក់ព័ន្ធ។

## ៥.៧.៨ ឧបករណ៍គ្រប់គ្រងហានិភ័យសម្រាប់អនុគម្រោងដទៃទៀត

289. ប្រភេទអនុគម្រោង ក្រៅពីហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្មទំនងជាពាក់ព័ន្ធនឹងសកម្មភាពអភិវឌ្ឍន៍សហគមន៍ និង / ឬ ការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹង ហើយមិនត្រូវបានគេរំពឹងថានឹងបណ្តាលឱ្យមានហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមឡើយ។

290. អនុគម្រោងគ្រប់គ្រងសំណល់រឹង នឹងត្រូវបង្កើតជាពិសេសដើម្បីដោះស្រាយហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមដែលកំណត់។

291. អនុគម្រោងដែលពាក់ព័ន្ធនឹងការងារសហគមន៍ នឹងត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រងការងារសហគមន៍ដែលត្រូវត្រៀមរៀបចំក្នុងដំណាក់កាលចាប់ផ្តើមគម្រោង (សូមមើលផែនការគ្រប់គ្រងលក្ខខណ្ឌការងារនិងពលកម្ម)។

292. អនុគម្រោងទាំងអស់នឹងត្រូវបានត្រួតពិនិត្យនិងនៅចំណុចចាំបាច់ ផែនការគ្រប់គ្រង បរិស្ថាន និងសង្គមនឹងត្រូវបានប្រើប្រាស់។

## ៥.៧.៩ ខ្លឹមសារសង្ខេបឧបករណ៍គ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នៃអនុគម្រោង តាមប្រភេទគម្រោង

293. ក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម (ESMF) នេះបានបង្ហាញពីផលប៉ះពាល់បរិស្ថានដែលនឹងអាចកើតមាន នៃអនុគម្រោងនីមួយៗ ដែលត្រូវផ្តល់ថវិកាដោយគម្រោង LASED III

(សូមមើលជំពូក ៤)។ តារាងទី ១៦ ខាងក្រោមនេះសង្ខេបពីឧបករណ៍សម្រាប់ការកាត់បន្ថយផលប៉ះពាល់បរិស្ថានអវិជ្ជមានដែលនឹងអាចកើតមាន និងការគ្រប់គ្រងហានិភ័យដែលបានកំណត់ ផ្អែកលើប្រភេទអនុគម្រោង។

| តារាងទី ១៦៖ ឧបករណ៍សម្រាប់ការកាត់បន្ថយផលប៉ះពាល់ ដែលអាចកើតមាន នៅកម្រិតអនុគម្រោង | | | | |
|---|---|---|---|---|
| ប្រភេទអនុគម្រោង | ផលប៉ះពាល់ និងហានិភ័យដែលអាចកើតមាន | កាត់បន្ថយផល និងការគ្រប់គ្រងហានិភ័យ | ឧបករណ៍ | ESS |
| ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ | 1. ផលប៉ះពាល់ទាក់ទងនឹងសំណង់ដូចជាសំឡេងរំខាន ធូលីដីល្បាប់ ការហូរច្រោះការចោលសំណល់ការគ្រប់គ្រងទឹកភ្លៀង សុខភាពនិងសុវត្ថិភាពសហគមន៍និងកម្មករ | ឧបករណ៍គ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន ដែលត្រូវបានដាក់បញ្ចូលទៅក្នុងការបញ្ជាក់ EHS នៅក្នុងឯកសារដេញថ្លៃ | ការពិពណ៌នាលម្អិតពីបរិស្ថាន សង្គមសុខភាព និងសុវត្ថិភាព (ESHSS) ដើម្បីបង្កើត និងបញ្ចូលក្នុងឯកសារកិច្ចសន្យាការងារទាំងអស់ វិធានការដាក់លាក់នៃអនុគម្រោងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៃគម្រោង ការវាយតម្លៃហានិភ័យនៃទីតាំងដែលត្រូវធ្វើ | ESS1<br>ESS2<br>ESS3<br>ESS4 |
| | 2. សុខភាព និងសុវត្ថិភាពរបស់បុគ្គលិកគម្រោងធ្វើដំណើរទៅកន្លែងដាច់ស្រយាល | អនុម័តនិងអនុវត្ត OHS ដែលត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារដេញថ្លៃ | OHSP | ESS1<br>ESS2 |
| | 3. ការថយចុះនៃប្រភពទឹកក្រោមដី ទឹកលើដី ដោយការធ្វើអាជីវកម្ម ដែលគ្មានប្រសិទ្ធភាពឬគ្មាននិរន្តរភាព | ការវាយតម្លៃធនធានទឹកសម្រាប់ទីតាំងគម្រោងនីមួយៗ គ្មានការអភិវឌ្ឍប្រព័ន្ធជាពសាស្ត្រដោយមិនបានបញ្ជាក់ថានឹងមិនមានផលប៉ះពាល់អវិជ្ជមានដល់អ្នកប្រើប្រាស់ពីមុនស្រាប់ និង / ឬសេវាកម្មអេកូឡូស៊ីទេ។ | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង (ត្រូវបានរៀបចំនៅការគ្រប់គ្រងកម្រិតទីតាំង) | ESS1<br>ESS3<br>ESS10 |
| | 4. ផលប៉ះពាល់សុខភាពនៃការផ្គត់ផ្គង់ទឹកស្តង់ដាមិនអាចបរិភោគបានដោយសារតែ (១) អា | ប្រភពទឹកទាំងអស់ដែលត្រូវយកទៅពិសោធន៍ក្នុងមន្ទីរពិសោធន៍។ ក្នុងករណីមានសារធាតុអាសេនិក ឬការចម្លងរោគសារធាតុគីមី ពិធីសារ MRD[8] ត្រូវបានអនុវត្ត ក៏ដូចជាមាន | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង (ប្រភពទឹកលើដី ត្រូវធ្វើតេស្តម្តងទៀត អំឡុងពេលពិនិត្យបឋមទីតាំង) | ESS4 |

[8] ដើម្បីឱ្យបន្សុីគ្នានឹងស្តង់ដាជាតិរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តវិធានការដូចខាងក្រោម៖
-អនុគម្រោងផ្គត់ផ្គង់ទឹកថ្មី ធ្វើតេស្តទឹករកសារធាតុនានារួមទាំងអាសេនិក និងធៀបនឹងស្តង់ដាជាតិ
-ផ្សព្វផ្សាយពីលទ្ធផលនៃការធ្វើតេស្តគុណភាពទឹកទៅមេភូមិ និងជូនដំណឹងថាតើទឹកអាចទទួលបានបាន ឬទេ
-ផ្តល់ការណែនាំស្តីពីជម្រើសប្រព្រឹត្តកម្មមូលដ្ឋាន ក្នុងករណីស្ថិតក្នុងប៉ារ៉ាម៉ែត្រ/លើសកម្រិតស្តង់ដា។ ភូមិមួយចំនួនប្រហែលជាត្រូវអនុវត្តអនុគម្រោងប្រព្រឹត្តកម្មទឹកពិសាក្នុងវដ្តបន្តបន្ទាប់។
-ក្នុងករណីដែលមានសារធាតុអាសេនិកខ្ពស់ជាងកម្រិតស្តង់ដា មិនគួរធ្វើប្រព្រឹត្តកម្មដើម្បីកំចាត់សារធាតុអាសេនិកទេ ព្រោះត្រូវចំណាយច្រើនលើការតម្លើង និងការជួសជុល និងកង្វះសមត្ថភាពក្នុងការដំណើរការ និងជួសជុលថែទាំប្រព័ន្ធនេះ។ ផ្ទុយទៅវិញ ការជំនួសដោយប្រភពទឹកដែលមានអាសេនិក

| តារាងទី ១៦៖ ឧបករណ៍សម្រាប់ការកាត់បន្ថយផលប៉ះពាល់ ដែលអាចកើតមាន នៅកម្រិតអនុគម្រោង | | | | |
|---|---|---|---|---|
| ប្រភេទអនុគម្រោង | ផលប៉ះពាល់ និងហានិភ័យដែលអាចកើតមាន | កាត់បន្ថយផល និងការគ្រប់គ្រងហានិភ័យ | ឧបករណ៍ | ESS |
| | សេនិកធម្មជាតិ; (២) ការបំពុលដោយសារជាតុគីមី (៣) ការចម្លងពោគជីវសាស្ត្រ | ប្រភពទឹកផឹកជំនួសដែលត្រូវបានផ្តល់ឱ្យ។<br>ក្នុងករណីមានការចម្លងពោគជីវសាស្ត្រ អណ្តូងត្រូវការសម្លាប់មេពោគ និងតេស្តសាកល្បងម្តងទៀត | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង នៃអនុគម្រោង | |
| | 4. កន្លែងវប្បធម៌អាចរួមបញ្ចូលទាំង ព្រៃឈើ ដីព្រៃអារក្ស ដីលំនៅដ្ឋាន និងកសិកម្ម | ការគូសផែនទីបេតិកកណ្ឌវប្បធម៌ដែលគេស្គាល់ការអនុវត្តច្បាប់ព្រៃឈើទាក់ទងនឹងការទទួលស្គាល់ នូវការប្រើប្រាស់ និងការអនុវត្តតាមបែបប្រពៃណីរបស់សហគមន៍មូលដ្ឋាន ថាជាប្រើប្រាស់សម្រាប់គោលបំណងវប្បធម៌ (សាសនានិង / ឬព្រៃអារក្ស) | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមតាមទីតាំង (ត្រូវបានរៀបចំនៅការគ្រប់គ្រងកម្រិតទីតាំង) | ESS1<br>ESS8<br>ESS10 |
| | 5. ការខូចខាតដោយសារទឹកជំនន់បណ្តាលមកពីការបាក់រលំនៃទំនប់វារីអគ្គិសនីគាំទ្រដោយគម្រោង | ធានានូវការរចនាប្លង់ប្រកបដោយសុវត្ថិភាព | ទំនប់វារីអគ្គិសនីទាំងអស់ត្រូវការការពិនិត្យបឋមនៃសុវត្ថិភាពនៃការរចនាប្លង់។ ទំនប់វារីអគ្គិសនីដែលធំ ហើយមានហានិភ័យខ្ពស់ត្រូវបានកំណត់ដោយ ESS4 ស្ថិតនៅក្នុងបញ្ជីផលប៉ះពាល់ អវិជ្ជមាន។ | ESS1<br>ESS4<br>ESS10 |
| ការអភិវឌ្ឍកសិកម្ម និងមុខរបរចិញ្ចឹមជីវិត | 1. ផលប៉ះពាល់[9] លើសុខភាព និងសុវត្ថិភាពនៃសហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោង ជាពិសេសទាក់ទិនទៅនឹងការប្រើប្រាស់ និងការប្រើថ្នាំសម្លាប់សត្វល្អិត និងជីគីមីដោយសុវត្ថិភាព | ការអនុវត្តឧបករណ៍បរិស្ថាន និងសង្គម ការណែនាំគោលនយោបាយនៃការអភិវឌ្ឍកសិកម្មល្អកម្ពុជាដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការលើកកម្ពស់ការយល់ដឹង និងកសិករទទួលបានការបណ្តុះបណ្តាលអំពីការប្រើប្រាស់សារជាតុគីមីកសិកម្មដោយត្រឹមត្រូវ | បញ្ញត្តិ ECOP (ប្រសិនបើមិនទាន់គ្រប់ដណ្តប់ដោយ CamGAP)<br>នៅកន្លែងដែលអ្នកផ្តល់ សេវាកម្ម ត្រូវបានធ្វើកិច្ចសន្យាសម្រាប់គម្រោងមុខរបរចិញ្ចឹមជីវិត ការអនុលោមតាម ECOP គឺជាលក្ខខណ្ឌកិច្ចសន្យា។ | ESS1<br>ESS3<br>ESS4<br>ESS10 |

តិច ដូចជា ទឹកភ្លៀង ទឹកជ្រោះធម្មជាតិ និងទឹកលើដីដែលអាចរកបាន នឹងជាដំណោះស្រាយមួយដ៏សមស្រប។ យកល្អគួររកប្រភពទឹកដែលទទួលទានបានថ្មី ដូចជា ទឹកលើដី ដែលគួរធ្វើតេស្តដើម្បីអនុលោមតាមស្តង់ដាដែលទទួលទានបាន។

[9] គម្រោងនឹងមិនផ្តល់ហិរញ្ញប្បទានដល់វត្ថុធាតុគ្រោះថ្នាក់ទាំងនេះទេ ប៉ុន្តែការផ្លាស់ប្តូរកម្មសិទ្ធិដីធ្លីអាចតម្រូវឱ្យកសិករថ្មីប្រើប្រាស់វត្ថុធាតុទាំងនេះ។

| តារាងទី ១៦៖ ឧបករណ៍សម្រាប់ការកាត់បន្ថយផលប៉ះពាល់ ដែលអាចកើតមាន នៅកម្រិតអនុគម្រោង | | | | |
|---|---|---|---|---|
| ប្រភេទអនុគម្រោង | ផលប៉ះពាល់ និងហានិភ័យដែលអាចកើតមាន | កាត់បន្ថយផល និងការគ្រប់គ្រងហានិភ័យ | ឧបករណ៍ | ESS |
| | 2. ការចម្លងរោគទៅក្នុងទឹកតាមការប្រើប្រាស់សារធាតុគីមីកសិកម្មមិនត្រឹមត្រូវ | ការលើកកម្ពស់ការយល់ដឹង | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៃអនុគម្រោង នៅពេលដែលកសិករត្រូវបានជំរុញឱ្យអនុវត្តតាមស្តង់ដារបស់ CamGAP / ECOP (ដែលកាន់តែមានការតឹងរ៉ឹងជាង) | ESS1<br>ESS3<br>ESS10 |
| | 3. ការបំពុលបរិស្ថានពីសំណល់រឹងដែលមិនអាចបំបែកបានពីសកម្មភាពកសិកម្ម | ការលើកកម្ពស់ការយល់ដឹង, វិធានការគ្រប់គ្រងសំណល់រឹង | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គមនៃអនុគម្រោង នៅពេលដែលកសិករត្រូវបានជំរុញឱ្យអនុវត្តតាមស្តង់ដារបស់ CamGAP / ECOP (ដែលកាន់តែមានការតឹងរ៉ឹងជាង) | ESS1<br>ESS3<br>ESS10 |

## ៥.៨ ការតាមដានការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម

294. គម្រោង LASED III នឹងតាមដាន និងរាយការណ៍ជាប្រព័ន្ធអំពីការអនុវត្តនីតិវិធីគ្រប់គ្រង ហានិភ័យទាក់ទងបរិស្ថាន និងសង្គម តាមរយៈការផ្ទៀងផ្ទាត់ការអនុវត្តផែនការគ្រប់គ្រងហានិភ័យទាំងអស់ ការកត់ត្រាទិន្នន័យសំខាន់ៗនៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងគម្រោង ការដាក់បញ្ចូលផ្នែកគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមដោយខានពុំបាន នៅក្នុងរបាយការណ៍វឌ្ឍនភាពទាំងអស់និង សវនកម្មទាក់ទងនឹងបរិស្ថាន និងសង្គម ត្រូវធ្វើឡើងដោយអ្នកជំនាញ ឯករាជ្យ មុនពេលធ្វើការពិនិត្យរយៈពេលពាក់កណ្តាលអាណត្តិ។ ក្រុមសវនកម្មទាក់ទងនឹងបរិស្ថាន និងសង្គមនឹងរួមបញ្ចូលជំនាញក្នុងការគ្រប់គ្រងហានិភ័យបរិស្ថាន ការគ្រប់គ្រងហានិភ័យសង្គម និងបញ្ហាជនជាតិដើមភាគតិច។

295. ផែនការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំងរួមមាន ESMP, SEP, RP, និង IPP តាមការណ៍ដែលពាក់ព័ន្ធ នឹងត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ហើយស្ថានភាពនៃការអនុវត្តវិធានការកាត់បន្ថយហានិភ័យនីមួយៗ នឹងត្រូវបានកត់ត្រាទុក។ សូមមើលការរៀបចំការអនុវត្ត និងការពិនិត្យតាមដាននៅក្នុងជំពូកទី ៨។

296. ការអនុវត្តឧបករណ៍គ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមកម្រិតអនុគម្រោង ត្រូវបានត្រួតពិនិត្យនិងកត់ត្រា។ គ្រោង ឬទម្រង់របាយការណ៍សាមញ្ញមួយនឹងត្រូវបានបង្កើតឡើងដោយគម្រោង ហើយនឹងត្រូវបានប្រើដើម្បីកត់ត្រាលទ្ធផលនៃការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម។ យ៉ាងហោចណាស់គ្រោងរបាយការណ៍នឹងរាប់បញ្ចូលនូវ៖

(a) នីតិវិធីគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងហានិភ័យដែលបានរៀបចំ

(b) ព្រឹត្តិការណ៍ហានិភ័យជាក់ស្តែងដែលកំពុងកើតឡើង
(c) ការស្ទង់មតិនៅលើទីតាំងស្តីពីគុណភាពនិងលទ្ធផលនៃការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម ផ្អែកលើការចុះទៅកាន់ទីតាំងរបស់ទីប្រឹក្សាផ្នែកគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម
(d) ការអភិវឌ្ឍសមត្ថភាពសម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម
(e) បទពិសោធន៍ដែលទទួលបាន និងអនុសាសន៍។

297. ការបំពេញកាតព្វកិច្ចរបស់អ្នកម៉ៅការទាំងអស់សម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងនឹង បរិស្ថាន និងសង្គម នឹងជាលក្ខខណ្ឌមួយសម្រាប់ការចេញនូវការទូទាត់ចុងក្រោយដល់អ្នកម៉ៅការ។

298. ផែនការគ្រប់គ្រងហានិភ័យនៅនឹងទីតាំង និងអនុគម្រោង ដែលមានភ្ជាប់ជាមួយស្ថានភាពអនុវត្តន៍ និងរបាយការណ៍គ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម ចុងក្រោយនៃអនុគម្រោងនឹងត្រូវរក្សាទុកជាឯកសារសម្រាប់ត្រួតពិនិត្យនៅពេលចាំបាច់។

299. ប្រព័ន្ធព័ត៌មានគ្រប់គ្រងរបស់គម្រោង LASED III នឹងកត់ត្រា ក្នុងកម្រិតអប្បបរមាសម្រាប់កម្រិតទីតាំង និងអនុគម្រោង៖
(a) នីតិវិធីគ្រប់គ្រងហានិភ័យទាក់ទងបរិស្ថាន និងសង្គម ដែលពាក់ព័ន្ធ
(b) កាលបរិច្ឆេទនៃការអនុម័តផែនការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងបរិស្ថាន និងសង្គមដែលតម្រូវឱ្យមាន។

300. របាយការណ៍វឌ្ឍនភាពរូបវន្តតាមកាលកំណត់របស់គម្រោង LASED III នឹងរួមបញ្ចូលផ្នែកមួយស្តីពីការអនុវត្តការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម។ របាយការណ៍ទាំងនេះ នឹងត្រូវព្រាងឡើងដោយភ្នាក់ងារអនុវត្តន៍ដោយមានការគាំទ្រពីទីប្រឹក្សាផ្នែកគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នៅថ្នាក់ខេត្តនិងថ្នាក់ជាតិ និងត្រូវបានគាំទ្រដោយទិន្នន័យពាក់ព័ន្ធ។

301. មុនពេលការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃគម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដំហាន៣ (LASED-III) គម្រោងនឹងធ្វើការជាមួយអ្នកពិគ្រោះយោបល់ឯករាជ្យ ឬក្រុមហ៊ុនពិគ្រោះយោបល់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សមរម្យ (ឧ.គ្មានទំនាក់ទំនងកិច្ចសន្យាផ្សេងទៀតជាមួយគម្រោង) ដើម្បីពិនិត្យមើលសង្គតិភាព និងគុណភាពនៃការអនុវត្តការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នៅក្នុងគម្រោង និងភាពអនុលោមតាមលក្ខខណ្ឌតម្រូវនៃ ESS1-ESS10។ ការរកឃើញនៃសវនកម្មនឹងត្រូវយកមកពិចារណានៅក្នុងការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ ហើយការកែប្រែនីតិវិធីគម្រោងនឹងត្រូវបានអនុម័តបើចាំបាច់។

## ៦. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន

302. ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ត្រូវបានរៀបចំ ដើម្បីអនុលោមតាមលក្ខខណ្ឌតម្រូវនៃការពិគ្រោះយោបល់ និងផ្សព្វផ្សាយព័ត៌មានរបស់ ESS1-ESS8 និងតាមលក្ខខណ្ឌតម្រូវរបស់ ESS10។ SEPពិពណ៌នាអំពីវិធីសាស្រ្តនៃការចូលរួមជាមួយភាគីពាក់ព័ន្ធអំឡុងពេលរៀបចំគម្រោង និងវិធីសាស្រ្តដែលត្រូវប្រើប្រាស់ពេញវដ្តនៃគម្រោង ដោយបែងចែករវាងភាគីដែលរងផលប៉ះពាល់ពីគម្រោង (PAP) និងភាគីដែលចាប់អារម្មណ៍ទៅលើគម្រោង។ SEP ពិពណ៌នាអំពីព័ត៌មានដែលត្រូវផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ និងវិធីសាស្រ្តដែលត្រូវប្រើសម្រាប់ការពិគ្រោះយោបល់ជាមួយភាគី ពាក់ព័ន្ធនៅដំណាក់កាលនីមួយៗ។ SEP រួមបញ្ចូលទាំងយន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)។ SEP បង្ហាញគំរូសម្រាប់ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធយ៉ាងសាមញ្ញ និងសង្ខេបជាក់លាក់ ដើម្បីរៀបចំសម្រាប់ទីតាំងការផ្តល់សម្បទានដីសង្គមកិច្ច និងការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចថ្មីនីមួយៗ ដោយរៀបរាប់លម្អិតអំពីសកម្មភាព និងពេលវេលាសម្រាប់ការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធនៅទីតាំង។

303. កំណត់គោលការណ៍សម្រាប់កំណត់អត្តសញ្ញាណរបស់ភាគីពាក់ព័ន្ធ (ភាគីដែលរងផលប៉ះពាល់ពីគម្រោង និងភាគីដែលចាប់អារម្មណ៍លើគម្រោង) និងលក្ខខណ្ឌតម្រូវទូទៅសម្រាប់ការផ្សព្វផ្សាយព័ត៌មាន ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ក្នុងការធ្វើផែនការសកម្មភាពនៅការផ្តល់សម្បទានដីសង្គមកិច្ច ឬការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចណាមួយ ការចូលរួមក្នុងអំឡុងពេលអនុវត្តន៍ និងរបាយការណ៍ខាងក្រៅ ក៏ដូចជាយន្តការដោះស្រាយបណ្តឹងតវ៉ារបស់គម្រោង (មើលខាងក្រោម)។

304. សម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ច ឬការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច លក្ខខណ្ឌតម្រូវនៃពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មានដែលត្រូវបានពិពណ៌នានៅក្នុង SEF នឹងឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវនៅកម្រិតគម្រោងនៃបទដ្ឋានបរិស្ថា និងសង្គមទី ១០។ ដូច្នេះផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ នៅទីតាំងជាក់លាក់ នឹងត្រូវបានរៀបចំ ហើយនឹងត្រូវបានផ្សព្វផ្សាយមុនពេលសកម្មភាពសំខាន់ៗចាប់ផ្តើមនៅទីតាំង។ ការផ្សព្វផ្សាយនឹងត្រូវដាក់ ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ ជាភាសាខ្មែរនៅលើគេហទំព័រគម្រោង និងតាមរយៈការបង្ហាញនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសម្រាប់ទីតាំងនីមួយៗ។ បញ្ញត្តិនៃការផ្សព្វផ្សាយបន្ថែមអាចត្រូវបានទាមទារសម្រាប់ការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ដែលអាចមានកម្រិតអក្ខរកម្មនិង/ឬជំនាញភាសាខ្មែរទាប។

305. ខ្លឹមសារនៃផែនការចូលរួលរបស់ភាគីពាក់ព័ន្ធតាមទីតាំង នឹងត្រូវស្របតាមគោលការណ៍ និងនីតិវិធីដែលមានចែងនៅក្នុងផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ នៃគម្រោងហើយនឹងរួមបញ្ចូលខ្លឹមសារដូចខាងក្រោម៖

(a) ការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធរួមទាំងទំនាក់ទំនងរបស់ពួកគេចំពោះគម្រោង និងតម្រូវការពិគ្រោះយោបល់ពិសេសឬឧបសគ្គនានាសម្រាប់ក្រុមនីមួយៗ

(b) ជំហាននៃការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការរៀបចំផែនការ និងការអនុវត្តការ ផ្តល់សម្បទានដីសង្គមកិច្ច ឬការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច

(c) ការចូលរួមរបស់ភាគីពាក់ព័ន្ធសម្រាប់ការវាយតម្លៃហានិភ័យទាក់ទងនឹងបរិស្ថាននិងសង្គម

(d) ជំហាននៃការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការរចនាប្លង់អនុគម្រោង

(e) យុទ្ធសាស្ត្រដើម្បីធានាឱ្យមានការតំណាងពេញលេញ នៃទស្សនៈ និងតម្រូវការរបស់ក្រុមជួបការលំបាក និងងាយរងគ្រោះរួមមានសហគមន៍ជនជាតិដើមភាគតិចក៏ដូចជា មនុស្សចាស់ ប្រជាជនក្រីក្រ ជនពិការ ស្ត្រី និងយុវជន

(f) យុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយព័ត៌មាន។

306. ឧបករណ៍គ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាននិងសង្គម តាមទីតាំង (ESMP, SEP, RP, IPP, តាមដែលត្រូវការ) នឹងត្រូវបានផ្សព្វផ្សាយ [នៅក្នុងសេចក្តីព្រាងមុនការអនុម័ត / បន្ទាប់ពីគ្មានការជំទាស់ពីធនាគារពិភពលោក] តាមរយៈមធ្យោបាយដូចគ្នានឹងផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ តាមទីតាំង។

## ៧. ការរៀបចំការអនុវត្ត

### ៧.១ តួនាទី និងការទទួលខុសត្រូវ

307. ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្នុងនាមជាភ្នាក់ងារប្រតិបត្តិនៃគម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជំហាន៣ (LASED-III) នឹងត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពីការអនុវត្ត ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF), ផែនការប្តេជ្ញាចិត្តផ្នែក បរិស្ថាននិងសង្គម (ESCF) និង ឧបករណ៍ដទៃទៀត។ ទោះយ៉ាងណា ការអនុវត្តនីតិវិធីគ្រប់គ្រង ហានិភ័យទាក់ទងនឹងបរិស្ថាន និង សង្គម គឺជាទំនួលខុសត្រូវរបស់ភ្នាក់ងារអនុវត្តគម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជំហាន ៣ (LASED-III) បុគ្គលិករបស់ពួកគេ និងដៃគូអង្គការមិនមែនរដ្ឋាភិបាលនានា។ ដើម្បីឆ្លុះបញ្ចាំងពីបញ្ហានេះ គេរំពឹងថាបុគ្គលិកគម្រោងទាំងអស់ រួមទាំងដៃគូអង្គការមិនមែនរដ្ឋាភិបាលនឹងដឹងអំពីគោលការណ៍ និង ឧបករណ៍សំខាន់ៗសម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាននិងសង្គមនៅក្នុងគម្រោង LASED។ ការទទួលខុសត្រូវនេះក៏ពង្រីកដល់អ្នកគ្រប់គ្រង និងអ្នកមើលការខុសត្រូវរបស់អ្នកម៉ៅការគម្រោង និងអ្នកផ្គត់ផ្គង់នៅចំណុចណាដែលពាក់ព័ន្ធ។

308. ទីភ្នាក់ងារអនុវត្តន៍គម្រោង LASED សំខាន់ៗនីមួយៗ (ក្រសួងដែនដី នគរូបនីយកម្មនិងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋបាលខេត្ត) នឹងមានមន្ត្រីរដ្ឋាភិបាលពីររូបតែងតាំងជាជនបង្គោលសម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម (ម្នាក់ជំនាញខាងបរិស្ថាន និងម្នាក់ជំនាញខាងផ្នែកទិដ្ឋភាពសង្គម)។ដៃគូអង្គការក្រៅរដ្ឋាភិបាលនីមួយៗ ក៏នឹងត្រូវបានគេរំពឹងថានឹងតែងតាំងជនបង្គោលមួយរូប សម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងនឹង បរិស្ថាន និងសង្គម។ មន្ត្រីទាំងនេះនឹងត្រូវបានរំពឹងថា នឹងចូលរួមវគ្គបណ្តុះបណ្តាលនិងព្រឹត្តិការណ៍ពាក់ព័ន្ធទាំងអស់។ ទំនួលខុសត្រូវសំខាន់ៗនៃជនបង្គោលទាំងនេះ រួមមានការពិនិត្យបឋមទាក់ទងនឹងបរិស្ថាន និងសង្គម និងការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និង

សង្គម និងឧបករណ៍ផ្សេងទៀតនៅកម្រិតទីតាំង ការពិនិត្យបឋមនៃអនុគម្រោង និងការកំណត់ចំណុចដែលនីតិវិធីវិធានការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមតម្រូវឱ្យមាន ការរៀបចំផែនការគ្រប់គ្រង បរិស្ថាន និងសង្គមនៃអនុគម្រោង និងឧបករណ៍នានាតាមដែលត្រូវការ និងការគាំទ្រការពិនិត្យតាមដាន និងការរាយការណ៍របស់ទីប្រឹក្សាគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម។




រូបភាពទី 3៖ បុគ្គលិកសំខាន់ៗនៃការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម

309. នឹងមានទីប្រឹក្សាគ្រប់គ្រងហានិភ័យទាក់ទងនឹងសង្គមមួយរូប ទីប្រឹក្សាគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថានមួយរូប និងទីប្រឹក្សាបញ្ហាជនជាតិដើមភាគតិចដែលប្រចាំការនៅក្នុង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មួយរូប នឹងធ្វើការពេញម៉ោងសម្រាប់គម្រោង LASED III។ មានទីប្រឹក្សាគ្រប់គ្រងហានិភ័យទាកទងនឹងបរិស្ថាន-សង្គម ដែលធ្វើការពេញម៉ោងយ៉ាងតិចចំនួន ៥ នាក់ ដែលនឹងផ្តល់ប្រឹក្សាដល់ក្រុមគម្រោងថ្នាក់ខេត្តនៅតាមបណ្តាខេត្តនានាដែលមានទីតាំងការផ្តល់សម្បទានដីសង្គមកិច្ច ឬការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចថ្មី កំពុងត្រូវបានរៀបចំ៖ ក្នុងករណីខ្លះទីប្រឹក្សាម្នាក់អាចនឹងត្រូវការគាំទ្រខេត្តច្រើនជាងមួយខេត្ត។ ភ្ជាប់ជាមួយរដ្ឋបាលខេត្តនីមួយៗ TORs នៃទីប្រឹក្សាទាំងនេះត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទី១០។តួនាទីចម្បងរបស់ទីប្រឹក្សាផ្នែកគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម (១) ដើម្បីកសាងសមត្ថភាពសម្រាប់ការអនុវត្ត ក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម, ផែនការប្តេជ្ញាចិត្តសម្រាប់គ្រប់គ្រងបរិស្ថាន និងសង្គម និងឧបករណ៍ការពារសុវត្ថិភាពផ្សេងទៀត (២) ជួយក្នុង

ការរៀបចំទីតាំងដាក់លាក់ SEP, ESMP, IPP និងឧបករណ៍ផ្សេងទៀតតាមតម្រូវការ (៣) ផ្តល់ដំបូន្មានតាមតម្រូវការទាក់ទងនឹងហានិភ័យបរិស្ថាន ឬសង្គមណាមួយដែលបានកំណត់ក្នុងពេលអនុវត្តន៍ និង (៤) តាមដាននិងរាយការណ៍អំពីការអនុវត្តនីតិវិធីការពារសុវត្ថិភាព រួមទាំងនៅកម្រិតអនុគម្រោង។

310. គម្រោងនេះ នឹងមានអ្នកជំនាញឯកទេសសម្រាប់បញ្ហាទាក់ទងនឹងបរិស្ថាន និងសង្គម ដែលលើសពីសមត្ថភាពបច្ចេកទេសរបស់ទីប្រឹក្សាផ្នែកបរិស្ថាន និងសង្គម រួមទាំងការផ្ទៀងផ្ទាត់សុវត្ថិភាពនៃទំនប់ទឹក និងករណីផ្សេងទៀតដែលអាចផ្អែកលើការណែនាំរបស់អ្នកជំនាញផ្នែកការពារសុវត្ថិភាពនៃធនាគារពិភពលោក។

311. សវនកម្មពាក់ព័ន្ធនឹងបរិស្ថាន និងសង្គមដែលនឹងត្រូវធ្វើឡើង មុនពេលការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ នឹងត្រូវបានធ្វើលទ្ធកម្មតាមរយៈក្រសួងដែនដី នគរូបនីយកម្ម និងសំណង់។

## ៧.២ ផែនការកសាងសមត្ថភាព

### ៧.២.១ ការវាយតម្លៃសមត្ថភាពសង្ខេប

312. ភ្នាក់ងារអនុវត្តន៍គម្រោង LASED III គ្រប់លំដាប់ថ្នាក់បានបង្កើតបទពិសោធន៍ និងសមត្ថភាពក្នុងការអនុវត្តនីតិវិធី ESS ក្នុងក្របខណ្ឌនៃគម្រោង LASED II។ ទោះយ៉ាងណាគម្រោង LASED III នឹងបង្ហាញពីបញ្ហាប្រឈមបន្ថែមទៀតរួមមាន (i) ការកែតម្រូវទៅនឹងលក្ខខណ្ឌតម្រូវរបស់ ESF (ii) លក្ខខណ្ឌតម្រូវបន្ថែមដែលជាលទ្ធផលពីការចូលរួមយ៉ាងជិតស្និទ្ធជាមួយសហគមន៍ជនជាតិដើមភាគតិច។

313. ចំណុចខ្សោយដែលត្រូវបានកត់សម្គាល់នៅក្នុងការអនុវត្តការការពារសុវត្ថិភាពផ្នែកបរិស្ថាន និងសង្គមនៅក្នុង LASED III រួមមាន៖

(a) នីតិវិធីដែលត្រូវការ ត្រូវបានអនុវត្តតាមបទដ្ឋានដែលអាចទទួលយកបាន។ បុគ្គលិកគម្រោង និងភ្នាក់ងារអនុវត្តន៍មិនធ្វើការវិភាគយ៉ាងសកម្ម ចំពោះហានិភ័យដែលមានសក្តានុពលលើសពីអ្វីដែលបានដោះស្រាយជាពិសេសដោយនីតិវិធីនោះទេ។ ការការពារសុវត្ថិភាព ភាគច្រើនត្រូវបានគេមើលឃើញថាជាទិដ្ឋភាពនៃការរៀបចំផែនការដីធ្លី (នេះអាចជាលទ្ធផលមួយផ្នែកនៃការរួមបញ្ចូលគ្នារវាងភារកិច្ចរបស់ GIS និងទីប្រឹក្សាផ្នែកការពារសុវត្ថិភាព) និងបញ្ហាដែលមិនមែនទីតាំង (ដូចជាការគ្រប់គ្រងសំណល់រឹងពុំបានល្អ ឬការប្រើប្រាស់គីមីកសិកម្មមិនត្រឹមត្រូវ) មិនត្រូវបានកំណត់អត្តសញ្ញាណ និងដោះស្រាយទេ។

(b) របាយការណ៍គម្រោងបង្ហាញថាយន្តការដោះស្រាយបណ្តឹងតវ៉ា (CHM) ត្រូវទទួលខុសត្រូវចំពោះសក្តានុពលនៃពាក្យបណ្តឹងមួយចំនួនធំដែលនឹងត្រូវបង្កើតឡើងក្នុងអំឡុងពេលនីតិវិធីផ្តល់បណ្ណកម្មសិទ្ធិដីធ្លី)។

(c) មិនមានការពិនិត្យតាមដាន និងការរាយការណ៍គ្រប់គ្រាន់អំពីបញ្ហា E&S។

314. ការផ្លាស់ប្តូរទៅក្របខណ្ឌ ESF នឹងតម្រូវឱ្យបុគ្គលិកគម្រោង និងភ្នាក់ងារអនុវត្តន៍នៅគ្រប់កម្រិតរួមទាំង អាជ្ញាធរមូលដ្ឋាន អ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់ អភិវឌ្ឍការយល់ដឹងទូលំទូលាយអំពីវិធីសាស្ត្រក្របខណ្ឌបរិស្ថាន និងសង្គម រួមទាំងគោលការណ៍សមាមាត្រ និងការគ្រប់គ្រងសម្របទៅនឹងហានិភ័យទាក់ទងនឹងបរិស្ថាន និង សង្គម។ វាក៏នឹងតម្រូវឱ្យមានការអភិវឌ្ឍសមត្ថភាពជាក់លាក់ទាក់ទងនឹងបទដ្ឋានបរិស្ថាន និងសង្គមនីមួយៗ ដែរ ប៉ុន្តែមិនមែនតែឯកឯងទេ (i) បទដ្ឋានបរិស្ថាន និងសង្គមទី២ - លក្ខខណ្ឌការងារ និងពលកម្ម ជាពិសេស សម្រាប់កម្មករដែលជួលដោយអ្នកម៉ៅការគម្រោង និងអ្នកផ្គត់ផ្គង់ (ii) បទដ្ឋានបរិស្ថាន និងសង្គមទី ៤ - ការ កំណត់អត្តសញ្ញាណ និងការគ្រប់គ្រងហានិភ័យសុខភាព និងសុវត្ថិភាពសហគមន៍ និង បទដ្ឋានបរិស្ថាន និង សង្គមទី ៨ - ជាពិសេសការកំណត់អត្តសញ្ញាណ និងការគ្រប់គ្រងហានិភ័យចំពោះបេតិកភណ្ឌសហគមន៍អរូបី ដែលទំនងជាមានសារសំខាន់ជាពិសេសនៅក្នុងសហគមន៍ជនជាតិដើមភាគតិច។

315. ទោះបីជាមានក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច ដែលមានស្រាប់តាំងពីការត្រៀមរៀបចំ គម្រោង LASED (២០០៧) បញ្ញត្តិរបស់វា មិនដែលត្រូវបានដំណើរការ ដោយហេតុថាពុំមានការផ្តល់សម្បទាន ដីសង្គមកិច្ច រហូតមកដល់បច្ចុប្បន្នត្រូវបានអនុវត្តនៅក្នុងតំបន់ដែលមានវត្តមាន របស់ជនជាតិភាគតិចយ៉ាងគួរ ឱ្យកត់សម្គាល់។ ការយល់ឃើញរបស់បុគ្គលិកគម្រោងអំពីអាទិភាព និងតម្រូវការរបស់សហគមន៍ជនជាតិដើម ភាគតិច ប្រហែលជាមិនត្រូវគ្នាទៅនឹងការពិតនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នោះទេ។ នេះគឺជាផ្នែកមួយដែលការ អភិវឌ្ឍសមត្ថភាពដែលបានរៀបចំយ៉ាងល្អនៅពេលចាប់ផ្តើមគម្រោង គឺជាគន្លឹះដើម្បីចៀសវាងបញ្ហាដែលអាច កើតមាននៅពេល ក្រោយ។

## ៧.២.២ យុទ្ធសាស្ត្របណ្តុះបណ្តាល និងវគ្គបណ្តុះបណ្តាលសំខាន់ៗ

316. ក្នុងករណីភាគច្រើនការបណ្តុះបណ្តាលដែលត្រូវការដើម្បីកសាងសមត្ថភាពក្នុងការអនុវត្តការគ្រប់គ្រង ហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នឹងតម្រូវឱ្យមានការបណ្តុះបណ្តាលម្តងទៀត ទាំងវគ្គបណ្តុះបណ្តាល សម្រាប់ក្រុមថ្មី ឬក្រុមបន្ថែមនៃសិក្ខាកាម ឬសម្រាប់គោលបំណងមួយចំនួននៅខាងក្រៅបរិបទនៃគម្រោង។ ដូច្នេះវានឹងមានតម្លៃក្នុងការវិនិយោគការអភិវឌ្ឍម៉ូឌុលបណ្តុះបណ្តាលដែលបានរចនាឡើងយ៉ាងល្អជាភាសាខ្មែរ ដោយមានខ្លឹមសារ សម្ភារចក្ខុ ឧទាហរណ៍ និងលំហាត់។ សម្ភារៈទាំងនេះអាចត្រូវបានបង្កើតឡើងដោយ បុគ្គលិកគម្រោង ឬដោយអ្នកឯកទេសខាងប្រធានបទដែលបានចុះកិច្ចសន្យា តាមចាំបាច់។ រាល់ឯកសារបណ្តុះ បណ្តាលស្តីពីការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នឹងត្រូវបានចែករំលែកជាសេចក្តីព្រាង សម្រាប់យោបល់ជាមួយអ្នកជំនាញធនាគារពិភពលោក។

317. សិក្ខាកាមគោលដៅ នឹងរួមបញ្ចូលបុគ្គលិកនៃភ្នាក់ងារអនុវត្តន៍គម្រោង LASED III ផ្សេងៗគ្នាតាមរដ្ឋ បាលខេត្ត ស្រុក និងឃុំ ដៃគូអង្គការមិនមែនរដ្ឋាភិបាល អ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់ និងសមាជិកសហគមន៍ ទទួលផលគម្រោង។ គេរំពឹងថាបុគ្គលិកគម្រោងទាំងអស់នឹងទទួលបានការ បណ្តុះបណ្តាលជាមូលដ្ឋាន នៅក្នុងគោលគំនិត និងក្របខណ្ឌសម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នៅក្នុងគម្រោង LASED II។ ទីប្រឹក្សាគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នឹងទទួលបានការបណ្តុះបណ្តាលទូលំ

ទូលាយបំផុត។ បន្ថែមពីលើការបណ្តុះបណ្តាលខ្លឹមសារ បុគ្គលិកផ្នែកគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នឹងទទួលបាន "ការបណ្តុះបណ្តាលសម្រាប់គ្រូបណ្តុះបណ្តាល" រួមទាំងវិធីសាស្រ្តបណ្តុះបណ្តាលក៏ដូចជាខ្លឹមសារ ដូច្នេះពួកគេអាចធ្វើការបណ្តុះបណ្តាលកម្រិតទាបនៅលើមូលដ្ឋានបន្ត។

318. មានការរំពឹងទុកថាបញ្ញត្តិសម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងនឹងលក្ខខណ្ឌការងារ និងពលកម្ម ស្របតាមបទដ្ឋានបរិស្ថាន និងសង្គមទី ២ គឺថ្មីចំពោះអ្នកម៉ៅការសំណង់ដែលកំពុងធ្វើការនៅគម្រោង LASED III។ ដូច្នេះបន្ថែមលើការដាក់ឱ្យអនុវត្តតាមបទដ្ឋានទាំងនេះជាលក្ខខណ្ឌនៃកិច្ចសន្យា វាត្រូវបានគេស្នើសុំថាការគ្រប់គ្រងការងាររបស់អ្នកម៉ៅការ និងបុគ្គលិកត្រួតពិនិត្យ នឹងត្រូវអនុវត្តវគ្គខ្លីស្តីពីច្បាប់ការងារ សិទ្ធិការងារ និងការអនុវត្តការងារប្រកបដោយសុវត្ថិភាព។

319. ម៉ូឌុលបណ្តុះបណ្តាលការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមដែលត្រូវបានបង្កើត និងផ្តល់ជូននៅដំណាក់កាលដំបូងនៃការអនុវត្តគម្រោង LASED III រួមមាន៖

(a) វគ្គបណ្តុះបណ្តាល / មេរៀនទូទៅសម្រាប់បុគ្គលិក និងដៃគូគម្រោងទាំងអស់លើការប្រើប្រាស់ឧបករណ៍គ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម នៅក្នុងគម្រោង LASED III

(b) វគ្គបណ្តុះបណ្តាលលម្អិតសម្រាប់ទីប្រឹក្សាគ្រប់គ្រងហានិភ័យ E&S និងជនបង្គោលដើម្បីអភិវឌ្ឍការយល់ដឹងឱ្យបានហ្មត់ចត់អំពីក្របខណ្ឌបរិស្ថាន និងសង្គម ការចូលរួមរបស់ភាគីពាក់ព័ន្ធសកម្មក្នុងការកំណត់អត្តសញ្ញាណហានិភ័យ គោលការណ៍សមាមាត្រ ការរៀបចំផែនការគ្រប់គ្រងហានិភ័យ ( EMP / SRMP, RAP ។ល។) និង ការពិនិត្យតាមដាន និងរាយការណ៍ហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គម។

(c) ការចូលរួមរបស់ភាគីពាក់ព័ន្ធ រួមទាំងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធជាមួយសហគមន៍ជនជាតិដើមភាគតិច

(d) ប្រតិបត្តិការនៃយន្តការដោះស្រាយបណ្តឹងតវ៉ា

(e) បញ្ញត្តិស្តីពីការគ្រប់គ្រងហានិភ័យ E&S នៅកម្រិតអនុគម្រោង រួមទាំងការធានាការអនុលោមតាម បទដ្ឋានបរិស្ថាន និងសង្គម ក្នុងការអនុវត្តគម្រោងហេដ្ឋារចនា សម្ព័ន្ធ និងមុខរបរចិញ្ចឹមជីវិត។

(f) វគ្គបណ្តុះបណ្តាលជាក់លាក់ស្តីពីការអនុលោមតាមលក្ខខណ្ឌការងារ និងពលកម្ម (ប្រហែលជារួមមានបទដ្ឋានបរិស្ថាន និងសង្គមផ្សេងទៀត ដូចជាសុខភាពនិងសុវត្ថិភាពសហគមន៍ ការគ្រប់គ្រងបរិស្ថាន ) សម្រាប់បុគ្គលិកមើលការខុសត្រូវនៃអ្នកម៉ៅការសំណង់។

(g) វគ្គបណ្តុះបណ្តាលស្តីពីការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងបរិស្ថាននៃទីតាំងសម្បទានដីសង្គមកិច្ច រួមមានការយុទ្ធសាស្រ្តអនាម័យ និងការបោះចោលសំរាម។

(h) វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងការចោលសារធាតុគីមីកសិកម្មដោយសុវត្ថិភាព និងសំណល់រឹងមិនអាចបំបែកបាន ដែលត្រូវបញ្ចូលទៅក្នុងវគ្គបណ្តុះ បណ្តាលកសិកម្ម

(i) ការរួមបញ្ចូលសុវត្ថិភាពចរាចរណ៍ក្នុងការរចនាប្លង់ផ្លូវជនបទ ដោយប្រើម៉ូឌុលវេងស្តីពីសុវត្ថិភាពចរាចរណ៍ដែលត្រូវប្រើសម្រាប់ការយល់ដឹងរបស់សហគមន៍ និងការបណ្តុះ បណ្តាលអំពីសុវត្ថិភាពចរាចរណ៍។

| តារាងទី ១៧៖ គ្រោងផែនការបណ្តុះបណ្តាល | | | |
|---|---|---|---|
| លេខ. | លទ្ធផលនៃការបណ្តុះបណ្តាល | សិក្ខាកាម | គ្រូបណ្តុះបណ្តាល / ធនធាន |
| 1 | បុគ្គលិកទីភ្នាក់ងារអនុវត្តន៍គម្រោងទាំងអស់ស្គាល់ច្បាស់ពីគោលការណ៍និងឧបករណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គមនៅក្នុងគម្រោង LASED III | បុគ្គលិករបស់ក្រុមហ៊ុន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់, ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ, រដ្ឋបាលខេត្ត / PLUAC, DWG, CC, ដៃគូអង្គការមិនមែនរដ្ឋាភិបាល | អ្នកឯកទេស ESS ជាមួយទីប្រឹក្សាគម្រោង |
| 2 | អ្នកប្រឹក្សាយោបល់ផ្នែកគ្រប់គ្រងហានិភ័យ E&S ជនបង្គោល និងបុគ្គលិកសំខាន់ៗដទៃទៀតអាចកំណត់អត្តសញ្ញាណហានិភ័យ E&S យ៉ាងសកម្មនិងបង្កើតវិធានការគ្រប់គ្រងហានិភ័យ ដឹកនាំឬណែនាំលើការអនុវត្តវិធានគ្រប់គ្រងហានិភ័យ E&S ផ្តល់ការបណ្តុះបណ្តាលលើ E&S និងធ្វើការពិនិត្យតាមដាន និងរាយការណ៍។ | ទីប្រឹក្សាគ្រប់គ្រងហានិភ័យ E&S ជនបង្គោលផ្នែកការពារសុវត្ថិភាពនៃភ្នាក់ងារអនុវត្តន៍ បុគ្គលិកដែលបានចាត់តាំងដោយដៃគូអង្គការក្រៅរដ្ឋាភិបាល។ល។ | អ្នកឯកទេស ESS ជាមួយទីប្រឹក្សាគម្រោង |
| 3 | បុគ្គលិកគម្រោងថ្នាក់ខេត្តយល់ពីឧបករណ៍និងវិធីសាស្ត្រសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធរួមទាំងការចូល រួមជាមួយសហគមន៍ IP | ទីប្រឹក្សាគ្រប់គ្រងហានិភ័យ E&S , ជនបង្គោល, ក្រុមការងារគម្រោងខេត្ត | អ្នកជំនាញការចូលរួមរបស់អ្នកពាក់ព័ន្ធជាមួយជំនាញ IP |
| 4 | យន្តការដោះស្រាយបណ្តឹងតវ៉ាបានបង្កើតឡើងនិងដំណើរការប្រកបដោយប្រសិទ្ធភាព និងតម្លាភាព | មន្ត្រីទទួលខុសត្រូវក្នុងការដោះស្រាយនិងឆ្លើយតបចំពោះបណ្តឹងតវ៉ានានា | អ្នកឯកទេស ESS |
| 5 | ESS ត្រូវបានដាក់បញ្ចូលក្នុងការរចនាប្លង់និងការអនុវត្តលើអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធនិងជីវភាព | អ្នកជំនាញហេដ្ឋារចនាសម្ព័ន្ធ បុគ្គលិកនៃមន្ទីរបច្ចេកទេសខេត្ត ។ល។ | អ្នកឯកទេស ESS |
| 6 | អ្នកម៉ៅការនិងអ្នកផ្គត់ផ្គង់ឱ្យគម្រោង LASED គឺស៊ាំនិងអាចបំពេញនូវតម្រូវការសម្រាប់លក្ខខណ្ឌការងារ និងពលកម្មរួមទាំងសិទ្ធិរបស់កម្មករនិងលទ្ធភាពទទួលបានយន្តការបណ្តឹងតវ៉ាស្របតាម ESS2។ | បុគ្គលិកត្រួតពិនិត្យរបស់អ្នកម៉ៅការនិងអ្នកផ្គត់ផ្គង់ដល់គម្រោង។ | កូនសៀវភៅពន្យល់ពីតម្រូវការ |
| 7 | ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងបរិស្ថាននិង អនាម័យនៅទីតាំង SLC តាមរយៈការយល់ដឹងទូលំទូលាយអំពីផែនការគ្រប់គ្រងបរិស្ថាន | PLUAC, DWG និងអ្នកដទៃទៀតចូលរួមក្នុងការរៀបចំ EMP / SRMP | ទីប្រឹក្សាគ្រប់គ្រងហានិភ័យ E&S ដើម្បីបណ្តុះបណ្តាលអ្នកម៉ៅការ |
| 8 | កសិករនៅទីតាំង LASED (រាប់បញ្ចូលទាំងអ្នកដែលត្រូវបានលើកទឹកចិត្តឱ្យទទួលយកផលិតកម្មសរីរាង្គ IPM ល។ ) មានការយល់ដឹងជាមូលដ្ឋានអំពីការប្រើប្រាស់ | សិក្ខាកាមកសិករក្នុងវគ្គបណ្តុះបណ្តាលស្តីពីមុខរបរចិញ្ចឹមជីវិត | ការបណ្តុះបណ្តាលដែលត្រូវអភិវឌ្ឍ និងផ្តល់ដោយក្រសួង |

| | | | |
|---|---|---|---|
| | ប្រកបដោយសុវត្ថិភាពនិងការចោលសារធាតុគីមីកសិកម្ម និងការចោលសំរាមដែលមិនប៉ះពាល់ដល់បរិស្ថាន។ | | កសិកម្មវក្ខាប្រមាញ់ និងនេសាទ |
| 9 | ផ្លូវដែលត្រូវបានរចនាឡើងក្រោម LASED III រួមបញ្ចូលនូវលក្ខណៈសុវត្ថិភាពផ្លូវថ្នល់ដែលបានធ្វើឱ្យប្រសើរឡើង ហើយការស្ថាបនាផ្លូវត្រូវបានអមដោយយុទ្ធនាការលើកកម្ពស់សុវត្ថិភាពចរាចរណ៍។ | បុគ្គលិកហេដ្ឋារចនាសម្ព័ន្ធសហគមន៍ក្នុងតំបន់។ | អ្នកឯកទេសសុវត្ថិភាពចរាចរណ៍ |

## ៧.៣ ថវិកាសម្រាប់ការអនុវត្តក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

320. ការចំណាយជាច្រើនក្នុងការអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យចំពោះបរិស្ថាន និងសង្គម (ESMF) សម្រាប់គម្រោង LASED III នឹងត្រូវបានបញ្ចូលជាចន្លេថវិកាគម្រោងឧទាហរណ៍សម្រាប់ការធ្វើផែនការសម្បទានដីសង្គមកិច្ច និងការផ្តល់កម្មសិទ្ធិដីសមូភាពដល់សហគមន៍ជនជាតិដើមភាគតិច និងសម្រាប់ការអនុវត្តអនុគម្រោង។ ដោយស្មើភាពគ្នា អត្ថប្រយោជន៍នៃក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម នឹងមិនលេចឡើងនៅក្នុងភាពជាច់តែឯងទេ ប៉ុន្តែនៅក្នុងលទ្ធផលដែលបានធ្វើឱ្យប្រសើរឡើង និងកាត់បន្ថយការកើតឡើង ឬភាពធ្ងន់ធ្ងរនៃផលប៉ះពាល់អវិជ្ជ មាន។

321. ការចំណាយដែលអាចកំណត់បានជាក់លាក់នៃការអនុវត្តក្របខណ្ឌស្តីពីការគ្រប់គ្រង ហានិភ័យចំពោះបរិស្ថាននិងសង្គម នឹងរួមមាន៖

(a) ប្រាក់បៀវត្ស និងប្រាក់ដែលមិនមែនជាប្រាក់បៀវត្សរបស់ទីប្រឹក្សា និងជនបង្គោលការពារសុវត្ថិភាព។
(b) ការចំណាយលើការបណ្តុះបណ្តាលទាក់ទងនឹងការគ្រប់គ្រងហានិភ័យ E&S
(c) ចំណាយនៃការរៀបចំទីតាំង EMP / SRMP, RAP, IPP និងឧបករណ៍គ្រប់គ្រងហានិភ័យ ផ្សេងៗទៀតតាមតម្រូវការ
(d) ថ្លៃដើមនៃការរៀបចំអនុគម្រោង EMSP, LMP, RAP ។ល។ តាមតម្រូវការ
(e) ការចំណាយនៃសវនកម្មបទដ្ឋានបរិស្ថាន និងសង្គមដែលត្រូវធ្វើមុនការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ។

322. ថវិកាសម្រាប់ការអនុវត្តក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម មិនរាប់បញ្ចូលចំណាយនៃការរៀបចំនិងអនុវត្តផែនការតាំងទីលំនៅថ្មី ក៏ដូចជាចំណាយទៅលើសំណងសម្រាប់ការតាំងទីលំនៅថ្មីដោយបង្ខំដែរ។ ការចំណាយទាំងនេះនឹងត្រូវបានផ្តល់ហិរញ្ញប្បទានដាច់ដោយឡែកពីគ្នាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចដែលបានបញ្ជាក់នៅក្នុង SOP-LAR (សូមមើល ក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី (RPF) សម្រាប់ព័ត៌មានលម្អិត)។

323. តារាងទី១៨ បង្ហាញពីសូចនាករថវិកាសម្រាប់ចំណាយទាំងនេះ

| តារាងទី១៨៖ចំណាយប៉ាន់ស្មានទៅការអនុវត្ត ESMF | | | |
|---|---|---|---|
| # | **សកម្មភាពក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាន និងសង្គម** | **ចំណាយប៉ាន់ស្មាន គិតជា USD** | **កំណត់សម្គាល់** |
| 1 | ចំណាយសម្រាប់ទីប្រឹក្សា និងជនបង្គោលគ្រប់គ្រងហានិភ័យ E&S | $៥០០,០០០ | ទីប្រឹក្សាជាតិ ៣ នាក់ |
| 2 | ចំណាយសម្រាប់ការរៀបចំម៉ូឌុលបណ្តុះបណ្តាល និងការ ផ្តល់ការបណ្តុះបណ្តាលការគ្រប់គ្រងហានិភ័យអំឡុងពេលចាប់ផ្តើមគម្រោង | $២០០,០០០ | ប្រមាណ ១០ ម៉ូឌុល, ប្រហែល ១០០ សិក្ខាកាម-ថ្ងៃ ក្នុងមួយម៉ូឌុល |
| 3 | ចំណាយសម្រាប់ការបណ្តុះបណ្តាលជំនាញ, កម្មវិធីសិក្ខាសាលា, ការបណ្តុះបណ្តាលអ្នកទទួលផលអំពីបញ្ហាគ្រប់គ្រងហានិភ័យ E&S ។ល។ | $១០០,០០០ | |
| 4 | ចំណាយសម្រាប់ការរៀបចំកម្រិតទីតាំង EMP/SRMP, RAP, IPP ។ល។ | $៥៧,០០០ | ទីតាំងថ្មីចំនួន ៥៧ |
| 5 | ចំណាយសម្រាប់ការរៀបចំអនុគម្រោង ESMP និងលិខិតុបករណ៍គ្រប់គ្រងហានិភ័យ E&S ផ្សេងទៀតតាមតម្រូវការ | $១១៤,០០០ | Est. ១០ s-p per site |
| 6 | ចំណាយសម្រាប់ការបណ្តុះបណ្តាលការគ្រប់គ្រងហានិភ័យ E&S Risk ទៅកាន់អ្នកទទួលផលពីគម្រោង | $៥៧,០០០ | |
| 7 | ចំណាយសម្រាប់សវនករ ESS | $៥០,០០០ | អ្នកពិគ្រោះយោបល់អន្តរជាតិ ២ នាក់ និងអ្នកពិគ្រោះយោបល់ជាតិ ២ នាក់ x ២៥ wd |
| | **ថវិកាប៉ាន់ស្មានសរុប** | **$១,០៧៨,០០០** | |

# ៨. យន្តការដោះស្រាយបណ្តឹងតវ៉ា

## ៨.១ យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)

324. យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) នៃគម្រោង LASED III (LASED III GRM) ត្រូវបានកំណត់និយមន័យ និងពិពណ៌នានៅក្នុងផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធនៃគម្រោង LASED III (SEP)។ យន្តការដោះស្រាយបណ្តឹងតវ៉ានៃគម្រោង LASED III នឹងអាចប្រើប្រាស់បានដោយបុគ្គលដែលទទួលផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធសម្រាប់បណ្តឹងតវ៉ា ទាក់ទិននឹងទិដ្ឋភាពនៃគម្រោង LASED III រួមមានបញ្ហាដែលគ្របដណ្តប់ដោយ ESS1-ESS10។ យ៉ាងណាក្តី គម្រោងនឹងបង្កើតនូវយន្តការដោះស្រាយបណ្តឹងតវ៉ាដាច់ដោយឡែកសម្រាប់បុគ្គលិកគម្រោង ដូចដែលតម្រូវដោយ បទដ្ឋានបរិស្ថាន និងសង្គមទី ២។

325. យន្តការដោះស្រាយបណ្តឹងតវ៉ាគម្រោង LASED III នឹងទទួល កត់ត្រា និងពិនិត្យបណ្តឹងតវ៉ាលើបញ្ហាទាំងឡាយណាដែលទាក់ទងនឹងគម្រោង និងផលប៉ះពាល់របស់វាប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ និងតម្លាភាព

ហើយនឹងផ្តល់នូវសំណងសមរម្យ។ យន្តការដោះស្រាយបណ្តឹងតវ៉ា នឹងរក្សាការសម្ងាត់ ហើយនឹងទទួលយកបណ្តឹងតវ៉ាដែលសុំមិនបញ្ចេញឈ្មោះ។ អ្នកពាក់ព័ន្ធទាំងអស់នឹងត្រូវបានជូនដំណឹងឱ្យបានពេញលេញអំពី យន្តការដោះស្រាយទំនាស់ រួមទាំងនីតិវិធីដាក់ និងដោះស្រាយ បណ្តឹងតវ៉ា និងពេលវេលាដែលត្រូវសេចក្តីសម្រេចនឹងត្រូវបានធ្វើឡើង។ យន្តការដោះស្រាយបណ្តឹងតវ៉ានៃគម្រោង LASED III នឹងត្រូវភ្ជាប់ទៅនឹងយន្តការបណ្តឹងតវ៉ាដែលមានស្រាប់ (ប្រព័ន្ធការិយាល័យប្រជាពលរដ្ឋ និងគណៈកម្មការសុរិយោដី)។ ការប្រើប្រាស់យន្តការដោះស្រាយបណ្តឹងតវ៉ានៃគម្រោង LASED III នឹងមិនប៉ះពាល់ដល់សិទ្ធិរបស់អ្នកប្តឹងតវ៉ាចំពោះការទទួលបានដំណោះស្រាយតាមប្រព័ន្ធតុលាការ ឬការដោះស្រាយផ្នែករដ្ឋបាលក្រៅប្រព័ន្ធតុលាការជំនួសទេ។

326. គោលការណ៍សំខាន់ៗនៃការតាក់តែងយន្តការដោះស្រាយបណ្តឹងតវ៉ា រួមមាន (១) ការបើកទូលាយ និងតម្លាភាព; (២) ភាពត្រឹមត្រូវយុត្តិធម៌; (៣) លទ្ធភាពចូលប្រើប្រាស់បាន; (៤) ការឆ្លើយតប និងប្រសិទ្ធភាព; និង (៥) អនាមិកភាព និងការសម្ងាត់។

327. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងនាមជា EA នឹងមានទំនួលខុសត្រូវរួមសម្រាប់យន្តការដោះស្រាយបណ្តឹងតវ៉ានៃគម្រោង LASED III។ នេះនឹងរួមបញ្ចូល (១) ការរក្សាបញ្ជីរួមនៃការដាក់ពាក្យបណ្តឹងតវ៉ា និងលទ្ធផល (២) កសាងសមត្ថភាព និងផ្តល់ការគាំទ្រ និងដំបូន្មានដល់ភ្នាក់ងារ និងដៃគូអនុវត្តន៍ទាំងអស់ និង (៣) អន្តរាគមន៍ដោយផ្ទាល់ដើម្បីគាំទ្រដំណោះស្រាយនៃ បណ្តឹងតវ៉ាក្នុងករណីចាំបាច់។

328. គម្រោងនឹងបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា (GRM) នៅថ្នាក់ជាតិដោយមានប្រធានគម្រោងជាអ្នកដឹកនាំ និងរួមបញ្ចូលជនបង្គោល GRM ពីទីភ្នាក់ងារអនុវត្តន៍ថ្នាក់ជាតិនីមួយៗ។ GRM នឹងរួមបញ្ចូលសមាជិកភាពមិនមែនរដ្ឋាភិបាល។ គម្រោងនេះនឹងបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ានៅថ្នាក់ខេត្ត (PGRC) នៅក្នុងខេត្តនីមួយៗដែលមាន SLC ឬ ICLT។ PGRC នឹងត្រូវដឹកនាំដោយប្រធានក្រុមគម្រោងថ្នាក់ខេត្ត និងរួមបញ្ចូលតំណាងនៃទីភ្នាក់ងារនីមួយៗដែលមានទំនួលខុសត្រូវក្នុងការអនុវត្តក៏ដូចជាសមាជិកនៃអង្គភាពអធិការកិច្ចបណ្តឹងតវ៉ារដ្ឋបាលខេត្ត (Provincial Administration Complaints Inspection Unit)។ គណៈកម្មាធិការអ្នកទទួលដីធ្លី SLC (SLC Land Recipients Committee) និងគណៈកម្មាធិការគ្រប់គ្រងដែនដី ICLT (ICLT Land Management Committee) មួយៗនឹងជ្រើសរើសតំណាងម្នាក់ដែលនឹងទទួលការបណ្តុះបណ្តាលក្នុងប្រតិបត្តិការរបស់ GRM ហើយនិងចូលរួមជាសមាជិកនៃ PGRC នៅពេលដែលបណ្តឹងតវ៉ាទាក់ទងនឹង SLC ឬ ICLT ដែលពួកគេតំណាងត្រូវបានពិចារណា។




*រូបភាព 1៖ទំនួលខុសត្រូវជាលក្ខណៈស្ថាប័ន LASED III GRM*

329. ភាគីពាក់ព័ន្ធអាចដាក់ពាក្យបណ្ដឹងតវ៉ាតាមវិធីសមស្របណាមួយ។ ដើមបណ្ដឹងអាចស្នើសុំអនាមិកភាពដែលឈ្មោះរបស់ពួកគេនឹងមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ការសម្ងាត់នឹងត្រូវបានត្រួតពិនិត្យផងដែរក្នុងអំឡុងពេលដែល GRM កំពុងពិចារណាលើករណីមួយ។

330. បុគ្គលិកគម្រោងនឹងត្រូវបានបណ្ដុះបណ្ដាលនៅលើសកម្មភាពមួយចំនួន ដូចជាថាតើពួកគេបានទទួលព័ត៌មានអំពីបណ្ដឹងតវ៉ា រួមមាន ១) របៀបពន្យល់អំពីសិទ្ធរបស់ភាគីពាក់ព័ន្ធដែលដាក់ពាក្យបណ្ដឹង ដំណើរការនៃពាក្យបណ្ដឹង និងជម្រើសនៃការរក្សាអនាមិកភាព និង (២) កត់ត្រាបណ្ដឹងតវ៉ានៅលើទម្រង់ស្តង់ដា (ឧបសម្ព័ន្ធ ៩); និង (៣) បញ្ជូនបណ្ដឹងតវ៉ាដែលបញ្ចប់រួចរាល់ជាមួយនឹងពាក្យបណ្ដឹងជាលាយល័ក្ខអក្សរ នឹងឯកសារជាភស្តុតាងទៅកាន់លេខាធិការនៃ PGRC។.

331. នៅពេលត្រូវបានជូនដំណឹងអំពីបណ្ដឹងតវ៉ាលេខាធិការនៃ PGRC នឹង (១) បញ្ចូលព័ត៌មានលម្អិតនៅក្នុងបញ្ជីពាក្យបណ្ដឹងដែលត្រូវបានដាក់រួមបញ្ចូលគ្នានៅថ្នាក់ជាតិ (២) ចម្លងការចុះឈ្មោះដែលបានធ្វើបច្ចុប្បន្នភាពទៅប្រធានក្រុមគម្រោងថ្នាក់ខេត្ត (៣) ជាមួយបុគ្គលិកដែលបានទទួលការបណ្ដុះបណ្ដាលមួយផ្សេងទៀតពិនិត្យពាក្យបណ្ដឹងដើម្បីកំណត់ថាតើវាពាក់ព័ន្ធនឹង LASED និងពាក់ព័ន្ធបញ្ហានៃខ្លឹមសារដែលអាចត្រូវបានស៊ើបអង្កេត ឬយ៉ាងណា និង (៤) ជូនដំណឹងដល់អ្នកប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទទួលស្គាល់ពាក្យបណ្ដឹងដោយបញ្ជាក់ថាតើនឹងមានសកម្មភាពតាមដានអ្វីខ្លះដែលនឹងត្រូវបានធ្វើឡើង និងបញ្ជាក់ពីសិទ្ធិរបស់ដើមបណ្ដឹង។

332. ប្រធាន PGRC នឹងចាត់តាំងបុគ្គលិកគម្រោងចំនួន ២ នាក់ដែលបានទទួលការបណ្តុះ បណ្តាលត្រឹមត្រូវ ដើម្បីស៊ើបអង្កេតអំពីបណ្តឹងតវ៉ានេះរួមមានបទសម្ភាសន៍ជាមួយដើមបណ្តឹង និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីពិនិត្យមើលឯកសារ និងការធ្វើអធិការកិច្ចទៅលើភស្តុតាងជាក់ស្តែង។ នៅពេលដែលមានការស្នើសុំភាពអនាមិករបស់អ្នកប្តឹងនឹងត្រូវបានផ្តល់អាទិភាព។ ក្រុមស៊ើបអង្កេតធ្វើការរាយការណ៍ទៅកាន់PGRC។

333. PGRC អាចសម្រេចចិត្ត (១) ថាមិនចាំបាច់មានសកម្មភាពអ្វីឡើយ (២) ចាត់វិធានការសមស្របដើម្បីដោះស្រាយបណ្តឹងតវ៉ា ឬ (៣) ដើម្បីបញ្ជូនបណ្តឹងតវ៉ាពី PGRC ទៅ GRC ថ្នាក់ជាតិ។ ដើម បណ្តឹងនឹងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់ PGRC។



*រូបភាពទី 2៖ដ្យាក្រាមនៃដំណើរ LASED III GRM*

334. ជនជាតិដើមភាគតិចនឹងត្រូវបានផ្តល់ជំនួយបន្ថែមដើម្បីធានាថាពួកគេមានសិទ្ធិស្មើគ្នាក្នុងការទទួលបាន GRM។ គម្រោងនេះនឹងគាំទ្រ និងបង់ថ្លៃចំណាយរបស់អ្នកសម្របសម្រួលដែលត្រូវបានជ្រើសរើសដោយជនជាតិដើមភាគតិច និងអ្នកដែលអាចយល់ភាសាជនជាតិដើមភាគតិច ឬគ្រាមភាសា ដើម្បីធ្វើជាអ្នកតស៊ូមតិសម្រាប់ដើមបណ្តឹង។ បណ្តឹងតវ៉ាទាក់ទងនឹងបញ្ហាផ្ទៃក្នុងជនជាតិដើមភាគតិចនឹងត្រូវបានដោះស្រាយនៅក្នុងសហគមន៍ជនជាតិដើមភាគតិច បន្ទាប់ពីដំណើរការដោះស្រាយវិវាទដែលអាចទទួលយកបានតាមផ្នែកវប្បធម៌ត្រូវបានធ្វើឡើង។

335. សវនកម្មនៃយន្តការដោះស្រាយបណ្តឹងតវ៉ានឹងជាផ្នែកមួយនៃសវនកម្ម ESS ដែលនឹងត្រូវធ្វើឡើងមុនការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ។

336. អ្នកពាក់ព័ន្ធគម្រោង និងភាគីដែលរងផលប៉ះពាល់នឹងទទួលបាននូវយន្តការបណ្តឹងតវ៉ាដែលមានស្រាប់បន្ថែមលើគម្រោង GRM។ ទាំងនេះត្រូវបានពិពណ៌នានៅក្នុង ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ ហើយរួមមានៈ

(a) ប្រព័ន្ធការិយាល័យប្រជាពលរដ្ឋសម្រាប់បណ្តឹងតវ៉ាទាក់ទងនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។

(b) យន្តការដោះស្រាយបណ្តឹងតវ៉ារបស់គណៈកម្មាធិការដោះស្រាយជំរកលំនៅដ្ឋានអន្តរក្រសួង (Inter-Ministerial Resettlement Committee) ដែលបង្កើតជាគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត ក្នុងករណីដែល NEF-GDR គិតថាបញ្ហានេះចាំបាច់ និង

(c) តុលាការ។

337. បទពិសោធន៍ដែលទទួលបានពីគម្រោង LASED II បង្ហាញពីតម្រូវការសម្រាប់ការបង្កើនសមត្ថភាពក្នុងការដោះស្រាយបណ្តឹងតវ៉ា ដែលអាចត្រូវបានបង្កើតឡើងក្នុងចំនួនដ៏ច្រើនឆ្លើយតបទៅនឹងដំណើរការរៀបចំ SLC និង ICLT។ នេះនឹងជាការពិចារណាដ៏សំខាន់ក្នុងការកសាងសមត្ថភាពសម្រាប់ការអនុវត្ត ESMF និង SEP (សូមមើលខាងក្រោម)។

## ៨.២ សេវាកម្មដោះស្រាយបណ្តឹងតវ៉ារបស់ធនាគារពិភពលោក

338. សហគមន៍ និងបុគ្គលដែលជឿជាក់ថាពួកគេរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីគម្រោងដែល គាំទ្រដោយធនាគារពិភពលោក (WB) អាចដាក់ពាក្យបណ្តឹងទៅកាន់យន្តការដោះស្រាយបណ្តឹងតវ៉ានៅកម្រិតគម្រោងដែលមានស្រាប់ ឬសេវាកម្មដោះស្រាយបណ្តឹងតវ៉ារបស់ធនាគារពិភពលោក។ សេវាកម្មដោះស្រាយបណ្តឹងតវ៉ាធានាថាពាក្យបណ្តឹងដែលទទួលបានត្រូវបានពិនិត្យឡើងវិញយ៉ាងឆាប់រហ័សដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងគម្រោង។ សហគមន៍ និងបុគ្គលដែលរងផលប៉ះពាល់ពីគម្រោង អាចបញ្ជូនពាក្យបណ្តឹងរបស់ពួកគេទៅក្រុមអធិការកិច្ចឯករាជ្យរបស់ធនាគារពិភពលោកដែលកំណត់ថា តើគ្រោះថ្នាក់បានកើតឡើង ឬអាចកើតឡើងដោយសារធនាគារពិភពលោកពុំបានគោរពតាមគោលការណ៍និងនីតិវិធីរបស់ខ្លួន។ ពាក្យបណ្តឹងអាចត្រូវបានដាក់នៅពេលណាមួយ បន្ទាប់ពីការព្រួយបារម្ភត្រូវបានបញ្ជូនដោយផ្ទាល់ទៅកាន់ធនាគារពិភពលោក ហើយគណៈគ្រប់គ្រងធនាគារត្រូវបានផ្តល់ឱកាសដើម្បីឆ្លើយតប។ សម្រាប់ព័ត៌មានស្តីពីរបៀបដាក់ពាក្យបណ្តឹងទៅសេវាកម្មដោះស្រាយបណ្តឹងតវ៉ាសាជីវកម្មរបស់ធនាគារពិភពលោកសូមមើលគេហទំព័រ http://www.worldbank.org/en/projects-operations/products-and-services/grievance-redress-service។ សម្រាប់ព័ត៌មានអំពីរបៀបដាក់បណ្តឹងតវ៉ាទៅកាន់ក្រុមអធិការកិច្ចធនាគារពិភពលោកសូមមើលគេហទំព័រ www.inspectionpanel.org។

# ៩. ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន ក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យ ចំពោះបរិស្ថាននិងសង្គម

## ៩.១ ការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធលើក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម និងឧបករណ៍ដែលពាក់ព័ន្ធ

339. ការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធលើ ESMF និងឧបសម្ព័ន្ធរបស់ខ្លួន និងលើផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ នឹងត្រូវបានអនុវត្តស្របគ្នានឹងការវាយ – បន្ទាប់ពីឯកសារត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រ www.mlmupc.gov.kh ជាមួយនឹងកាលបរិច្ឆេទដែលបានគ្រោងទុកសម្រាប់ការផ្សព្វផ្សាយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០។ ដោយមើលឃើញពីវិធានការរបស់រដ្ឋាភិបាលដើម្បីចៀសវាងការរីករាលដាលនៃជំងឺកូវីដ-១៩ ការពិគ្រោះយោបល់ទល់មុខគ្នានឹងមិនអាចធ្វើទៅបានទេ ដូច្នេះការពិគ្រោះយោបល់តាមអនឡាញនឹងត្រូវបានប្រើនៅពេលសមស្រប។ ដូចដែលបានព្រមព្រៀងជាមួយធនាគារពិភពលោក ដំណើរការពិគ្រោះយោបល់នឹងអនុវត្តតាមវិធីសាស្រ្តចំនួន ៣ យ៉ាងរួមមានតាមអនឡាញ ការហៅទូរស័ព្ទ / អ៊ីមែល និងការិយាល័យឃុំ។

340. ការពិគ្រោះយោបល់តាមអ៊ីនធឺណិត៖ ទីភ្នាក់ងារអនុវត្តន៍ (IAs) រួមមាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានប្រកាសឯកសារទាំងនោះតាមប្រព័ន្ធអ៊ីនធឺណិតនៅលើគេហទំព័ររបស់ខ្លួន និងប្រភពអ៊ីនធឺណិតផ្សេងទៀត (ដូចជាគេហទំព័រហ្វេសប៊ុក) ដែលផ្តល់នូវតំណភ្ជាប់ទៅឯកសារនានា។ នេះរួមបញ្ចូលទាំងការបកប្រែជាភាសាខ្មែរនៃសេចក្តីសង្ខេបរបស់ឯកសារ យន្តការដោះស្រាយបណ្តឹងតវ៉ា និងតារាង ទី១១ ស្តីពី ESMFs (សង្ខេបហានិភ័យ / ផលប៉ះពាល់ និងវិធានការកាត់បន្ថយជាអប្បបរមា)។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផលិតវីដេអូខ្លីពី ៥-១០ នាទី ដែលពន្យល់អំពីគម្រោង ផលប៉ះពាល់ វិធានការកាត់បន្ថយផលប៉ះពាល់ជាអប្បបរមា យន្តការដោះស្រាយបណ្តឹងតវ៉ា ដែលឯកសារទាំងនោះអាចរកបានតាមប្រព័ន្ធអ៊ីនធឺណិត និងវិធីចែករំលែកក្តីកង្វល់ / យោបល់ / សំណួរ។

341. ការពិគ្រោះយោបល់តាមទូរស័ព្ទ៖ ទីភ្នាក់ងារអនុវត្តន៍ជ្រើសរើសបុគ្គលិក SEO ដើម្បីបង្កើតបញ្ជីអ្នកចូលរួម / ប្រជាជនដែលរងផលប៉ះពាល់ពីតំបន់គម្រោង និងលេខទូរស័ព្ទរបស់ពួកគេដោយធានាថាមានអ្នកតំណាងជាស្រ្តីនៅក្នុងបញ្ជី។

342. អំឡុងពេលនៃការហៅទូរស័ព្ទ ក្រុមការងារ SEO អាចធ្វើការសង្ខេបដល់មនុស្សម្នាក់ៗ (អ្នកចូលរួម) អំពីគម្រោងផលប៉ះពាល់ និងហានិភ័យ ក៏ដូចជាវិធានការកាត់បន្ថយផលប៉ះពាល់ ការដោះស្រាយសំណងបណ្តឹង និងព័ត៌មានទំនាក់ទំនង និងសុំយោបល់ពីពួកគេ។ ពួកគេក៏អាចផ្ញើសារតាម រយៈអ៊ីមែល បន្ទាប់ពីការហៅទូរស័ព្ទ ជាមួយគេហទំព័រហ្វេសប៊ុក និងយូធូប (ប្រសិនបើមាន) និងតំណភ្ជាប់នៃឯកសារ។ អ្នកចូលរួមក៏អាចត្រូវបានស្នើសុំឱ្យបញ្ជូនព័ត៌មានទៅអ្នកជិតខាងរបស់ពួកគេផងដែរ។

343. ការពិគ្រោះយោបល់នៅសាលាឃុំ៖ ឯកសារដែលបានបកប្រែទាំងអស់រួមទាំង យន្តការដោះស្រាយបណ្តឹងតវ៉ា និងតារាងទៅ ១១ នៃក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម (សង្ខេបអំពីហា

និភ័យ / ផលប៉ះពាល់ និងវិធានការកាត់បន្ថយផលប៉ះពាល់ជាអប្បបរមា ) អាចរកបាននៅការិយាល័យឃុំ។ បណ្ណប្រកាសដែលអនុញ្ញាតឱ្យមនុស្សដឹងពីឯកសារក៏អាចត្រូវបានបិទផ្សាយនៅក្នុងទីតាំងដែលអាចមើលឃើញ ដូចជានៅខាងក្រៅសាលារៀន វត្ត និងផ្សារជាដើម។

344. ការចងក្រងឯកសារ និងការផ្តល់យោបល់នឹងមានដូចខាងក្រោម៖

( ក ) នៅក្នុងការហៅទូរស័ព្ទ និងហ្វេសប៊ុក / គេហទំព័រ ទីភ្នាក់ងារអនុវត្តន៍បង្កើតកាលកំណត់ពេលវេលាច្បាស់លាស់ដើម្បីទទួលបានមតិឆ្លើយតបនៃសេចក្តីព្រាងឯកសារ។

( ខ ) នៅពេលមតិយោបល់ / សំណួរត្រូវបានផ្សព្វផ្សាយ សម្រាប់ព័ត៌មានទាំងនេះត្រូវបានបញ្ចូលនៅលើគេហទំព័រហ្វេសប៊ុក ដូច្នេះមនុស្សផ្សេងទៀតក៏អាចមើលឃើញផងដែរ ( ចាប់តាំងពីពេលពិគ្រោះយោបល់ប្រជាជនបានស្តាប់ឮមនុស្សផ្សេងទៀតជាសំណួរ )។

( គ ) ផ្អែកលើមតិយោបល់ រៀបចំរបាយការណ៍ពិគ្រោះយោបល់ ដោយកត់សម្គាល់វិធីសាស្ត្រដែលបានប្រើ និងមតិយោបល់ / សំណួរដែលទទួលបាន។

## ៩.២ ការផ្សព្វផ្សាយជាសាធារណៈ

345. ដោយអនុលោមតាមគោលការណ៍របស់ធនាគារពិភពលោក និងលក្ខខណ្ឌតម្រូវរបស់បទដ្ឋានបរិស្ថាន និងសង្គមទី ១០ បញ្ញត្តិដូចខាងក្រោមត្រូវបានបង្កើតឡើងសម្រាប់បង្ហាញជាសាធារណៈនូវក្របខណ្ឌស្តីពីការគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គមចុងក្រោយ និងឧបករណ៍គ្រប់គ្រងហានិភ័យ E&S។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១៖ សេចក្ដីសង្ខេបនៃប្រភេទអនុគម្រោង ដែលមានសិទ្ធិទទួល បាន និងមិនមានសិទ្ធិទទួល បាននៃ គម្រោង LASED III

### 1. បញ្ជីវិជ្ជមានពី សៀវភៅណែនាំស្ដីពីការអនុវត្តគម្រោង

ហេដ្ឋារចនាសម្ព័ន្ធ

(a) ផ្លូវជនបទ និងផ្លូវធ្វើដំណើរចូល

(b) ការផ្គត់ផ្គង់ទឹកជនបទ

(c) ប្រព័ន្ធធារាសាស្ត្រទំហំតូច

(d) អគារសាលារៀន និងផ្ទះគ្រូ

(e) ប៉ុស្តិ៍សុខាភិបាល

(f) មជ្ឈមណ្ឌលសហគមន៍

(g) ការបង្កើត និងដំណើរការគណៈកម្មការ និងសកម្មភាព O&M។

### 2. ការគាំទ្រការអភិវឌ្ឍសហគមន៍

(a) ជ្រើសតាំង និងបណ្ដុះបណ្ដាលក្រុមសហគមន៍ និងមេដឹកនាំ

(b) បង្កើត និងដំណើរការក្រុមដែលមានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ( economic interest groups )

(c) បង្កើត និងដំណើរការក្រុមតំហែទាំងហេដ្ឋារចនាសម្ព័ន្ធ

(d) បង្កើត និងដំណើរការក្រុមមូលនិធិវិលជុំ (រួមមាន មូលនិធិបង្វិលប្រាក់សន្សំ និងឥណទាន [SCGs] និងក្រុមមូលនិធិវិលជុំនៃគ្រួសារដែលរងផលប៉ះពាល់ខ្លាំងជាងគេ [MVHGs])

(e) បង្កើត និងដំណើរការក្រុមប្រកបរបរចិញ្ចឹមជីវិត ( livelihood groups )

(f) បង្កើត និងដំណើរការក្រុមផលិតកម្ម និងទីផ្សារកសិកម្ម

(g) បង្កើត និងដំណើរការសហករណ៍កសិកម្ម ( AC )។

សាលាស្រែកសិករ, សាលាពាណិជ្ជកម្មកសិករ ជាដើម

### 3. បញ្ជីផលប៉ះពាល់អវិជ្ជមានសន្និដ្ឋាន

- ផ្លូវជំជាតិ និងតាមខេត្ត
- ទំនប់វារីអគ្គិសនីដែលធំ និងមានហានិភ័យខ្ពស់ ( ដូចបានបញ្ជាក់នៅក្នុង បទដ្ឋានបរិស្ថាន និងសង្គមទី ៣ ឧបសម្ព័ន្ធ ១ )
- អគារសាសនា និងសន្តិសុខ
- បច្ចេកទេសកសិកម្មដែលតម្រូវឱ្យមានការប្រើប្រាស់យ៉ាងខ្លាំងនៃសារធាតុគីមីដែលមានគ្រោះថ្នាក់
- ការចំណាយណាមួយដែលមានគោលបំណងផ្នែកយោធា ឬយោធាប្រតិព័ន្ធ
- ការងារស៊ីវិលសម្រាប់រដ្ឋបាលរដ្ឋាភិបាល ឬគោលបំណងសាសនា
- ផលិត ឬប្រើប្រាស់ទំនិញគ្រោះថ្នាក់ផ្នែកបរិស្ថាន អាវុធ ឬគ្រឿងញៀន

- ផលិតកម្ម ឬការប្រើប្រាស់ឌីណាមិក
- ការផ្តល់ហិរញ្ញប្បទានដល់ប្រាក់ខែរបស់រដ្ឋាភិបាល
- ផលិតកម្ម កែចម្លង កាន់កាប់ រក្សាទុក ឬលក់ថ្នាំជក់ ឬផលិតផលដែលមានផ្ទុកថ្នាំជក់ និងគេសជ្ជៈ
- សកម្មភាពក្នុងតំបន់អភិរក្សធម្មជាតិឬតំបន់ផ្សេងទៀតដែលត្រូវបានកំណត់សម្រាប់ការអភិរក្សជីវចម្រុះ លើកលែងតែមានការលើកលែងជាមុន
- ការជីកយករ៉ែ ឬជីករ៉ែថ្មផ្កាថ្ម
- ការអភិវឌ្ឍធនធានធនធានទឹកតាមដងទន្លេដែលហូរចូលប្រទេសមួយផ្សេងទៀត
- ការប្រែប្រួលដល់ការហូរទឹកទន្លេចូលសមុទ្រ
- ការផ្តល់ជូនការងារ ឬសេវាកម្មទំនិញដោយអ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ដែលត្រូវបានប្រកាសថាមិនមានសិទ្ធិគ្រប់គ្រាន់ដោយធនាគារពិភពលោក។

# ឧបសម្ព័ន្ធ ២៖ បទពិសោធន៍ការគ្រប់គ្រងហានិភ័យទាក់ទងបរិស្ថាន និងសង្គម នៅក្នុងគម្រោង LASED II

## 1. ក្របខណ្ឌសម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងបរិស្ថាន និងសង្គម

1. ក្របខណ្ឌសម្រាប់ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមនៅក្នុងគម្រោង LASED ត្រូវបានកំណត់ដោយឯកសារដូចខាងក្រោម៖
   - (a) សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង LASED (កំណែបច្ចុប្បន្នចុះកាលបរិច្ឆេទនៅខែមករា ឆ្នាំ២០១៧);
   - (b) ក្របខណ្ឌគោលនយោបាយការតាំងទីលំនៅថ្មី (ចុះកាលបរិច្ឆេទនៅខែមេសា ឆ្នាំ ២០១៦ និងរួមបញ្ចូលនូវឧបសម្ព័ន្ធ ៦ នៅក្នុង សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង);
   - (c) ការវាយតម្លៃបរិស្ថាន និងផែការគ្រប់គ្រងបរិស្ថាន (EA-EMP), ចុះកាលបរិច្ឆេទនៅខែធ្នូ ឆ្នាំ ២០០៧; ឯកសារនេះដាក់ចូលជាឧបសម្ព័ន្ធ ៧ក នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង បច្ចុប្បន្ន);
   - (d) ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ចុះចុះកាលបរិច្ឆេទនៅខែធ្នូ ឆ្នាំ២០០៧;
   - (e) ក្របខណ្ឌផែនការជនជាតិដើម ចុះចុះកាលបរិច្ឆេទនៅខែធ្នូ ឆ្នាំ២០០៧;
   - (f) ក្របខណ្ឌនៃការចូលរួមរបស់ពលរដ្ឋ ចុះកាលបរិច្ឆេទនៅខែវិច្ឆិកា ឆ្នាំ២០០៧;
   - (g) ទម្រង់សម្រាប់ការការពារសុវត្ថិភាពសង្គម (ទម្រង់ PIM ៤) និងការការពារបរិស្ថាន (ទម្រង់ PIM ៥)។

2. ការគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមនៅក្នុងគម្រោង LASED II អាចកើតមានទាំងនៅកម្រិតទីតាំង (ឧទាហរណ៍ទាក់ទងនឹងការកំណត់អត្តសញ្ញាណ ការស្ទង់មតិការធ្វើផែនការការប្រើប្រាស់ដីធ្លី ការបែងចែកដីធ្លី និងការចេញបណ្ណកម្មសិទ្ធិ ។ល។ នៅតំបន់សម្បទានដី សង្គមកិច្ច (នៅក្នុងគម្រោង LASED III, និងនៅក្នុង ICLT); កម្រិតអនុគម្រោង ដែលផលប៉ះពាល់ផ្នែកបរិស្ថាននិង / ឬសង្គមអាចកើតឡើងដោយសារការរចនាប្លង់ និងការអនុវត្តអនុគម្រោងគាំទ្រហេដ្ឋារចនាសម្ព័ន្ធ ឬមុខរបរចិញ្ចឹមជីវិត។

3. ការកំណត់ទីតាំង និងនីតិវិធីរៀបចំផែនការប្រើប្រាស់ដីដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង LASED រួមមានបញ្ញត្តិជាក់លាក់ដូចខាងក្រោមដើម្បីកំណត់និងគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាននិងសង្គម:
   - (a) ជំហានទី ១.៣៖ កិច្ចប្រជុំថ្នាក់ខេត្តដើម្បីពិនិត្យសំណើរបស់ SLC រួមបញ្ចូលទាំងតំណាងសហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់ SLC ប្រសិនបើមាន។ ផែនទី "ហតស្ពត" តាមខេត្តត្រូវបានបង្ហាញ ដែលគូសបញ្ជាក់អំពីសក្តានុពលនៃតំបន់ SLC តំបន់ជុំវិញ តំបន់ខ្សែទឹកខាងលើ និងខាងក្រោម និងការដាក់បញ្ចូលសម្រាប់ការការពារសុវត្ថិភាពសង្គម ច្បាប់ និងបរិស្ថាន។

(b) នៅជំហានទី ១.៣ វាត្រូវតែបានបញ្ជាក់ថា SLC មិនត្រូវបានប្រើដើម្បីតាំងទីលំនៅប្រជាជនឱ្យនៅឆ្ងាយពីសម្បទានដីសេដ្ឋកិច្ច (ELC) ឡើយ។

(c) ជំហានទី ១.៤៖ ការចុះទៅឃុំដើម្បីពិនិត្យបឋមនៃសំណើ SLC រួមមានការរៀបចំទម្រង់ ៤៖ ការពិនិត្យបឋមការការពារសុវត្ថិភាពសង្គម; និងទម្រង់ទី ៥៖ ការពិនិត្យបឋមនៃការការពារបរិស្ថាន។

(d) ដើម្បីចៀសវាងការលើកទឹកចិត្តដល់ការទន្ទ្រានយកដីសម្បទានសង្គមលើសពីការដោះស្រាយក្រៅផ្លូវការដែលអាចកើតមានរួចហើយ កាលបរិច្ឆេទបញ្ចប់សម្រាប់គោលបំណងនៃការកាន់កាប់មុន ត្រូវបានកំណត់ជាពីរខែមុនពេលកិច្ចប្រជុំជាសាធារណៈលើកដំបូងស្តីពីផែនការសម្បទានដីសេដ្ឋកិច្ច។ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវផ្តល់កំណត់ហេតុអំពីការកាន់កាប់មុនកាលបរិច្ឆេទនោះ។

(e) នៅជំហានទី ៣ ព័ត៌មានសាធារណៈស្តីពីផែនការ SLC ត្រូវបានផ្សព្វផ្សាយជាប្រព័ន្ធសម្រាប់ជាព័ត៌មានរបស់អ្នកដែលនឹងទទួលដី និងអ្នកប្រើប្រាស់ដីដែលមានស្រាប់។

(f) របាយការណ៍វិភាគយេនឌ័រត្រូវបានរៀបចំនៅជំហានទី ៣ និង

(g) សំណុំលក្ខណៈវិនិច្ឆ័យដែលមានតម្លាភាព និងសមភាព ត្រូវបានកំណត់និងប្រកាស។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសត្រូវមានអព្យាក្រឹតភាពផ្នែកយេនឌ័រហើយមិនត្រូវលម្អៀងទៅនឹងក្រុមសង្គមណាមួយឡើយ។ ប្រជាជនងាយរងគ្រោះនិងផ្លាស់ទីលំនៅ និងជនជាតិដើមអាចទទួលបានការអនុគ្រោះ។

(h) ជំហានទី ៤៖ ការកំណត់ដីរដ្ឋ ការធ្វើផែនទី ការធ្វើចំណាត់ថ្នាក់ និងការចុះឈ្មោះរួមមាន ការស្ទង់មតិ និងការគូសផែនទីលម្អិតនៃតំបន់សម្បទានដីសង្គមកិច្ច (២) ព្រៃឈើបម្រុងទុក ឬដីការពារបរិស្ថាន (៣) តំបន់បុរាណវិទ្យា និងវប្បធម៌សំខាន់ៗ; និង (៤) កន្លែងដែលមានសារសំខាន់សម្រាប់សហគមន៍ជនជាតិដើមក្នុងតំបន់។ ផែនទីបង្ហាញប្រភេទរូបភាព និងតារាងនៃដីកាន់កាប់រៀងៗខ្លួនរបស់បុគ្គលត្រូវបង្ហាញក្នុងរយៈពេល ៣០ ថ្ងៃ។

(i) ជំហានទី ៥៖ ការប្រើប្រាស់ដីធ្លី និងការធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធដែលមានការចូលរួម រួមមានការពិចារណាបន្ថែមទៀតអំពីការការពារបរិស្ថាន និងការកែលម្អការពិនិត្យបឋមនៃបរិស្ថាន។ ផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រោង ក៏ត្រូវបានរៀបចំនៅជំហាននេះដោយមានកិច្ចសហការពីក្រុមប្រឹក្សាឃុំ។

(j) បន្ទាប់ពីការរៀបចំការវិភាគកសិ-ប្រព័ន្ធអេកូឡូស៊ី (Agro-Ecosystem Analysis - AEA), ការវាយតម្លៃសមត្ថភាពអនុវត្តន៍ និងការវាយតម្លៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធ, DWG រួមគ្នាជាមួយក្រុមប្រឹក្សាឃុំពិនិត្យនិងកែសម្រួលទម្រង់ពិនិត្យឡើងវិញ (ទម្រង់ ៤៖ ការការពារសុវត្ថិភាពសង្គម និងទម្រង់ ៥៖ ការការពារបរិស្ថាន ) និងផែនទីដី សង្គមកិច្ចដើម្បីធានាថារាល់បញ្ហាដែលចម្បងៗទាក់ទងនឹងបញ្ហាខាងក្រោមត្រូវបានដោះស្រាយ ឬបញ្ជាក់ឱ្យច្បាស់៖ (១) ផលប៉ះពាល់នៃសម្បទានដីសង្គមកិច្ច ដែលបានដាក់ស្នើលើការប្រើប្រាស់ដីធ្លីព្រៃឈើ និងជម្រកនាពេលបច្ចុប្បន្នផ្សេងទៀត។ (២) ផលប៉ះពាល់លើជនជាតិដើម (៣) ផលប៉ះពាល់នៃ

ការតាំងទីលំនៅថ្មី (៤) ផលប៉ះពាល់លើតំបន់បេតិកភណ្ឌវប្បធម៌ (៥) ភាពសមស្របដីសម្រាប់កសិកម្ម និង (៦) ការឆ្លើយតបទៅនឹងបញ្ហាដែលលើកឡើងនៅក្នុងការវិភាគយេនឌ័រ។

(k) នៅជំហានទី ៦៖ ការពិនិត្យឡើងវិញ និងការអនុម័តលើរបាយការណ៍សម្បទានដីសង្គមកិច្ចរបស់ឃុំសង្កាត់ PLUAC មានទំនួលខុសត្រូវក្នុងការពិនិត្យបឋមថារបាយការណ៍សម្បទានដីសង្គមកិច្ច គោរពនូវការការពារសុវត្ថិភាពសង្គម និងបរិស្ថានហើយដំណើរការនៃការជ្រើសរើស TLR គឺស្របច្បាប់ និងមានតម្លាភាព។

(l) ក្នុងជំហានទី ៧ អ្នកទទួលដីធ្លីត្រូវបានជ្រើសរើសដោយផ្អែកលើដំណើរការបើកចំហ ការចូលរួម និងតម្លាភាពដែលការពារសមធម៌ និងរួមបញ្ចូលទាំងយន្តការដោះស្រាយបណ្តឹងតវ៉ា។

4. សម្រាប់ការរចនាប្លង់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលរួមមានផ្លូវថ្នល់ ការផ្គត់ផ្គង់ទឹក ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាពសាស្ត្រ និងអគារសហគមន៍ វិស្វករដែលធ្វើការនៅក្នុងគម្រោងនេះមានភារកិច្ចធ្វើការសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំប្លង់។ សម្រាប់ការអភិវឌ្ឍប្រព័ន្ធជាពសាស្ត្រដែលមានតម្រូវការបច្ចេកទេសស្មុគស្មាញ ក្រុមហ៊ុនពិគ្រោះយោបល់ត្រូវបានជួលឱ្យអនុវត្តការងារនេះ។ ផែនការពិនិត្យបឋម ESS និងផែនការគ្រប់គ្រងហានិភ័យ ផែនការទទួលបានដីដំបូង និងផែនការគ្រប់គ្រងបរិស្ថានត្រូវបានរៀបចំតាមតម្រូវការនៅដំណាក់កាលនេះ។ ដោយសារតម្រូវការតំបន់សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងព្រំដែននៃសម្បទានដីសង្គមកិច្ច ត្រូវបានបម្រុងទុកនៅដំណាក់កាលរៀបចំផែនការប្រើប្រាស់ដី វាពុំសមស្របទេសម្រាប់ការធ្វើផែនការកាន់កាប់ដីបន្ថែមទៀត ប៉ុន្តែនេះអាចកើតឡើងក្នុងករណីដែល (១) សំណង់ ឧទាហរណ៍ ផ្លូវចូលដំណើរការ គឺត្រូវបានតម្រូវនៅខាងក្រៅព្រំដែននៃតំបន់សម្បទានដីសង្គមកិច្ច (២) ការសិក្សាសមិទ្ធិលទ្ធភាព បង្ហាញពីតម្រូវការដើម្បីផ្លាស់ប្តូរទីតាំងនៃហេដ្ឋារចនាសម្ព័ន្ធដែលបានស្នើឡើង ពីគម្រោងដែលបានស្នើសុំដំបូងនៅក្នុងផែនការប្រើប្រាស់ដី (ជាការពិត វាបានកើតឡើងនៅលើតំបន់សម្បទានដីសង្គមកិច្ច មួយនៅខេត្តកំពង់ឆ្នាំង អំឡុងពេលអភិវឌ្ឍន៍ផ្លូវមួយដែលគាំទ្រដោយគម្រោង KfW-IPLR។

5. សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង មានបញ្ញត្តិសម្រាប់អនុគម្រោងមិនមែនហេដ្ឋារចនាសម្ព័ន្ធ និងជំនួយឥតសំណងដែលត្រូវពិនិត្យដើម្បីអនុវត្តតាមការការពារ រួមទាំងការដាក់ពាក្យស្នើសុំគ្រាប់ពូជ (កថាខណ្ឌ ៣៤០) និងសំណើវិនិយោគសម្រាប់ការរស់នៅ (កថាខណ្ឌ ៣៤៨)។ វិសាលភាពនៃការត្រួតពិនិត្យទាំងនេះរួមមានផលប៉ះពាល់សង្គម សមធម៌យេនឌ័រ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និង "ការអនុលោមតាមក្របខណ្ឌច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងការការពារសុវត្ថិភាពសង្គម និងបរិស្ថាននៃគម្រោង"។

6. ការពិពណ៌នាអំពីតួនាទីអនុវត្តនិងការទទួលខុសត្រូវនៅក្នុង សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង បានផ្តល់ការទទួលខុសត្រូវដល់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ "ការត្រួតពិនិត្យ និងណែនាំ...សកម្មភាពការពារដែលបានអនុវត្តនៅថ្នាក់ក្រោមជាតិរួមទាំងការអនុវត្តអនុគម្រោង" (កថាខណ្ឌ ៣៩២)។ ទោះយ៉ាងណាក៏ដោយ វាមិនត្រូវបានសរសេរលម្អិតទេ ថាតើការទទួលខុសត្រូវនេះត្រូវបានរំសាយវិញយ៉ាងដូចម្តេច។

7. ផ្នែកទី ៥.៦៦ នៃ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង ពិពណ៌នាអំពីក្របខណ្ឌការចូលរួមរបស់ពលរដ្ឋ (CEF) ក្របខណ្ឌកិច្ចសន្ទនាសហគមន៍ និងយន្តការដោះស្រាយពាក្យបណ្តឹងរបស់គម្រោង។ CEF គឺជាឯកសារអនុវត្តល្អបំផុតដែលបានវិវត្តតាមរយៈការកែប្រែជាច្រើនលើកច្រើនសារផ្អែកលើបទពិសោធន៍គម្រោង និង "ពិពណ៌នាអំពីគោលការណ៍និងដំណើរការសម្រាប់ការចែករំលែក និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ការលើកទឹកចិត្តការចូលរួមជាសាធារណៈ ការធានានូវតម្លាភាព គណនេយ្យភាព និងដំណោះស្រាយវិវាទ" នៅក្នុងគម្រោង (សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង កថាខណ្ឌ ៥២៨)។ យន្តការដោះស្រាយពាក្យបណ្តឹងមានពីរកម្រិតគឺនៅថ្នាក់មូលដ្ឋានជាពិសេសពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងស្ថាប័នដែលរងផលប៉ះពាល់ពីគម្រោងនៅថ្នាក់មូលដ្ឋាន ឬថ្នាក់ខេត្ត និងនៅថ្នាក់គ្រប់គ្រងគម្រោង (PMT) ដែលជាចម្បងសម្រាប់បុគ្គលិកគម្រោង អ្នកពិគ្រោះយោបល់, អង្គការក្រៅរដ្ឋាភិបាល អ្នកម៉ៅការ / អ្នកផ្គត់ផ្គង់វិស័យឯកជន។ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង កំណត់ទទួលខុសត្រូវចំពោះបណ្តឹងតវ៉ាថ្នាក់មូលដ្ឋានក្នុងការដោះស្រាយជាមួយដៃគូអង្គការក្រៅរដ្ឋាភិបាល។ ពាក្យបណ្តឹងនៅថ្នាក់គ្រប់គ្រងគម្រោង នឹងត្រូវបញ្ជូនទៅតាមរយៈក្រុមការងារគណនេយ្យភាពខេត្ត (PAWG) ដែលបច្ចុប្បន្នត្រូវបានជំនួសដោយការិយាល័យប្រជាពលរដ្ឋ។ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង (កថាខណ្ឌ ៥៤៤) ក៏ផ្តល់ផងដែរនូវបណ្តឹងដោយផ្ទាល់ទៅថ្នាក់គ្រប់គ្រងគម្រោង (PMT) តាមរយៈការិយាល័យ គេហទំព័រ អ៊ីម៉ែល ឬលេខទូរស័ព្ទរបស់គម្រោង ឬបញ្ជូនបន្តដោយអ្នកផ្តល់សេវាកម្ម និងអង្គការក្រៅរដ្ឋាភិបាល។ PMT គឺដើម្បីបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា (CHC)។ ដំណើរការដែលត្រូវអនុវត្តដោយ CHC ត្រូវបានរៀបរាប់លម្អិតនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង កថាខណ្ឌ ៥៤៦។ លើសពីនេះទៀត សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង ផ្តល់ព័ត៌មានលម្អិតនៃសេវាកម្មដោះស្រាយបណ្តឹងតវ៉ារបស់ធនាគារពិភពលោករួមមានគោលបំណង វិសាលភាព និងដំណើរការរបស់វា (កថាខណ្ឌ ៥៤៧ - ៥៨៥)។

8. ផ្នែក ៥.៨ នៃ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង សង្ខេបថាគោលនយោបាយសុវត្ថិភាព និងបរិស្ថាន ត្រូវបានពិចារណាថាជាការឆ្លើយតបដំណើរការ ដោយ LASED (តារាង ៤៣ នៃ PIM, ត្រូវបានរៀបចំឡើងវិញជាតារាង ១ ដូចខាងក្រោម)។

| តារាង ១៩៖ គោលនយោបាយសុវត្ថិភាពដំណើរការដោយគម្រោង LASED II | | |
|---|---|---|
| គោលនយោបាយសុវត្ថិភាព | ដំណើរការ | |
| គោលនយោបាយប្រតិបត្តិការ/BP ជម្រកធម្មជាតិ ៤.០៤ | មាន | |
| គោលនយោបាយប្រតិបត្តិការ/BP ព្រៃឈើ ៤.៣៦ | មាន | |
| គោលនយោបាយប្រតិបត្តិការ/BP ការគ្រប់គ្រងសត្វល្អិត ៤.០៩ | | គ្មាន |
| គោលនយោបាយប្រតិបត្តិការ/BP ធនធនវប្បធម៌រូបី ៤.១១ | មាន | |
| គោលនយោបាយប្រតិបត្តិការ/BP ជនជាតិដើមភាគតិច ៤.១០ | | គ្មាន |
| គោលនយោបាយប្រតិបត្តិការ/BP ការតាំងលំនៅឡើងវិញដោយបង្ខំ ៤.១២ | មាន | |
| គោលនយោបាយប្រតិបត្តិការ/BP នៃទំបន់ទឹក ៤.៣៧ | មាន | |
| គោលនយោបាយប្រតិបត្តិការ/BP នៃគម្រោងផ្លូវទឹកអន្តរជាតិ ៧.៥០ | | គ្មាន |
| គោលនយោបាយប្រតិបត្តិការ/BP នៃគម្រោងក្នុងតំបន់មានជម្លោះ ៧.៦០ | | គ្មាន |

9. ផ្នែក ៥.៨ នៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង ក៏មានផ្នែកដែលត្រូវបានពិពណ៌នាថាជា "បទពិសោធន៍ដែលទទួលបាន" ពីការអនុវត្តការការពារសុវត្ថិភាពនៅក្នុងគម្រោង តាមរយៈសេចក្តីសង្ខេបនៃការអនុវត្តការការពារសុវត្ថិភាពរបស់គម្រោង ជាជាងការវាយតម្លៃ និងការឆ្លុះបញ្ចាំងលើលទ្ធផលក៏ដោយ។

## 2. ភស្តុតាងនៃផលប៉ះពាល់ផ្នែកបរិស្ថាននៃគម្រោង

10. ផ្នែកនេះរួមជាមួយផ្នែកខាងក្រោមនៃផលប៉ះពាល់ផ្នែកសង្គម គឺផ្អែកលើឯកសារគម្រោង LASED និងការធ្វើបាយការណ៍ និងការសង្កេតនៅទីតាំងសម្បទានដីសង្គមកិច្ចដែលមានស្រាប់។ វាមិនមែនជាបញ្ជីនៃផលប៉ះពាល់បរិស្ថាន (ឬសង្គម) ទាំងអស់នៃគម្រោងទេ។

11. ការរៀបចំផែនការដីធ្លីគឺជាចំណុចសំខាន់នៃគម្រោង LASED។ តាមទស្សនៈការពារសុវត្ថិភាព នេះជានាថាជាមួយនឹងទំនុកចិត្តកម្រិតខ្ពស់ ទីតាំងដែលតម្លៃខ្ពស់ ឬងាយរងគ្រោះផ្នែកបរិស្ថាន នឹងត្រូវបានកំណត់ក្នុងអំឡុងពេលកំណត់អត្តសញ្ញាណសម្បទានដីសង្គមកិច្ច ការធ្វើផែនទីហតស្ពត (Hot-spot mapping) ដំណើរការពិនិត្យបឋម និងដំណើរការផែនការ និងវិធានការអភិរក្សសមស្របនឹងត្រូវបានអនុម័ត។ គម្រោងនេះបានចៀសវាងការទន្ទ្រានយក ឬធ្វើឱ្យប៉ះពាល់ទីតាំងសំខាន់ផ្នែក បរិស្ថាន។ ជាលទ្ធផលនៃសកម្មភាពគម្រោង ព្រំដែននៃទីតាំងសំខាន់ផ្នែកបរិស្ថាន ត្រូវបានកំណត់ដោយស្របច្បាប់តាមរយៈការធ្វើផែនទីសុរិយោដី និងដោយរូបវន្តតាមការដាក់បង្គោលព្រំដែន និងការយល់ដឹងអំពីទីតាំងសំខាន់ផ្នែកបរិស្ថានត្រូវបានលើកឡើង។ តំបន់ព្រៃសហគមន៍ត្រូវបានបង្កើតឡើងនៅក្នុងសម្បទានដីសង្គមកិច្ច និងស្ថាប័នសម្រាប់ការគ្រប់គ្រងរបស់ពួកគេ។

12. គម្រោងមិនបានជោគជ័យទាំងស្រុងក្នុងការការពារការទន្ទ្រានចូលតំបន់ការពារ។ បញ្ហានេះហាក់ដូចជាបញ្ហាជាក់លាក់មួយ ដែលតំបន់ការពារដូចជាព្រំប្រទល់ព្រៃសហគមន៍លើដីស្រែខាងក្រៅសម្បទានដីសង្គមកិច្ច ដែលផ្តល់ឱ្យកសិករ (មិនមែនជាអ្នកទទួលបានសម្បទានដីសង្គមកិច្ច) នូវការលើកទឹកចិត្តដើម្បីទន្ទ្រានកាន់កាប់ដីធ្លី។ ដើម្បីទទួលបានជោគជ័យ សហគមន៍ព្រៃឈើគួរតែត្រូវបានផ្តល់តម្លៃជាធនធានមានជីវិតរបស់សហគមន៍ រួមទាំងជាប្រភពផលិតផលប្រកបដោយនិរន្តរភាព ដូចជាអុស និងអនុផលព្រៃឈើ។ ខណៈពេលដែលមានភស្តុតាងមួយចំនួននៃការប្រើប្រាស់សម្រាប់គោលបំណងទាំងនេះ ចំណាប់អារម្មណ៍ទទួលបានពីបទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធសម្បទានដីសង្គមកិច្ច ថាព្រៃឈើសហគមន៍ត្រូវបានគេមើលឃើញថាជាការរៀបចំដើម្បីការពារព្រៃឈើសម្រាប់ជាប្រយោជន៍របស់ខ្លួន ជាជាងដោយសារតែតម្លៃព្រៃឈើដល់សហគមន៍។ ប្រសិនបើនេះជាការយល់ឃើញពិតប្រាកដ ស្ថាប័នព្រៃឈើសហគមន៍នឹងបរាជ័យ។ គេអាចធ្វើបានច្រើនទៀតដើម្បីសម្របការគ្រប់គ្រងព្រៃឈើសហគមន៍ តាមតម្រូវការសហគមន៍។ វាត្រូវបានគេកត់សម្គាល់ផងដែរថា ខណៈពេលដែលសហគមន៍ព្រៃឈើត្រូវបានបង្កើតឡើងដោយកំណត់និងអភិរក្សតំបន់ព្រៃឈើដែលមានស្រាប់នៅក្នុងសម្បទានដីសង្គមកិច្ច ទោះបីជាធម្មតាមានការរិចរិលយ៉ាងធ្ងន់ធ្ងរ ក៏មានតំបន់ដីនៅក្នុងដីសម្បទានដសង្គមកិច្ចដែលគ្មានគម្របព្រៃឈើ ប៉ុន្តែតំបន់ទាំងនេះមិនសមស្របសម្រាប់កសិកម្មនោះទេ។ តំបន់ទាំងនេះត្រូវបានគេបែងចែកជាដីស្រែទោះបីជាពុំមានភាពសមស្របសម្រាប់គោលបំណងទាំងនោះ ហើយក្នុងករណីខ្លះវាបង្ហាញថាកសិករដែលទទួលបានដីទាំងនោះកំពុងធ្វើស្រែចំការលើដី ដែលត្រូវបានគេបម្រុងទុកសម្រាប់អ្នក

ផ្សេងទៀត។ វាជាការល្អប្រសើរជាងមុនក្នុងការដាំឡើងវិញនូវដើមានជីជាតិទាបទាំងនេះជាមួយប្រភេទដើមឈើដើម និងអនុញ្ញាតឱ្យពួកគេបង្កើតជាជីព្រៃសហគមន៍ឡើងវិញ។

13. ពុំមានភស្តុតាងណាមួយពីការសង្កេតទីតាំង ឬរបាយការណ៍គម្រោង អំពីផលប៉ះពាល់អវិជ្ជមានដែលនៅបន្តមាន ពីសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៃគម្រោង។ ផ្លូវថ្នល់និងប្រព័ន្ធធារាសាស្ត្រមួយចំនួនត្រូវបានរចនាឡើងមិនពេញលក្ខណៈ និងទទួលរងនូវការហូរច្រោះទៅនឹងដី និងតំបន់ជិតនោះក្នុងប្រវែង ២០ ម៉ាយ៍ ប៉ុន្តែដោយសារតែសណ្ឋានដីរាបស្មើជាទូទៅ នេះមិនបណ្តាលឱ្យមានបញ្ហាសំណឹករាលដាលទេ។

14. របាយការណ៍ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃគម្រោង LASED II ស្តីពីភាពជោគជ័យនៃការគ្រប់គ្រងហានិភ័យបរិស្ថាននៅអនុគម្រោង រួមទាំងការរៀបចំ និងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន (EMP) សម្រាប់អនុគម្រោងនីមួយៗ។ ការអនុវត្ត EMP ទាំងនេះត្រូវបានត្រួតពិនិត្យ និងគ្មានការរំលោភបំពានធ្ងន់ធ្ងរណាមួយត្រូវបានគេរាយការណ៍ឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ កត់សម្គាល់ថា ការត្រួតពិនិត្យអាចត្រូវបានធ្វើឱ្យប្រសើរឡើង រួមទាំងការរៀបចំរបាយការណ៍រួមស្តីពីការអនុលោមតាមគោលការណ៍ការពារសុវត្ថិភាព។ ការត្រួតពិនិត្យពាក់ កណ្តាលអាណត្តិ ពុំបានធ្វើការរាយការណ៍ស្តីពីការលំបាកដែលបានជួបប្រទះក្នុងការអនុវត្តនីតិវិធីការពារសុវត្ថិភាពទាក់ទងនឹងសុវត្ថិភាពទំនប់ ដោយអ្នកពិគ្រោះយោបល់វិស្វកម្ម ដែលចូលរួមក្នុងការគោលបំណងព្យាយាមវាយតម្លៃទិដ្ឋភាពសុវត្ថិភាព ការរចនាប្លង់ និងជម្រើសនៃការចំណាយ។

15. ការរៀបចំការការពារសុវត្ថិភាពគម្រោងហាក់ដូចជាមិនសូវមានការអភិវឌ្ឍ និងរឹងមាំទាក់ទងនឹងផលប៉ះពាល់ដែលមិនអាចគ្រប់គ្រងបានតាមរយៈការធ្វើផែនការប្រើប្រាស់ដីធ្លី។ ផលប៉ះពាល់ទាំងនេះរួមមាន (១) ទិដ្ឋភាពសុខភាពបរិស្ថាននៃតំបន់លំនៅដ្ឋាននៃសម្បទានដីសង្គមកិច្ច (២) ហានិភ័យសក្តានុពលបរិស្ថាន និងសុខភាពនៃសកម្មភាពកសិកម្ម និង (៣) ការបំផ្លាញបរិស្ថានដែលមានសក្តានុពលជាផលប៉ះពាល់បន្ទាប់បន្សំនៃចលនាប្រជាជន។

16. អ្នកទទួលដីសម្បទានដីសង្គមកិច្ច ករណីភាគច្រើនផ្លាស់ទៅទីតាំងសម្បទានដីសង្គមកិច្ចពីភូមិបែបប្រពៃណីដែលមានដង់ស៊ីតេទាប។ តំបន់លំនៅដ្ឋាននៃទីតាំងសម្បទានដីសង្គមកិច្ច ត្រូវបានគ្រោងទុកជាទីក្រុងតូចៗដែលមានលក្ខណៈប្រជុំជន។ ការរៀបចំភូមិសម្រាប់ការចោលសំណល់ និង អនាម័យអាចក្លាយជាការមិនអាចទទួលយកបាននៅក្នុងបរិយាកាសថ្មីនេះ។ ផែនការទីតាំង LASED រួមបញ្ចូលទាំងតំបន់ដែលត្រូវបានកំណត់សម្រាប់ការចោលសំរាម ប៉ុន្តែមិនមានប្រព័ន្ធប្រមូលណាមួយទេ ដូច្នេះសំណល់រឹងត្រូវបានដុតបង្កើតជាផ្សែងពុល ឬរាយប៉ាយពាសពេញកន្លែងនោះ។ បញ្ហានេះនឹងកាន់តែធ្ងន់ធ្ងរប្រសិនបើទីផ្សារជោគជ័យត្រូវបានបង្កើតឡើងនៅលើទីតាំងសម្បទានដីសង្គមកិច្ច។ អ្នកទទួលដីបានរើចេញពីភូមិដែលការបន្ទោរបង់ដោយបើកចំហជារឿងធម្មតា ឬជាទម្លាប់ទៅ ហើយ។ LASED បានផ្តល់សម្ភារសម្រាប់ការសាងសង់បង្គន់ ប៉ុន្តែយុទ្ធសាស្ត្រនេះមិនមានលក្ខណៈគ្រប់គ្រាន់ទេ៖ សម្ភារបង្គន់អាចត្រូវបានគេសង្កេតឃើញបោះបង់ចោល ឬប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតនៅទីតាំងនោះ ខណៈដែលផ្ទះជាច្រើនខ្វះបង្គន់អនាម័យត្រឹមត្រូវ។ នៅក្នុងការតាំងទីលំនៅនៃដង់ស៊ីតេតំបន់លំនៅដ្ឋានសម្បទានដីសង្គមកិច្ចនេះ ត្រូវតែចាត់ទុកថាជាការបង្កើតគ្រោះថ្នាក់សុខភាពដោយផ្ទាល់ និងតាមរយៈសក្តានុពលនៃការចម្លងរោគទៅក្នុងការផ្គត់ផ្គង់ទឹក។

17. ការអនុវត្តកសិកម្មភាគច្រើននៅក្នុងតំបន់គម្រោង និងនៅលើតំបន់សម្បទានដីសង្គមកិច្ចមានអាំងតង់ស៊ីតេទាប ហើយកសិករប្រើបរិមាណមានកំណត់នៃសារធាតុគីមីកសិកម្ម។ កសិករខ្លះដែលមានការគាំទ្រពីគម្រោងកំពុងដាំដំណាំសរីរាង្គ។ នេះគឺជាយុទ្ធសាស្ត្រដ៏ទាក់ទាញមួយដោយសារវាមានតម្រូវការៈ កសិករនឹងផលិតដំណាំសរីរាង្គ ប្រសិនបើដំណាំលក់ក្នុងតម្លៃខ្ពស់ ហើយដូច្នេះនឹងបង្កើតប្រាក់ចំណេញកាន់តែច្រើនសម្រាប់កសិករ។ ទោះយ៉ាងណាក៏ដោយភស្តុតាងត្រូវបានគេមើលឃើញពីការប្រើប្រាស់សារធាតុគីមីកសិកម្ម រួមទាំងថ្នាំសម្លាប់សត្វល្អិតដែលអាចបង្កគ្រោះថ្នាក់នៅទីតាំងសម្បទានដីសង្គមកិច្ច។ កសិករដែលត្រូវបានសម្ភាស មិនបានទទួល ឬមិនបានរំឭកអំពីការ បណ្ដុះបណ្ដាលណាមួយក្នុងការប្រើប្រាស់សារធាតុគីមីកសិកម្មប្រកបដោយសុវត្ថិភាពនោះទេ។ វាជាការសំខាន់ណាស់ដែលត្រូវទទួលយកថាកសិករនឹងប្រើប្រាស់សារធាតុគីមីកសិកម្ម នៅពេលវាមានអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្មសម្រាប់ពួកគេក្នុងការធ្វើដូច្នោះ ហើយគម្រោងនេះគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីធានាថាកសិករមានចំណេះដឹង និងជំនាញដែលត្រូវការដើម្បីប្រើប្រាស់គីមីដោយសុវត្ថិភាព។

18. តំបន់សម្បទានដីសង្គមកិច្ចគម្រោង LASED ជាការតាំងទីលំនៅដ៏សន្ធឹកដែលមានប្រជាជនរហូតដល់ ៣,០០០ - ៥,០០០ នាក់ក្នុងករណីខ្លះ។ ដីដែលអាចរកបានសម្រាប់ទីតាំងទាំងនោះភាគច្រើនដាច់ស្រយាលពីការតាំងទីលំនៅដែលមានស្រាប់។ ដូច្នេះការបង្កើតសម្បទានដីសង្គមកិច្ចធ្វើឱ្យមានការផ្លាស់ប្តូរទីលំនៅប្រជាជនយ៉ាងច្រើន ជាញឹកញាប់ទៅក្នុងតំបន់ដែលអាចនៅជាប់នឹងតំបន់ងាយរងគ្រោះខាងបរិស្ថាន ឬតំបន់អភិរក្ស។ មានហានិភ័យជាក់ស្តែងដែលនៅជិតតំបន់អភិរក្សសត្វព្រៃ អាចបណ្តាលឱ្យមានការកើនឡើងនូវសកម្មភាពដែលមានគ្រោះថ្នាក់ដូចជាការកាប់ឈើ ការបរបាញ់ ឬសូម្បីតែការទន្ទ្រានយកដី។ មិនមានភស្តុតាងផ្ទាល់ដែលបង្ហាញពីការពិតដែលកើតឡើងជាលទ្ធផលនៃគម្រោង LASED ទេ។ ទោះយ៉ាងណាក៏ដោយនៅទីតាំងសម្បទានដីសង្គមកិច្ចមួយចំនួន ផលិតកម្មធ្យូងគឺជាសកម្មភាពចិញ្ចឹមជីវិតដ៏សំខាន់មួយ។ ប្រសិនបើធ្យូងត្រូវបានផលិតដោយប្រើឈើ ដែលត្រូវបានឈូសឆាយចេញពីដីកសិកម្មសម្បទានសង្គមកិច្ច សកម្មភាពនេះគ្មានគ្រោះថ្នាក់ទេ ប៉ុន្តែប្រសិនបើឈើគឺទាញយកមកពីប្រភពតំបន់ព្រៃឈើ នៅពេលនេះឬអនាគត វាអាចមានផលប៉ះពាល់បរិស្ថាន។ ក្របខណ្ឌគម្រោងសម្រាប់ការការពារបរិស្ថានគួរតែរាប់បញ្ចូលការពិចារណាអំពីសក្តានុពលផលប៉ះពាល់បន្ទាប់បន្សំនៃប្រភេទនេះ ដែលអាចកើតឡើងហួសពីព្រំដែនសម្បទានដីសង្គមកិច្ចខ្លួនឯង។

## 3. ភស្តុតាងនៃផលប៉ះពាល់ផ្នែកសង្គមនៃគម្រោង

19. គោលបំណងនៃ LASED គឺដើម្បីផ្តល់ផលប្រយោជន៍សង្គមជាចម្បងដល់សមាជិកក្រីក្របំផុតនៃសហគមន៍ជនបទ តាមរយៈលទ្ធភាពច្រើនជាងមុន និងកាន់តែមានសុវត្ថិភាពក្នុងការទទួលបានដី និងតាមរយៈអត្ថប្រយោជន៍ដែលបានមកពីការទូទាត់ជំនួយ សកម្មភាពគាំទ្រជីវភាព និងគាំទ្រសេវាកម្មសង្គម នៅក្នុងតំបន់គម្រោង។ គម្រោងត្រូវបានគេចាត់ទុកថាជាជោគជ័យគួរឱ្យកត់សម្គាល់មួយ ដោយសារតែសមិទ្ធិផលរបស់វានៅក្នុងតំបន់ទាំងនេះ។

20. របាយការណ៍ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃគម្រោង LASED II បានលើកឡើងថាក្របខណ្ឌគោលនយោបាយការតាំងទីលំនៅថ្មី (RPF) មិនត្រូវបានបង្កើតឡើងដោយហេតុថា អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធមិនបានបណ្តាលឱ្យមានតម្រូវការក្នុងការតាំងទីលំនៅថ្មី។ ការបែងចែកដីធ្លីនៅក្នុង LASED ហាក់ដូចជាត្រូវបានអនុវត្តប្រកបដោយតម្លាភាព និងសមធម៌ ដោយមានបណ្តឹងតិចតួចដែលកើតមាន ដោយពិចារណាលើសក្តានុពលនៃភាពធាប់ប្រែប្រួលសក្តានុពលរបស់ដំណើរការនេះ។ ទំនាស់ដែលអាចកើតមានជាមួយអ្នកប្រើប្រាស់ដីមុន (រួមទាំងក្នុងករណីខ្លះជាមួយជនឱកាសនិយមដែលទន្ទ្រានយកទីតាំងសម្បទានដីសង្គមកិច្ចដែលបានស្នើ) ហាក់ដូចជាត្រូវបានដោះស្រាយយ៉ាង ល្អប្រសើរ។ ទោះយ៉ាងណាក៏ដោយ បញ្ហាមួយចំនួនបានកើតឡើងដូចដែលបានរៀបរាប់លម្អិតនៅក្នុងការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃគម្រោង LASED II។ នេះរាប់បញ្ចូលទាំងបណ្តឹងទាមទារសំណងជាច្រើនលើកម្មសិទ្ធិដីធ្លីមុនទីតាំងសម្បទានដីសង្គមកិច្ចនៅឃុំ (ខេត្តក្រចេះ)។ ភាគច្រើននៃការទាមទារទាំងនេះត្រូវបានដោះស្រាយដោយការចរចារដោយរាប់បញ្ចូល ទាំងការដោះដូរដីជាមួយដីសម្បទានសង្គមកិច្ច ឬនៅខាងក្រៅដីសម្បទានសង្គមកិច្ច។ នៅពេលនៃ ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ នេះ (ខែមីនា ឆ្នាំ២០១៩) បណ្តឹងតវ៉ាចំនួន ៧៦ ត្រូវបានដោះស្រាយហើយ ៥១ ទៀតនៅពុំទាន់ដោះស្រាយរួច ភាគច្រើនគឺមកពីគ្រួសារដែលមិនបានចូលរួមក្នុងដំណើរការស៊ើបអង្កេត និងចរចា។ បទពិសោធន៍ជាមួយនឹងយន្តការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានពិភាក្សាបន្ថែមទៀតនៅក្នុងផ្នែក បន្ទាប់។

21. ដំណើរការនៃការបែងចែកដីធ្លីដោយខ្លួនឯង បង្កើតឱ្យមានពាក្យបណ្តឹងជាច្រើនដែលមានលម្អិតនៅក្នុងការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ។ រូបភាពទាំងនេះខ្លះបង្ហាញពីការប៉ុនប៉ងរបស់អ្នកទទួលដី ដើម្បីពង្រីកដីឡូត៍របស់ពួកគេដោយរំកិលបង្គោល។ ក្នុងករណីមួយ ដើមបណ្តឹងបានទទួលដីតូចជាងការសន្យា ហើយត្រូវបានផ្តល់សំណងជាមួយដីបន្ថែម។ ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ ក៏បានបញ្ជាក់ផងដែរថាមានបញ្ហាជាមួយអ្នកទទួលសម្បទានដីសង្គមកិច្ច ដែលបានរំលោភយកដីរដ្ឋបាល និងដីបម្រុងទុករួមទាំងដីដែលត្រូវការសម្រាប់សាងសង់ប្រព័ន្ធធារាសាស្រ្តនៅទីប៉ូ ខេត្តកំពង់ធំ (ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ កថាខណ្ឌ ២៥៤)។

22. សហគមន៍គោលដៅនៃគម្រោង LASED និង LASED II មិនបានរាប់បញ្ចូលសហគមន៍ជនជាតិដើមភាគតិចទេ ទោះបីជាមានចំនួនជនជាតិដើមភាគតិចរស់នៅទីតាំងសម្បទានដីសង្គមកិច្ចក៏ដោយ។ មិនមានបញ្ហាអ្វីបានកើតឡើងទាក់ទងនឹងសិទ្ធិជនជាតិដើមភាគតិចឡើយ។

23. គ្រួសារដែលទទួលបានជោគជ័យ ក្នុងការបង្កើតខ្លួនឯងនៅទីតាំងសម្បទានដីសង្គមកិច្ច ហាក់ដូចជាមានដំណើរការល្អ ដោយមានជនជាតិភាគតិចគួរឱ្យកត់សម្គាល់បានក្លាយជាអ្នកមានជីវភាពធូរធារតាមរយៈការរួមបញ្ចូលគ្នារវាងសកម្មភាពកសិកម្ម និងអាជីវកម្មនៅទីតាំងទាំងនោះ។ ទោះជាយ៉ាងណាក្តី ការពិតដែលថាទំហំគួរឱ្យកត់សម្គាល់នៃសម្បទានដីសង្គមកិច្ច នៅទំនេរ បង្ហាញថាមិនមែនអ្នកទទួលដីទាំងអស់បានទទួលជោគជ័យក្នុងការផ្លាស់ប្តូរ នេះទេ។ ក្នុងករណីខ្លះ អ្នកទទួលដីកំពុងធ្វើស្រែលើដីកសិកម្មសម្បទានសង្គមកិច្ច ប៉ុន្តែដីលំនៅដ្ឋានរបស់ពួកគេនៅទំនេរព្រោះពួកគេមានភាពងាយស្រួល ក្នុងការរស់នៅក្នុងភូមិដើម និងធ្វើដំណើរទៅធ្វើការនៅលើដីរបស់ខ្លួន។ ហេតុផលសម្រាប់បញ្ហានេះអាចខុសគ្នា ប៉ុន្តែបញ្ហាប្រឈមក្នុងការរស់នៅលើសម្បទានដីសង្គមកិច្ច ត្រូវតែជាកត្តាមួយ។

24. ទទួលសម្បទានដីសង្គមកិច្ច ត្រូវបានជ្រើសរើសពីផ្នែកក្រីក្រ និងគ្មានដីរបស់សហគមន៍នៅក្នុងឃុំដើម - ជាផ្លូវការការបែងចែកដល់គ្រួសារមកពីក្រៅឃុំមិនត្រូវបានអនុញ្ញាតទេ។ នៅតាមភូមិដើមរបស់ពួកគេ គ្រួសារទាំងនេះទោះបីក្រីក្រក៏ដោយពួកគេ នឹងទទួលបានអត្ថប្រយោជន៍ពីបណ្តាញគាំទ្រ រួមទាំងសាច់ញាតិ និងអ្នកជិតខាង ក៏ដូចជាអាផ្ទាធរមូលដ្ឋាន។ ពួកគេអាចមានលទ្ធភាពក្នុងការទទួលបានការអប់រំ និងសេវាសុខភាពដែលមានភាពងាយស្រួល។ ការផ្លាស់ទៅរស់នៅលើទីតាំងសម្បទានដីសង្គមកិច្ចដ៏ឆ្ងាយ អាចមានជះឥទ្ធិពលដល់ការបាត់បង់បណ្តាញគាំទ្រដែលមានស្រាប់ ក៏ដូចជាធ្វើឱ្យលទ្ធភាពចូលប្រើសេវាកម្មកាន់តែពិបាកជាងមុនដែលជាបញ្ហាប្រឈមជាពិសេសសម្រាប់គ្រួសារក្រីក្រ។ គួរកត់សម្គាល់ថាការត្រួតពិនិត្យពាក់កណ្តាលអាណត្តិរបស់គម្រោង LASED II កំណត់ពីតម្រូវការដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់អ្នកទទួលដីរវាងភូមិដើមរបស់ពួកគេ និងទីតាំងសម្បទានដីសង្គមកិច្ច ជាអាទិភាពខ្ពស់នៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍសម្បទានដី សង្គមកិច្ច (ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ កថាខណ្ឌ ២៤៥)។

25. មានហានិភ័យដែលលំនាំនៃការរើសអើងក្នុងសង្គម ផ្អែកលើភាពក្រីក្រ ឬកត្តាផ្សេងៗទៀតអាចត្រូវបានផ្ទេរទៅទីតាំងសម្បទានដីសង្គមកិច្ច ទោះបីជាវាត្រូវបានគេកត់សម្គាល់ឃើញនាពេលកន្លងមកថាអ្នករស់នៅក្នុងតំបន់ទីតាំងសម្បទានដីសង្គមកិច្ច បានបង្ហាញនូវការពេញចិត្តនៅពេលពួកគេបានរួចផុតពីស្ថានភាពមួយដែលពួកគេត្រូវបានចាត់ទុកអ្នកដែលមានឋានៈសង្គមទាបទៅសហគមន៍ថ្មី ដែលពួកគេអាចត្រូវបានគេគោរព។ បញ្ហាសង្គមផ្សេងទៀតរួមទាំងអំពើហិង្សាផ្អែកលើយេនឌ័រ (ជារឿយៗទាក់ទងនឹងការសេពគ្រឿងស្រវឹង) ក៏អាចផ្ទេរទៅទីតាំងសម្បទានដីសង្គមកិច្ច ដែលជាកន្លែងដែលមានវិសាលភាពតិចសម្រាប់អន្តរាគមន៍ និងជំនួយដែលមានប្រសិទ្ធិភាពពីអាជ្ញាធរមូលដ្ឋាន ឬស្ថាប័នសេវាសង្គមដែលមាននៅតាមជនបទនៅកម្ពុជា (ឧទាហរណ៍ គណៈកម្មាធិការស្ត្រី និងកុមារឃុំ សង្កាត់)។

## 4. បទពិសោធន៍ជាមួយយន្តការដោះស្រាយបណ្តឹងតវ៉ា

26. ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃគម្រោង LASED II ពិភាក្សាអំពីបទពិសោធន៍ជាមួយយន្តការដោះស្រាយពាក្យបណ្តឹង (CHM) ដែលជាប្រធានបទនៃរបាយការណ៍ឯករាជ្យមួយ។ ការអនុវត្តនៃការផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយអំពីការអភិវឌ្ឍទីតាំងសម្បទានដីសង្គមកិច្ច បាននាំឱ្យមាននូវបណ្តឹងមួយចំនួន ជាពិសេសទាក់ទងទៅនឹងការអភិវឌ្ឍសម្បទានដីសង្គមកិច្ចនៅ ឃុំដូង ដែលសមត្ថភាពនៃប្រព័ន្ធដោះស្រាយត្រូវបានគ្រប់ដណ្តប់។ ពាក្យបណ្តឹងភាគច្រើនត្រូវបានគេបញ្ជូនដោយផ្ទាល់មាត់ (សន្ទតតាមទូរស័ព្ទ) ហើយអ្នកដែលទទួលពាក្យបណ្តឹងមិនតែងតែអាចកត់ត្រាព័ត៌មានបានគ្រប់គ្រាន់នោះទេ។ គម្រោងបានរៀបចំសំណើដើម្បីធ្វើឱ្យសាមញ្ញនូវទម្រង់ដែលត្រូវបានប្រើក្នុងការកត់ត្រា និងដំណើរការពាក្យបណ្តឹង។ ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ ស្នើជាជម្រើសជំនួសដូចជាការបង្កើនការបណ្តុះបណ្តាលបុគ្គលិកថ្នាក់ខេត្ត និងបង្កើនធនធានមនុស្ស សម្រាប់ដោះស្រាយបណ្តឹងតវ៉ា ឬបញ្ចូល CHM ជាមួយប្រព័ន្ធដោះស្រាយពាក្យបណ្តឹងរបស់គណៈកម្មការសុរិយោដី ដែលដឹកនាំដោយថ្នាក់ជាតិដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយអភិបាលរងនៅថ្នាក់ខេត្ត និងដោយប្រធានមន្ទីររៀបចំដែនដីខេត្តនៅថ្នាក់ស្រុក។

## 5. ការវិភាគផ្នែកខ្វះខាត

### បទដ្ឋានបរិស្ថាន និងសង្គមទី ១ –ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ទាក់ទងនឹងបរិស្ថាន និងសង្គម

27. ផ្នែកនេះ និងផ្នែកខាងក្រោមនៃ ESMF សង្ខេបពីគម្លាតនៅក្នុងក្របខណ្ឌនៃការការពារសុវត្ថិភាពសម្រាប់ LASED II (ដែលត្រូវបានបង្កើតឡើងដើម្បីអនុលោមតាមគោលនយោបាយសុវត្ថិភាពមុនរបស់ធនាគារពិភពលោក) ទាក់ទងទៅនឹងតម្រូវការរបស់ ESS១-ESS៨ and ESS១០ និងESF។ ផ្នែកនេះកត់សម្គាល់ពីលក្ខណៈពិសេសនៃគម្រោងដែលអាចបញ្ជាក់ថាពាក់ព័ន្ធនឹងតម្រូវការរបស់ ESS នីមួយៗ។ វាមិនត្រូវបានចូលរួមជាការវិភាគហានិភ័យពេញលេញ ដែលកើតឡើងនៅផ្នែកក្រោយៗទៀតនោះទេ។

28. គម្រោង LASED II មានសំណុំឯកសារសុវត្ថិភាពល្អិតល្អន់ និងរឹងមាំដែលត្រូវបានរៀបចំដើម្បីអនុវត្តតាមគោលនយោបាយសុវត្ថិភាព។ ឯកសារទាំងនេះបង្ហាញនូវភស្តុតាងគ្រប់គ្រាន់ដើម្បីគ្រប់គ្រងហានិភ័យទាក់ទងនឹងបរិស្ថាន និងសង្គមដែលបានជួបប្រទះក្នុងការអនុវត្តគម្រោងដូចដែលបានរៀបរាប់ខាងលើ។ ទោះយ៉ាងណាក៏ដោយ (១) មិនមែនរាល់បញ្ញត្តិស្តីពីការការពារសុវត្ថិភាពនៃគម្រោង LASED II បានកើតឡើងនៅក្នុងការអនុវត្តជាក់ស្តែងឡើយ (២) គម្រោង LASED III រួមបញ្ចូលទាំងសកម្មភាព និងទីតាំងដែលខុសគ្នាឆ្ងាយពីអ្វីដែលមាននៅគម្រោង LASED II និង (៣) វិសាលភាពនៃ ESF ទាមទារឱ្យមានការពិចារណាលើសក្តានុពលនៃហានិភ័យ ដែលមិនត្រូវបានគ្របដណ្តប់ដោយក្របខណ្ឌគម្រោង LASED II។

29. ការរៀបចំឯកសារសុវត្ថិភាពបច្ចុប្បន្ន ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោមបង្ហាញសំណុំឧបករណ៍សុវត្ថិភាពដែលតម្រូវ សម្រាប់ការអនុលោមតាម ESF នៅខាងឆ្វេង បន្ទាប់មកមានឯកសារដែលពាក់ព័ន្ធនៅក្នុងគម្រោង LASED II និងបញ្ចប់ដោយយោបល់លើគម្លាតដែលអាចកើតមាន។

| **តារាងទី ២០៖ឧបករណ៍ការពារ ESF បើប្រៀបធៀបជាមួយក្របខណ្ឌការពារសុវត្ថិភាពនៃគម្រោង LASED II** | | |
|---|---|---|
| ឧបករណ៍ការពារសុវត្ថិភាព ESF | **ឯកសារ LASED II ដែលពាក់ព័ន្ធ** | **សម្គាល់** |
| ក្របខណ្ឌគ្រប់គ្រងហានិភ័យចំពោះបរិស្ថាននិងសង្គម (ESMF) | EA-EMP | ចុះឆ្នាំ ២០០៧ |
| ផែនការប្តេជ្ញាចិត្តសម្រាប់គ្រប់គ្រងបរិស្ថាន និងសង្គម (ESCP) | EA-EMP | ចុះឆ្នាំ ២០០៧ |
| ក្របខណ្ឌគោលនយោបាយការតាំងទីលំនៅថ្មី (RPF) | RPF | រៀបចំខែមេសា មិនត្រូវបានអនុវត្តនៅក្នុង LASED II |
| ក្របខណ្ឌផែនការជនជាតិដើមភាគតិច (IPPF) | IPPF | រៀបចំឆ្នាំ២០០៧ មិនត្រូវបានអនុវត្តនៅក្នុង LASED II |
| ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF) | | រៀបចំឆ្នាំ២០០៧ មិនច្បាស់ថាត្រូវបានអនុវត្តនៅក្នុង LASED II |
| ក្របខណ្ឌការងារគ្រប់គ្រងការងារ (in ESMF) | | មិនមានបញ្ញត្តិជាក់លាក់ |
| និតិវិធីសុវត្ថិភាពនិងសុខភាពសហគមន៍ (in ESMF) | | មិនមានបញ្ញត្តិជាក់លាក់ |
| ក្របខណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEF) | | ក្របខណ្ឌនៃការចូលរួមរបស់ពលរដ្ឋ (២០០៧) យន្តការដោះស្រាយបណ្តឹងតវ៉ា |

30. នៅកន្លែងដែលមានឯកសារពាក់ព័ន្ធពីគម្រោង LASED II ពួកគេត្រូវការការពិនិត្យមើលឡើងវិញនិងធ្វើបច្ចុប្បន្នភាពដើម្បីឱ្យស្របទៅនឹងការរចនាប្លង់នៃគម្រោង LASED III និងជាមួយនឹងតម្រូវការរបស់ ESF។ ការដាក់បញ្ចូលទៅក្នុងគម្រោង LASED III នៃការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ដល់ដំណើរការ ICLT តម្រូវឱ្យមានការកែប្រែទៅលើក្របខណ្ឌផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិច និងអាចទៅលើក្របខណ្ឌគោលនយោបាយផ្លាស់ទីលំនៅដោយសារគម្រោង និង ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ផងដែរ។

31. ជាទូទៅ ESP ផ្តោតសំខាន់ខ្លាំងជាងទៅលើ "ឋានានុក្រមកាត់បន្ថយ" (ចៀសវាង កាត់បន្ថយជាអប្បបរមា កាត់បន្ថយ និងផ្តល់សំណង) បើប្រៀបធៀបទៅនឹង Ops ហើយនីតិវិធីអាចត្រូវការកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីបញ្ហានេះ។

32. ដូចដែលបានកត់សម្គាល់ខាងលើ បញ្ញត្តិសម្រាប់ការត្រួតពិនិត្យការអនុវត្តនីតិវិធីការពារសុវត្ថិភាពនៅក្នុងគម្រោង LASED II មិនមានលក្ខណៈរឹងមាំទេ។ ការត្រួតពិនិត្យនិងរាយការណ៍អំពីការអនុវត្ត ESS គឺជាទំនួលខុសត្រូវមួយក្នុងចំណោមទំនួលខុសត្រូវសំខាន់ៗរបស់អ្នកខ្ចីនៅក្រោម ESS 1។

## បទដ្ឋានបរិស្ថាន និងសង្គមទី ២ ៖ លក្ខខណ្ឌការងារ និងពលកម្ម

33. ការជួលកម្លាំងពលកម្ម លក្ខខណ្ឌការងារ និងសុខភាព និងសុវត្ថិភាពការងារមិនត្រូវបានពិចារណាក្នុងក្របខណ្ឌការពារ LASED II បើទោះបីជាការធ្វេសប្រហែសមួយចំនួនអាចត្រូវបានអនុវត្ត ឧទាហរណ៍តាមរយៈ

នីតិវិធីគ្រប់គ្រងកិច្ចសន្យា។ ក្នុងគម្រោង LASED III បុគ្គលិកគម្រោង ("កម្មករផ្ទាល់") កម្មករជាប់កិច្ចសន្យានិងកម្មករក្នុងសហគមន៍ទាំងអស់សុទ្ធតែអាចស្របតាមប្បញ្ញត្តិរបស់ បទដ្ឋានបរិស្ថាន និងសង្គមទី ២។ ការធានាលក្ខខណ្ឌការងារប្រកបដោយសមធម៌ ស្របច្បាប់ និងសុវត្ថិភាព ការសម្រុះសម្រួលដែលពាក់ព័ន្ធ និងសិទ្ធិគ្រប់គ្រាន់ក្នុងការរៀបចំនិងសម្តែង បណ្តឹងតវ៉ាសម្រាប់កម្មករជាប់កិច្ចសន្យា ទំនងជាបញ្ហាលេចធ្លោបំផុតនៅក្នុងការអនុវត្តជាក់ស្តែង។ វិសាលភាពនៃ បទដ្ឋានបរិស្ថាន និងសង្គមទី ២ អាចពង្រីកដល់កម្មករដែលមិនមានវត្តមាននៅលើទីតាំងគម្រោង ដូច្នេះការអនុវត្តច្បាប់អាចជាបញ្ហាប្រឈម។ វិធីសាស្រ្តរបស់ បទដ្ឋានបរិស្ថាន និងសង្គមទី ២ គឺខុសគ្នាពីវប្បធម៌ធ្វើការតាមបែបបុរាណរបស់អ្នកម៉ៅការសំណង់ដូចជាអ្នកដែលនឹងត្រូវជួលឱ្យធ្វើការក្នុងគម្រោង LASED III ហើយនិងការអនុវត្តប្រកបដោយប្រសិទ្ធិភាពនៃ ESS2 ទំនងជាត្រូវការវិធីសាស្រ្តអភិវឌ្ឍន៍សមត្ថភាព ក៏ដូចជាការគ្រប់គ្រងការអនុវត្តច្បាប់។

34. C/SF សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការអនុវត្តអនុគម្រោង ដោយរាប់បញ្ចូលកិច្ចសន្យាសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅគម្រោង LASED II។ ការវិភាគគម្លាតនៃ C/SF PIM ប្រៀបធៀបនឹងតម្រូវការ បទដ្ឋានបរិស្ថាន និងសង្គមទី ២ ត្រូវបានផ្តល់ជាឧបសម្ព័ន្ធទី ៩។

## បទដ្ឋានបរិស្ថាន និងសង្គមទី ៣- ប្រសិទ្ធភាពធនធាន និងការទប់ស្កាត់ និងគ្រប់គ្រងការបំពុល

35. ឯកសារការពារសុវត្ថិភាពគម្រោង LASED II មិនរាប់បញ្ចូលនូវប្បញ្ញត្តិជាក់លាក់ ដើម្បីធានាបាននូវប្រសិទ្ធភាពធនធាន ឬការការពារនិងការគ្រប់គ្រងការបំពុល។

36. គម្រោង LASED III មិនរំពឹងថានឹងមានលទ្ធផលនៅក្នុងការដំឡើងណាមួយដែលជាអ្នកប្រើប្រាស់ថាមពលដ៏សំខាន់ក្នុងការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG)។ បទដ្ឋានបរិស្ថាន និងសង្គមទី ៣ ត្រូវការការប៉ាន់ប្រមាណនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ ប៉ុន្តែផ្តល់នូវការលើកលែងចំពោះគម្រោងដែលមានប្រភពបំភាយឧស្ម័នចម្រុះនិងតូចៗ (ឧទាហរណ៍គម្រោងអភិវឌ្ឍន៍ដឹកនាំដោយសហគមន៍)។ វាត្រូវបានចាត់ទុកថាគម្រោង LASED III ទំនងជានឹងស្ថិតក្នុងចំណាត់ថ្នាក់ចុងក្រោយនេះ - ប្រសិនបើវាត្រូវបានកំណត់មិនដូច្នេះទេជំនួយបច្ចេកទេសពី ធនាគារពិភពលោកទំនងជាត្រូវការសម្រាប់ទិដ្ឋភាពនេះ។ គម្រោងLASED III មិនត្រូវបានគេរំពឹងថានឹងបណ្តាលឱ្យមានប្រភពបំពុលសំខាន់ៗទេ។

37. ទិដ្ឋភាពរបស់ បទដ្ឋានបរិស្ថាន និងសង្គមទី ៣ ដែលពាក់ព័ន្ធច្រើនបំផុតទៅនឹងគម្រោង LASED III គឺ (១) តម្រូវការ ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក និង (២) បញ្ញត្តិសម្រាប់ការគ្រប់គ្រងថ្នាំសម្លាប់សត្វល្អិត។ គម្រោងនេះនឹងមិនផ្គត់ផ្គង់ថ្នាំសម្លាប់សត្វល្អិតដោយផ្ទាល់ទេ ប៉ុន្តែវាអាចទៅរួចដែលថាគម្រោងនេះនឹងនាំឱ្យមានការកើនឡើងនៃការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត។

## បទដ្ឋានបរិស្ថាន និងសង្គមទី ៤ – សុខភាព និងសុវត្ថិភាពសហគមន៍

38. ESS4 មានតម្រូវការមួយចំនួនដែលមិនត្រូវបានគ្របដណ្តប់ ជាបញ្ហាការពារសុវត្ថិភាពនៅក្នុងគម្រោង LASED II ឬដែលនឹងត្រូវការវាយតម្លៃនិងគ្រប់គ្រងឱ្យកាន់តែស៊ីជម្រៅនៅក្នុងគម្រោង LASED III។ ទាំងនេះទំនងជារួមមាន៖

(a) សុវត្ថិភាពចរាចរណ៍ និងផ្លូវថ្នល់

(b) ការប៉ះពាល់ក្នុងសហគមន៍ចំពោះបញ្ហាសុខភាព

39. សុវត្ថិភាពទំនប់ទឹកត្រូវបានដាក់បញ្ចូលក្នុងក្របខណ្ឌគម្រោង LASED IIដោយសារគម្រោងនេះត្រូវបានគេគិតគូថាអាចអនុវត្តមាន OP / BP ៤.៣៧។ គម្រោង LASED III ត្រូវបានគេរំពឹងថានឹងគាំទ្រដល់ការសាងសង់ទំនប់វារីអគ្គិសនី ដែលមានប្រភេទនិងទំហំប្រហាក់ប្រហែលទៅនឹងគម្រោង LASED II។ គ្មានទំនប់ណាមួយក្នុងចំណោមទំនប់ទាំងនេះនឹងស្ថិតក្នុងនិយមន័យនៃទំនប់ទឹកធំ នៅក្នុង ESS-3 ឧបសម្ព័ន្ធ១ទេ ហើយនៅក្នុងការអនុវត្តជាក់ស្តែង វាហាក់ដូចជាមិនមានទំនប់តូចជាងនេះទេដែលអាចបំពេញតាមលក្ខខណ្ឌដែលទំនប់តូចៗបំពេញតម្រូវការសុវត្ថិភាពទំនប់ (បទដ្ឋានបរិស្ថាន និងសង្គមទី ៣ ឧបសម្ព័ន្ធ ១ កថាខណ្ឌទី ២) ។ ទោះយ៉ាងណាក៏ដោយនីតិវិធីសុវត្ថិភាពទំនប់ដែលត្រូវបានអនុម័តសម្រាប់គម្រោង LASED II គួរតែត្រូវបានរក្សាទុកនិងពិនិត្យឡើងវិញសម្រាប់ការអនុលោមតាម បទដ្ឋានបរិស្ថាន និងសង្គមទី ៣។

40. បញ្ហាសក្តានុពលមួយផ្សេងទៀតដែលមិនត្រូវបានពិចារណានៅក្នុងគម្រោង LASED II គឺលទ្ធភាពដែលទីតាំង SLC ឬ ICLT អាចស្ថិតនៅក្នុងតំបន់ឥទ្ធិពលនៃទំនប់វារីអគ្គិសនីទាំងមានស្រាប់ ឬតាមគ្រោងទុក។ ទិដ្ឋភាពនេះនឹងត្រូវពិភាក្សាបន្ថែមទៀតនៅខាងក្រោម។

41. គ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ(UXO)ដែលបច្ចុប្បន្នត្រូវបានគេហៅថាជាសំណល់ផ្ទុះនៃ សង្គ្រាមមានវត្តមាននៅក្នុងគម្រោង LASED II និងខេត្តគោលដៅដែលមានសក្តានុពល LASED III។ បញ្ហានេះត្រូវបានកត់សំគាល់នៅក្នុង EA-EMP ហើយតាមពិតតំបន់មួយនៃ តំបន់ LASED ដំបូងៗ ត្រូវការការជីកយករ៉ែយ៉ាងទូលំទូលាយ។ ទោះយ៉ាងណាសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង LASED II មិនមានបញ្ញត្តិជាក់លាក់ដើម្បីគ្រប់គ្រងហានិភ័យនេះទេ។

## បទដ្ឋានបរិស្ថាន និងសង្គមទី ៥ - លទ្ធកម្មដីធ្លី ការរឹតត្បិតលើការប្រើប្រាស់ដីធ្លី និងការតាំងទីលំនៅថ្មីដោយបង្ខំ

42. ក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅឡើងវិញ (RPF)ត្រូវបានរៀបចំសម្រាប់គម្រោង LASED II ក្នុងឆ្នាំ២០១៦ ប៉ុន្តែមិនត្រូវបានអនុវត្តដោយសារបញ្ហាដីធ្លីត្រូវបានគ្រប់គ្រងក្រោមគម្រោងរៀបចំផែនការប្រើប្រាស់ដីធ្លី / ការកំណត់អត្តសញ្ញាណដី ការត្រួតពិនិត្យ និងការគ្រោងក្របខណ្ឌ SLC ដូច្នេះអនុគម្រោង ក្នុងករណីភាគច្រើន នឹងមាននៅលើដីដែលបានគូសវាស និងបញ្ជាក់ជាដីសាធារណៈ និងរាល់ការទាមទារកម្មសិទ្ធិណាមួយត្រូវបានដោះស្រាយ។

43. ទោះបីជាក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី នៃគម្រោង LASED II ទើបតែមានថ្មីៗនេះ វាត្រូវបានរៀបចំឡើងនៅក្រោម OP/BP ៤.១២ លើកមុន។ តម្រូវការរបស់ បទដ្ឋានបរិស្ថាន និងសង្គមទី ៥

មានលក្ខណៈប្រហាក់ប្រហែលគ្នាប៉ុន្តែមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ជាពិសេសផលប៉ះពាល់លើអ្នកប្រើប្រាស់ដីដែលខ្វះការតាំងទីលំនៅថ្មី និងការដាក់កំហិតលើការចូលទៅកាន់តំបន់ការពារស្របច្បាប់។ RPF នឹងត្រូវការពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពដើម្បីឱ្យស្របទៅនឹងបញ្ញត្តិទាំងនេះ។ លើសពីនេះទៀតការគាំទ្រដល់ IPs និង ICLT អាចត្រូវការការពិចារណាជាក់លាក់សម្រាប់ការពារសិទ្ធិរបស់អ្នកប្រើប្រាស់ដីធ្លីនៅក្នុងតំបន់ទាំងនេះ។

បទដ្ឋានបរិស្ថាន និងសង្គមទី ៦ - ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតដោយនិរន្តរភាព

44. បញ្ញត្តិនៃ LASED II EA-EMP និង សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងសម្រាប់ការកំណត់អត្តសញ្ញាណ និងការចៀសវាងផលប៉ះពាល់និងអវិជ្ជមានលើតំបន់បរិស្ថានសំខាន់ និងតំបន់អភិរក្សទំនងជាទូលំទូលាយគ្រប់គ្រាន់ ដើម្បីធានាថា គម្រោង LASED III អនុលោមទៅតាម បទដ្ឋានបរិស្ថាន និងសង្គមទី ៦។ កត្តាដែលអាចមិនរាប់បញ្ចូលរួមមាន (១) ការធានាថាគ្រប់ប្រភេទតំបន់ងាយរងគ្រោះនិងធនធានធម្មជាតិមានជីវិតគ្របដណ្តប់ដោយ បទដ្ឋានបរិស្ថាន និងសង្គមទី ៦ ត្រូវបានដាក់បញ្ចូល និង (២) បញ្ញត្តិដើម្បីកំណត់អត្តសញ្ញាណនិងគ្រប់គ្រងហានិភ័យដែលអាចកើតមានចំពោះតំបន់ដែលនៅក្រៅព្រំដែននៃទីតាំងសម្បទានដីសង្គមកិច្ច ឬកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច។

## ៩.២.១ បទដ្ឋានបរិស្ថាន និងសង្គមទី ៧ - ជនជាតិដើមភាគតិច /សហគមន៍បុរាណក្នុងអនុតំបន់សាហារ៉ាទ្វីបអាហ្វ្រិកដែលមិនមានការទទួលស្គាល់ជាប្រវត្តិសាស្ត្រ

45. គម្រោង LASED II មានក្របខណ្ឌផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលមានស្រាប់ (IPPF) ដែលបានព្រាងនៅក្នុងឆ្នាំ ២០០៧ សម្រាប់ការអនុលោមតាម OP / BP ៤.១០ ទោះបីគម្រោងមិនបានគាំទ្រទីតាំងសម្បទានដីសង្គមកិច្ច នៅតំបន់ណាដែលមានសហគមន៍ជនជាតិដើមក៏ដោយ បញ្ញត្តិនៃឯកសារនេះមិនដែលត្រូវបានអនុវត្តនោះឡើយ។ ក្របខណ្ឌផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិច ត្រូវការការកែសម្រួលដើម្បីនាំវាឱ្យស្របទៅនឹងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ថ្មី។ ក្របខណ្ឌផែនការសម្រាប់សហគមន៍ជនជាតិដើមភាគតិច ឆ្នាំ២០០៧ គឺមានលក្ខណៈសង្ខេបហើយផ្តល់ជូនជាចម្បងសម្រាប់ការកំណត់ដីជនជាតិដើមភាគតិច និងមិនរាប់បញ្ចូលដីជនជាតិដើមភាគតិច ពីតំបន់សម្បទានដីសង្គមកិច្ច (ទោះបីជា IPs ជាគ្រួសារនីមួយៗមានសិទ្ធិស្មើគ្នាជាអ្នកទទួលដីក៏ដោយ)។ ឯកសារនេះមិនបានបញ្ជាក់ច្បាស់ពីគោលការណ៍ បទដ្ឋានបរិស្ថាន និងសង្គមទី ៧ នៃការសម្រេចចិត្តដោយសេរី បានដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (FPIC)។ ឯកសារនេះក៏នឹងត្រូវការការពិនិត្យមើលឡើងវិញនិងធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងថាគម្រោង LASED III នឹងគាំទ្រយ៉ាងជាក់លាក់ដល់ដំណើរការផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ដែលខុសពីដំណើរការផ្តល់សម្បទានដីសង្គមកិច្ច ដែលគម្រោង LASED II បានគាំទ្រហូតមកដល់បច្ចុប្បន្ន។ ស្ថានភាពសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាមានការវិវត្តគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ ២០០៧ ដោយសារតែការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃតំបន់ដែលជនជាតិដើមភាគតិចរស់នៅ ការធ្វើសមាហរណកម្មជនជាតិដើមភាគតិចកាន់តែជិតស្និទ្ធទៅនឹងសេដ្ឋកិច្ច និងដោយសារវឌ្ឍនភាពនៃដំណើរការរបស់ ICLT ដែលមិនបានចាប់ផ្តើមប្រកបដោយប្រសិទ្ធភាពក្នុង ២០០៧។

## បទដ្ឋានបរិស្ថាន និងសង្គមទី ៨- បេតិកភណ្ឌវប្បធម៌

46. គម្រោង LASED II មានក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF) ដែលត្រូវបានព្រាងនៅក្នុងឆ្នាំ ២០០៧ ដើម្បីអនុលោមតាម OP/BP ៤.១១។ វាមិនច្បាស់ទេថានីតិវិធីនៅក្នុង CHPF ត្រូវបានអនុវត្តជាផ្លូវការ ទោះបីជាវាត្រូវបានគេដឹងថាការសាងសង់ផ្លូវចូលតំបន់សម្បទានដីសង្គមកិច្ចមួយនៅខេត្តក្រចេះដែលត្រូវបានផ្តល់មូលនិធិដោយគម្រោង KfW-IPLR បានប្រទះឃើញរូបសំណាកអង្គរមួយដែលត្រូវបានគេយកមកដាក់ការពារជាបន្តបន្ទាប់នៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្ត។

47. ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF) មានភាពស៊ីសង្វាក់គ្នាយ៉ាងទូលំទូលាយជាមួយបទដ្ឋានបរិស្ថាន និងសង្គមទី ៨ ប៉ុន្តែនឹងតម្រូវឱ្យមានការពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាព ដែលរួមមានការសង្កត់ធ្ងន់កាន់តែខ្លាំងលើការកំណត់ផលប៉ះពាល់ ដែលអាចកើតមានឡើងលើបេតិកភណ្ឌវប្បធម៌អរូបី និងលើតំបន់ធម្មជាតិដែលមានសារសំខាន់ខាងវប្បធម៌។ CHPF ដែលមានស្រាប់គឺផ្អែកលើការវិភាគនៃបេតិកភណ្ឌវប្បធម៌នៅខេត្តគោលដៅដំបូងនៃគម្រោង LASED រួមមាន ខេត្តក្រចេះ កំពង់ធំ និងត្បូងឃ្មុំ (កាលពីមុននៅខេត្តកំពង់ចាម) ទោះបីជាបញ្ហាដែលមានសក្តានុពលនឹងមានលក្ខណៈប្រហាក់ប្រហែលគ្នានៅតាមខេត្តដទៃទៀតក៏ដោយ។

## បទដ្ឋានបរិស្ថាន និងសង្គម – ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌មាន

48. គម្រោង LASED មានក្របខណ្ឌចូលរួមយ៉ាងសកម្មរបស់ពលរដ្ឋ CEF ដែលរៀបចំឡើងនៅឆ្នាំ ២០០៧។ CEF ពិពណ៌នាអំពីគោលបំណង ដំណើរការ ទ្រង់ទ្រាយនិងតម្រូវការចាំបាច់សម្រាប់ការចូលរួមជាមួយអ្នកពាក់ព័ន្ធនៅដំណាក់កាលនីមួយៗនៃដំណើរការសម្បទានដីសង្គមកិច្ច និងគោលការណ៍ណែនាំក្នុងការចែករំលែកព័ត៌មាន និងការទំនាក់ទំនង។ តម្រូវការជាច្រើនសម្រាប់ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) នៅក្នុង ESS10 ត្រូវបានគ្របដណ្តប់យ៉ាងពេញលេញដោយ CEF ដូចដែលមានបង្ហាញក្នុងតារាងទី ២១ ខាងក្រោម។

| តារាង ២១: ការប្រៀបធៀបតម្រូវការ ESS10 ជាមួយ LASED CEF | |
|---|---|
| លក្ខខណ្ឌតម្រូវ ESS10 | បញ្ញត្តិផ្លូវផ្ទង់ក្នុង LASED CEF |
| ពេលវេលានិងវិធីនៃការចូលរួមជាមួយអ្នកពាក់ព័ន្ធ | ការចូលរួមជាមួយអ្នកពាក់ព័ន្ធនៅដំណាក់កាលនីមួយៗនៃដំណើរការ |
| ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ | គោលការណ៍ណែនាំសម្រាប់ទំនាក់ទំនងនិងការចែករំលែកព័ត៌មាន |
| ជំនះឧបសគ្គចំពោះការចូលរួម / ក្រុមដែលរងផលប៉ះពាល់ខុសគ្នា | សារសំខាន់នៃការរួមបញ្ចូលទាំងក្រុមងាយរងគ្រោះបានសង្កត់ធ្ងន់ប៉ុន្តែមិនមានវិធានការជាក់លាក់ |
| ការបង្ហាញព័ត៌មាន | នីតិវិធីលម្អិតនិងពេលវេលាសម្រាប់ការបង្ហាញព័ត៌មានសំខាន់ៗ |
| ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ | CEF ត្រូវបានបង្កើតឡើងតាមរយៈដំណើរការពិគ្រោះយោបល់ |

| | |
|---|---|
| យន្តការដោះស្រាយបណ្តឹងតវ៉ា | ពាក្យបណ្តឹងដែលទាក់ទងដោយផ្ទាល់ទៅនឹងការបែងចែកដីធ្លីរបស់ SLC ដែលបានពិពណ៌នានៅក្នុងជំហានទីមួយៗនៃដំណើរការនៅក្នុងយន្តការដោះស្រាយពាក្យបណ្តឹង CEF ត្រូវបានពិពណ៌នាដាច់ដោយឡែកពីគ្នានៅក្នុង PIM |

49. ដូច្នេះ ក្របខណ្ឌជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ មានភាពសមស្របដើម្បីពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពដើម្បីក្លាយជា ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ ដែលទាមទារដោយ ESS10។ លក្ខខណ្ឌតម្រូវ ESS10 មួយចំនួនត្រូវការព័ត៌មានលម្អិតបន្ថែមនៅក្នុងផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធរួមទាំងបញ្ញត្តិជាក់លាក់សម្រាប់ធានាថាក្រុមផ្សេងៗគ្នានៅក្នុងសហគមន៍មូលដ្ឋានអាចចូលរួមបាន។ នេះអាចមានសារសំខាន់ដែលថាគម្រោង LASED III នឹងធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច ប៉ុន្តែក៏អាចត្រូវការបញ្ញត្តិរឹងមាំសម្រាប់ការចូលរួមរបស់ស្ត្រីផងដែរ។

50. យន្តការដោះស្រាយពាក្យបណ្តឹងនៃគម្រោង LASED (ការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌) មិនត្រូវបានពិពណ៌នានៅក្នុងក្របខណ្ឌជំរុញការចូលរួមរបស់ប្រជាពលរដ្ឋទេ ប៉ុន្តែត្រូវបានបង្ហាញយ៉ាងលម្អិតនៅក្នុង សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង។ CHM ត្រូវការការពិនិត្យឡើងវិញដើម្បីធានាថាវាឆ្លើយតបទៅនឹងតម្រូវការរបស់ ESS10 ក៏ដូចជាដោះស្រាយការលំបាកដែលបានជួបប្រទះក្នុងការអនុវត្តរបស់វា (សូមមើលខាងលើ)។

51. ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ នឹងតម្រូវឱ្យមានសុពលភាពឡើងវិញសម្រាប់គម្រោង LASED III តាមរយៈការលាតត្រដាងនិងការពិភាក្សាជាមួយភាគីពាក់ព័ន្ធ។ ដោយសារសហគមន៍គោលដៅ នៃគម្រោង LASED III មិនត្រូវបានគេដឹងជាមុន ការធ្វើបែបនេះនឹងត្រូវធ្វើឡើងតាមរយៈសិក្ខាសាលាពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធដែលតំណាងសហគមន៍សម្បទានដីសង្គមកិច្ចបច្ចុប្បន្ន តំណាងជនជាតិដើមភាគតិច និងអ្នកពាក់ព័ន្ធដទៃទៀតនឹងចូលរួម។

# ឧបសម្ព័ន្ធទី ៣៖ ទម្រង់ការពិនិត្យបឋមនៃទីតាំង

| កាលបរិច្ឆេទ | | GIS យោង | |
|---|---|---|---|

| ខេត្ត | ស្រុក | ឃុំសង្កាត់ |
|---|---|---|
| | | |

1. ទិន្នន័យរដ្ឋបាលនិងប្រជាជនឃុំ (ទទួលបានព័ត៌មានពីមេឃុំ និងមេភូមិ)

| ឈ្មោះភូមិឬអនុភូមិ | ចំនួនគ្រួសារ | ជនជាតិ: ខ្មែរឬជនជាតិដើម (ឈ្មោះ) | គម្រោង LASED III | | |
|---|---|---|---|---|---|
| | | | បើគ្មានដីលំនៅដ្ឋានឬដីកសិកម្ម | មានដីលំនៅដ្ឋានតែគ្មានដីកសិកម្ម | គ្មានដីធ្លីត្រូវបានផ្លាស់ទីលំនៅដោយដី ELC |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | |

2. ការប្រើប្រាស់ដីបច្ចុប្បន្ននៅក្នុងតំបន់ SLC ដែលបានស្នើសុំ (ទទួលបានព័ត៌មានពីមេឃុំនិងមេភូមិ)

| ប្រភពដើមនៃអ្នកប្រើប្រាស់ដី SLC | | ជនជាតិ | ចំនួនគ្រួសារសរុបនៅ SLC | ការប្រើប្រាស់ដីបច្ចុប្បន្ននៅក្នុង SLC (ចំនួន គ្រួសារ) | | | | ដីដែលត្រូវបានធ្វើឡើងនៅខាងក្រៅ SLC ដែលបានស្នើសុំ | | |
|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះភូមិដើម | ថាតើភូមិស្ថិតនៅក្នុងឃុំ SLC | | | គ្រោងផ្ទះ | គ្រោងផ្ទះ | គ្រោងផ្ទះ | ដីសរុបនៅក្នុងហិកតា | គ្រោងផ្ទះ | ដីស្រែចំការ | |
| | | | | | | | | | < 5ha | > 5 ha |
| ការប្រើប្រាស់ដីដោយគ្មានការអនុញ្ញាតនៅក្នុងតំបន់ SLC ដែលបានស្នើសុំមុនពេលកាលបរិច្ឆេទនៃថ្ងៃបញ្ចប់ ៖ ______________________ | | | | | | | | | | |
| | | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ការប្រើប្រាស់ដីដោយគ្មានការអនុញ្ញាតនៅក្នុងតំបន់ SLC ដែលបានស្នើសុំចាប់ពីកាលបរិច្ឆេទនៃថ្ងៃបញ្ចប់ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| កម្មសិទ្ធិដីធ្លីស្របច្បាប់នៅក្នុងតំបន់ SLC ដែលបានស្នើសុំ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

3. ជនជាតិដើមភាគតិច

| | | | | |
|---|---|---|---|---|
| តើក្រុមប្រឹក្សាឃុំមានតំណាងមកពីជនជាតិដើមភាគតិចទេ ? | មាន | | គ្មាន | |
| តើមានភូមិណាក្នុងឃុំមានមេភូមិជាជនជាតិភាគតិចទេ ? | មាន | | គ្មាន | |
| តើជនជាតិដើមភាគតិចណាម្នាក់អនុវត្តកសិកម្មពនេចរនៅក្នុងតំបន់ SLC ដែលបានគ្រោងទុក ? | មាន | | គ្មាន | |

4. បង្ហាញទីតាំងភូមិទាំងអស់របស់ជនជាតិខ្មែរ និងជនជាតិដើមភាគតិចប្រសិនបើមាននៅលើផែនទីប្រើប្រាស់ដី SLC

5. បង្ហាញទីតាំងនៃតំបន់បេតិកភណ្ឌវប្បធម៌ទាំងអស់នៅលើផែនទីប្រើប្រាស់ដី SLC

## ការប្រើប្រាស់ដីដោយក្រុមគ្រួសារនៅតំបន់សម្បទានដីសង្គមកិច្ច

កាលបរិច្ឆេទនៃថ្ងៃបញ្ចប់សម្រាប់ការទាមទារដោយអ្នកប្រើដីធ្លីដែលគ្មានការអនុញ្ញាតនៅក្នុងសម្បទានដីសង្គមកិច្ចដើម្បីក្លាយជា TLRs ៖ ____________________

| លេខរៀង | ឈ្មោះអ្នកកាន់កាប់ (មេគ្រួសារ) | ជនជាតិ | ជាការកាន់កាប់ដោយគ្មានការអនុញ្ញាត ឬស្របច្បាប់ | ការកាន់កាប់ដោយគ្មានការអនុញ្ញាតបានចាប់ផ្តើមមុនឬក្រោយកាលបរិច្ឆេទនៃថ្ងៃបញ្ចប់ | លេខនៃសមាជិកគ្រួសារ | តំបន់ប្រើក្នុង SLC | | | ដីដែលជាកម្មសិទ្ធិនៅក្រៅតំបន់ SLC (គិតជាហិកតា) | ថាតើទទួលបានផលប៉ះពាល់ដោយការកាន់កាប់ដី (មាន/មិនមាន) | ថាតើជាដីទទួលបាននៅក្នុង SLC (មាន/មិនមាន) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ការស្នាក់នៅតែប៉ុណ្ណោះ (មាន/មិនមាន) | កសិកម្មតែប៉ុណ្ណោះ (គិតជាហិកតា) | ទាំង ស្នាក់នៅនិងកសិកម្ម (គិតជាហិកតា) | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| 3 | | | | | | | | | | | |
| 4 | | | | | | | | | | | |
| 5 | | | | | | | | | | | |
| 6 | | | | | | | | | | | |
| 7 | | | | | | | | | | | |
| 8 | | | | | | | | | | | |
| 9 | | | | | | | | | | | |
| 10 | | | | | | | | | | | |
| 11 | | | | | | | | | | | |
| 12 | | | | | | | | | | | |
| 13 | | | | | | | | | | | |
| 14 | | | | | | | | | | | |
| 15 | | | | | | | | | | | |
| 16 | | | | | | | | | | | |
| 17 | | | | | | | | | | | |
| 18 | | | | | | | | | | | |
| 19 | | | | | | | | | | | |
| 20 | | | | | | | | | | | |
| ពង្រីកតារាងនិងការចុះបញ្ជីតាមតម្រូវការ។ | | | | | | | | | | | |

ទម្រង់នៃការពិនិត្យបឋមនៃទីតាំងសម្រាប់លក្ខណៈពិសេសដែលបង្កើតនូវហានិភ័យទៅនឹងបរិស្ថាននិងសង្គម

បំពេញការពិនិត្យបឋមនៃនេះសម្រាប់ទីតាំង SLC ឬ ICLT

ដោយផ្អែកលើចម្លើយ ចូលវាយតម្លៃផលប៉ះពាល់និងលទ្ធភាពនៃការកើតឡើងនៃហានិភ័យនិមួយៗនិងស្នើឱ្យមានវិធានការកាត់បន្ថយផលប៉ះពាល់នៅក្នុងទីតាំង ESMP

| # | លក្ខណៈពិសេស | នៅក្នុងតំបន់ទីតាំង | នៅជិតគ្នា | ក្នុងចម្ងាយ ១ គីឡូម៉ែត្រ | ក្នុងចម្ងាយ ៥ គីឡូម៉ែត្រ | ESS ពាក់ព័ន្ធ | ព័ត៌មានលម្អិត |
|---|---|---|---|---|---|---|---|
| 1 | ប្រភពទឹកធម្មជាតិ ឬផ្លូវទឹក (បឹង ទន្លេ ។ល។) | | | | | ESS3 | ប្រសិនបើនៅនឹងទីតាំងសូមបំពេញទម្រង់ពិនិត្យបឋមសម្រាប់ប្រភពទឹក |
| 2 | កសិកម្មពាណិជ្ជកម្មប្រើថ្នាំសម្លាប់សត្វល្អិតខ្លាំង | | | | | ESS3, ESS4 | ហានិភ័យនៃការចម្លងរោគនៃការផ្គត់ផ្គង់ទឹកនៅ SLC ឬ ICLT |
| 3 | ទឹកទន្លេដែលមានទំនប់ទឹកធំ ៗ នៅដើមទឹក | | | | | ESS4 | ហានិភ័យនៃទឹកជំនន់ពីការបង្ហូរទឹកភ្លាមៗ |
| 4 | តំបន់ដែលរងការលិចលង់ដោយធម្មជាតិ | | | | | ESS4 | ហានិភ័យនៃការខូចខាតនិងការបាត់បង់អាយុជីវិតដោយសារទឹកជំនន់ |
| 5 | ទីតាំងនៃចំការមីនដែលបានរកឃើញ | | | | | ESS4 | ហានិភ័យនៃការស្លាប់ឬរបួសពី ERW |
| 6 | ទីតាំងនៃឧប្បត្តិហេតុ ERW | | | | | ESS4 | ហានិភ័យនៃការស្លាប់ឬរបួសពី ERW |
| 7 | ប្រតិបត្តិការរុករករ៉ែឬខ្សែ ទឹកដែលត្រូវបានបំពុលដោយប្រតិបត្តិការរុករករ៉ែ | | | | | ESS4 | ហានិភ័យនៃការចម្លងរោគនៃការផ្គត់ផ្គង់ទឹកនៅ SLC ឬ ICLT |
| 8 | តំបន់ព្រៃដែលគេដឹងថាមានអត្រាខ្ពស់នៃជំងឺគ្រុនចាញ់ | | | | | ESS4 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 9 | សត្វពស់ ឬសត្វគ្រោះថ្នាក់ដទៃទៀត | | | | | ESS4 | |
| 10 | តំបន់ដែលត្រូវបានប្រើសម្រាប់ការដាំដុះដំណាំ | | | | | ESS5 | ការផ្លាស់ទីលំនៅរបស់អ្នកប្រើប្រាស់ដីដែលមានស្រាប់ |
| 11 | តំបន់ដែលត្រូវបានប្រើសម្រាប់ចិញ្ចឹមសត្វ | | | | | ESS5 | ការបាត់បង់លទ្ធភាពទទួលបានធនធានសម្រាប់អ្នកប្រើប្រាស់ដីធ្លីដែលមានស្រាប់ |
| 12 | តំបន់ដែលត្រូវបានប្រើសម្រាប់ការប្រមូលអុស នេសាទ ឬប្រមូលផលអនុផលព្រៃឈើ | | | | | ESS5 | ការបាត់បង់លទ្ធភាពទទួលបានធនធានសម្រាប់អ្នកប្រើប្រាស់ដីធ្លីដែលមានស្រាប់ |
| 13 | តំបន់ការពារធម្មជាតិ (ជម្រកធម្មជាតិ ជម្រកសត្វព្រៃ និងព្រៃការពារ) | | | | | ESS6 | ហានិភ័យដែលអាចមាននៃការខូចខាតដោយផ្ទាល់<br>ហានិភ័យដែលអាចមាននៃការខូចខាតដោយប្រយោលប្រសិនបើអ្នកទទួលដី SLC ប្រើដីក្នុងគោលបំណងខុសច្បាប់ |
| 14 | សហគមន៍មិនមែនខ្មែរ | | | | | ESS7 | កត់ចំណាំថាសហគមន៍ដែលមិនត្រូវបានចាត់ទុកជា IP ដោយរដ្ឋាភិបាលកម្ពុជាអាចត្រូវបានការពារដោយ ESS7 |
| 15 | តំបន់បេតិកភណ្ឌវប្បធម៌រូបី ឬអរូបី | | | | | ESS8 | សក្តានុពលនៃការខូចខាតដល់បេតិកភណ្ឌវប្បធម៌ |

ទម្រង់ពិនិត្យបឋមនៃទីតាំងសម្រាប់ប្រភពទឹកនៅទីតាំងនោះ

បំពេញការពិនិត្យបឋមនេះសម្រាប់បឹង ឬអូរនីមួយៗនៅក្នុងតំបន់ទីតាំងនោះ

ដោយផ្អែកលើចម្លើយ ចូលវាយតម្លៃផលប៉ះពាល់និងលទ្ធភាពនៃការកើតឡើងនៃហានិភ័យនិមួយៗនិងស្នើឱ្យមានវិធានការកាត់បន្ថយផលប៉ះពាល់នៅក្នុង ESMP តាមទីតាំង

1. ពិពណ៌នាអំពីទីតាំងនិងប្រភេទនៃប្រភពទឹក

2. សម្រាប់បឹង៖
   a. តើផ្ទៃដីមានទម្រង់ដូចម្តេចនៅរដូវវស្សា?
   b. ផ្ទៃដីមានទម្រង់ដូចម្តេចនៅរដូវប្រាំង (អាចជាបឹងរីងស្ងួត)
   c. តើបឹងទាំងមូលនៅខាងក្នុងតំបន់ទីតាំងដែរឬទេ?
   d. តើបឹងត្រូវបានប្រើសម្រាប់នេសាទទេ?
   e. តើបឹងនេះត្រូវបានប្រើសម្រាប់ទាញយកទឹកសម្រាប់កសិកម្មឬគោលបំណងផ្សេងទៀតទេ?
   f. តើបឹងនេះត្រូវបានបំពុលចេញពីប្រភពណាមួយទេ? (ធ្វើតេស្តគុណភាពទឹក)
   g. តើបឹងនេះជាជម្រកសំខាន់សម្រាប់បក្សីឬសត្វដែរឬទេ?

3. សម្រាប់អូរឬស្ទឹង៖
   a. តើផ្នែកនៃអូរឬស្ទឹងនៅខាងក្នុងទីតាំងនោះមានប្រវែងប៉ុន្មាន?
   b. តើអូរឬស្ទឹងមានទទឹងទំហំប៉ុនណានៅរដូវវស្សា?
   c. តើអូរឬស្ទឹងមានទទឹងទំហំប៉ុនណានៅរដូវប្រាំង?

d. តើអូរឬស្ទឹងហូរប៉ុន្មានខែក្នុងមួយឆ្នាំ?
e. តើអូរឬស្ទឹងហូរចូលទីតាំងពីខាងក្រៅទេ? ប្រសិនបើមាន៖
   i. តើទឹកត្រូវបានយកចេញពីអូរឬស្ទឹងនៅខ្សែទឹកខាងលើនៃទីតាំង សម្រាប់ប្រព័ន្ធធារាសាស្ត្រឬគោលបំណងផ្សេងទៀតដែរឬទេ?
   ii. តើមានប្រភពដែលអាចមានការបំពុលណាមួយ (ឧ. ចម្ការកសិពាណិជ្ជកម្ម ប្រតិបត្តិការរុករករ៉ែឬប្រតិបត្តិការឧស្សាហកម្ម ។ល។) នៅជិតអូរឬស្ទឹង និងខ្សែទឹកខាងលើនៃទីតាំងនោះទេ?
   iii. តើគុណភាពទឹកត្រូវធ្វើតេស្តគុណភាពហើយឬនៅ?
f. តើអូរឬស្ទឹង ហូរកាត់ព្រំប្រទល់ទីតាំងដែរឬទេ? ប្រសិនបើមាន៖
   i. តើទឹកត្រូវបានយកចេញពីអូរឬស្ទឹងនៅខ្សែទឹកខាងក្រោមនៃទីតាំង សម្រាប់ប្រព័ន្ធធារាសាស្ត្រឬគោលបំណងផ្សេងទៀតដែរឬទេ?
   ii. តើអូរ ឬស្ទឹងហូរចូលបឹងដែលត្រូវបានប្រើសម្រាប់នេសាទឬជាជម្រកសំខាន់សម្រាប់បក្សីឬសត្វ?

## ឧបសម្ព័ន្ធទី ៤៖ គម្រោងតាមទីតាំងនៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម

### ធាតុដែលបានលើកឡើងតាមទីតាំងរបស់ ESMP

### ១. ការពិពណ៌នាអំពីទីតាំង/តំបន់

- បញ្ជាក់យ៉ាងច្បាស់អំពីទីតាំងដែលបានស្នើឡើងនិងបរិបទភូមិសាស្ត្រអេកូឡូស៊ីសង្គមនិងពេលវេលារួមទាំងការវិនិយោគក្រៅផ្លូវការដែលអាចត្រូវបានទាមទារ (ឧទាហរណ៍ផ្លូវថ្នល់ការផ្គត់ផ្គង់ទឹក។ល។) ជាធម្មតារួមបញ្ចូលផែនទីបង្ហាញទីតាំងនិងតំបន់គម្រោងនៃឥទ្ធិពល។

- ពិពណ៌នាអំពីស្ថានភាពរូបវន្ត ជីវសាស្ត្រ និងសេដ្ឋកិច្ចសង្គមដែលពាក់ព័ន្ធរួមទាំងការផ្លាស់ប្តូរដែលបានរំពឹងទុកមុនពេលគម្រោងចាប់ផ្តើម។

### 2. ផលប៉ះពាល់ដែលអាចកើតឡើង

ព្យាករ និងវាយតម្លៃផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមាន

### 3. ផែនការកាត់បន្ថយ

ESMP គួរតែកំណត់វិធានការដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថានដែលអាចកើតមានដល់កម្រិតដែលអាចទទួលយកបាន។ ផែនការគួរតែរួមបញ្ចូលវិធានការសំណងប្រសិនបើវិធានការកាត់បន្ថយផលប៉ះពាល់មិនអាចធ្វើទៅបាន។ ជាពិសេសផែនការកាត់បន្ថយ៖

a. កំណត់ និងសង្ខេបផលប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗដែលបានរំពឹងទុក (ដែលរួមមានទាំងជនជាតិដើមភាគតិចឬការតាំងទីលំនៅថ្មីដោយបង្ខំ)
b. ពិពណ៌នាវិធានការកាត់បន្ថយផលប៉ះពាល់នីមួយៗជាមួយការពិពណ៌នាលម្អិតបច្ចេកទេស - រួមទាំងប្រភេទនៃផលប៉ះពាល់ដែលវាទាក់ទង និងលក្ខខណ្ឌដែលវាត្រូវទាមទារ (ឧទាហរណ៍បន្តឬក្នុងករណីនៃយថាភាព) រួមគ្នាជាមួយការរចនាប្លង់ ការពិពណ៌នាឧបករណ៍ និងប្រតិបត្តិការនីតិវិធី តាមសមរម្យ
c. ប៉ាន់ស្មានផលប៉ះពាល់បរិស្ថានដែលអាចកើតឡើងនៃវិធានការទាំងនេះ និង
d. ផ្តល់នូវការភ្ជាប់ជាមួយផែនការកាត់បន្ថយផ្សេងទៀត (ឧទាហរណ៍សម្រាប់ការតាំងទីលំនៅថ្មីដោយបង្ខំ ជនជាតិដើមភាគតិច ឬទ្រព្យសម្បត្តិវប្បធម៌) ដែលត្រូវការសម្រាប់គម្រោង។

### 4. ផែនការពិនិត្យតាមដាន

ផែនការគួរតែផ្តល់ព័ត៌មានអំពីទិដ្ឋភាពបរិស្ថាន និងសង្គមសំខាន់ៗរបស់គម្រោង ជាពិសេសផលប៉ះពាល់របស់គម្រោងនិងប្រសិទ្ធភាពនៃវិធានការកាត់បន្ថយផលប៉ះពាល់។ វាកំណត់គោលដៅពិនិត្យតាមដាន និងបញ្ជាក់ប្រភេទនៃការពិនិត្យតាមដាន ដោយភ្ជាប់ជាមួយផលប៉ះពាល់ដែលអាចកើតឡើងដែលបានកំណត់ និងវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានលើកឡើង។ ជាពិសេសផែនការពិនិត្យតាមដានផ្តល់ជូន៖

a. ការពិពណ៌នាជាក់លាក់និងការពិពណ៌នាលម្អិតបច្ចេកទេសនៃវិធានការពិនិត្យតាមដានទាំងប៉ារ៉ាម៉ែត្រដែលត្រូវវាស់ វិធីសាស្ត្រដែលត្រូវប្រើទីតាំងគំរូភាពញឹកញាប់នៃការវាស់វែង ការរកឃើញដែនកំណត់ (ក្នុងករណីដែលសមស្រប) និងនិយមន័យនៃកម្រិតដែលនឹងបង្ហាញពីតម្រូវការនៃសកម្មភាពកែតម្រូវ និង

b. នីតិវិធីពិនិត្យតាមដាន និងរាយការណ៍ដើម្បី (១) ធានាឱ្យមានការរកឃើញលឿននូវលក្ខខណ្ឌដែលត្រូវការវិធានការកាត់បន្ថយផលប៉ះពាល់ជាពិសេសនិង (២) ផ្តល់ព័ត៌មានអំពីវឌ្ឍនភាពនិងលទ្ធផលនៃការកាត់បន្ថយ។

## 5. ការរៀបចំការអនុវត្តនិងការអភិវឌ្ឍសមត្ថភាព

a. គ្របដណ្តប់លើអនុផែនការផ្សេងទៀតដូចជា (១) ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធនៅ ទីតាំងជាក់លាក់ (២) ការបង្ហាញនិងពិគ្រោះយោបល់ (៣) យន្តការដោះស្រាយបណ្តឹងតវ៉ា (៤) ផែនការការពារបេតិកភណ្ឌវប្បធម៌និងផែនការផ្សេងៗទៀតដែលត្រូវបានអនុវត្តចំពោះសំណើ SLC / ICLT។

b. ផ្តល់នូវការពិពណ៌នាជាក់លាក់នៃការរៀបចំស្ថាប័ន - ដែលទទួលខុសត្រូវក្នុងការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ និងការពិនិត្យតាមដាន (ឧទាហរណ៍សម្រាប់ប្រតិបត្តិការ ការត្រួតត្រាមើល ការអនុវត្ត ការពិនិត្យតាមដានការអនុវត្ត វិធានការដោះស្រាយ ហិរញ្ញវត្ថុ ការរាយការណ៍ និងការបណ្តុះបណ្តាលបុគ្គលិក)។

## 7. កាលវិភាគនៃការអនុវត្តនិងការប៉ាន់ស្មានតម្លៃ

a. ផ្តល់កាលវិភាគនៃការអនុវត្តសម្រាប់វិធានការដែលត្រូវតែអនុវត្តជាផ្នែកមួយនៃគម្រោងដែលបង្ហាញពីដំណាក់កាលនិងការសម្របសម្រួលជាមួយផែនការអនុវត្តគម្រោងទាំងមូល និង

b. ពិពណ៌នាអំពីការប៉ាន់ប្រមាណដើមទុន និងការចំណាយជាប្រចាំ និងប្រភពថវិកា (ឧទាហរណ៍ តារាងចំណាយគម្រោងសម្រាប់ការអនុវត្តនិងតាមដាន ESMP

## B. ឧទាហរណ៍នៃតារាងមាតិកា

| តារាងមាតិកា |
|---|
| **១ បុព្វកថា**<br>១.១ ការពិពណ៌នា<br>១.២ វិសាលភាពនិងការអភិវឌ្ឍ<br>១.៣ ការរួមបញ្ចូល ESMP |
| **២ ការកំណត់អត្តសញ្ញាណផលប៉ះពាល់បរិស្ថាននិងសង្គមដែលអាចកើតឡើង**<br>២.១ ផលប៉ះពាល់បរិស្ថាន<br>២.១.១ ការបំពុលខ្យល់<br>២.១.២ ការបំពុលទឹកនិងទឹកសំណល់<br>២.១.៣សំណល់រឹង<br>២.១.៤ សំឡេងរំខាន<br>២.១.៥ ក្លិន<br>២.១.៦ សុខភាពនិងសុវត្ថិភាពការងារ(OHS)<br>២.១.៧ សុខភាពនិងសុវត្ថិភាពសហគមន៍(CHS)<br>២.១.៨ ។ល។. |

## តារាងមាតិកា


២.២ ផលប៉ះពាល់សង្គម

២.២.១ សុខភាព និងសុវត្ថិភាពការងារ(OHS)

២.២.២ សុខភាព និងសុវត្ថិភាពសហគមន៍(CHS)

២.២.៣ ទំនាស់

២.២.៤ អំពើហិង្សាទាក់ទងនឹងយេនឌ័រ

២.២.៥ ការហូរចូលនូវពលកម្មពលកម្ម

២.២.៦ ។ល។

**៣ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម**

៣.១ វិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើ

៣.២ ផែនការពិនិត្យតាមដាន

៣.៣ អ្នកម៉ៅការ ESMP

**៤ ការអនុវត្តESMP**

៤.១ ការរៀបចំស្ថាប័ន

៤.២ ការពិនិត្យតាមដាននិងរាយការណ៍ ESMP

៤.៣ តារាងពេលវេលានិងថវិកាការអនុវត្ត

៤.៤ ផែនការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ

៤.៥ ការបង្ហាញនិងការពិគ្រោះយោបល់

៤.៦ យន្តការដោះស្រាយបណ្តឹងតវ៉ា

**៥ ការអភិវឌ្ឍសមត្ថភាពនិងការបណ្តុះបណ្តាល**

៥.១ ការអភិវឌ្ឍសមត្ថភាព

៥.២ ការបណ្តុះបណ្តាល

៥.៣ ការងារស៊ីវិល

៥.៤. ថវិកាសម្រាប់ការអនុវត្ត ESMP

ឧបសម្ព័ន្ធ កៈ បញ្ជីពិនិត្យតាមដាន

ឧបសម្ព័ន្ធ ខៈ ផែនការគ្រប់គ្រងធនធានវប្បធម៌រូបវន្ត (បើចាំបាច់)

ឧបសម្ព័ន្ធ គៈ ផែនការគ្រប់គ្រងសត្វល្អិត (បើចាំបាច់)

ឧបសម្ព័ន្ធ ឃៈ ផែនការសកម្មភាពការតាំងទីលំនៅថ្មី (បើចាំបាច់)

ឧបសម្ព័ន្ធ ងៈ ផែនការជនជាតិដើមភាគតិច (បើចាំបាច់)

- និងឧបសម្ព័ន្ធផ្សេងទៀតដូចដែលបានអនុវត្ត

## ឧបសម្ព័ន្ធ ៥៖ ទម្រង់ពិនិត្យបឋមលើអនុគម្រោង

### ទម្រង់ពិនិត្យបឋមលើហានិភ័យបរិស្ថាន និងសង្គមក្នុងអនុគម្រោង

ទម្រង់នេះមានគោលបំណងកំណត់រកហានិភ័យបរិស្ថាន និងសង្គមដែលអាចកើតចេញពីការអនុវត្តអនុគម្រោងនេះ។ លទ្ធផលពីការពិនិត្យបឋមនេះ នឹងត្រូវបានប្រើប្រាស់សម្រាប់ការបង្កើតវិធានការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមក្នុងអនុគម្រោង (ESMP)។

| ប្រភេទ | សំណួរសម្រាប់ការពិនិត្យបឋម | មែន/ទេ | មតិយោបល់ |
|---|---|---|---|
| កំណត់រកប្រភេទអនុគម្រោងពីតារាងនេះ | ផ្លូវថ្នល់ | | |
| | ជាពសាស្ត្រ | | |
| | ការសាងសង់អគារ | | |
| | ការផ្គត់ផ្គង់ទឹក | | |
| | អនាម័យ | | |
| | ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត | | |
| | ការបណ្តុះបណ្តាលកសិកម្ម | | |
| | ការបង្ហាញពីការធ្វើកសិកម្ម | | |
| | ការផ្គត់ផ្គង់សម្ភារកសិកម្ម | | |
| | ការធ្វើទីផ្សារកសិកម្ម | | |
| | ការរៀបចំសហគមន៍ | | |
| | ការកសាងសមត្ថភាព | | |
| | ប្រភេទផ្សេងទៀត | | |
| ទីតាំង | តើផ្នែកណាមួយនៃអនុគម្រោងនឹងស្ថិតនៅក្រៅតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់សម្រាប់ផ្តល់បណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬទេ? | | |
| ផ្លូវទឹក | តើអនុគម្រោងនឹងធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹក ឬផ្លូវទឹកដែលមានផ្នែកមួយស្ថិតនៅក្រៅតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់សម្រាប់ផ្តល់បណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬទេ? | | |
| លក្ខខណ្ឌការងារ និងពលកម្ម | តើអនុគម្រោងនឹងត្រូវបានអនុវត្តដោយកម្មករដែលជួលដោយក្រុមហ៊ុនម៉ៅការសាងសង់ ឬទេ? | | |
| | តើអនុគម្រោងនឹងត្រូវបានអនុវត្តដោយកម្មករដែលជួលដោយប្រភេទក្រុមហ៊ុនម៉ៅការ ឬអ្នកផ្តល់សេវាផ្សេងទៀត ឬទេ? | | |
| | តើនឹងមានការជួលកម្មករក្នុងសហគមន៍ឱ្យអនុវត្តអនុគម្រោង ឬទេ? | | |
| | តើអនុគម្រោងនឹងតម្រូវឱ្យមានការប្រើប្រាស់ឥដ្ឋ ឬក្បឿង ឬទេ? | | |

| ប្រភេទ | សំណួរសម្រាប់ការពិនិត្យបឋម | មែន/ទេ | មតិយោបល់ |
|---|---|---|---|
| | តើអនុគម្រោងនឹងតម្រូវឱ្យមានការប្រើប្រាស់សម្ភារជាំជុះក្នុងកសិកម្មនៅតាមចម្ការធំៗ ឬទេ? | | |
| បរិស្ថាន | តើអនុគម្រោងនឹងបង្កការបំពុលដោយធូលី ដែលអាចប៉ះពាល់ដល់ប្រជាជនរស់នៅជិតនោះ ឬទេ? | | |
| | តើអនុគម្រោងនឹងបង្កសំឡេងរំខាន ដែលអាចប៉ះពាល់ដល់ប្រជាជនរស់នៅជិតនោះ ឬទេ? | | |
| | តើមានស្ទឹង ឬប្រភពទឹកដែលអាចត្រូវបានបំពុលដោយសារអនុគម្រោង ឬទេ? | | |
| | តើអនុគម្រោងនឹងបង្កឱ្យមានសំណល់រឹងដែលមិនអាចបំបែកតាមបែបជីវសាស្ត្រ ដែលត្រូវមានការបោះចោលឱ្យបានសមស្រប ឬទេ? | | |
| សុខភាព និង សុវត្ថិភាព សហគមន៍ | តើអនុគម្រោងនឹងបង្កគ្រោះថ្នាក់ចរាចរណ៍កាន់តែច្រើន ឬទេ? | | |
| | តើសកម្មភាពសាងសង់ក្នុងគម្រោងធ្វើឱ្យមានមុខសញ្ញាគ្រោះថ្នាក់ចរាចរណ៍ក្នុងពេលសាងសង់ ឬទេ? | | |
| | តើការអនុវត្តអនុគម្រោងនឹងពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងម៉ាស៊ីនធុនធ្ងន់នៅតាមទីតាំងដែលមហាជនចេញចូល ឬទេ? | | |
| | តើនឹងមានការប្រើប្រាស់សារធាតុគីមីណាមួយក្នុងការអនុវត្តអនុគម្រោង ឬទេ? | | |
| | តើមានមុខសញ្ញាគ្រោះថ្នាក់នៃគ្រាប់មីនកប់ក្នុងដី/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ/សំណល់អាវុធជាតិផ្ទុះបន្សល់ពីសង្គ្រាមនៅទីតាំងអនុគម្រោង ឬនៅជិតទីតាំងអនុគម្រោង ឬទេ? | | |
| | ប្រសិនបើអនុគម្រោងពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកពិសា តើការផ្គត់ផ្គង់ត្រូវបានធ្វើតេស្តរកសារធាតុអាសេនិក ឬទេ? | | |
| | ប្រសិនបើអនុគម្រោងពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកពិសា តើការផ្គត់ផ្គង់ត្រូវបានធ្វើតេស្តរកការបំពុលដោយសារធាតុគីមី ឬទេ? | | |
| | ប្រសិនបើអនុគម្រោងពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកពិសា តើការផ្គត់ផ្គង់ត្រូវបានធ្វើតេស្តរកការបំពុលដោយជីវសាស្ត្រ ឬទេ? | | |
| ការប្រែប្រួលអាកាសធាតុ | តើអនុគម្រោងនឹងធ្វើឱ្យមានការបំភាយ $CO_2$ កាន់តែច្រើន ឬទេ? | | |
| | តើអនុគម្រោងស្ថិតក្នុងតំបន់មួយដែលងាយប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ (ឧ.ទឹកជំនន់) ឬទេ? | | |

| ប្រភេទ | សំណួរសម្រាប់ការពិនិត្យបឋម | មែន/ទេ | មតិយោបល់ |
| --- | --- | --- | --- |
| | តើមានហានិភ័យដែលការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យគម្រោងគ្មាននិរន្តរភាព ឬទេ? (ឧ. ការដាំដុះដំណាំដែលនឹងមិនលូតលាស់ នៅពេលធាតុអាកាសកាន់តែក្ដៅ) | | |
| លទ្ធកម្មដីធ្លី | តើអនុគម្រោងនឹងត្រូវបានធ្វើឡើងនៅលើដីធ្លីដែលជាកម្មសិទ្ធិឯកជន ឬស្ថិតក្រោមការប្រើប្រាស់ឯកជន ឬទេ? | | |
| | តើនឹងមានការជម្លៀសប្រជាជនចេញពីផ្ទះសម្បែងដោយសារអនុគម្រោង ឬទេ? | | |
| | តើនឹងមានប្រជាជនបាត់បង់ផ្នែកខ្លះនៃដីផលិតកម្មរបស់ខ្លួន ដោយសារអនុគម្រោង ឬទេ? | | |
| | តើអនុគម្រោងនឹងត្រូវបានអនុវត្តលើដីដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងធនធានទ្រព្យសម្បត្តិរួម ឬទេ? (ឧ. វាលស្មៅសម្រាប់ចិញ្ចឹមសត្វ នេសាទ អនុផលព្រៃឈើ។ល។) | | |
| ធនធានធម្មជាតិ | តើអនុគម្រោងនឹងធ្វើឱ្យមានការទាញយកទឹកប្រើប្រាស់កាន់តែច្រើនពីទន្លេធម្មជាតិ ឬទេ? | | |
| | តើអនុគម្រោងនឹងធ្វើឱ្យមានការទាញយកទឹកប្រើប្រាស់កាន់តែច្រើនពីបឹងធម្មជាតិ ឬទេ? | | |
| | តើអនុគម្រោងនឹងធ្វើឱ្យមានការទាញយកទឹកប្រើប្រាស់កាន់តែច្រើនពីប្រភពទឹកក្រោមដី ឬទេ (លើកលែងតែការប្រើប្រាស់ក្នុងគ្រួសារ)? | | |
| | តើអនុគម្រោងនឹងត្រូវបានអនុវត្តក្នុងតំបន់ដែលជាព្រៃធម្មជាតិ ឬតំបន់ដីសើមធម្មជាតិបច្ចុប្បន្ន ឬទេ? | | |
| | តើមានតំបន់ដែលមានសារៈសំខាន់សម្រាប់ជីវចម្រុះក្នុងរង្វង់ ១ គីឡូម៉ែត្រពីអនុគម្រោង ឬទេ? | | |
| | តើអនុគម្រោងនឹងតម្រូវឱ្យមានការទាញយកធនធានរ៉ែណាមួយ ឬទេ? | | |
| បេតិកភណ្ឌវប្បធម៌ | តើមានកន្លែងដែលមានបេតិកភណ្ឌវប្បធម៌រូបី (ប្រាសាទបុរាណ សំណង់វប្បធម៌ដែលមានតម្លៃ ទីកន្លែងដែលមានសារសំខាន់ផ្នែកវប្បធម៌ចំពោះសហគមន៍មូលដ្ឋាន) ដែលអាចរងផលប៉ះពាល់ដោយសារអនុគម្រោង ឬទេ? | | |
| | តើមានកន្លែងដែលមានសារសំខាន់ដោយសារតែសម្រស់ធម្មជាតិ (ឧ. ទឹកជ្រោះ បឹងបួរ។ល។) ដែលអាចរងផលប៉ះពាល់ដោយសារអនុគម្រោង ឬទេ? | | |
| | តើមានហានិភ័យដែលអនុគម្រោងនឹងបង្កផលប៉ះពាល់អវិជ្ជមានលើបេតិកភណ្ឌអរូបីដែលមានសារសំខាន់ចំពោះសហគមន៍មូលដ្ឋាន ឬទេ? | | |

| ប្រភេទ | សំណួរសម្រាប់ការពិនិត្យបឋម | មែន/ទេ | មតិយោបល់ |
|---|---|---|---|
| ជនជាតិដើម<br>ភាគតិច | តើអនុគម្រោងនឹងបង្កផលប៉ះពាល់លើជនជាតិដើមភាគតិចតាមវិធីណាមួយ<br>ឬទេ ? | | |
| | ប្រសិនបើអនុគម្រោងប៉ះពាល់ដល់ជនជាតិដើមភាគតិច តើពួកគេត្រូវបាន<br>ពិគ្រោះយោបល់ពេញលេញ និងឯកភាពទទួលយកអនុគម្រោង ឬទេ ? | | |
| ការពិគ្រោះ<br>យោបល់<br>អ្នកពាក់ព័ន្ធ | តើសហគមន៍ដែលនឹងរងផលប៉ះពាល់ដោយសារអនុគម្រោង ទទួលបាន<br>ព័ត៌មានអំពីផែនការអនុគម្រោង ឬទេ ? | | |
| | តើសហគមន៍ដែលនឹងរងផលប៉ះពាល់ដោយសារអនុគម្រោងបានចូលរួមក្នុង<br>ការពិភាក្សាពីការរៀបចំអនុគម្រោង ឬទេ ? | | |
| | តើមានការជំទាស់លើផ្នែកណាមួយនៃអនុគម្រោងពីសំណាក់សហគមន៍<br>មូលដ្ឋាន ឬទេ ? | | |
| | | | |
| សំណួរផ្សេងទៀត<br>ផ្អែកលើ<br>ហានិភ័យដែល<br>បានកំណត់ក្នុង<br>ផែនការគ្រប់គ្រង<br>បរិស្ថាន និង<br>សង្គមតាមទីតាំង | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ឧបសម្ព័ន្ធ ៦ ៖ ទម្រង់ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ក្នុងអនុគម្រោង

ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ក្នុងអនុគម្រោងជាតារាងធម្មតាដូចមានបង្ហាញខាងក្រោម។ នេះជាទម្រង់សមស្របព្រោះវាមានលក្ខណៈសាមញ្ញ ដែលមន្ត្រីឃុំ ក្រុមហ៊ុនម៉ៅការសាងសង់ អាចស្គាល់ច្បាស់ យល់ និងប្រើប្រាស់សម្រាប់គ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងពេលអនុវត្តអនុគម្រោង។

ទម្រង់នេះនឹងត្រូវបានរៀបចំឡើងបន្ថែមទៀតក្នុងពេលចាប់ផ្ដើមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣ (LASED III) រួមទាំងការរៀបចំវិធានការស្តង់ដាសម្រាប់ការគ្រប់គ្រងហានិភ័យ និងកាត់បន្ថយផលប៉ះពាល់ សម្រាប់ប្រភេទអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធទូទៅ (ផ្លូវថ្នល់ ធារាសាស្ត្រ ការផ្គត់ផ្គង់ទឹក ។ល។)។ បញ្ញត្តិស្តង់ដាទាំងនេះនឹងស៊ីសង្វាក់គ្នានឹងក្រមប្រតិបត្តិផ្នែកបរិស្ថាន (ECoP) (ឧបសម្ព័ន្ធ ៦) ប៉ុន្តែវានឹងត្រូវបានប្រើប្រាស់ដោយផ្ទាល់ក្នុងការរៀបចំឯកសារកិច្ចសន្យា និងការអនុវត្តកិច្ចសន្យា។

សម្រាប់ហានិភ័យបរិស្ថាន និងសង្គមនីមួយៗដែលបានកំណត់ឃើញ ទម្រង់នេះនឹងបង្ហាញពី ១) កម្រិតផលប៉ះពាល់ ប្រសិនបើព្រឹត្តិការណ៍ហានិភ័យកើតឡើង ៖ ខ្ពស់ ធ្ងន់ធ្ងរ មធ្យម ឬទាប ២) លទ្ធភាពនៃការកើតមានព្រឹត្តិការណ៍ហានិភ័យក្នុងពេលអនុវត្តអនុគម្រោង (ខ្ពស់ ធ្ងន់ធ្ងរ មធ្យម ទាប) ៣) វិធានការកាត់បន្ថយហានិភ័យ រួមទាំងវិធានការដែលត្រូវអនុវត្តដោយក្រុមហ៊ុនម៉ៅការសាងសង់ ៤) ការទទួលខុសត្រូវលើវិធានការកាត់បន្ថយហានិភ័យនីមួយៗ និង ៥) ក្របខណ្ឌពេលវេលា (ឧ. មុនពេលចាប់ផ្ដើមការសាងសង់ ក្នុងពេលសាងសង់។ល។)។ សម្រាប់វិធានការកាត់បន្ថយផលប៉ះពាល់ដែលជាបន្ទុករបស់ក្រុមហ៊ុនម៉ៅការសាងសង់ វិស្វករត្រួតពិនិត្យនឹងខិតខំធានាថាមានការអនុវត្តវិធានការបានសមស្រប។ ការអនុវត្តវិធានការកាត់បន្ថយហានិភ័យបរិស្ថាន និងសង្គមនឹងត្រូវបានរាយការណ៍ ហើយនឹងក្លាយជាលក្ខខណ្ឌមួយសម្រាប់ការអនុម័តការទូទាត់។

| ការពិពណ៌នាពីហានិភ័យ | កម្រិតផលប៉ះពាល់ | | | | លទ្ធភាពនៃការកើតឡើង | | | | វិធានការកាត់បន្ថយហានិភ័យ | ការទទួលខុសត្រូវ | ក្របខណ្ឌពេលវេលា |
|---|---|---|---|---|---|---|---|---|---|---|---|
| | H | S | M | L | H | S | M | L | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

# ឧបសម្ព័ន្ធ ៧ ៖ ក្រមប្រតិបត្តិផ្នែកបរិស្ថាន (ECOP) សម្រាប់អនុគម្រោង

## ក្រមប្រតិបត្តិផ្នែកបរិស្ថានទី ១ ៖ ការអភិវឌ្ឍសហគមន៍/ហេដ្ឋារចនាសម្ព័ន្ធជនបទ

## ១.សំណង់អគារ

| អនុគម្រោង | វិធានការទប់ស្កាត់/កាត់បន្ថយផលប៉ះពាល់លើបរិស្ថាន |
|---|---|
| អគារសិក្សា និង មជ្ឈមណ្ឌលសហគមន៍ | a. រៀបចំប្រព័ន្ធលូបង្ហូរទឹកគ្រប់គ្រាន់នៅជុំវិញអគារ ដើម្បីកុំឱ្យមានទឹកនឹង។ ជំងឺបង្កដោយសត្វល្អិត និងលក្ខខណ្ឌគ្មានអនាម័យអាចកើតឡើងដោយសារប្រព័ន្ធលូបង្ហូរទឹកមិនគ្រប់គ្រាន់។<br>b. បង្កើនពន្លឺធម្មជាតិ និងប្រព័ន្ធខ្យល់ចេញចូលដើម្បីកាត់បន្ថយការប្រើប្រាស់ពន្លឺសិប្បនិម្មិត និង ម៉ាស៊ីនត្រជាក់។ ប្រើប្រាស់បង្អួចធំៗដើម្បីផ្តល់ពន្លឺ និងខ្យល់អាកាសដល់បន្ទប់។<br>c. អគារសិក្សាគួរមានបន្ទប់ធំសម្រាប់សកម្មភាពខាងក្នុងបន្ទប់ សួនកុមារនៅខាងក្រៅ និងមូលដ្ឋាន<br>d. អនាម័យ (ឧ. បន្ទប់ទឹក និងបង្គន់ដែលមានអាងទឹកស្អុយ)<br>e. បញ្ចៀសការប្រើប្រាស់គ្រឿងស៊ីម៉ង់ដែលមានសារធាតុអាបេស្តូស ធ្វើជាគ្រឿងប្រក់។ |
| មណ្ឌលសុខភាពនៅ ជនបទ | a. ផ្តល់ចំនួនបន្ទប់គ្រប់គ្រាន់ ដូចជា បន្ទប់ព្យាបាល បន្ទប់អ្នកជំងឺ កន្លែងរង់ចាំ និងមូលដ្ឋានអនាម័យ (ឧ. បន្ទប់ទឹក បង្គន់ដែលមានអាងទឹកស្អុយ)<br>b. គួររៀបឥដ្ឋការ៉ូ ព្រោះវាងាយសម្អាត និងផ្តល់អនាម័យ<br>c. រៀបចំប្រព័ន្ធលូបង្ហូរទឹកគ្រប់គ្រាន់នៅជុំវិញអគារ ដើម្បីកុំឱ្យមានទឹកនឹង។ ជំងឺបង្កដោយសត្វល្អិត និងលក្ខខណ្ឌគ្មានអនាម័យអាចកើតឡើងដោយសារប្រព័ន្ធលូបង្ហូរទឹកមិនគ្រប់គ្រាន់។<br>d. ធ្វើយ៉ាងណាឱ្យមានខ្យល់អាកាសក្នុងបន្ទប់<br>e. បញ្ចៀសការប្រើប្រាស់គ្រឿងស៊ីម៉ង់ដែលមានសារធាតុអាបេស្តូ ធ្វើជាគ្រឿងប្រក់។ |
| ទីផ្សារជនបទ | a. ត្រូវមានប្រព័ន្ធលូបង្ហូរទឹកល្អប្រសើរក្នុង និងជុំវិញទីផ្សារ (ជុំវិញតូប/រោង) ដើម្បីជានា អនាម័យ<br>b. សម្រាប់អគារផ្សារនៅមួយកន្លែង គួរផ្តល់មូលដ្ឋានអនាម័យ (ឧ. បង្គន់ ដែលមានអាងទឹកស្អុយ និង អាងទឹកសម្រាប់លាងសម្អាតដៃ) នៅជិតអគារផ្សារ។ អគារទីផ្សារនៅមួយកន្លែងសំដៅលើអគារដែល មានសំណង់បេតុង ដែលត្រូវបានសង់ជាអចិន្ត្រៃយ៍នៅលើទីតាំងមួយ។<br>c. ផ្តល់ធុងសំរាមដែលអាចសម្អាតបានជាប្រចាំ។<br>d. ដាក់តូប/ហាងក្នុងផ្សារដែលលក់ផលិតផល/ទំនិញស្ងួត និងសើម ដាច់ពីគ្នា<br>e. គួរប្រើផ្នែកម្រាលដែលក្រាលឥដ្ឋ/គ្រួស ព្រោះវាងាយស្រួលសម្អាត និងថែទាំ។ ផ្ទៃជម្រាលសម្រាប់ ប្រព័ន្ធលូបង្ហូរទឹក។<br>f. ធ្វើយ៉ាងណាឱ្យតូប/ហាងមានដំបូលគ្របដើម្បីកុំឱ្យមានទឹកនឹងក្នុងរដូវវស្សា។ |

## ២.ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ (ការផ្តល់លទ្ធភាពចេញចូលទីតាំង)

| អនុគម្រោង | វិធានការទប់ស្កាត់/កាត់បន្ថយផលប៉ះពាល់លើបរិស្ថាន |
|---|---|
| ផ្លូវថ្នល់ | **ការពិចារណាទូទៅ ៖**<br>a. ការគ្រប់គ្រងសំណល់នៅទីតាំងសំណង់ទាំងអស់ (រួមទាំងស្នាមកាយដី) លើទីតាំងបោះចោលដែលបានអនុម័ត (ចម្ងាយ >៣០០ ម៉ែត្រពីទន្លេ ស្ទឹងបឹងបួរ ឬតំបន់ដីសើម)។ បោះចោលសំរាមលោហធាតុ និងវត្ថុធាតុដែលនៅសល់ (ឥន្ធនៈ ប្រេង ខ្លាញ់) ក្នុងទីតាំងដែលបានអនុញ្ញាតនៅពេលសាងសង់។ កុំចាក់សំណល់ប្រេងលើដី និងក្នុងផ្លូវទឹក ព្រោះវាអាចបំពុលដី និងទឹកក្រោមដី។<br>b. គួរអនុវត្តវិធានការគ្រប់គ្រងសំណឹកឱ្យបានមុនរដូវភ្លៀង ជាពិសេសអនុវត្តភ្លាមៗក្រោយការសាងសង់។ ជួសជុលថែទាំ និងអនុវត្តវិធានការឡើងវិញរហូតដល់រុក្ខជាតិដុះវិញ។<br>c. គួរមានសំណង់ទប់ដីទៅតាមភាពចាំបាច់ដើម្បីពន្យឺត ឬបង្វែរទិសទឹកហូរច្រោះ និងស្ទាក់ទប់ដីរហូតដល់មានរុក្ខជាតិដុះ។<br>d. បាញ់ទឹកលើផ្លូវដី ស្នាមកាយដី វត្ថុធាតុនានា និងគំនរដីដែលកាយទុក ដើម្បីកាត់បន្ថយសំណឹកដោយសារខ្យល់ទៅតាមភាពចាំបាច់។<br>e. គំនរដីដែលកាយទុក ត្រូវមានគម្របគ្របនៅពេលមិនប្រើប្រាស់។<br>f. បញ្ចៀសការសាងសង់ផ្លូវកាត់ព្រៃបឋម ព្រោះវាអាចបង្កជាសកម្មភាពកាប់ឈើខុស ច្បាប់។<br>g. បញ្ចៀសការសាងសង់ផ្លូវលើដីធូរ ជម្រាលចោត និងជិតច្រាំងទន្លេ។ ត្រូវអនុវត្តវិធានការបន្ថែម (មើលផ្នែក ៤.២ ខាងក្រោម) ប្រសិនបើគ្មានជម្រើសសម្រាប់ការតម្រង់ផ្លូវ។ |
| | **ការពារសំណឹកជម្រាល និងការបាក់ដី ដោយអនុវត្តវិធានការខាងក្រោម ៖**<br>a. ដាំស្មៅដែលលូតលាស់លឿន និងរកបានក្នុងមូលដ្ឋាន នៅលើទីជម្រាលដែលងាយរងសំណឹក។ ស្មៅទាំងនេះជួយរក្សាលំនឹងជម្រាល និងការពារសំណឹកដីដោយសារទឹកភ្លៀង និងទឹកហូរច្រោះ។ គួរប្រើពូជស្មៅដែលមានក្នុងមូលដ្ឋាន លូតលាស់លឿន ដុះតាន់តាប់លើដី និងចាក់ឫសជ្រៅ ដើម្បីរក្សាលំនឹងដី។<br>b. ដាក់ប្រឡាយស្ទាក់ទឹក ដែលមានប្រសិទ្ធភាពបំផុតក្នុងតំបន់ដែលសំបូរភ្លៀងធ្លាក់ និងមានជម្រាល។ ប្រឡាយប្រភេទនេះជួយស្កាត់ និងបង្វែរទឹកហូរច្រោះលើដីពីតំបន់ងាយរងសំណឹក និងជម្រាល/មុនទៅដល់ជម្រាលចោត ដើម្បីកាត់បន្ថយសំណឹកផ្ទៃដីដែលអាចកើតមានឡើង។<br>c. សម្រាប់ជម្រាលចោត ត្រូវប្រើច្រាំងរាងជណ្តើរដើម្បីរក្សាលំនឹងកាន់តែល្អ។ នៅលើជម្រាលចោតសម្ភារមិនអាចដាក់នឹងបាន ហើយងាយនឹងដួលលំបន្តិចម្តងៗ។<br>d. ដាក់ជញ្ជាំងទប់នៅផ្នែកខាងក្រោមនៃជម្រាលមិននឹង។ ជញ្ជាំងនេះត្រូវមានប្រហោងសម្រាប់បង្ហូរទឹកពីបាតផ្លូវ ដើម្បីបន្ថយសម្ពាធលើផ្ទៃជញ្ជាំង។<br>e. អាចប្រើថ្ម (ដុំថ្ម) ដើម្បីជួយការពារជម្រាល។<br>f. ទប់ស្កាត់ការបង្ហូរទឹកចេញដោយគ្មានការគ្រប់គ្រង ពីផ្ទៃផ្លូវ ដោយសង់ប្រឡាយបង្ហូរទឹកជំលួម និងបង្ហូរទឹកចេញពីជម្រាលខាងក្រោម។ |
| | សំណឹក<br>a. ប្រសិនបើអាច ការងារសាងសង់ផ្លូវត្រូវស្ថិតនៅតំបន់ដែលបានកាប់ឆ្ការរួច។<br>b. ហាមប្រើប្រាស់គ្រឿងម៉ាស៊ីនធុនធ្ងន់ដើម្បីកាប់ឆ្ការតំបន់ដែលងាយទទួលរងសំណឹក។<br>c. ក្នុងករណីមានសកម្មភាពកាប់ឆ្ការ អ្នកត្រូវ ៖<br>- ដាក់សញ្ញាសម្គាល់ឱ្យច្បាស់នៅតំបន់ដែលត្រូវកាប់ឆ្ការ មុនធ្វើសកម្មភាព<br>- ពុះច្រៀក ឬកែច្នៃឈើដើមដែលបានកាប់ឆ្ការ សម្រាប់ប្រើជាគម្របការពារសំណើមនៅទីតាំង<br>- សម្អាតទីតាំងបណ្តើរៗក្នុងពេលបំពេញការងារ<br>- កាយដីស្រទាប់លើភ្លាមៗបន្ទាប់ពីបានកាប់ឆ្ការ និងដាក់ជាគំនរនៅទីតាំង<br>- គ្របគំនរដី នៅពេលមិនប្រើប្រាស់ |

| | |
|---|---|
| | - អនុវត្តវិធានការគ្រប់គ្រងសំណឹកបណ្ដោះអាសន្ន និងសង់សំណង់គ្រប់គ្រងទឹកហូរច្រោះ/ទប់ដី ជុំវិញតំបន់ដែលបានកាប់ឆ្ការភ្លាមៗ បន្ទាប់ពីបានកាប់ឆ្ការរួច<br>- ស្ដារតំបន់ដែលបានកាប់ឆ្ការឡើងវិញឱ្យបានឆាប់តាមដែលអាចទៅធ្វើបាន<br>- ដាក់ដីស្រទាប់លើមកវិញ និងដាក់គម្របការពារសំណើមលើទីតាំងផ្លូវចាស់ និង<br>- ដាក់គម្របការពារសំណើមលើជម្រាលដែលមានការទប់មិនឱ្យបាក់ដី មុននឹងដាំដុះ។<br>d. គំនរដីត្រូវ ៖<br>a. ស្ថិតលើផ្ទៃដីដែលស្អាត រាបស្មើ និងមានប្រព័ន្ធលូបង្ហូរទឹកល្អប្រសើរ និងស្ថិតក្នុងទីតាំងដែលគេអាចមើលឃើញច្បាស់<br>b. នៅឆ្ងាយពីប្រព័ន្ធលូបង្ហូរទឹក និង<br>c. នៅចម្ងាយយ៉ាងតិច ៣០ ម៉ែត្រពីក្រិតសម្គាល់កម្ពស់ទឹកគិតជាមធ្យម ឬកម្ពស់ទឹកក្នុងផ្លូវទឹក។<br>e. គំនរដីនីមួយៗត្រូវនៅឆ្ងាយពីគ្នាយ៉ាងតិច ២ ម៉ែត្រ។<br>f. ត្រូវសង់សំណង់គ្រប់គ្រងទឹកហូរច្រោះ/ទប់ដីបណ្ដោះអាសន្ននៅជុំវិញគំនរដីទាំងអស់<br>g. ការកាត់ជម្រាលដីសម្រាប់ឱ្យទឹកហូរ ត្រូវស្ថិតនៅលើជម្រាលដីធំៗដែលត្រូវបានកាត់។<br>h. ហាមកាយដី និងចាក់ដីក្នុងពេលមានភ្លៀងខ្លាំង។ |
| | a. ក្នុងករណីដែលការងារសាងសង់ផ្លូវធ្វើឡើងក្នុងផ្លូវទឹក មិនត្រូវដាក់គ្រឿងម៉ាស៊ីននៅក្រៅផ្លូវសម្រាប់ដឹកជញ្ជូនក្នុងផ្លូវទឹកទេ<br>b. ត្រូវបង្វែរទឹកហូរច្រោះដោយធម្មជាតិពីតំបន់ដែលគ្មានសកម្មភាពមនុស្ស ឱ្យហូរជុំវិញការដ្ឋាន ដើម្បីកុំឱ្យរំខានដល់សកម្មភាពក្នុងការដ្ឋាន<br>c. ការពារប្រព័ន្ធលូបង្ហូរទឹកដែលអាចនឹងប៉ះពាល់ដោយសារការងារសាងសង់ផ្លូវ ដោយសង់សំណង់គ្រប់គ្រងទឹកហូរច្រោះ/ទប់ដី<br>d. ការបង្ហូរទឹកភ្លៀងដោយផ្ទាល់ចេញពីប្រព័ន្ធលូបង្ហូរទឹក កន្លែងកាត់ដី និងច្រាំង ត្រូវបានហាមឃាត់ លុះត្រាតែមានសង់សំណង់ទប់ដីនៅលើប្រព័ន្ធលូបង្ហូរទឹក ស្នាមកាយ និង ច្រាំង។<br>e. ត្រូវជួសជុលថែទាំសំណង់គ្រប់គ្រងទឹកហូរច្រោះ/ទប់ដី ដើម្បីឱ្យសំណង់ទាំងនោះនៅអាចប្រើប្រាស់បាន។<br>f. ការបង្ហូរទឹកភ្លៀងចេញពីប្រព័ន្ធលូបង្ហូរទឹកតាមផ្លូវ មិនត្រូវបង្កជា ៖<br>- សំណឹកច្រាំងផ្លូវទឹក ឬ<br>- បង្កកំទេចកំណក្នុងផ្លូវទឹកដែលត្រូវហូរចាក់ទៅ។<br>g. ការស្តុកទុកប្រេងឥន្ធនៈ ប្រេងរំអិល សារជាតុគីមី និងសារជាតុគ្រោះថ្នាក់ផ្សេងទៀតក្នុងចម្ងាយ ៣០ ម៉ែត្រពីក្រិតសម្គាល់កម្ពស់ទឹកគិតជាមធ្យម ឬកម្ពស់ទឹកក្នុងផ្លូវទឹក ត្រូវបានហាមឃាត់។<br>h. ការចាក់ប្រេងគ្រឿងម៉ាស៊ីនក្នុងចម្ងាយ ៣០ ម៉ែត្រពីក្រិតសម្គាល់កម្ពស់ទឹកគិតជាមធ្យម ឬកម្ពស់ទឹកក្នុងផ្លូវទឹក ឬប្រភពទឹកលើដីណាមួយ ត្រូវបានហាមឃាត់។<br>i. ការស្តុកទុកគ្រឿងម៉ាស៊ីនក្នុងចម្ងាយ ៣០ ម៉ែត្រពីក្រិតសម្គាល់កម្ពស់ទឹកគិតជាមធ្យម ឬកម្ពស់ទឹកក្នុងផ្លូវទឹកពេញមួយយប់ ឬនៅពេលមិនប្រើប្រាស់ ត្រូវបានហាមឃាត់។<br>j. ការបង្ហូរកាកសំណល់ដោយផ្ទាល់ទៅក្នុងទឹក ត្រូវបានហាមឃាត់។<br>k. ការបង្ហូរកាកសំណល់ក្នុងចម្ងាយ ៣០ ម៉ែត្រពីក្រិតសម្គាល់កម្ពស់ទឹកគិតជាមធ្យម ឬកម្ពស់ទឹកក្នុងផ្លូវទឹក ឬប្រភពទឹកលើដីណាមួយ ត្រូវបានហាមឃាត់។<br>l. ការប្រើប្រាស់ថ្នាំសម្លាប់រុក្ខជាតិចង្រៃក្នុងចម្ងាយ ១៥០ ម៉ែត្រពីក្រិតសម្គាល់កម្ពស់ទឹកគិតជាមធ្យម ឬកម្ពស់ទឹកក្នុងផ្លូវទឹក ត្រូវបានហាមឃាត់។ |
| | ការធ្វើឱ្យដីកខ្វក់ ៖<br>a. ការប្រើប្រាស់អ៊ីដ្រូកាបូន ឬសារជាតុគ្រោះថ្នាក់ផ្សេងទៀតសម្រាប់កាត់បន្ថយធូលី ត្រូវបានហាមឃាត់។ |

| | |
|---|---|
| | b. ប្រេងឥន្ធនៈ ប្រេងរំអិល សារធាតុគីមី និងសារធាតុគ្រោះថ្នាក់ទាំងអស់ ត្រូវបិទស្លាកសម្គាល់ច្បាស់លាស់។<br>c. ប្រេងឥន្ធនៈ ប្រេងរំអិល សារធាតុគីមី និងសារធាតុគ្រោះថ្នាក់ទាំងអស់ ត្រូវរក្សាទុកក្នុងកន្លែងស្តុកដែលអាចរក្សាទុកប្រដាប់ផ្ទុកធំបំផុតយ៉ាងហោចណាស់ ១១០%។<br>d. ទឹកបង្ហូរចេញពីកន្លែងស្តុកដែលត្រូវប្រើប្រាស់ដើម្បីរក្សាទុកប្រេងឥន្ធនៈ ប្រេងរំអិល សារធាតុគីមី និងសារធាតុគ្រោះថ្នាក់ ត្រូវបង្ហូរចូលរណ្តៅសម្រាប់ស្តុកប្រេងកំពប់។<br>e. ត្រូវមានឧបករណ៍សម្រាប់សំអាតប្រេងកំពប់នៅការដ្ឋាន។<br>f. និយោជិត និងក្រុមហ៊ុនម៉ៅការ ត្រូវទទួលការបណ្តុះបណ្តាលពីរបៀបប្រើប្រាស់ឧបករណ៍សម្រាប់សំអាតប្រេងកំពប់។<br>g. ការពង្រាយសំរាម រួមទាំងការចាក់ចោលសំណល់ ត្រូវបានហាមឃាត់។<br>h. ត្រូវដាក់ និងរក្សាទុកសំណល់ក្នុងធុងសំរាមបិទជិត។<br>i. ត្រូវបោះចោលសំណល់នៅកន្លែងចាក់សំរាមដែលនៅជិតបំផុត ឬកន្លែងចាក់សំរាមដែលមានការគ្រប់គ្រង។<br>j. ក្នុងករណីដែលទីតាំងដែលមានការងារសាងសង់ផ្លូវ គ្មានកន្លែងចាក់សំរាម ឬកន្លែងដាក់សំណល់ដោយមានការគ្រប់គ្រង ត្រូវបោះចោលសំណល់នៅទីតាំង ឬតាមរបៀបដែលកំណត់ដោយប្រតិបត្តិករគ្រប់គ្រងសំណល់ពាក់ព័ន្ធដែលមានសមត្ថកិច្ច។<br>k. ត្រូវការពារផ្ទៃសំណង់ និងដើមឈើនៅជិតតំបន់ដែលត្រូវក្រាលកៅស៊ូថ្នល់ប្រភេទប៊ីទូមិន តាមរបៀបដែលទប់ស្កាត់ការសោច ឬធ្វើឱ្យខូចសោភណ្ឌភាពថ្នល់។<br>l. ការបាញ់កៅស៊ូថ្នល់ប្រភេទប៊ីទូមិន ក្នុងល្បឿនខ្យល់លើស ៥០ គីឡូម៉ែត្រ/ម៉ោង ត្រូវបានហាមឃាត់។<br>m. រាល់វត្ថុធាតុដែលចាក់ពេញ ឬសម្ភារដែលកំពុងត្រូវបានផ្លាស់ប្តូរ មិនត្រូវប្រឡាក់ប្រឡូកជាដាច់ខាត (ឧ. ស្មៅចង្រៃ គ្រាប់ពូជ ប្រេង សារធាតុគីមី និងសារធាតុធ្វើឱ្យកខ្វក់ផ្សេងទៀត)។ |
| | ការគ្រប់គ្រងសំណល់គ្រោះថ្នាក់<br>a. ការដុតផ្លាស្ទិក ឬសារធាតុបំពុលសរីរាង្គផ្សេងទៀត ត្រូវបានហាមឃាត់។<br>b. ដីដែលបំពុលដោយប្រេងឥន្ធនៈ ប្រេងរំអិល សារធាតុគីមី និងសារធាតុគ្រោះថ្នាក់ ត្រូវចាត់ទុកជាសំណល់គ្រោះថ្នាក់។<br>c. សំណល់គ្រោះថ្នាក់ ដូចជា សំណល់ប្រេង ត្រូវប្រមូលទុក និងបោះចោលនៅទីតាំងដែលអនុម័តដោយមន្ទីរ។ |
| ស្ពានតូចៗ | **<u>ការការពារសំណឹក៖</u>** មធ្យោបាយសំខាន់ក្នុងការការពារជម្រាល និងសំណឹកគឺការសង់ជញ្ជាំងទប់ច្រាំង (ជញ្ជាំងទំនាញដែលទ្រទប់ច្រាំង ឬជម្រាលដែលអាចរអិល) និងការតំរៀបថ្មទប់ច្រាំងធម្មតា (stone pitching)<br>(a) ជញ្ជាំងទប់ច្រាំង<br>- ជម្រាលរបស់ជញ្ជាំងទប់ច្រាំង គួរមានផលធៀបយ៉ាងតិច ១ បញ្ឈរ ៖ ២ ផ្តេក។ ប្រហែលជាត្រូវកែសម្រួលជម្រាលរាបទៅតាមស្ថានភាពដីនៅការដ្ឋាន។<br>- ការរៀបជញ្ជាំងទប់ច្រាំងគួរប្រើថ្មដែលរឹងមាំ និងហាប់ល្អ ដើម្បីបង្កើនទម្ងន់អតិបរមា។<br>- គួរប្រើខ្សែចងផ្តោប ដើម្បីទប់ស្កាត់កុំឱ្យជញ្ជាំងទប់ច្រាំងប៉ោង។ ខ្សែចងផ្តោបគួរដាក់នៅត្រឹមកម្ពស់ ១ ភាគ ៣ នៃជញ្ជាំងទប់ច្រាំង។<br>- ជញ្ជាំងទប់ច្រាំងគួរថ្លក់យ៉ាងតឹងជាប់ដីដោយដាក់ជញ្ជាំងទប់ច្រាំងក្រោមកម្រិត scour depth។<br>- ក្នុងករណីដែលគ្មានការតំរៀបថ្មទប់ច្រាំង (stone pitching) គួរក្រាលដីគ្របស្រទាប់ខាងលើ ដើម្បីឱ្យមានស្មៅដុះ និងទប់ជម្រាល។ |

| | |
|---|---|
| | (b) ការតំរៀបថ្មទប់ច្រាំង អាចប្រើសម្រាប់តែវិធានការការពារសំណឹកក្នុងករណីដែលគេចាត់ទុកថាហានិភ័យសំណឹកមានតិចតួចបំផុត។ ការតំរៀបថ្មទប់ច្រាំង មិនសូវធន់នឹងចរន្តទឹកខ្លាំងទេ និងច្រើនត្រូវបានប្រើប្រាស់ជាស្រទាប់ខាងលើ (top finish) នៃផ្ទៃជញ្ជាំងទប់ច្រាំង។ |
| កងលូ | (a) ដាក់ថ្មធំៗនៅកន្ទុយកងលូដើម្បីទប់ស្កាត់សំណឹក។<br>(b) ធ្វើយ៉ាងណាឱ្យក្បាលកងលូគ្មានដីខ្សាច់ និងគ្រួស ៖ ទឹកត្រូវតែអាចហូរកាត់កងលូ។<br>(c) ធានាថា ទឹកនៅផ្លូវជិតៗនោះ អាចហូរចូលទៅក្នុងប្រឡាយសងខាងផ្លូវដោយសេរី។<br>(d) ក្នុងករណីដែលកងលូស្ថិតក្នុងផ្លូវទឹក ៖<br>- កងលូត្រូវរត់ស្របគ្នានឹងបណ្តាញផ្លូវទឹក<br>- ផ្ទៃចំហរក្រោមផ្លូវសម្រាប់ដឹកជញ្ជូនត្រូវដាក់នៅជិតចំណុចកណ្តាលនៃបណ្តាញផ្លូវទឹក<br>- ផ្លូវបង្ហៀរនៃកងលូត្រូវដាក់នៅត្រឹម ឬក្រោមកម្រិតបាតផ្លូវទឹក និង<br>(e) ការប្រើប្រាស់កងលូដែលមានទំហំខាងក្រោមត្រូវបានហាមឃាត់ ៖<br>- សម្រាប់កងលូជាបំពង់ អង្កត់ផ្ចិតបំពង់ត្រូវតិចជាង ៦០០ មិល្លីម៉ែត្រ និង<br>- សម្រាប់កងលូប្រអប់ ផ្ទៃត្រូវតិចជាង ៦០០ មិល្លីម៉ែត្រ x ៦០០ មិល្លីម៉ែត្រ។ |

## ៣. ការផ្គត់ផ្គង់ទឹក

| អនុគម្រោង | វិធានការទប់ស្កាត់/ការបន្ថយផលប៉ះពាល់លើបរិស្ថាន |
|---|---|
| អណ្តូងជ្រៅ/រាក់ | a. គួរធ្វើផ្ទៃពាសជុំវិញអណ្តូងដើម្បីសម្រួលដល់ប្រព័ន្ធលូបង្ហូរទឹក ធ្នឹមខ្វែង និងរ៉កដែលមានខ្សែទាញ និងធុងមួយសម្រាប់ដងទឹក។ ខ្សែ និងធុងធ្វើឱ្យអណ្តូង និងទឹកកាន់តែមាន អនាម័យ។<br>b. កាំជណ្តើរដែក (ដាក់ភ្ជាប់នឹងជញ្ជាំងអណ្តូងជ្រៅ) ជួយដល់សកម្មភាពជួសជុលថែទាំអណ្តូង ឬករណីមានគ្រោះអាសន្ន។<br>c. ជាទូទៅ ទឹកលើដីជាផ្ទៃទឹកបើកចំហរ។ ដូច្នេះ ចាំបាច់ត្រូវមានគម្រប/ដំបូល/សំណាញ់ដែករាយពីលើដើម្បីការពារកុំឱ្យមានស្លឹកឈើ ឬកម្ទេចកម្ទីធ្លាក់ចូល។<br>d. អណ្តូងគួរស្ថិតនៅទីតាំងខ្សែទឹកខាងលើនៃអាងស្តុកទឹកស្អុយ និងយ៉ាងហោចណាស់គួរស្ថិតនៅចម្ងាយ ១០ ម៉ែត្រពីអាងទឹកស្អុយ ព្រោះវាអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹកពិសាប្រសិនបើស្ថិតនៅជិតអាងពេក (ហានិភ័យសុខភាព)។<br>e. មុននឹងប្រើប្រាស់ប្រភពទឹកថ្មី សូមយកសំណាកគំរូទៅធ្វើតេស្ត។ ប៉ារ៉ាម៉ែត្រអប្បបរមាសំខាន់ៗសម្រាប់ការធ្វើតេស្តទឹក ៖ ចំនួនសរុបនៃបាក់តេរីក្នុងពោះវៀនធំ (coliform) កម្រិត pH សារធាតុអាសេនិក នីត្រាត ពណ៌ ភាពល្អក់ និងសីតុណ្ហភាព។ |
| ការប្រមូលទឹកភ្លៀង | a. អាងស្តុកទឹកភ្លៀង គួររក្សាទុកឱ្យបានល្អបំផុត ដោយភ្ជាប់នឹងទបង្ហូរទឹកលើដំបូល និង បំពាក់ក្បាលរូប៊ីណេ និងទុយោទឹកឱ្យបានល្អបំផុត។<br>b. ប្រសិនបើភ្ជាប់បំពង់ចែកចាយទឹកទៅនឹងអាងស្តុកទឹក សូមបំពាក់បំពង់នោះឱ្យបានកម្ពស់ ១០ សង់ទីម៉ែត្រពីបាតអាង/ធុង ដើម្បីអាចស្តុកទឹកបានកាន់តែល្អ។<br>c. គម្របអាងស្តុកត្រូវតែជាប់តឹងណែនល្អដើម្បីបញ្ចៀសការឡើងកម្តៅ និងការកាន់ស្លែ ( ដោយសារត្រូវពន្លឺថ្ងៃ ) និងទប់ស្កាត់កុំឱ្យមានសត្វល្អិត កម្ទេចកម្ទី (សំណល់រឹង) និងស្លឹកឈើធ្លាក់ចូល។<br>d. គួរដាក់បំពង់ខ្យល់ដែលមានសំណាញ់ការពារុញ នៅក្នុងគម្របដើម្បីជួយឱ្យមានចរន្តខ្យល់ក្នុងអាងស្តុក ដើម្បីធានាគុណភាពទឹក។<br>e. ត្រូវសម្អាតទបង្ហូរទឹកលើដំបូលជាប្រចាំ ព្រោះអាចមានអាចម៍សត្វ និងស្លឹកឈើនៅលើដំបូល ឬក៏អាចបង្កហានិភ័យសុខភាពប្រសិនបើអាចម៍សត្វ និងស្លឹកឈើទាំងនោះហូរចូលក្នុងអាងស្តុកទឹក។<br>f. អាងស្តុកទឹកត្រូវតែមានប្រព័ន្ធបង្ហូរទឹកហៀរចេញ នៅពេលមានភ្លៀងខ្លាំង។ ប្រព័ន្ធបង្ហូរទឹកហៀរចេញ គួរអាចទប់ស្កាត់ការហូរថយក្រោយ និងបញ្ឈប់មិនឱ្យសត្វចង្រៃ/សត្វកកេរ/សត្វល្អិតចូលក្នុង |

| | |
|---|---|
| | ប្រព័ន្ធនេះ។ ការរចនាបានល្អនឹងអាចឱ្យមានការបង្ហូរទឹកហៀរចេញយ៉ាងតិច ២ ដង/ឆ្នាំ ដើម្បីបង្ហូរកំទេចកករ ដែលអណ្តែតនៅផ្ទៃខាងលើនៃទឹកដែលស្តុក និងរក្សាគុណភាពទឹក។ |
| ទឹកផុស | a. ប្រភពទឹកផុសត្រូវមានបំពាក់ចម្រោះ និងខ្សាច់ចម្រោះ (sand trap)។ សង់ជញ្ជាំងនៅចន្លោះបំពង់បង្ហូរចូល និងបំពង់បង្ហូរចេញដើម្បីធ្វើជាអាងដាក់ខ្សាច់។ សង់ជញ្ជាំងនៅក្នុងស្នាមចោះ (ផ្នែកខាងក្រោម) សម្រាប់គ្រប់គ្រងលំហូរទឹក។ ត្រូវសម្អាតដីខ្សាច់តាមដំណាក់កាល (O&M)។<br>b. អាងទឹកត្រូវមានកន្លែងចោះដាក់បំពង់ PVC (អង្កត់ផ្ចិតរន្ធ ២ មិល្លីម៉ែត្រ) សម្រាប់បង្ហូរទឹកចូល ឬអាចមានបំពង់ខ្លី ដោយមានពាសលួសសំណាញ់ ជុំវិញផ្នែកចំហរនៅខាង កន្ទុយ។<br>c. អាងទឹកត្រូវមានរបងព័ទ្ធជុំវិញដើម្បីការពារប្រភពទឹកផុសពីការប្រើប្រាស់ជាសាធារណៈ និងការបំពុលនានា និងត្រូវមានដំបូល/គម្របការពារស្លឹកឈើ ឬកម្ទេចកម្ទីផ្សេងទៀតធ្លាក់ចូល។ |
| ទឹកទុយោភ្ជាប់ពីប្រភពទឹក | **ការទប់ស្កាត់ការបំពុលនៅប្រភពទឹក ៖**<br>a. សង់សំណង់ដែលមានគម្របគ្របលើប្រភពទឹកដើម្បីកុំឱ្យស្លឹកឈើ ឬកំទេចកំទីធ្លាក់ចូល។<br>b. ត្រូវសង់របងដើម្បីការពារប្រភពទឹក (ជាពិសេសទឹកផុស) ពីការប្រើប្រាស់ជាសាធារណៈ និងការបំពុលនានា។<br>c. គួរមានចម្រោះ (ដីខ្សាច់/គ្រួស) ទប់កំទេចដី មុននឹងទឹកផុសហូរចូលក្នុងអាងស្តុក និងត្រូវផ្លាស់ប្តូរចម្រោះតាមដំណាក់កាលនៅពេលជួសជុលថែទាំ។<br><br>**ការតបំពង់ ៖**<br>a. ការតបំពង់ PVC សម្រាប់បង្ហូរ និងចែកចាយទឹក ត្រូវបង្កប់នៅក្រោមដី (០,៥ ម៉ែត្រ) ដើម្បីការពារបំពង់ពីការខូចខាត (ឧ. យានយន្តឆ្លងកាត់ កាំរស្មី UV។ល។)។<br>b. ការដាក់បំពង់ PVC ឱ្យត្រូវកាំរស្មី UV អាចធ្វើឱ្យបំពង់បាត់សារធាតុផ្លាស្ទិក ដែលនាំឱ្យបំពង់ផុយស្រួយ។<br>c. គួរដាក់បំពង់ឱ្យរត់ត្រង់ និងមានលក្ខណៈទេរចុះក្រោម។<br>d. ប្រសិនស្ថានភាពមិនអំណោយផលសម្រាប់ការបង្កប់ទុយោ (ប្រើទុយោលើដី) ត្រូវប្រើបំពង់ដែក និងមានទ្រនាប់ ឬឃ្លុំការពារ ព្រោះការលើកដាក់ចុះឡើងអាចធ្វើឱ្យលេចជ្រាប/បាក់បែក។<br>e. បំពង់បង្ហូរចេញ និងគ្រឿងបំពាក់ភ្ជាប់ពីអាងស្តុកទឹក <u>មិនត្រូវប្រើ</u>បំពង់ PVC ទេ ព្រោះវាត្រូវពន្លឺថ្ងៃ/កាំរស្មី UV។ គួរប្រើបំពង់ និងគ្រឿងបំពាក់ធ្វើពីដែក។ |

## ៤.ជារាសាស្ត្រខ្នាតតូច

| អនុគម្រោង | វិធានការទប់ស្កាត់/កាត់បន្ថយផលប៉ះពាល់លើបរិស្ថាន |
|---|---|
| ជារាសាស្ត្រខ្នាតតូច | a. គួរសង់ជញ្ជាំងរៀបឥដ្ឋ ឬដាក់ថ្មផ្តុំចូលគ្នា នៅតាមផ្លូវ ដើម្បីការពារសំណឹកតាមច្រាំង ជម្រាល។<br>b. គួរប្រើឫស្សីសម្រាប់ការពារនៅតាមភ្លឺស្រែ នៅពេលចំណុះទឹកទាប។<br>c. ការដាក់ផ្ទាំងរបាំង (bar screen) (ចម្រឹងដែកបញ្ឈរ អង្កត់ផ្ចិតប្រហែល ២០ មិល្លីម៉ែត្រ និងស្ថិតក្នុងរង្វង់ផ្ទៃស្រឡះ ១០ សង់ទីម៉ែត្រដើម្បីសម្រួលដល់ការជួសជុលថែទាំ) នៅខាងមុខសំណង់កងលូ (ខ្សែទឹកខាងលើ) ជួយទប់ស្កាត់កុំឱ្យវត្ថុធំៗ និងកម្ទេចកម្ទីធ្វើឱ្យស្ទះប្រព័ន្ធប្រឡាយ។ មុំនៅចន្លោះផ្នែកខាងក្រោមនៃប្រឡាយ និងផ្ទាំងរបាំង គឺ ៤៥-៨០ ដឺក្រេ។ |

## ៥.មូលដ្ឋានអនាម័យ ៖ ការស្តារ ឬការពង្រីកតិចតួច

| អនុគម្រោង | វិធានការទប់ស្កាត់/កាត់បន្ថយផលប៉ះពាល់លើបរិស្ថាន |
|---|---|
| បង្គន់សាធារណៈ | a. បង្គន់ទាំងអស់ត្រូវមានអាងស្តុកទឹកស្អុយសម្រាប់ធ្វើប្រព្រឹត្តកម្មសំណល់លាមក។<br>b. បំពង់ PVC សម្រាប់ភ្ជាប់បង្គន់កាច់/ចាក់ទឹកទៅនឹងអាងស្តុកទឹកស្អុយ ត្រូវបង្កប់ក្រោមដី ឬមានគម្របគ្រប (ស៊ីម៉ង់) ដើម្បីការពារ និងកុំឱ្យត្រូវកម្តៅថ្ងៃ។<br>c. គួរប្រើបំពង់ដែកដាក់លើអាងស្តុកទឹកស្អុយ។ កុំប្រើបំពង់ PVC ព្រោះវាមិនធន់នឹងកម្តៅថ្ងៃទេ។<br>d. អាងទឹកស្អុយត្រូវមានបំពង់ខ្យល់ដើម្បីបង្ការកុំឱ្យមានឧស្ម័នប្រមូលផ្តុំក្នុងអាង និងគួរមាន "ប្រហោងលូ" សម្រាប់ចូលក្នុងអាងទឹកស្អុយ ក្នុងករណីចាំបាច់។<br>e. បង្គន់គួរស្ថិតនៅចម្ងាយយ៉ាងតិច ២០ ម៉ែត្រពីប្រភពទឹក (អណ្តូង ទឹកផុស ទន្លេ)។ |
| អាងទឹកស្អុយ | a. អាងទឹកស្អុយត្រូវមានបំពង់ខ្យល់ដើម្បីបង្ការកុំឱ្យមានឧស្ម័នប្រមូលផ្តុំក្នុងអាង និងគួរមាន "ប្រហោងលូ" សម្រាប់ចូលក្នុងអាងទឹកស្អុយ ក្នុងករណីចាំបាច់។<br>b. អាងទឹកស្អុយត្រូវមានអាងពីរ ៖ អាងទី ១ សម្រាប់ដាក់កកលាមក ចំណែកអាងទី ២ សម្រាប់ប្រព្រឹត្តកម្មខ្យល់។ ជាទូទៅ អាងទាំងនេះធ្វើប្រព្រឹត្តកម្មទឹកស្អុយបានល្អ។ កាកសំណល់ពីអាងទឹកស្អុយដែលបានធ្វើប្រព្រឹត្តកម្មដោយផ្នែក អាចបំពុលទឹកក្រោមដី និងទឹកលើដី។<br>c. មិនត្រូវបង្ហូរកាកសំណល់ពីអាងទឹកស្អុយចេញកណ្តាលវាល ឬទៅក្នុងទឹកលើដីឡើយ។ ត្រូវធ្វើប្រព្រឹត្តកម្មកាកសំណល់ទាំងនោះមុនពេលបង្ហូរចេញ។ វិធានការការពារ ៖ ១) ចម្រោះនៅក្រោមដី (underground leach field) ២) ចម្រោះដោយរុក្ខជាតិ (vegetated leach field) ឬ ៣) រណ្តៅសម្រាប់បញ្ជៀប។<br>d. ត្រូវត្រួតពិនិត្យអាងទឹកស្អុយតាមដំណាក់កាល និងត្រូវសម្អាតកកលាមកចេញ (ឬបូមចេញ) រៀងរាល់ពីរបីឆ្នាំម្តងដើម្បីអាចប្រើប្រាស់អាងបន្តទៀត។ |

## ក្រុមប្រតិបត្តិផ្នែកបរិស្ថានទី ២ ៖ ការអភិវឌ្ឍកសិកម្ម និងបរិចិញ្ចឹមជីវិត

## ១.សកម្មភាពកសិកម្ម

| អនុគម្រោង | វិធានការទប់ស្កាត់/កាត់បន្ថយផលប៉ះពាល់លើបរិស្ថាន |
|---|---|
| សកម្មភាពកសិកម្ម | a. មិនប្រើពូជដំណាំដែលមានលក្ខណៈរាតត្បាត<br>b. អនុវត្តរបៀប/វិធីសាស្ត្រ/បច្ចេកវិទ្យាកសិកម្មដែលមាននិរន្តរភាព (ឧ. កសិរុក្ខកម្ម ពហុវប្បកម្ម និងដំណាំវិលជុំ វិធានការចម្រុះក្នុងការគ្រប់គ្រងសត្វចង្រៃ (ជំរុញឱ្យសត្វរំពារ ដូចជា សត្វស្លាប និងប្រចៀវ ស៊ីសត្វល្អិតដែលស៊ីដំណាំ)<br>c. កាត់បន្ថយការបាត់បង់ដីស្រទាប់លើ ដោយសារសំណឹក និងថយចុះជីជាតិដី (ដំណាំគម្រប និងការដាក់គម្របការពារសំណើមដី (បង្កើតគម្របដីដែលមានរុក្ខជាតិ និងដាក់សំណល់រុក្ខជាតិ) ការដាំស្មៅ (ដាំស្មៅតាមផ្លូវព័ទ្ធជុំវិញ។ល។)<br>d. ធ្វើការអភិរក្ស និងប្រើប្រាស់ទឹកដោយប្រសិទ្ធភាព<br>e. កាត់បន្ថយការប្រើប្រាស់សារជាតុគីមីកសិកម្មមិនត្រឹមត្រូវ ដើម្បីកាត់បន្ថយបរិមាណសារជាតុពុលក្នុងដី និងទឹក<br>f. កាត់បន្ថយការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងលើកកម្ពស់វិធីសាស្ត្រចម្រុះសម្រាប់ការគ្រប់គ្រងសត្វចង្រៃ ទៅតាមបញ្ញត្តិជាតិ<br>g. កាត់បន្ថយ កែច្នៃឡើងវិញ និងប្រើប្រាស់ឡើងវិញនូវសំណល់កសិកម្ម (សំណល់ធម្មជាតិ សត្វ រុក្ខជាតិ)។ |

## ២.ការចិញ្ចឹមសត្វ

| អនុគម្រោង | វិធានការទប់ស្កាត់/កាត់បន្ថយផលប៉ះពាល់លើបរិស្ថាន |
|---|---|
| ការចិញ្ចឹមសត្វ | a. ព័ទ្ធរបងជុំវិញប្រភពទឹកកុំឱ្យសត្វស៊ីស្មៅចេញចូល<br>b. បង្កើនផលធៀបកាបូន-នីត្រូសែន ក្នុងចំណីសត្វដើម្បីកាត់បន្ថយការកកើតមេតាន និង នីត្រូអុកស៊ីត<br>c. លើកកម្ពស់ការស្តុកទុក រៀបចំទុកដាក់ និងប្រើប្រាស់ចំណីសត្វដោយប្រសិទ្ធភាព ដោយកត់ត្រាពីការទិញ និងការប្រើប្រាស់ចំណីសត្វ<br>d. ប្រើប្រដាប់ដាក់ចំណីដែលមានគម្រប ឬការការពារដើម្បីកុំឱ្យចំណីសត្វត្រូវភ្លៀង និងខ្យល់<br>e. សូមលាយសំណល់ចំណីសត្វ និងសារជាតុអាចកែច្នៃឡើងវិញផ្សេងទៀត សម្រាប់ធ្វើជី ឬរៀបចំឡជុត ឬទីតាំងចាក់សំរាម<br>f. កិនចំណីសត្វដើម្បីឱ្យសត្វងាយស៊ី។ ចំណុចនេះនឹងជួយសន្សំសំចៃ និងកាត់បន្ថយបរិមាណលាមកសត្វ (និងបង្កើនប្រសិទ្ធផលផលិតកម្ម)<br>g. ធានាផលិតកម្ម និងសង់កន្លែងស្តុកលាមកសត្វដើម្បីកុំឱ្យទឹកនោម និងលាមកសត្វបំពុលទឹកលើដី និងក្រោមដី (ឧ. ចាក់បេតុង ប្រមូលកាកសារជាតុរាវពីទ្រុងសត្វ និងប្រើប្រាស់ទបង្ហូរទឹកលើដំបូលនៅលើសំណង់សម្រាប់ប្រមូល និងបង្វែរទឹកភ្លៀងដែលស្អាត)<br>h. គ្រប់គ្រងសីតុណ្ហភាព សំណើម និងកត្តាពាក់ព័ន្ធនឹងបរិស្ថានផ្សេងទៀតនៃការស្តុកលាមកសត្វដើម្បីកាត់បន្ថយការបំភាយមេតាន និងនីត្រូអុកស៊ីត។ ចំណុចនេះរួមមានការប្រើប្រាស់អាងស្តុកដែលបិទជិត ឬការទាំងស្រុងស្រទាប់លើនៃស្រះ/បឹងស្តុកលាមកសត្វកណ្តាលវាល<br>i. រក្សាសំណល់ឱ្យនៅស្ងួតដោយបោះចោល ជំនួសឱ្យឬបន្ថែមលើការកាច់ទឹកបង្ហូរដើម្បីកំចាត់សំណល់<br>j. ដាក់គំនរលាមកសត្វ និងទឹកនោមនៅឆ្ងាយពីកន្លែងរស់នៅ ប្រភពទឹក ទំនាបលិចទឹក វាលជីក |

| | |
|---|---|
| | អណ្តូង (wellhead field) ឬដែនជម្រកដែលងាយរងផលប៉ះពាល់ផ្សេងទៀត<br>k. ប្រមូល និងស្តុកទុកលាមកសត្វជាប្រចាំសម្រាប់ធ្វើជីកំប៉ុស្ត និងយកទៅចាក់វាលដើម្បីបន្ថយក្លិនពុល និងរឹតត្បិតភ្នាក់ងារបង្ករោគ។<br>l. ពង្រាយលាមកសត្វដោយអនុវត្តយុទ្ធសាស្រ្តល្អប្រសើរ ដែលគិតគូរពីហានិភ័យចំពោះសុខភាព និងបរិស្ថាន ដោយសារវត្តមានភ្នាក់ងារគីមី និងជីវសាស្រ្ត និងតុល្យភាពសារជាតិចិញ្ចឹមក្នុងទីតាំងកសិកម្ម។ ធានាថា លាមកសត្វគឺសម្រាប់យកទៅប្រើតែលើដីកសិកម្មប៉ុណ្ណោះ ក្នុងអំឡុងពេលដែលសមស្របសម្រាប់ការប្រើប្រាស់ជាសារជាតិចិញ្ចឹមរុក្ខជាតិ (ជាទូទៅ មុនពេលចាប់ផ្តើមរដូវបង្កបង្កើនផល)។<br>m. សម្អាតក្រោល និងរោងដាក់ចំណីជាប្រចាំ<br>n. កាត់បន្ថយការប្រើប្រាស់ទឹកក្នុងពេលសម្អាត (ឧ. ប្រើក្បាលបាញ់ដែលមានសម្ពាធខ្ពស់ និងលំហូរតិច)<br>o. បង្កើនផលិតភាព និងប្រសិទ្ធភាពនៃផលតិកម្មបសុសត្វ (ដើម្បីកាត់បន្ថយការបំភាយមេតានពីសត្វ) តាមរយៈការកែលម្អអាហារូបត្ថម្ភ និងសែន ការគ្រប់គ្រងដោយគ្រឿងម៉ាស៊ីន (ឧ. អន្ទាក់របាំង ពន្លឺ និងសំឡេង) ដើម្បីសម្លាប់ ផ្លាស់ទីតាំង ឬបណ្តេញសត្វចង្រៃ<br>p. គួរគ្របពំនូកលាមកសត្វដោយប្រើប្រភេទក្រណាត់ដែលអាចជ្រាបបានសម្រាប់ប្រើលើដី (geotextile) (ដែលអាចឱ្យទឹកជ្រាបចូលក្នុងពំនូក និងរក្សាដំណើរការធ្វើជីកំប៉ុស្ត) ដើម្បីកាត់បន្ថយការកកើតរុយ<br>q. ប្រើសត្វរំពារដើម្បីគ្រប់គ្រងសត្វចង្រៃ។ ការពារសត្រូវធម្មជាតិរបស់សត្វចង្រៃដោយផ្តល់ដែនជម្រកសមស្រប (ឧ. គុម្ពោតព្រៃសម្រាប់ធ្វើសំបុក និងរុក្ខជាតិផ្សេងទៀត) ដែលអាចផ្តល់ជម្រកដល់សត្វរំពារទាំងនោះ។<br>r. កាត់បន្ថយអត្រាងាប់ ដោយថែទាំសត្វឱ្យបានល្អ និងទប់ស្កាត់ជំងឺ<br>s. គួរព្យាបាល ឬមើលថែសត្វដែលឈឺ ឬងាប់ដើម្បីបន្ថយការឈឺចាប់ និងភាពតានតឹង រួមទាំងការដាក់ដាច់ដោយឡែក ឬបំផ្លាញឱ្យបានសមស្រប ប្រសិនបើចាំបាច់<br>t. គួរបញ្ជាក់ពីសត្វដែលងាប់មុននឹងយកទៅចោល ហើយសត្វដែលនៅរស់ គួរសម្លាប់ចោលភ្លាមៗ។ សត្វដែលងាប់គួរយកចេញភ្លាមៗ និងបោះចោលឱ្យបានសមស្រប។<br>u. កំណត់រក និងរក្សាទុកសត្វដែលឈឺ និងរៀបចំនីតិវិធីឃាំងទុក និងបង្វែរ/បំភ័ន្ត ដើម្បីយកចេញ និងបោះចោលសត្វដែលងាប់ឱ្យបានសមស្របទៅតាមការណែនាំក្នុងបទប្បញ្ញត្តិជាតិ។ |

## ឧបសម្ព័ន្ធ ៨ ៖ ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងលើបរិស្ថាន និងវិធានការកាត់បន្ថយផលប៉ះពាល់

| ប្រភេទគម្រោង | ផលប៉ះពាល់<br>ដែលអាចកើតឡើង | វិធានការកាត់បន្ថយផលប៉ះពាល់ | ឧបករណ៍ | បទដ្ឋាន<br>បរិស្ថាន និង<br>សង្គម |
|---|---|---|---|---|
| ១.ការរៀបចំផែនការប្រើប្រាស់ដីៈ ការជ្រើសរើស និងការរៀបចំផែនការអភិវឌ្ឍសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់បណ្ណកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | ១.១ ផលប៉ះពាល់លើដីចម្រុះនៅតាមទីតាំងសំខាន់ៗ តាមរយៈការដាក់បញ្ចូលក្នុងព្រំប្រទល់នៃសម្បទានដីសង្គមកិច្ច និងការផ្តល់បណ្ណកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | ១. ទីតាំងសម្បទានដីសង្គមកិច្ច ៖ អនុវត្តនីតិវិធីរៀបចំផែនការលំហក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដូចជា ការកំណត់អត្តសញ្ញាណតំបន់ដីចម្រុះសំខាន់ៗ[10] និងផាត់ចេញពីការបែងចែកដី ដោយពិចារណាពីសមត្ថភាពរបស់បរិស្ថាន និងការវិភាគកសិ-ប្រព័ន្ធអេកូឡូស៊ី ការបង្កើតតំបន់ទ្រនាប់នៅចន្លោះទីតាំងគម្រោង និងតំបន់ដីចម្រុះសំខាន់ៗក្នុងករណីដែលតំបន់ដីចម្រុះទាំងនោះស្ថិតនៅជិតទីតាំងសម្បទានដីសង្គមកិច្ច។<br>២.ទីតាំងសម្រាប់ការផ្តល់បណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចៈ អនុវត្តដំណើរការ ៣ ជំហានដើម្បីឱ្យជនជាតិដើមភាគតិចទទួលបានបណ្ណកម្មសិទ្ធិដីធ្លី។ ចំណុចនេះរួមបញ្ចូលសមាសភាគដែលស្រដៀងគ្នានឹងសមាសភាគដែលអនុវត្តនៅតាមទីតាំងសម្បទានដីសង្គមកិច្ចថ្មី (ឧ. ការពិនិត្យបឋមនៅកម្រិតទីតាំង ការវាយតម្លៃបរិស្ថាន ESMP តាមទីតាំង ដំណើរការពិនិត្យបឋមនៅកម្រិតអនុគម្រោង)។ ផ្អែកតាមការពិនិត្យបឋមលើបរិស្ថាននៅតាមទីតាំងដែលត្រូវផ្តល់បណ្ណកម្មសិទ្ធិនីមួយៗ (ICLT) គម្រោងនឹងអាចកំណត់រកធនធានធម្មជាតិនៅមូលដ្ឋាន និងតំបន់អភិរក្សសំខាន់ៗ។ បន្ទាប់ពីកំណត់បានហើយ គម្រោងនឹងសម្របសម្រួលកិច្ចពិភាក្សាជាមួយអាជ្ញាធរមានភាគពាក់ព័ន្ធដើម្បីកំណត់ពីតួនាទីរបស់ជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងតំបន់ទាំងនេះ។ | ក.ដំណើរការពិនិត្យបឋមដោយប្រើឧបករណ៍ខាងក្រោម ៖<br>១.ថ្នាក់ខេត្ត ៖<br>ក) រូបភាពពីផ្កាយរណប និងរូបថតពីអាកាស<br>ខ) IBAT<br>គ) GIS<br>ឃ) ផែនទីពីក្រសួងកសិកម្ម និងក្រសួង បរិស្ថាន (និងក្រសួងពាក់ព័ន្ធផ្សេងទៀត)<br>២.ថ្នាក់ស្រុក ៖<br>ក) ការណែនាំផ្នែកបច្ចេកទេសដើម្បីផ្តល់ សុពលភាពដល់ការគូសផែនទី<br>ខ) ការវិភាគកសិ-ប្រព័ន្ធអេកូឡូស៊ី<br>គ) សមត្ថភាពរបស់ បរិស្ថាន<br><br>៣.វិធានការផ្សេងទៀតៈ<br>ក) សវនកម្មបរិស្ថានដោយឯករាជ្យដើម្បីពិនិត្យឡើងវិញលើ LUP ចុងក្រោយ<br>ខ) អ្នកឯកទេសបរិស្ថានរបស់ធនាគារពិភពលោកដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ បញ្ជាក់ភាពត្រឹមត្រូវ តាមរយៈការចុះពិនិត្យដោយចៃដន្យតាមទីតាំងដើម្បីបញ្ចប់ដំណើរការ LUP។ | ESS1<br>ESS6<br>ESS10 |
| | ១.២ ផលប៉ះពាល់អវិជ្ជមានដោយសារការអភិវឌ្ឍៈ ការបំផ្លិចបំផ្លាញតំបន់ងាយរងផលប៉ះពាល់ដែលស្ថិតនៅក្រៅ ឬត្រូវបានផាត់ចេញពីទីតាំងសម្បទានដីសង្គមកិច្ច ប៉ុន្តែរងគ្រោះដោយសារការធ្វើ | បង្កើនការគ្រប់គ្រងហានិភ័យនៅតាមតំបន់អភិរក្សសំខាន់ៗ និងគាំទ្រដល់សហគមន៍រងផលប៉ះពាល់ដោយគ្រប់គ្រងធនធានធម្មជាតិរបស់ពួកគេ និង/ឬតំបន់អភិរក្សសំខាន់ៗដោយប្រសិទ្ធភាព។ | ១.ការពិនិត្យបឋម<br>២. ESMP តាមទីតាំង ដែលសម្រួលដល់វិធានការគ្រប់គ្រងហានិភ័យ | ESS1<br>ESS6<br>ESS10 |

[10] ដូចជា តំបន់ការពារដោយច្បាប់ ដែនបម្រុងសត្វព្រៃ ព្រៃសហគមន៍ ព្រៃដែលនៅសល់ ឬដែនជម្រកសម្រាប់ការការពារ និងការអភិរក្ស ច្រករបៀងជីវចម្រុះ និងស្ទឹងធម្មជាតិ។

| | | | | |
|---|---|---|---|---|
| | អាជីវកម្មកាន់តែច្រើន ដោយសារលទ្ធភាពចេញចូលកាន់តែងាយស្រួល បន្ទាប់ពីការបង្កើតតំបន់សម្បទានដីសង្គមកិច្ច | ការគ្រប់គ្រងហានិភ័យត្រូវ ៖<br>១.កំណត់រកតំបន់ធនធានធម្មជាតិ/តំបន់អតិរក្សសំខាន់ៗនៅមូលដ្ឋានតាមរយៈការពិនិត្យបឋមលើ LUP<br>២.បង្កើតតំបន់ទ្រនាប់ និងច្រករបៀងជីវចម្រុះ<br>៣.កសាងការយល់ដឹងពីការអភិរក្សជីវចម្រុះ<br>៤.ដាំដើមឈើនៅក្នុងតំបន់សមូហភាព<br>៥.ដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>៦.ផ្តល់យន្តការ និងការគាំទ្រដើម្បីជួយដល់សហគមន៍រងផលប៉ះពាល់លើការគ្រប់គ្រងធនធានធម្មជាតិរបស់ពួកគេប្រកបដោយនិរន្តរភាព។ | | |
| | ១.៣ ការបំពុលខ្យល់ដោយសារការដុត ការបំពុលទឹក និងការបំពុលដីដែលកើតចេញពីការគ្រប់គ្រងសំណល់រឹងមិនបានល្អនៅតំបន់លំនៅដ្ឋានក្នុងទីតាំងសម្បទានដីសង្គមកិច្ច | រៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងសំណល់រឹងដោយប្រសិទ្ធភាពនៅតាមទីតាំងនីមួយៗ | ESMP តាមទីតាំង | ESS1<br>ESS3<br>ESS10 |
| | ១.៤ ផលប៉ះពាល់សុខភាពពីការផ្គត់ផ្គង់ទឹក ដែលបំពុលដោយសកម្មភាពនៅខ្សែទឹកខាងលើ ឬការកកើតសារធាតុអាសេនិកក្នុងធម្មជាតិ | ការពិនិត្យបឋមតាមទីតាំង ការធ្វើតេស្តការផ្គត់ផ្គង់ទឹក | ESMP តាមទីតាំង | ESS1<br>ESS4<br>ESS10 |
| | ១.៥ ការរងរបួសដោយសារសំណល់អាវុធជាតិផ្ទុះបន្សល់ពីសង្គ្រាម | ការវាយតម្លៃហានិភ័យតាមទីតាំងដោយពិគ្រោះយោបល់ជាមួយ CMAA/CMAC | ១.ការពិនិត្យបឋម<br>២. ESMP តាមទីតាំង | ESS1<br>ESS4<br>ESS10 |
| | ១.៦ ជំងឺឆ្លងតាមទឹក និងជំងឺឆ្លងតាមភ្នាក់ងារបង្កពោគដោយសារការតាំងទីលំនៅ | ការកសាងការយល់ដឹង សកម្មភាពទឹកស្អាត និងអនាម័យ ( WASH ) | ESMP តាមទីតាំង | ESS1<br>ESS4<br>ESS10 |
| | ១.៧ ការខូចខាតក្នុងគ្រោះទឹកជំនន់ដោយសារការខូចដំណើរការទំនប់ទឹកនៅខ្សែទឹកខាងលើតំបន់គម្រោង | ការពិនិត្យបឋមតាមទីតាំង | ការពិនិត្យបឋម | ESS1<br>ESS4<br>ESS10 |
| | ១.៨ អ្នកទទួលផលពីគម្រោងប្រឈមនឹងហានិភ័យអាកាសធាតុ ( ទឹកជំនន់ និងគ្រោះរាំងស្ងួត ) | ការពិនិត្យបឋមតាមទីតាំង | ១.ការពិនិត្យបឋម<br>២.ESMP តាមទីតាំង | ESS1<br>ESS4<br>ESS10 |
| ២.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍ | ២.១ ផលប៉ះពាល់ពាក់ព័ន្ធនឹងការសាងសង់ ដូចជា សំឡេងរំខាន ធូលី កម្ទេចកំណសំណឹក ការបោះចោលសំរាម ការគ្រប់គ្រងជំនន់ទឹកភ្លៀង សុខភាព និងសុវត្ថិភាពកម្មករ និងសហគមន៍ | ឧបករណ៍គ្រប់គ្រងហានិភ័យបរិស្ថាន ដែលត្រូវបានដាក់បញ្ចូលក្នុងការពិពណ៌នាលម្អិតពី EHS ក្នុងឯកសារដេញថ្លៃ | ១.ផែនការគ្រប់គ្រងលក្ខខណ្ឌការងារនិងពលកម្ម<br>២.ESHSS ដែលដាក់បញ្ចូលក្នុងឯកសារកិច្ចសន្យាការងារទាំងអស់<br>៣.ESMP អនុគម្រោងដែលរួមបញ្ចូល ECoPs និង OHSP | ESS1<br>ESS2<br>ESS3<br>ESS4 |

| | | | | |
|---|---|---|---|---|
| | ២.២ សុខភាព និងសុវត្ថិភាពរបស់បុគ្គលិកធ្វើការក្នុងគម្រោងដែលធ្វើដំណើរទៅទីតាំងដាច់ស្រយាល | ប្រើប្រាស់ និងអនុវត្ត OHS ដែលត្រូវបានដាក់បញ្ចូលក្នុងឯកសារដេញថ្លៃ | ១.ផែនការគ្រប់គ្រងលក្ខខណ្ឌការងារនិងពលកម្ម<br>២.OHSP | ESS1<br>ESS2 |
| | ២.៣ ការបំផ្លិចបំផ្លាញប្រភពទឹកក្រោមដី និងលើដីដោយសារការធ្វើអាជីវកម្មដោយគ្មានប្រសិទ្ធភាព ឬនិរន្តរភាព | ការវាយតម្លៃធនធានទឹកសម្រាប់ទីតាំងគម្រោងនីមួយៗ។ ការអភិវឌ្ឍន៍ជាពាសស្រ្តត្រូវបញ្ជាក់ថានឹងមិនបង្កផលប៉ះពាល់អវិជ្ជមានលើអ្នកប្រើប្រាស់បច្ចុប្បន្ន និង/ឬសេវាប្រព័ន្ធអេកូឡូស៊ី។ | ESMP តាមទីតាំង (រៀបចំក្នុងការគ្រប់គ្រងហានិភ័យនៅកម្រិតទីតាំង) | ESS1<br>ESS3<br>ESS10 |
| | ២.៤ ទីតាំងវប្បធម៌អាចរួមមានព្រៃឈើ ដីព្រៃអារក្ស ដីលំនៅដ្ឋាន និងដីកសិកម្ម | ការគូសផែនទីបេតិកភណ្ឌវប្បធម៌ដែលស្គាល់ ការអនុវត្តច្បាប់ស្តីពីព្រៃឈើដោយផ្អែកលើការទទួលស្គាល់ការប្រើប្រាស់ជាប្រពៃណី និងការអនុវត្តរបស់សហគមន៍មូលដ្ឋានជាព្រៃការពារសម្រាប់គោលបំណងវប្បធម៌ (សាសនា និង/ឬព្រៃអារក្ស) | ១.ក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌ (CHPF)<br>២.ESMP តាមទីតាំង | ESS1<br>ESS8<br>ESS10 |
| | ២.៥ ការខូចខាតក្នុងទីកជំនន់ដោយសារការខូចដំណើរការជាពាសស្រ្ត ឬទំនប់តូចដែលគាំទ្រដោយគម្រោង | ធានាការរៀបចំដោយសុវត្ថិភាព | ១.ការពិនិត្យបឋម<br>២.ESMP តាមទីតាំង | ESS1<br>ESS4<br>ESS10 |
| | ២.៦ ផលប៉ះពាល់សុខភាពដោយសារការផ្គត់ផ្គង់ទឹកដែលគ្មានគុណភាពសម្រាប់ពិសាដោយសារ ១) ជាតិអាសេនិកក្នុងធម្មជាតិ ២) ការបំពុលដោយសារជាតុគីមី ៣) ការបំពុលដោយជីវសាស្រ្ត | ប្រភពទឹកទាំងអស់ត្រូវឆ្លងកាត់ការធ្វើតេស្តនៅមន្ទីរពិសោធន៍<br>ក្នុងករណីមានការបំពុលដោយជាតុអាសេនិក និងសារជាតុគីមី ត្រូវអនុវត្តពិធីសាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ[11] និងប្រភពទឹកពិសាផ្សេងទៀតដែលផ្តល់ជូន ក្នុងករណីនៃការបំពុលដោយជីវសាស្រ្ត ត្រូវសម្លាប់មេរោគក្នុងអណ្តូង និងធ្វើតេស្តឡើងវិញ | ESMP តាមទីតាំង (ប្រភពទឹកលើដីត្រូវធ្វើតេស្តក្នុងពេលពិនិត្យបឋមតាមទីតាំង)<br>ESMP អនុគម្រោង | ESS4 |
| ៣.ការអភិវឌ្ឍកសិកម្ម និងរបរចិញ្ចឹមជីវិត | ៣.១ ផលប៉ះពាល់[12]លើសុខភាព និងសុវត្ថិភាពរបស់សហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោង | អនុវត្ត ESMF រួមទាំងគោលការណ៍ណែនាំ GAP របស់ក្រសួងកសិកម្ម និងការកសាងការយល់ដឹងរបស់កសិករស្តីពីការប្រើប្រាស់ និងរៀបចំទុកដាក់សារជាតុគីមីកសិកម្មដោយសុវត្ថិភាព | ១.ESMP តាមទីតាំង<br>២.បទប្បញ្ញត្តិស្តីពី ECop (ប្រសិនបើមិនត្រូវបានលើកឡើងក្នុង CamGAP) និង OHSP ដែលត្រូវបានដាក់ | ESS1<br>ESS3<br>ESS4<br>ESS10 |

[11] ដើម្បីឱ្យបន្សុីគ្នានឹងស្តង់ដាជាតិរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តវិធានការដូចខាងក្រោម៖
-អនុគម្រោងផ្គត់ផ្គង់ទឹកថ្មី ធ្វើតេស្តទឹករកសារជាតុនានា រួមទាំងអាសេនិក និងធៀបនឹងស្តង់ដាជាតិ
-ផ្សព្វផ្សាយពីលទ្ធផលនៃការធ្វើតេស្តគុណភាពទឹកទៅមេភូមិ និងជូនដំណឹងថាតើទឹកអាចពិសាបាន ឬទេ
-ផ្តល់ការណែនាំស្តីពីជម្រើសប្រព្រឹត្តកម្មមូលដ្ឋាន ក្នុងករណីស្ថិតក្នុងប៉ារ៉ាម៉ែត្រ/លើសកម្រិតស្តង់ដា។ ភូមិមួយចំនួនប្រហែលជាត្រូវអនុវត្តអនុគម្រោងប្រព្រឹត្តកម្មទឹកពិសាក្នុងវដ្តបន្តបន្ទាប់។
-ក្នុងករណីដែលមានសារជាតុអាសេនិកខ្ពស់ជាងកម្រិតស្តង់ដា មិនគួរធ្វើប្រព្រឹត្តកម្មដើម្បីកំចាត់សារជាតុអាសេនិកទេ ព្រោះត្រូវចំណាយច្រើនលើការតម្លើង និងការជួសជុល និងកង្វះសមត្ថភាពក្នុងការដំណើរការ និងជួសជុលថែទាំប្រព័ន្ធនេះ។ យកល្អគួររកប្រភពទឹកពិសាថ្មី ដូចជា ទឹកលើដី ដែលគួរធ្វើតេស្តដើម្បីអនុលោមតាមស្តង់ដាពិសា។
[12] គម្រោងនឹងមិនផ្តល់ហិរញ្ញប្បទានដល់វត្ថុធាតុគ្រោះថ្នាក់ទាំងនេះទេ ប៉ុន្តែការផ្លាស់ប្តូរកម្មសិទ្ធិដីធ្លីអាចតម្រូវឱ្យកសិករប្រើប្រាស់វត្ថុធាតុទាំងនេះ។

| | | | | |
|---|---|---|---|---|
| | ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់ និងរៀបចំទុកដាក់ថ្នាំសម្លាប់សត្វល្អិត និងជីគីមីដោយសុវត្ថិភាព | | បញ្ចូលក្នុងឯកសារដេញថ្លៃរបស់ក្រុមហ៊ុនម៉ៅការ | |
| | ៣.២ ការធ្វើឱ្យទឹកកខ្វក់ដោយសារការប្រើប្រាស់សារធាតុគីមីកសិកម្មមិនសមស្រប | អនុវត្ត ESMF រួមទាំងការកសាងការយល់ដឹង | ១.ESMP តាមទីតាំង<br>២.ECoP/CamGAP ( យកមួយណាដែលតឹងរ៉ឹងជាង ) | ESS1<br>ESS3<br>ESS10 |
| | ៣.៣ ការបំពុលបរិស្ថានដោយសារសំណល់រឹងដែលមិនអាចបំបែកតាមបែបជីវសាស្ត្រដែលបន្សល់ទុកពីសកម្មភាពកសិកម្ម | អនុវត្ត ESMF រួមទាំងការកសាងការយល់ដឹង វិធានការគ្រប់គ្រងសំណល់រឹង | ESMP តាមទីតាំង និង ECoP/EMP | ESS1<br>ESS3<br>ESS10 |